ហេង ហុង

# ឱ! លោកធំ

# ខ្មែរ

## សោកនាដកម្មនៃកម្ពុជា

# ឱ! លោកធំខ្មែរ

«សោកនាដកម្មនៃកម្ពុជា»

ហេង ហុង

## មតបោះពុម្ពលើកទី ៣

បន្ទាប់ពីបានបោះពុម្ពលើកទី២ ខ្ញុំបានជួប និងបានពិភាក្សាជាមួយរៀមច្បង ដូចជា បងប្រុសអតីតយុទ្ធជនកងរំដោះ(បានចេញតស៊ូកំឡុងទសវត្សរ៍ឆ្នាំ១៩៧០ រួមជាមួយកងទ័ពខ្មែរក្រហម តាមការអំពាវនាវរបស់លោក នរោត្តម សីហនុ ដែលជំនាន់នោះគេហៅថា យុទ្ធជនកងរំដោះ) បងប្រុសអតីតពលករ"ផែនការ ក៥" (ដែលរដ្ឋាភិបាលលោក ហ៊ុន សែន បានកេណ្ឌអោយទៅកាប់ព្រៃនៅតំបន់ប៉ៃលិនតាមរយៈ "ផែនការ ក៥" កំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និងរៀមច្បងមួយចំនួនទៀត ហើយពួកគាត់បាននិយាយរំលឹកព្រឹត្តិការណ៍ខ្លះៗដែលគាត់នៅចងចាំ។ ដោយយល់ឃើញថាពត៌មានទាំងនេះ មានសារសំខាន់ និងជាភស្តុតាងបញ្ជាក់ច្បាស់បន្ថែមទៀត ខ្ញុំក៏ពិនិត្យរៀបបញ្ចូលក្នុងសៀវភៅនេះដើម្បីបោះពុម្ពលើកទី៣។ ទន្ទឹមនឹងនេះ ខ្ញុំបានវាយចូលកុំព្យូទ័រជាថ្មីដោយប្រើពុម្ពអក្សរយូនីកូដខ្មែរ និងបានធ្វើការកែសំរួលជំពូក ចំណងជើងខ្លះៗ ព្រមទាំងពាក្យ និងឃ្លាត្រង់ទំព័រមួយចំនួនផងដែរ។ ទោះជាយ៉ាងណា អត្ថន័យជារួមក្នុងសៀវភៅនេះមិនប្រែប្រួលទេ។

ដូចនេះ ខ្ញុំសូមការអធ្យាស្រ័យពីសំណាក់ជនរួមជាតិខ្មែរ ដែលគាំទ្រសៀវភៅ "ឱ! លោកធំខ្មែរ"នេះ។

ភ្នំពេញ ថ្ងៃទី ០៧ មករា ២០១០

ហេង ហុង



## មតបោះពុម្ពលើកទី ២

ក្រោយពីបានបោះពុម្ពលើកទី១ចំនួន៩០០ក្បាលមក មានសំណូមពរអោយបោះពុម្ពបន្ថែម និងមានការទិតៀនថា ប្រភេទអក្សរតូច ពិបាកក្នុងការអាន។ ដោយទទួលបានដំណឹងអំពីការគាំទ្រពីជនរួមជាតិយ៉ាងនេះ ខ្ញុំមានសេចក្តីរំភើបជាខ្លាំង ហើយក៏បានចាប់ផ្តើមយ៉ាងប្រញ៉ាប់ប្រញ៉ាល់ក្នុងការរៀចំពិនិត្យឡើងវិញ ដើម្បីឆ្លើយតបទៅនឹងឆន្ទះរបស់ជនរួមជាតិ។ ដូចនេះ ក្នុងការបោះពុម្ពលើកទី២នេះ ខ្ញុំបានជ្រើសរើសប្រភេទអក្សរធំជាងមុន និងធ្វើការកែសំរួលឃ្លា និងពាក្យនៅត្រង់ទំព័រខ្លះៗសូមអធ្យាស្រ័យ។

សូមថ្លែងអំណរគុណជាអតិបរិមាចំពោះជនរួមជាតិខ្មែរ ដែលបានរិះគន់សៀវភៅ "ឱ! លោកធំខ្មែរ"នេះ។

ភ្នំពេញ ថ្ងៃទី ២៨ ធ្នូ ១៩៩៧

ហេង ហុង

# មាតិការឿង

ទំព័រ

គោលគំនិត .................................................................... ១

ជំពូក I

សតវត្សទី ១២ ............................................................ ៤

ជំពូក II

សតវត្សទី ១៣-១៩ ..................................................... ៧

ជំពូក III សតវត្សទី ២០

ប្រទេសខ្មែរ និងមហិច្ឆតាបារាំង .................................... ១៧

សង្គមរាស្ត្រនិយម(១៩៥៣) ......................................... ២៣

លទ្ធិសីហានុនិយម និងសង្គ្រាមសំលាប់ខ្មែរ ................... ២៩

ព្រឹត្តិការណ៍ជុំវិញថ្ងៃ១៨មិនា១៩៧០ ............................. ៣៨

សាធារណរដ្ឋខ្មែរ ......................................................... ៤៦

ល្បិចយួនកំឡុងទសវត្សរ៍ឆ្នាំ១៩៧០ដែលយើងស្គាល់ថា

យួនយៀកកុង និងយួនធីវគី ......................................... ៥០

ផ្នត់គំនិតរបស់មេដឹកនាំចិន ចំពោះខ្មែរ .......................... ៥៧

សាធារណរដ្ឋខ្មែរត្រូវរលំ ............................................. ៦២

កម្ពុជាប្រជាធិបតេយ្យ .................................................. ៧០

វិធីយួនសំលាប់ខ្មែរកំឡុងថ្ងៃ៧មករា១៩៧៩ ................... ៨១

សាធារណរដ្ឋប្រជាមានិតុកម្ពុជា(១៩៧៩) ...................... ៨៧

មេដឹកនាំយួនប្រើរូបមន្តចាស់ ....................................... ៩១

សាធារណរដ្ឋប្រជាមានិតុកម្ពុជា(១៩៨៥) ....................... ៩៥



យួនូបនីយកម្ម(១៩៧៩) ............................................... ១០៧

ខ្មែរជាអ្នកបង្កើតលក្ខខណ្ឌអោយបរទេសឈ្លានពាន ...... ១១៤

មូលហេតុនៃសង្គ្រាម .................................................... ១១៦

គំនិតផ្តួចផ្តើម សំណូមពរដើម្បីបញ្ចប់សង្គ្រាម

និងការបរាជ័យ ............................................................ ១២៤

សន្តិភាពចិតលើមេដឹកនាំចិន យួន និងសៀម ............... ១៣៥

ផ្នត់គំនិតរបស់មេដឹកនាំសៀមចំពោះខ្មែរ ...................... ១៤៣

ជំហរជប៉ុនចំពោះខ្មែរ .................................................. ១៤៨

ហេតុអ្វីបានគេនាំគ្នាធ្វើបាបខ្មែរ .................................... ១៥១

សង្គ្រាមសំលាប់ខ្មែរត្រូវបានបញ្ចប់ (១៩៩១) ................. ១៥៥

បញ្ហាបន្សល់ទុក .......................................................... ១៦២

ជំពូក IV

ដើម្បីអនាគតខ្មែររុងរឿង ............................................. ១៦៦

លោកធំ ...................................................................... ១៧៤

ឯកសារ ....................................................................... ១៨២

# គោលគំនិត

ខ្ញុំចាប់ផ្ដើមប្រមូលឯកសារ និងរៀបចំចងក្រងជាសៀវភៅនេះ ឆ្នាំ ១៩៩០ ពេលដែលខ្ញុំបានដឹងថា សហគមអន្តរជាតិ ចង់បានសន្តិភាពសំរាប់ប្រជាពលរដ្ឋខ្មែរ ហើយគេតែងរិះរកគ្រប់មធ្យោបាយ ដើម្បីបញ្ចប់សង្គ្រាមរ៉ាំរៃសំលាប់ខ្មែរគ្នាឯងជាបន្ទាន់។ តែផ្ទុយទៅវិញ អ្នកនយោបាយខ្មែរបែរជាទទឹងរឹងរូសយ៉ាងចចេស ទាំងងឹតទាំងងងល់មិនព្រមទទួលស្គាល់ និងថែមទាំងបន្តការកាប់សំលាប់បង្ហូរឈាមប្រជាពលរដ្ឋខ្មែរតទៅទៀត មិនចង់ឈប់។

ដូចជនរួមជាតិបានដឹងហើយថា ប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ប្រទេសខ្មែរ មានសង្គ្រាមសំលាប់ខ្មែរគ្នាឯងយ៉ាងសាហាវ និងស្ទើរតែរលាយជាតិបាត់ពីផែនទីពិភពលោក។ តែមកដល់ថ្ងៃនេះ មិនទាន់មានមេដឹកនាំខ្មែរណាមួយស្មោះត្រង់ចំពោះពលរដ្ឋខ្មែរ ក្លាហានហ៊ានសារភាពលាតត្រដាងការពិត និងហ៊ានទទួលកំហុសដែលខ្លួនបានប្រព្រឹត្តនៅឡើយទេ។ មានតែមេដឹកនាំខ្មែរដែលប្រកបដោយពុតត្បុត កំហូច បោកប្រាស់ មិនព្រមទទួលស្គាល់លទ្ធផលនៃអំពើរបស់ខ្លួន។ មិនតែប៉ុណ្ណោះ គេខំប្រើគ្រប់កលល្បិច ហឹង្សា អមនុស្ស និងគេខំបំផ្លើសខុសទៅជាត្រូវ ត្រូវទៅជាខុស អាក្រក់ទៅជាល្អ ដើម្បីបិទបាំងកំហុសរបស់គេទៀតផង ហើយគេតែងឆ្លើយដាក់គ្នាទៅវិញទៅមក គ្មានសតិសម្បជញ្ញៈ។

សៀវភៅនេះ ផ្តោតជាពិសេសលើសកម្មភាពនិងអត្តចរិករបស់លោកធំខ្មែរនាប៉ុន្មានទសវត្សរ៍ចុងក្រោយប៉ុណ្ណោះ និងលទ្ធផលសរុបក្នុងការគ្រប់គ្រង ព្រមទាំងបង្ហាញថា តើមេដឹកនាំខ្មែរ ដែលយើងហៅថាអ្នកនយោ



បាយទាំងនោះ មានឧត្តមគតិជាតិ និងសមត្ថភាពក្នុងការដឹកនាំប្រទេសរឺទេ? រឺដឹកនាំតាមចិត្តមានៈ តណ្ហា តាមទំនើងនឹកឃើញ និងការសងសឹក? រឺក៏ដឹកនាំតាមការបញ្ជោរ ការបង្គាប់បញ្ជារបស់បរទេស?។

កាលណាយើងផ្តើមនិយាយពីរបបគ្រប់គ្រងរបស់លោកធំខ្មែរ និងសង្គ្រាមសំលាប់ខ្មែរ ពីដំណាក់ពេលមួយទៅមួយ វាតែងទាក់ទងជាប់ទៅនឹងប្រទេសយួន សៀម ចិន និងបណ្តាប្រទេសមួយចំនួនទៀត បារាំង សហរដ្ឋអាមេរិក សូវៀត និងជប៉ុនជាដើមដោយចៀសមិនផុត។ ប្រទេសខ្លះ បានជ្រៀតជ្រែកចូលក្នុងកិច្ចការនយោបាយខ្មែរ ញុះញង់អោយខ្មែរឈ្លោះគ្នា អោយខ្មែរបំផ្លាញខ្មែរខ្លួនឯង និងបង្វិលលោកធំខ្មែរអោយបំរើមហិច្ឆតារបស់គេ ហើយមានប្រទេសខ្លះរហូតដល់យកប្រទេសខ្មែរ ធ្វើជាទីលានប្រយុទ្ធបង្ហាញឫទ្ធអំណាចនិងដើម្បីពិសោធន៍ទាំងកំលាំងនយោបាយនិងយោធារបស់គេជាដើម។

សៀវភៅនេះ គ្មានបំណងនឹងជីកគាស់កកាយសើរើយករឿងដែលកន្លងផុត មកធ្វើជារឿងថ្មីដើម្បីចាក់ដុតពន្យុះអោយមានការសងសឹក ហុតឈាមរវាងមនុស្សដូចគ្នាឡើយ។ អ្វីដែលកើតមានរួចទៅហើយ គឺជាប្រវត្តិសាស្ត្រ។ ដើម្បីកុំអោយប្រវត្តិសាស្ត្របង្វិលបង្ហោចខ្មែរត្រឡប់មកវិញដដែលៗ សូមអោយខ្មែរទទួលស្គាល់ និងយកលទ្ធផលនៃព្រឹត្តិការណ៍ចាស់នេះ មកធ្វើជាបទពិសោធន៍។

ក្រោយពីបានរកឃើញហេតុផលហើយ សៀវភៅនេះសូមចូលរួមផ្តល់គំនិតទូទៅខ្លះៗ ដល់កូនខ្មែរក្នុងការពិចារណាថា តើជនជាតិខ្មែរត្រូវធ្វើយ៉ាងណាដើម្បីអនាគតរុងរឿងថ្កុំថ្កើងរបស់ខ្លួន?។

ឆ្លៀតពេលនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅចំពោះ៖

- រៀមច្បងទាំងឡាយដែលខ្ញុំតែងទៅជួបពិភាក្សាពីបញ្ហាជុំវិញខ្មែរ
- មិត្តភក្តិខ្ញុំដែលបានជួយចំលងចូលកុំព្យូទ័រ

ខ្ញុំសូមការអធ្យាស្រ័យ ដ៏ខ្ពង់ខ្ពស់បំផុតពីបងប្អូនមិត្តអ្នកអាន បើសិនជានៅលើទំព័រខ្លះមានពាក្យ រឺឃ្លាឃ្លោងមិនពិរោះ រឺមួយមិនសមរម្យយ៉ាងណាក្តី ព្រោះខ្ញុំមិនមែនជាអ្នកមានទេពកោសល្យខាងពិពណ៌នាបែបរឿងល្ខោនទេ។ ខ្ញុំជាកូនខ្មែរអ្នកឈឺឆ្អាលរឿងខ្មែរម្នាក់ដែរនោះ មានការរន្ធត់ខ្លាំងពេក ចំពោះភាពមហន្តរាយ និងសោកនាដកម្ម ហើយខ្ញុំមិនយល់ព្រមអោយភាពខ្ទេចខ្ទីនៃមាតុភូមិយើងនេះ ថិតក្នុងភាពងងឹត គ្មានដឹងមុខមាត់ថាជាស្នាដៃរបស់អ្នកណាខ្លះ ទើបខ្ញុំខំស្រាវជ្រាវ និងបកប្រែពីសៀវភៅ និងឯកសារភាសាអាល្លឺម៉ង់ ដើម្បីរៀបរៀងជាសៀវភៅ "ឱ! លោកធំខ្មែរ" នេះឡើង។ ជាគោលបំណងរបស់ខ្ញុំ គឺចង់អោយខ្មែរយើងចៀសវាងអោយផុតនូវរាល់កំហុស ដែលធ្លាប់មានក្នុងអតីតកាល និងឈប់ចង់លឺនូវអំពើពង្រិចពង្រិលជាតិរបស់លោកធំខ្មែរនេះតទៅទៀត។

ក្រុងប៊ែឡាំង ២៨ ១០ ១៩៩៤

**ហេង ហុង**



**ជំពូក I**

## សតវត្សទី ១២

អ្នកប្រវត្តិសាស្ត្រខ្មែរបានកោតសរសើរស្ទើរមិនដាច់ពីមាត់ អំពីជ័យវរ្ម័នទី៧ ដែលជាស្តេចខ្លាំងពូកែ និងមានស្មារតីជាតិខ្ពស់។ ព្រះអង្គបានការពារទឹកដីខ្មែរ អោយគង់វង្ស និងមិនត្រឹមតែប៉ុណ្ណោះបានកសាង និងពង្រីកទឹកដីខ្មែរដ៏ល្បីល្បាញ ក្នុងសម័យនោះទៀតផង។ មានភស្តុតាងជាច្រើនបានបញ្ជាក់នូវគុណសម្បត្តិទាំងនេះ។

នៅឆ្នាំ១១៧៧ ស្តេចចាមបានចាត់លើកទ័ពជើងទឹកមានទូក សំពៅជាដើម មកវាយយកប្រទេសខ្មែរ។ ពួកកងទ័ពចាមបានចូលលុកលុយក្នុងប្រទេសខ្មែរ និងបានត្រួតត្រាប្រទេសខ្មែរអស់រយៈពេល៤ឆ្នាំ ព្រមទាំងបានជញ្ជូនយកទ្រព្យសម្បត្តិខ្មែរ ទៅប្រទេសចាមជាច្រើនទៀតផង។ ក្នុងកំឡុងពេលដែលចាមត្រួតត្រានោះ ប្រទេសខ្មែរទាំងមូលត្រូវខ្ទេចខ្ទីមួយភាគធំដោយកងទ័ពចាមបំផ្លាញ។ មូលហេតុនេះដែលធ្វើអោយស្តេចជ័យវរ្ម័នទី៧គង់នៅមិនសុខ ទ្រង់តាំងចេញប្រមូល និងបង្កើតកងទ័ពខ្មែរ ដើម្បីប្រឆាំងតទល់នឹងពួកចាមឈ្លានពាន។ ទ្រង់ផ្តើមតាំងសង្គ្រាមជើងទឹកទប់ទល់ពួកចាមរហូតដល់កំចាត់ពួកនេះចេញអស់ពីប្រទេសខ្មែរ។ ចាប់ពីពេលនោះមក ប្រទេសខ្មែរបានស្គាល់សេចក្តីសុខក្សេមក្សាន្តឡើង។

ក្រោយពីបានដេញពួកចាមអស់ ព្រះបាទជ័យវរ្ម័នទី៧បានតាំងប្តេជ្ញាថា៖ នឹងធ្វើការសងសឹកអោយបានល្បីខ្ទរខ្ទារ។ ប៉ុន្តែ មុននឹងសំរេចតាមសេចក្តីប្តេជ្ញានេះ ទ្រង់មានកិច្ចទៅបង្ក្រាបការបះបោរក្នុងប្រទេសសិន។ ពួកបះបោរទាំងនេះ សុទ្ធតែមនុស្សខូចកាចឃោរឃៅ ធ្វើទុក្ខធ្វើបាបប្រជា

ពលរដ្ឋខ្មែរ។ ក្រោយពីបានបង្ក្រាបពួកបះបោរអស់ហើយ ទ្រង់ក៏ចាត់វិធានការវាយយកក្រុងចំប៉ា។ ចាប់ពីឆ្នាំ១២០៣រហូតដល់ឆ្នាំ១២២០ ក្រុងចំប៉ាទុកដូចជាអាណាខេត្តរបស់ខ្មែរ។ ព្រះបាទជ័យវរ្ម័នទី៧បានស្រោចស្រង់ព្រះរាជនគរ អោយរួចផុតពីការបាក់បែកខ្ទេចខ្ទីដោយការលុកលុយរបស់ចាម ហើយទ្រង់ក៏បានរៀបចំកសាងប្រទេសជាតិឡើងវិញ ដូចជា បានសាងនូវមន្ទីរពេទ្យ មហាវិទ្យាល័យ ប្រាសាទ និងសាលាសំណាក់ជាច្រើនទៀតទុកសំរាប់អ្នកដំណើរតាមផ្លូវថ្នល់។ មិនតែប៉ុណ្ណោះ ទ្រង់បានធ្វើការវាយដណ្តើមយកទឹកដីខ្លះដែលបាត់បង់មកវិញ និងបានពង្រីកទឹកដីបន្ថែមដោយបង្ក្រាបជ្រោយម៉ាឡាយូមួយភាគ ហើយទន្ទ្រានផ្សាយឫទ្ធានុភាពរហូតដល់ក្រុងភូមា។ ក្នុងសម័យនោះមានស្ថានីយ៍ព្យាបាលជំងឺចំនួន១០២ដែលរាយពេញព្រះរាជនគរ ព្រោះទ្រង់បានមើលឃើញនូវសេចក្តីឈឺចាប់របស់ប្រជាពលរដ្ឋ ក៏ដូចជាសេចក្តីឈឺចាប់របស់ព្រះអង្គដែរ។ នេះគឺជាឧត្តមគតិយ៉ាងសំខាន់ក្នុងការដឹកនាំប្រទេស។ ព្រះអង្គបានយល់ពីសេចក្តីឈឺចាប់ខ្លោចផ្សាររបស់ប្រជាពលរដ្ឋ និងយល់នូវអ្វីដែលពលរដ្ឋត្រូវការចាំបាច់។ ក្រោយពីបានរំដោះប្រទេស ព្រះអង្គចាប់ផ្តើមសាងអ្វីៗ ដែលជាសេចក្តីត្រូវការរបស់ពលរដ្ឋ។ កត្តាទាំងនេះដែលធ្វើអោយពលរដ្ឋទូទាំងប្រទេស ស្រឡាញ់ គោរពទុកចិត្តលើព្រះអង្គ និងរួមសាមគ្គីគ្នាយ៉ាងសស្រាក់សស្រាំក្នុងការការពារ និងកសាងប្រទេសជាតិ។

ដោយឃើញប្រជាពលរដ្ឋគោរពយ៉ាងនេះ ព្រះអង្គទៅជាសប្បាយនឹងមហិទ្ធិរិទ្ធនិងអំណាចរបស់ខ្លួន។ ពេលនេះ ព្រះអង្គប្រើអំណាចមកលើប្រជាពលរដ្ឋឯង អោយសង់នេះ សង់នោះហួសកំលាំងតាមអំពើចិត្ត។ ព្រះអង្គភ្លេចគិតថា៖ ក្នុងការធ្វើសង្គ្រាមរំដោះទឹកដី ប្រជាពលរដ្ឋមានការហត់



នឿយអស់កំលាំងខ្លាំង។ ប្រជាពលរដ្ឋខំចំណាយអស់កំលាំងកាយចិត្តដើម្បីដណ្តើមជ័យជំនះលើខ្មាំងសត្រូវ គួរទុកអោយប្រជាពលរដ្ឋសំរាក និងកសាងជីវភាពអោយបានរឹងមាំសិន។ ប៉ុន្តែដោយមោទនភាពលើអនុភាពខ្លួន ព្រះអង្គលែងគិតគូរនូវអ្វីដែលប្រជាពលរដ្ឋត្រូវការចាំបាច់ សំរាប់បន្តជីវិតទៅថ្ងៃមុខ។ ព្រះអង្គ សំរុកយ៉ាងណាដើម្បីអោយល្បីល្បាញ និងដើម្បីអោយប្រជាពលរដ្ឋគ្រប់រូបស្ងើចសរសើរស្នាដៃឫទ្ធអំណាចរបស់ខ្លួន។ ព្រះអង្គបានបង្ខំអោយកសាងប្រសាទតូច ធំ រាប់រយនៅតាមតំបន់នានា។ ការកសាងប្រសាទទាំងនេះ គឺសំរាប់តែយសស័ក្តិរបស់ស្តេច ដែលប្រសាទខ្លះឥតមានប្រយោជន៍អ្វីទាល់តែសោះ គ្រាន់តែជាកន្លែងសម្រាករបស់ស្តេច រឺកន្លែងដែលស្តេចធ្វើបុណ្យអំណាចប៉ុណ្ណោះ។ ពិសេសមិនគ្រាន់តែរវល់មនុស្សដែលជាអ្នកកសាងទេ ថែមទាំងចំណាយអស់ទ្រព្យសម្បត្តិនិងថវិកាជាតិជាច្រើនទៀតផង។ ទ្រព្យសម្បត្តិដែលព្រះអង្គយកមកទុកអោយនៅស្មៀមគឺមាស៥០០០គីឡូក្រាម ត្បូង៩០០០០គ្រាប់ និងទឹកប្រាក់ជាច្រើន។

ទាំងនេះអាចជាមូលហេតុ ដែលធ្វើអោយជីវភាពរបស់ប្រជាពលរដ្ឋខ្មែរបាក់ស្រុត និងបណ្តាលអោយមានការបាក់បែកគ្នាទៀតផង។ ខ្មាំងសត្រូវក៏ឆ្លៀតឱកាសនេះចូលមកពន្យុះបន្ថែម។ អោយតែមានការឃោសនាពីក្រៅមកបន្តិចបន្តួច តែងជឿគេ និងចូលរួមជាមួយគេដោយគិតថាប្រហែលជានឹងអាចរស់គ្រាន់បើជាងនេះ។ តែស្នាដៃនេះ ក៏ជាមរតកមួយដ៏វិសេសវិសាលដល់កូនខ្មែរជំនាន់ក្រោយ និងបញ្ជាក់ពីប្រវត្តិរុងរឿងរបស់ខ្មែរក្នុងសម័យនោះ ដែលពេលណាក៏មានខ្មែរមានអំនួត មានមោទនភាព និងអតីតកាលរបស់ខ្លួនជានិច្ច។

**ជំពូក ៤**

## សតវត្សទី១៣-១៩

ចាប់ពីសតវត្សទី១៣មក មហានគរខ្មែរត្រូវធ្លាក់ចុះដុនដាបបន្តិចម្តងៗជាលំដាប់ ដោយហេតុតែការបាក់បែកគ្នា និងអ្នកដឹកនាំខ្មែរ(ស្តេច) ប្រើអំណាចផ្តាច់ការដើម្បីអោយគេគោរពសរសើរខ្លួន។ អ្នកដែលមានថ្វីដៃបន្តិចបន្តួច និងវោហារខ្លះក៏ចេញដើរប្រមូលគ្នាជាក្រុម ជាកងកាប់ចាក់គ្នាដើម្បីឡើងធ្វើស្តេច។

ក្នុងប្រវត្តិសាស្ត្រខ្មែរ បានកត់ត្រាទុកស្ទើរតែមិនអស់នូវចំបាំង ដែលកើតមានឡើងដោយសារតែការបែងចែកអំណាច និងទ្រព្យសម្បត្តិមិនស្មើគ្នារវាងបងប្អូនបង្កើត រវាងបងប្អូនខ្សែស្រឡាយនិងគ្នានៅក្នុងរង្វង់គ្រួសារស្តេច ក៏ដូចក្នុងរង្វង់គ្រួសារមន្ត្រីជាដើម។ អ្នកដែលត្រូវទទួលបានអំណាចតិចតួច រឺទ្រព្យសម្បត្តិមិនសមនឹងចិត្តលោភលន់របស់ខ្លួន តាំងក្រេវក្រោធកើតទុក្ខមិនសុខចិត្ត ចេញតស៊ូ ដេកក្នុងព្រៃប្រមែប្រមូលបង្កើតកងទ័ព។ ពេលបានល្មមនឹងធ្វើចំបាំង ក៏ចាប់ផ្តើមវាយលុកមកលើអ្នកកាន់អំណាចក្នុងស្រុក ដោយគ្មានគិតពីសេចក្តីស្លាប់ និងទុក្ខវេទនារបស់ប្រជាពលរដ្ឋឡើយ។ ជូនកាលចម្បាំងរវាងគ្រួសារស្តេចនិងស្តេច រវាងស្តេចនិងមន្ត្រីកើតមានជាហូរហែរ។ រហូតសំលាប់គ្នាឯងមិនអស់ចិត្ត រត់ទៅរកប្រទេសជិតខាងអោយមកជួយសំលាប់ខ្មែរគ្នាឯងថែមទៀត ព្រោះខ្លួនមិនអាចដណ្តើម រឺការពារអំណាចដោយខ្លួនឯងបាន។ នៅឆ្នាំ១៤៩៤-១៤៩៧ ក្នុងរាជ្ជកាលព្រះបាទសុគន្ធបទ ដោយប្រើអំណាចហួសហេតុពេក ដឹងខ្លួនថាខុស ខ្លាចស្តេចយកទោស នាយកន(នាយកនជាពលព្រះងាជាស្តេចហ្លួង)



គេចខ្លួនទៅបង្កទ័ព រួចឃោសនាថា៖ ព្រះបាទសុគន្ធបទ អោយខ្លួនរកចាប់ព្រះអង្គចន្ទរាជា។ ព្រះអង្គចន្ទរាជានឹកភ័យ ក៏ភៀសខ្លួនទៅស្រុកសៀម។ នៅឆ្នាំ១៥០៥ នាយកនធ្វើចម្បាំងនិងព្រះមហាក្សត្រ ហើយបានទាំងសំលាប់ព្រះអង្គនៅកំពង់ស្វាយ(កំពង់ធំ) រួចនាយកនឡើងគ្រងរាជ។ លុះព្រះអង្គចន្ទរាជាបានជ្រាបថា ស្តេចកនបានធ្វើគតព្រះបាទសុគន្ធបទទ្រង់យាងមកកម្ពុជាវិញ និងបានចាប់ផ្តើមធ្វើចម្បាំងនិងស្តេចកន រហូតសំលាប់ស្តេចកនបាន ហើយឡើងគ្រងរាជ្យ(១៥០៥-១៥៥៥)។ ការប្រយុទ្ធរវាងខ្មែរនិងខ្មែរនេះ បណ្តាលអោយប្រទេសជាតិចុះខ្សោយ រួចពួកសៀមបានលើកទ័ពយ៉ាងសំបើមមកវាយខ្មែរនៅឆ្នាំ១៥៨១-១៥៩៣។

ចូលមកដល់សតវត្សទី១៧ ប្រទេសខ្មែរឈានដល់ការបាត់បង់ទឹកដីយ៉ាងធំ នៅប៉ែកខាងត្បូងនៃប្រទេសដែលខ្មែរយើងសព្វថ្ងៃហៅ “កម្ពុជាក្រោម” គឺដោយសារទឹកកាមតណ្ហារបស់ស្តេចខ្មែរ។ នៅឆ្នាំ១៦២០ ជាសម័យជ័យជេដ្ឋាទី២គ្រងរាជ្យនៅកម្ពុជា គួរណាស់តែស្តេចនេះស្វែងរកសេចក្តីសុខ និងភាពរីកចំរើនជូនប្រទេសជាតិ។ ផ្ទុយទៅវិញ ស្តេចនេះបែរជានាំភ្លើងមកដុតរោលបេះដូងកូនខ្មែរបន្ថែមនិងបានធ្វើអោយប្រទេសជាតិធ្លាក់ចូលក្នុងភាពមហន្តរាយយ៉ាងអណោចអធម្ម។ ស្តេចជ័យជេដ្ឋាទី២បានវង្វេងនិងកាមតណ្ហា យកសម្ពស្សស្រីយួនជាគ្រឿងល្បែងមកបន្លែង និងអាយុជីវិតខ្មែររាប់លាននាក់។ យ៉ាងហោចណាស់ ត្រូវដឹងថា ខ្លួនជាអ្នកគ្រប់គ្រងប្រទេស ប្រជាពលរដ្ឋរស់រឺស្លាប់ដោយសារខ្លួន ត្រូវរិះរកគ្រប់មធ្យោបាយដើម្បីសេចក្តីសុខ និងភាពរុងរឿងជូនប្រជាពលរដ្ឋ។ តែស្តេចនេះដេកដួលទៅតាមការបញ្ចុកបញ្ចុលរបស់ស្តេចយួន ដោយសារតែការសំឡឹងឃើញកូនស្រីគេ។ ឯស្តេចយួនខិតខំលួងលោមស្តេចខ្មែរ និងអោយកូនស្រីរបស់

ខ្លួនមកបបោរអង្អែលស្ដេចខ្មែរ ក៏ដោយសារតែសំឡឹងឃើញដីនៅប៉ែកខាងត្បូងសំរាប់ពលរដ្ឋយួន។

នៅពេលដែលស្ដេចយួនលើកកូនស្រីខ្លួន ដែលមានសម្ផស្សស្អាតមកអោយស្ដេចខ្មែរនេះ តើគេមានបំណងប៉ុណ្ណា?។ យើងពិចារណាមើលតើស្ដេចនេះ ស្រឡាញ់ប្រជាពលរដ្ឋរបស់គេយ៉ាងណា? បានជាគេហ៊ានលះបង់កូនក្រមុំខ្លួនផ្ទាល់ តើមានស្ដេចខ្មែរណាមួយដែលក្លាហានហ៊ានបូជាយ៉ាងនេះ?។ ក្រោយពីបានរៀបការស្ដេចខ្មែរជាមួយកូនក្រមុំខ្លួនរួចស្ដេចយួនបានសុំដីមួយចំនួននៅប៉ែកខាងត្បូង ដើម្បីអោយជនជាតិខ្លួនតាំងទីលំនៅដោយសន្តិវិធី។ ពេលនោះស្ដេចសៀមច្រណែន និងដើម្បីប្រជែងឥទ្ធិពលខ្លួន ក៏លើកទ័ពមកវាយខ្មែរនៅឆ្នាំ១៦២៣។ ចាប់ពីខណៈនេះមក ប្រទេសខ្មែរកាន់តែចាប់ផ្ដើមចុះដុនដាបខ្លាំងឡើងៗ ដោយសារតែសង្គ្រាមកើតឡើងមិនឈប់ឈរ។ បន្តិច ស្ដេចមួយបាត់អំណាចរត់ទៅសៀម សុំអោយសៀមជួយលើកទ័ពមកធ្វើចម្បាំង។ ក្រោយមក ស្ដេចមួយទៀតបាត់អំណាច រត់ទៅពឹងយួនអោយលើកទ័ពមកជួយច្បាំង (មានច្រើនលើកច្រើនសារណាស់ តែមិនមែនជាគោលបំណងក្នុងសៀវភៅនេះ)។ ទីបំផុត យួន សៀមប្រលេះយកទឹកដីខ្មែរស្ទើរអស់។

ម្យ៉ាងទៀតដោយសារការស្រេកឃ្លានអំណាចខ្លាំងពេក រហូតដល់លួចសំលាប់គ្នាដើម្បីសោយរាជ្យ ដូចជា នៅឆ្នាំ១៦៧២ ព្រះបាទជ័យជេដ្ឋាទី៣ បានធ្វើគតព្រះបាទបុទមរាជា រួចឡើងគ្រងរាជ្យទៅ។ សោយរាជ្យបានតែ៦ខែ ព្រះអង្គត្រូវព្រះមហេសីព្រះបាទបុទមរាជាញុះញង់ចាម និងជ្វាអោយធ្វើគតព្រះអង្គទៀត។ ការល្មោភអំណាចនាំកើតមានការសង្ស័យ និងកើតជាសង្គ្រាមឡើង ដូចជា នៅឆ្នាំ១៧៣៦ ព្រះអង្គសត្ថាទី២មានសេចក្ដី



សង្ស័យចំពោះព្រះមហេសី និងព្រះញាតិវង្សខ្លះ ព្រះអង្គបានប្រុងនឹងចាប់ក្សត្រទាំងនេះធ្វើគត។ លុះបានជ្រាបដំណឹងនេះ ព្រះមហេសី និងក្សត្រទាំងឡាយនោះនាំគ្នារត់ទៅប្រទេសសៀម រួចសៀមលើកទ័ពមកឈ្លានពានខ្មែរ ឯព្រះបាទសត្ថាទី២ ក៏ភៀសខ្លួនទៅប្រទេសយួន។

កត្តាមួយទៀតដែលបណ្ដាលអោយសៀម និងយួន អាចកាត់យកទឹកដីខ្មែរបាន គឺនាម៉ឺនចង់ឡើងធ្វើស្ដេច លក់ខ្លួនអោយសៀម និងយួន។ នៅឆ្នាំ១៧៧៩ មាននាម៉ឺន៣នាក់ឈ្មោះ សូ មូ និងម៉ែន ចូលដៃនឹងយួន រួចបានធ្វើឃាតព្រះមហាក្សត្រ។ ក្រោយមក ប្រកាសខ្លួនជាស្ដេចចៅហ្វាយហើយលើករាជ្យថ្វាយទៅព្រះអង្គអេង។ ទាស់នឹងសម្ដេចមូ នោះម៉ែនរត់ទៅប្រទេសសៀម។ ក្រោយមកម៉ែន និងសូបានផ្សំគំនិតគ្នាសំលាប់មូ ឆ្នាំ១៧៨២ លុះសំលាប់មូបានហើយ ម៉ែនសំលាប់សូទៅទៀត។ ប្រទេសខ្មែរក្នុងគ្រានេះធ្លាក់ចូលដល់ភាពច្របូកច្របល់រកទីបំផុតគ្មាន ណាមួយខ្មាំងសត្រូវជិតខាងនៅជុំវិញខ្លួន ដែលជំរុញអោយខ្មែរត្រូវតែមានកាតព្វកិច្ចការពារដើម្បីសេចក្ដីរស់របស់ខ្លួន។ តែការពារយ៉ាងម៉េច បើស្ដេច និងមន្ត្រីខាងលើកំពុងតែប្រយុទ្ធហុតឈាមគ្នាយ៉ាងនេះ។ ប្រជាពលរដ្ឋរកតែពុទ្ធោ ឯស្ដេចនិងមន្ត្រីគិតតែប្រជែងគ្នាពីមួយទៅមួយដើម្បីរាជបល្ល័ង្គ ដែលជាហេតុនាំអោយប្រទេសជិតខាងឆក់យកឱកាសលូកដៃចូលជ្រៀតជ្រែកក្នុងនយោបាយផ្ទៃក្នុងរបស់ខ្មែរ។

ដោយស្ថានភាពសង្គមមានភាពរង្គោះរង្គើ និងគ្មានស្ថេរភាពយ៉ាងនេះ បានជានៅឆ្នាំ១៨១៣ ប្រទេសខ្មែរក្លាយជាសមរភូមិក្ដៅរបស់មេដឹកនាំយួន និងសៀម ក្នុងការដណ្ដើមយកដាក់ជាចំណុះខ្លួន។ ក្នុងរាជ្ជកាលព្រះអង្គចន្ទ សៀម និងយួន បានរំលោភយ៉ាងខ្លាំងមកលើខ្មែរ។ សៀមអោយ

ព្រះអង្គចន្ទទៅទទួលរាជភិសេកនៅបាងកក ឯស្តេចយួនបង្ខំអោយចំណុះខ្លួន ហើយនៅឆ្នាំ១៨១១ សៀមលើកទ័ព មកឈ្លានពានខ្មែរ។

នៅឆ្នាំ១៨១៣ មានចៅហ្វាយខេត្តកំពង់ស្វាយឈ្មោះ ម៉េង ក្បត់នឹងព្រះរាជាខ្មែរ សៀមបានយកម្លូព្រៃ ទន្លេរពៅ និងស្ទឹងត្រែង។ ក្នុងពេលនោះដែរយួនយកដីភាគខាងត្បូងព្រែកជីកពីចូដុតទៅហាទៀង។ នៅឆ្នាំ១៨៣២ សៀមលើកទ័ពមកឈ្លានពានម្តងទៀត ហើយចៅហ្វាយខេត្តពោធិសាត់ឈ្មោះ កា ក្បត់ចូលដៃ។ តែពេលនោះ យួនវាយត្រលប់មកវិញ ពួកសៀមក៏ថយទៅ។ បានសេចក្តីថា៖ ពេលណាយួនមានប្រៀបខ្លាំងជាង រុញសៀមដល់ព្រំប្រទល់ខាងលិច ពេលសៀមមានប្រៀបជាងវិញ រុញយួនដល់ព្រំប្រទល់ខាងកើតនៃប្រទេស។ ក្រោយមក យួនបានដេញសៀមអស់ពីប្រទេសខ្មែរ រួចបានកាន់កាប់ប្រទេសខ្មែរទាំងស្រុង។ ចាប់ពីពេលនោះមក មេដឹកនាំយួនអនុវត្តនយោបាយបំបាត់ពូជសាសន៍ខ្មែរម្តងទៀត តាមវិធីធ្វើទណ្ឌកម្ម និងវិធីធ្វើប្រជាពលរដ្ឋខ្មែរក្លាយជាពលរដ្ឋយួន។

វិធីបំប្លែងប្រជាពលរដ្ឋខ្មែរអោយក្លាយជាយួននេះ គឺមេដឹកនាំយួនបានអនុវត្តតាំងពីសតវត្សទី១៧មកម្លេះនៅក្នុងតំបន់កម្ពុជាក្រោម ហើយខ្មែរយើងនៅទីនោះ បានក្រោកឡើងប្រឆាំងគគ្រឹកគគ្រេង ដែលបណ្តាលអោយគំរោងផែនការរបស់មេដឹកនាំយួនបរាជ័យ។

នៅសតវត្សទី១៩ មេដឹកនាំយួនបានសាកល្បងទូទាំងប្រទេសខ្មែរ។ បន្ទាប់ពីស្តេចអង្គចន្ទសុគតឆ្នាំ១៨៣៥ មេដឹកនាំយួនបានចូលកាន់កាប់ក្នុងកិច្ចការនយោបាយខ្មែរទាំងស្រុង។ ដំបូង មេដឹកនាំយួនធ្វើអ្នករដ្ឋការខ្មែរអោយក្លាយជាជនជាតិយួន ទៅតាមទំនាក់ទំនងផ្លូវការ រួចមកប្រជាពលរដ្ឋទូទៅ។ នៅតាមខេត្តនានា ត្រូវប្តូរអោយទៅជារបៀបគ្រប់គ្រងយួន ព្រមជា



មួយនោះដែរការហូរចូលនៃជនជាតិយួនកាន់តែច្រើន។ មេដឹកនាំយួនបានបង្ខំខ្មែរអោយបំបាត់ទំនៀមទំលាប់ប្រពៃណីរបស់ខ្លួន ដូចជា បង្ខំអោយខ្មែរស្លៀកពាក់សំលៀកបំពាក់ជារបៀបយួន បង្ខំខ្មែរអោយកំទេចព្រះពុទ្ធរូបចោល និងបំបាត់ព្រះពុទ្ធសាសនា។

វិធីធ្វើទណ្ឌកម្មនៅឆ្នាំ១៨២០ មេដឹកនាំយួនបានបង្ខំខ្មែរអោយជីកព្រែកដែលមានឈ្មោះ"វិញតេ" ចាប់ពីឈូងសមុទ្រសៀមក្បែរហាទៀងជាប់នឹងដៃទន្លេមេគង្គដាឡាត់។ ព្រែកនេះសំរាប់បំរើដល់ចលនានៃកងទ័ពជើងទឹករបស់យួន និងមានផលប្រយោជន៍សំខាន់សំរាប់ការបញ្ចេញបញ្ចូលទឹកធ្វើស្រែចំការនៅតំបន់ ដែលយួនមកកាន់កាប់ក្នុងទឹកដីកម្ពុជាក្រោម។ វិធីទណ្ឌកម្មម្យ៉ាងទៀត គឺយកប្រជាពលរដ្ឋខ្មែរទៅកប់ទាំងរស់ត្រឹមក ធ្វើជាចង្ក្រានសំរាប់ដាំទឹកតែ ហើយយួនប្រាប់ថា នៅអោយស្មៀមប្រយ័ត្នកំពប់តែអុងអញ។ អំពើឃោរឃៅរបស់មេដឹកនាំយួនមកលើខ្មែរ និងវិធានការបំបាត់ពូជសាសន៍ខ្មែរនេះ បានធ្វើអោយប្រជាពលរដ្ឋខ្មែរមានកំហឹងឈឺចាប់ក៏ប្រមូលជាកំលាំងក្រោកបះបោរប្រឆាំងយ៉ាងខ្លាំង តែកំលាំងនេះ ត្រូវបានបង្ក្រាបពីពួកយួនវិញ។

នៅឆ្នាំ១៨៤០ មេដឹកនាំយួនប្តូរវិធីសាស្ត្រកាន់កាប់ប្រទេសកម្ពុជាដោយកំចាត់ខ្មែរដែលហ៊ានងើបបះបោរ។ យួនបានបង្កើតច្បាប់ថ្មីមួយទៀត បន្ថែមទៅលើច្បាប់ចាស់ គឺអ្នករដ្ឋការខ្មែរត្រូវដកហូតនិងមិនត្រឹមតែប៉ុណ្ណោះមន្ត្រីនាម៉ឺនខ្មែរត្រូវបញ្ជូនទៅប្រទេសយួន។ បន្ទាប់មក លើកបន្តុបក្មេងស្រីម្នាក់ដែលមានអាយុ៨ឆ្នាំឈ្មោះ អង្គមី អោយសោយរាជ្យ ព្រមជាមួយនោះ មានអ្នកហែរហម និងអ្នកបង្គាប់បញ្ជាជាជាតិយួន។ តាមពិត អង្គមី មិនត្រូវបានឡើងសោយរាជ្យទេ ប៉ុន្តែយួនធ្វើការផ្លាស់ប្តូរដោយងងើល

ដោយសារខ្លួនចង់លេបប្រទេសខ្មែរ។ ការទន្ទ្រានចូលក្នុងប្រព័ន្ធគ្រួសារស្តេចខ្មែរនេះ គឺជាវិធីបំបែកបំបាក់ផ្ទៃក្នុង ព្រោះមេដឹកនាំយួនដឹងថា ចាប់ពីសតវត្សទី១៣មក ខ្មែរកាប់ចាក់សំលាប់គ្នា តែពីរឿងការបែងចែកអំណាច និងទ្រព្យសម្បត្តិមិនស្មើគ្នា ក្នុងរង្វង់ត្រកូលស្តេចនេះឯង។ ម្យ៉ាងទៀត ដោយសារតែ អង្គមី នៅក្មេង វាពិតជាផ្តល់លក្ខណៈងាយស្រួល ក្នុងការសំរេចផែនការខ្លួន។ នេះគឺជាយុទ្ធសាស្រ្តចុងក្រោយរបស់គេ ដើម្បីរំលាយជាតិខ្មែរនាពេលនោះ។ វិធីនេះមានប្រសិទ្ធិភាពមែន គឺចាប់ពីគ្រានោះមក មន្រ្តីនាម៉ឺនខ្មែរត្រូវទំលាក់ចុះចេញពីអំណាច ចលនាតស៊ូក្រោកប្រឆាំងទាំងប៉ុន្មានត្រូវកំទេចបានដូចបំណង។ ក្នុងរាជ្ជកាលអង្គមី ខ្មែរគ្មានអំណាចអ្វីទាំងអស់ អំណាចត្រូវថិតក្នុងកណ្តាប់ដៃមេដឹកនាំយួន។ យួនដាក់ទ័ពនៅកម្ពុជា និងតំរូវអោយខ្មែរចិញ្ចឹមទ័ពនេះ។ ចៅហ្វាយស្រុកយួនត្រួតត្រាលើចៅហ្វាយស្រុកខ្មែរ ឯមន្រ្តីរាជការខ្មែរ ត្រូវស្លៀកពាក់សំលៀកបំពាក់តាមរបៀបយួន។ ខេត្ត ស្រុកខ្លះ បានត្រូវផ្លាស់ឈ្មោះជាភាសាយួន ដូចជាភ្នំពេញ ហៅថា "ណាមយ៉ាង"។ ក្នុងកិច្ចការរដ្ឋ ត្រូវប្រើភាសាយួន។ មេដឹកនាំយួនខំបំផ្លាញបូជនីដ្ឋានខាងព្រះពុទ្ធសាសនា បំផ្លាញចោលនូវព្រះពុទ្ធរូប កំទេចចេតីយ៍ បង្ខំអោយកាប់ដើមពោធិចោល។ ដើមពោធិជានិមិត្តរូបនៃព្រះពុទ្ធ ដែលខ្មែរមានជំនឿ និងគោរព។

នៅឆ្នាំ១៨៤១ មេទ័ពយួនម្នាក់ឈ្មោះ អុង ទ្រឿងគុន បានធ្វើផែនការមួយដើម្បីយកកម្ពុជា។ អុង ទ្រឿងគុន បានចាប់នាម៉ឺនមន្រ្តីខ្មែរបញ្ជូនទៅស្រុកយួន ហើយធ្វើទារុណកម្ម។ អំពើយង់ឃ្នងនេះបានធ្វើអោយប្រជាពលរដ្ឋខ្មែរឈឺចាប់ នាំគ្នាងើបបះបោរឡើងកាប់សំលាប់យួនទាំងទាហាន ទាំងស៊ីវិលនៅគ្រប់កន្លែងអស់រយៈពេល៨ថ្ងៃ។ នៅក្នុងព្រះនគរ យួនធ្វើទុក្ខបុក



ម្នេញខ្លាំងពេក ខ្មែរបានព្រមព្រៀងគ្នាសុំអោយព្រះអង្គឌួង ដែលគង់នៅប្រទេសសៀម ស្តេចយាងមកគ្រប់គ្រងរាជ្យវិញ។ នៅឆ្នាំ១៨៤១ដដែល ស្តេចសៀម បានចាត់មេទ័ពសៀមអោយដង្ហែព្រះអង្គមកគ្រងរាជ្យនៅកម្ពុជា។ ដោយសារគ្រានោះប្រទេសកម្ពុជាភាគខាងកើត ស្ថិតនៅក្រោមការកាន់កាប់របស់យួន ព្រះអង្គ ក៏បានធ្វើចំបាំងជាមួយយួនពីរលើក។ ទ័ពយួនប្រយុទ្ធមិនឈ្នះ បានសុខចិត្តព្រមទទួលចុះហត្ថលេខាឈប់ច្បាំងរវាងខ្មែរ និងយួននៅឆ្នាំ១៨៤៦។ សៀម និងយួន បានព្រមព្រៀងគ្នាទទួលស្គាល់ព្រះបាទអង្គឌួង ជាព្រះមហាក្សត្រនៃប្រទេសកម្ពុជា។ តែសៀម និងយួនមិនព្រមប្រគល់ទឹកដីទាំងប៉ុន្មាន ដែលខ្លួនបានដណ្តើមយកនោះ មកអោយខ្មែរវិញសោះ។ សៀមបានសុំព្រះបាទអង្គឌួងអោយសំរេចសន្ធិសញ្ញាផ្តាច់យកខេត្តម្លូព្រៃ និងទន្លេពៅដែលសៀមយកបានកាលពីមុន។ ព្រះបាទសម្តេចព្រះ អង្គឌួង មានព្រះតម្រាស់ថា "ខ្ញុំមិនអោយអ្វីទៅសៀមទាំងអស់ ប៉ុន្តែសៀមខ្លាំងពូកែ សៀមទុកសិនចុះខេត្តណាដែលសៀមយកបានពីមុននោះ"។ ក្នុងខេត្តដែលសៀមយកបាន សៀមបានប្រើមធ្យោបាយត្រជាក់ គឺបន្ថយពន្ធដារពីប្រជាពលរដ្ឋខ្មែរ និងយកតែកំរៃបន្តិចបន្តួច ទៅប្រទេសខ្លួនវិញ។ ឯយួនប្រើមធ្យោបាយខុសពីសៀម នៅគ្រប់ខេត្តទាំងប៉ុន្មានដែលខ្លួនដណ្តើមបានពីខ្មែរ គឺប្រើមធ្យោបាយខិតខំបំបាត់ដំណែលការត្រួតត្រាចាស់របស់ខ្មែរអោយសាបសូន្យ ហើយប្រមូលយកយួនមកតាំងនៅជំនួសវិញ។

ដោយក្រុមមេដឹកនាំយួន និងសៀមក្តាប់បាននូវចំណុចខ្សោយយ៉ាងច្បាស់ថា៖ ខ្មែរឆ្កួតនឹងស្រី ទ្រព្យសម្បត្តិ បុណ្យស័ក្តិលើកបន្ទុប ចង់បានអំណាចតែលើខ្មែរគ្នាឯង ងាយបំបែកបំបាក់អោយកាប់សំលាប់គ្នាយ៉ាងនេះ គេទាំងពីរបានព្រមព្រៀងគ្នាក្នុងការរំលាយជាតិខ្មែរ។ ប្រទេសខ្មែរត្រូវចែក

ជាពីរ គឺមួយចំណែកខាងលិចទន្លេមេគង្គ ត្រូវបានទៅប្រទេសសៀម និង ផ្នែកខាងកើតបានទៅប្រទេសយួន។ គំនិតមហិច្ឆតារបស់មេដឹកនាំទាំងពីរ បានជំរុញអោយខ្មែរភ័យបារម្ភជាខ្លាំង ទើបព្រះបាទ អង្គឌួង ទ្រង់សំរេចព្រះទ័យនឹងចងស្ពានមេត្រីជាមួយបារាំង ក្នុងបំណងរំដោះកម្ពុជាអោយរួចផុត ពីកណ្តាប់ដៃសៀមនិងយួន ព្រមទាំងទាមទារខេត្តរបស់ខ្មែរមកវិញ។ នៅឆ្នាំ១៨៥៥ ព្រះអង្គបានចាត់បញ្ជូនព្រះរាជសារលិខិតមួយច្បាប់ទៅថ្វាយ ព្រះអធិរាជណាប៉ូឡេអុងទី៣នៃប្រទេសបារាំង ដើម្បីសំដែងមិត្តភាពរវាង ព្រះអង្គចំពោះបារាំង។ នៅឆ្នាំ១៨៥៦ ព្រះអង្គ បានអោយបញ្ជូនព្រះរាជលិខិតមួយច្បាប់ទៀតទៅព្រះចៅណាប៉ូឡេអុងទី៣។ ក្នុងព្រះរាជលិខិតនោះ ព្រះអង្គរំលឹកពីទឹកដីខ្មែរដែលយួនបានដណ្តើមយកនិងសូមកុំអោយបារាំង ទទួលដីទាំងនោះពីយួន។

នៅឆ្នាំ១៨៥៩ គឺនៅពេលដែលយួនកំពុងបរាជ័យ ក្នុងការតទល់និង បារាំង ព្រះបាទ អង្គឌួង ចាត់ការវាយដើម្បីរំដោះទឹកដីមកវិញ។ ព្រះអង្គ បានចាត់អោយធ្វើបន្ទាយជាច្រើននៅជិតមាត់ជ្រូក និងពាម ហើយទ្រង់ ចាត់មន្ត្រីម្នាក់ឈ្មោះ កែម អោយធ្វើជាមេទ័ព។ ជោគជ័យលើកដំបូងបាន ធ្វើអោយព្រះអង្គមានសេចក្តីសង្ឃឹមច្រើនណាស់ តែដោយនៅឆ្នាំ១៨៦០ ព្រះអង្គ សុគតទៅ មេទ័ពកែមបានត្រឡប់មកកាន់ព្រះរាជធានីឧត្តុង្គវិញ។

តាមការសុំរបស់ព្រះបាទ អង្គឌួង បារាំងបានយល់ព្រមចូលមកជួយ ធ្វើអន្តរាគមន៍ទាន់ពេលវេលា ទឹកដីខ្មែរបានចិតនៅគង់វង្សពិតមែន។ ទន្ទឹម នឹងជួយការពារប្រទេសកម្ពុជា មេដឹកនាំបារាំងបានគាបសង្កត់យ៉ាងខ្លាំង មកលើខ្មែរដែរ។ ក្រោយពីព្រះបាទ អង្គឌួង សុគតទៅ ព្រះបាទ នរោត្តម (ជាកូនបងរបស់ព្រះបាទ អង្គឌួង)ឡើងសោយរាជ្យបន្ត។ មេដឹកនាំបារាំង



បានបង្ខំព្រះបាទ នរោត្តម អោយចុះលើសន្ធិសញ្ញាបី៖

- សន្ធិសញ្ញា១៨៦៣ មានការសមរម្យខ្លះមកលើកម្ពុជាទាំងមូល។
- សន្ធិសញ្ញា១៨៨៤ ជានឹមពិតៗមកលើកម្ពុជា ទាំងព្រះរាជា ទាំងប្រជារាស្ត្រ គ្មានអំណាចអ្វីទាំងអស់។ ដើម្បីបង្ខំអោយចុះលើសន្ធិសញ្ញានេះ បារាំងបានធ្វើការរំលោភយ៉ាងខ្លាំងទៅលើព្រះអង្គ។
- ឯសន្ធិសញ្ញា១៨៩៧ បានដកហូតជាបង្ហើយពីព្រះមហាក្សត្រ នូវសិទ្ធិអំណាចដែលសេសសល់បន្តិចបន្តួច។

ព្រះបាទ នរោត្តម មានព្រះទ័យប្រឆាំងនិងអាណានិគមបារាំង ជាពិសេសប្រឆាំងនិងសន្ធិសញ្ញា១៨៨៤។ ព្រះអង្គ តែងទាមទារឥតឈប់ឈរនូវទឹកដីកម្ពុជាក្រោម។

## ជំពូក III សតវត្សទី ២០

## ប្រទេសខ្មែរ និងមហិច្ឆតាបារាំង

យុទ្ធវិធីបំបាត់ពូជខ្មែរទាំងប៉ុន្មាន ដែលមេដឹកនាំយួនបានស្រាវជ្រាវរកឃើញនិងបានអនុវត្តមកលើខ្មែររួចមកហើយនោះ បានក្លាយជាបទពិសោធន៍យ៉ាងពិសេសសំរាប់បារាំង។

តាំងពីឆ្នាំ១៨៦៣ជិតមួយសតវត្ស កម្ពុជានៅក្រោមអំណាចបារាំង។ ក្នុងពេលនោះ កិច្ចការក្រៅប្រទេស គឺនយោបាយក្រៅប្រទេស និងការទាក់ទងនឹងបរទេសទូទៅស្ថិតនៅក្នុងកណ្តាប់ដៃបារាំងទាំងអស់។ ក្នុងប្រទេស កិច្ចការរដ្ឋាភិបាលនៅក្នុងកណ្តាប់ដៃបារាំងដែរ។ មន្ត្រីខ្មែរទាំងឡាយនៅក្រោមអំណាចមន្ត្រីបារាំង។ នៅតាមខេត្តមានរ៉េស៊ីដង់ម្នាក់ធ្វើការជាប់នឹងចៅហ្វាយខេត្តខ្មែរ។ អំណាចទាហានត្រូវបារាំងកាន់កាប់។ មេទាហានទាំងឡាយសុទ្ធតែបារាំង។ ក្នុងជួរកងទ័ព ខ្មែរមានមុខងារយ៉ាងធំណាស់ជានាយទាហានរង។ បារាំងបានផ្សព្វផ្សាយវប្បធម៌របស់គេនៅគ្រប់សាលារៀន ឯវប្បធម៌ខ្មែរទៅជ្រកកោននៅតែតាមវត្តអារាម។ នៅខែតុលា១៨៨៤ បារាំងចាប់ផ្តើមផ្លាស់ប្តូរការគ្រប់គ្រងក្នុងស្ថាប័នផ្សេងៗទាំងអស់។ នៅចុងឆ្នាំ១៨៨៤ បារាំងបានបញ្ចូលវិធានការណ៍ ដែលជាទំរង់ជ្រៀតជ្រែកក្នុងវង្សត្រកូលគ្រួសារស្តេច ក៏ដូចក្នុងកិច្ចការរដ្ឋខ្មែរ ដូចជា ការដកអំណាចពីស្តេចខ្មែរ ការត្រួតពិនិត្យទៅលើប្រភពប្រពៃណីនៃអ្នករដ្ឋការខ្មែរ ការរៀបរយជាថ្មីនៃរបបត្រួតត្រា។ ពេលនោះ មានការផ្តួចផ្តើមគំនិតតាំងពីស្តេចរហូតដល់អ្នកធ្វើការក្រោមៗដោយមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធក្នុងគោលបំណងប្រឆាំងរបបគ្រប់គ្រងបារាំងនៅពាសពេញប្រទេសដើម្បីឯករាជ្យជាតិ។ ក្នុង



រវាងឆ្នាំ១៨៦៥ដល់ឆ្នាំ១៨៦៧ មានការបះបោរពីរក្រុមដែលដឹកនាំដោយអាចារ្យស្វានិងពោកំបោរ។ តែការបះបោរនោះត្រូវបានបង្ក្រាបអស់វិញ។

ដើម្បីបំបាត់ចលនាតស៊ូបះបោរនេះ អ្នកដឹកនាំបារាំងបានយករូបមន្តដែលមេដឹកនាំយួនបានរកឃើញ និងបានអនុវត្តមកលើខ្មែររួចមកហើយនោះមកប្រើ គឺការបំបែកបំបាក់ក្នុងវង្សត្រកូលស្តេច ដោយបង្កើតអោយមានវិបត្តិ។ សូមបញ្ជាក់បន្តិចថា៖ ព្រះបាទ នរោត្តម បានប្រឆាំងនឹងនយោបាយអាណានិគមរបស់បារាំងដែលធ្វើអោយបារាំងមិនពេញចិត្ត។ ដើម្បីកាច់បំបាក់ឥទ្ធិពលរបស់ព្រះអង្គ មេដឹកនាំបារាំងបានរិះរកគ្រប់វិធីដើម្បីបង្ខូចកេរ្តិ៍ឈ្មោះ និងបានរិះរកមធ្យោបាយយ៉ាងណាដើម្បីអោយគ្រួសារស្តេចផ្សេងទៀត ស្រឡាញ់ចូលចិត្តខ្លួនគឺ "គ្រួសារ ស៊ីសុវត្ថិ"។ ក្រោយពេលដែលព្រះបាទ នរោត្តម សុគតទៅក្នុងឆ្នាំ១៩០៤ មេដឹកនាំបារាំងបានបង្ខំអោយ ស៊ីសុវត្ថិ ឡើងគ្រងរាជបន្ត(ស៊ីសុវត្ថិ ត្រូវជាប្អូនរបស់នរោត្តម)។ ព្រះបាទ ស៊ីសុវត្ថិ ជាព្រះរាជាមួយព្រះអង្គប្រកបដោយសប្បុរសល្អ។ ព្រះអង្គតែងជាសក្ការៈរបស់ប្រជាពលរដ្ឋ និងព្រះអង្គមានមនោសញ្ចេតនាប្រជាធិបតេយ្យ ដោយលប់ចោលនូវអំពើទារុណកម្មលើរូបកាយ។ បន្ទាប់ពីព្រះបាទ ស៊ីសុវត្ថិ សុគតទៅ នោះបុត្ររបស់ព្រះអង្គនាម ស៊ីសុវត្ថិ មុនីវង្ស ត្រូវបានឡើងគ្រងរាជ្យបន្ត(១៩២៧-១៩៤១)។ ព្រះបាទ ស៊ីសុវត្ថិ មុនីវង្សមានហឫទ័យទុកដាក់លើវិស័យព្រះសង្ឃ ទាំងការសិក្សានិងវប្បធម៌។

នេះវាពិតជាផ្ទុយនិងគំនិតរបស់បារាំង ព្រោះបារាំងខិតខំផ្សព្វផ្សាយវប្បធម៌របស់វា ហើយបំបាត់វប្បធម៌ខ្មែរ។ ដើម្បីសំរេចមហិច្ឆតាខ្លួន មេដឹកនាំបារាំងបានធ្វើការដោះដូរគ្រួសារស្តេចខ្មែរម្តងទៀត។ បន្ទាប់ពី ស៊ីសុវត្ថិ មុនីវង្ស សុគតឆ្នាំ១៩៤១ បារាំងបានទុកអោយគ្រួសារស៊ីសុវត្ថិ ធ្លាក់ចុះ និង

ត្រឡប់ទៅរកគ្រួសារ នរោត្តម វិញ។ ការរំលោភដោយងងើលម្តងហើយម្តងទៀតរបស់មេដឹកនាំបារាំងនេះ បានធ្វើអោយគ្រួសារ ស៊ីសុវត្ថិ ស្រឡាំងកាំងនិងកើតទុក្ខដូចដែលគ្រួសារ នរោត្តម ពីមុនដែរ គឺនៅពេលដែលគ្រួសារនេះត្រូវបារាំងបដិសេធចេញពីអំណាចឆ្នាំ១៩០៤។ ការផ្លាស់ប្តូរនេះបានធ្វើអោយ ស៊ីសុវត្ថិ សិរិមត: អាក់អន់ចិត្តនឹងបារាំងយ៉ាងខ្លាំង។

នៅឆ្នាំ១៩៤១ បារាំងបានលើកលោក នរោត្តម សីហនុ ដែលមានអាយុ១៨ឆ្នាំអោយឡើងសោយរាជ្យ។ មូលហេតុដែលបារាំងលើកលោក សីហនុ បន្តុបជាស្តេចនេះ ដោយសារលោក សីហនុ នៅក្មេង ហើយបារាំងពិតជាស្គាល់ចរិកលោក សីហនុ យ៉ាងច្បាស់ទៀតផង។ យើងគិតមើល តើមនុស្សអាយុ១៨ឆ្នាំ ចេះគិតពិចារណាអ្វីខ្លះ? វាពិតជាផ្តល់លក្ខណ:ងាយស្រួលដល់បារាំងក្នុងការគ្រប់គ្រងប្រទេសខ្មែរ។ ចាប់ពីពេលនោះមក មេដឹកនាំបារាំងធ្វើអ្វីស្រេចតែចិត្ត ហើយវិធីផ្លាស់ប្តូរត្រកូលស្តេចនេះមានប្រសិទ្ធភាពណាស់។ ក្រោយមកក្នុងវង្ងង់គ្រួសារស្តេច មិនសូវជាត្រូវរ៉ូវគ្នាទេ (សូមអាន ″ព្រឹត្តិការណ៍ជុំវិញថ្ងៃ១៨មិនា១៩៧០″)។

បន្ទាប់ពីបន្តុបលោក នរោត្តម សីហនុ ជាស្តេចមក មេដឹកនាំបារាំងបានបញ្ចេញមហិទ្ធិរិទ្ធរបស់ខ្លួនតាមការគ្រោង។ នៅក្នុងផ្នែករដ្ឋបាលត្រូវដឹកនាំដោយបារាំង។ ពេលនោះបារាំងលូកដៃកកូរយ៉ាងខ្លាំងទៅលើអរិយធម៌ខ្មែរ។ មេដឹកនាំបារាំងដឹងថា៖យួនបានអនុវត្តការរំលាយពូជខ្មែរមិនបានសំរេចដូចបំណងដោយសារមានមូលដ្ឋានគ្រឹ: ដែលធ្វើអោយបារាំងចាប់អារម្មណ៍។ ដូចនេះ បារាំងបានធ្វើទុក្ខបុកម្នេញជាខ្លាំងទៅលើព្រះសង្ឃ និងវត្តអារាម។ នៅតាមសាលារៀន បារាំងបង្ខំអោយកូនខ្មែរនិយាយតែភាសាបារាំងអ្នកនិយាយភាសាខ្មែរត្រូវបង់ពិន័យជាទឹកប្រាក់។ វត្ថុបុរាណជាច្រើន



ដែលមានតំលៃថ្លៃៗ ត្រូវបានដឹកជញ្ជូនទៅប្រទេសបារាំង។ វត្ថុទាំងនេះសុទ្ធតែជាសម្បត្តិវប្បធម៌ខ្មែរ ដែលជាកេរ្តិ៍ដំណែលរបស់ដូនតាយើងបានបន្សល់ទុកតាំងពីរាប់សតវត្សមកហើយ។ អរិយធម៌ខ្មែរស្ទើររលាយផុតដង្ហើមក្នុងជំនាន់បារាំងគ្រប់គ្រងប្រទេសខ្មែរ។ វប្បធម៌ខ្មែរដែលនៅរស់មានជីវិតរហូតដល់សព្វថ្ងៃនេះ គឺដោយសារព្រះសង្ឃនៅតាមវត្តអារាមបានប្រមូលចងក្រងនិងថែរក្សាទុក។ ព្រះសង្ឃខ្មែរបានធ្វើពលិកម្មគ្រប់បែបយ៉ាងប្រឆាំងគ្រប់សកម្មភាពរបស់បារាំង ដែលបានគំរាមកំហែងមកលើវប្បធម៌ខ្មែរ ដូចជា ចង់បំបាត់ភាសាជាដើម។

មិនតែប៉ុណ្ណោះ របបគ្រប់គ្រងបារាំងបានបង្កើតអោយមានឧបសគ្គដល់ការលូតលាស់នៃផលិតកម្មជាតិនៅកម្ពុជា ដោយហេតុតែទីផ្សារក្នុងប្រទេសបានត្រូវបើកចំហរដល់ការនាំចូលដោយសេរី ״មិនយកពន្ធដារ″ នូវគ្រឿងផលិតកម្មឧស្សាហកម្មទាំងឡាយពីក្រៅប្រទេស។ នាហ្មឺនជាន់ខ្ពស់នៃរដ្ឋបាលខ្មែរជាច្រើនដែលពឹងផ្អែកលើអំណាច និងកិត្យានុភាពរបស់បារាំងបានបិទភ្នែកចំពោះសកម្មភាពទាំងនេះ ហើយបានចាប់ផ្តើមប្រព្រឹត្តអំពើទាំងឡាយទាក់ទងនឹងសំណូកសូកប៉ាន់ ដែលបានក្លាយទៅជាជំងឺសង្គមដ៏ធ្ងន់ធ្ងរក្នុងប្រទេស។ ពួកនាហ្មឺនពុករលួយក្នុងសម័យនោះ មិនគ្រាន់តែស៊ីសំណូកដើម្បីធ្វើការអ្វីមួយទេ គ្រាន់តែសុំបោះត្រាលើឯកសារ រឺសំណុំលិខិតអ្វីមួយក៏ទាមទារអោយបង់កំរៃដែរ។

កត្តាខាងលើនេះហើយ ដែលបណ្តាលអោយមានចលនាតស៊ូជាច្រើនក្រុមនៅតាមតំបន់ខុសៗគ្នាពាសពេញប្រទេស។ បណ្តាអ្នកដឹកនាំការបះបោរនៅសម័យនោះមានស្ថានភាពខាងសង្គមប្លែកៗគ្នា។ មេដឹកនាំខ្លះជានាម៉ឺន ខ្លះជាមន្ត្រីជាន់ចាស់ ដែលចេញមកពីវណ្ណ:ជាន់ខ្ពស់នៃសង្គម

ហើយចលនាកុប្បកម្មបែបនេះ បានកើតមានឡើងដោយកំហឹងចំពោះការបាត់បង់បុព្វសិទ្ធិអំណាច និងចំណូល។ មេដឹកនាំខ្លះ គឺជាអ្នកតំណាងនៃអ្នកកាន់ព្រះពុទ្ធសាសនា ដោយមានកំហឹងចំពោះការរំលោភរបស់បារាំងមកលើជាតិសាសន៍ខ្លួន។ ពួកបារាំងបានទទួលជ័យជំនះលើចលនាតស៊ូទាំងនេះជាបន្តបន្ទាប់ ដោយការប្រើប្រាស់កលល្បិចគ្រប់បែបយ៉ាង ចំពោះមេដឹកនាំទាំងនោះ តាំងពីការទិញទឹកចិត្តរហូតដល់ការចាប់ឃុំឃាំង ធ្វើទុក្ខទោស និងសម្លាប់ជីវិត។

ការនេះគេមិនពិបាកយល់ទេ ព្រោះមន្ត្រីជាន់ខ្ពស់ខ្លះដែលបានមកធ្វើមេដឹកនាំចលនាតស៊ូកុប្បកម្មបះបោរ បានប្រែខ្លួនទៅជាអ្នកបំរើដ៏ស្លូតបូតរបស់រដ្ឋាភិបាលបារាំង ដោយបានធ្វើជានាម៉ឺនវិញនៅក្នុងរដ្ឋបាលបារាំង។ មូលហេតុម្យ៉ាងទៀត ដែលមិនអាចយកជ័យជំនះលើបារាំងបានគឺដោយសារភាពកង្វះទំនាក់ទំនង និងសាមគ្គីភាពរវាងក្រុមចលនាតស៊ូនីមួយៗ។ ដូចតាមសេចក្តីរាយការណ៍របស់បារាំង មានការសង្កេតឃើញអំពីចលនាតស៊ូខ្មែរនៅពេលនោះ ពុំមានការឯកភាពគ្នារឹងមាំរវាងគ្នាឡើយ។ មេក្រុមនីមួយៗពុំដែលមានការព្រមព្រៀងគ្នា ក្នុងការប្រយុទ្ធរួមប្រឆាំងបារាំងទេ។ ក្រុមនីមួយៗបានធ្វើការប្រយុទ្ធ ដោយពឹងផ្អែកលើតែកំលាំងរបស់ក្រុមខ្លួនផ្ទាល់ ជួនកាលបង្កើតជាទំនាស់រវាងមេដឹកនាំផ្សេងៗទៀតផង។ ក្រឡាហោមគង់ ជាមេដឹកនាំក្រុមតស៊ូមួយក្រុម បានសាកល្បងបង្រួបបង្រួមកងកំលាំងយុទ្ធជនទាំងប្រាំបួនក្រុម ដែលធ្វើការតស៊ូនៅតំបន់ខាងត្បូងភ្នំពេញអោយស្ថិតនៅក្រោមកិច្ចបញ្ជាការតែមួយ។ ក្នុងការអំពាវនាវនោះ មានតែចលនាតស៊ូក្រោមកិច្ចបញ្ជាការរបស់ពិស្ណុលោកឈូកតែមួយគត់ដែលយល់ព្រមតាម។ គុណវិបត្តិនេះដែលធ្វើអោយពួកបរទេស វាយបន្ថោកមេដឹកនាំ



ខ្មែរនិងធ្វើអោយគេមិនញញើត និងរំលោភមកលើអធិបតេយ្យភាពប្រទេសខ្លួន។ ដោយចំណុចខ្សោយនេះដែលមេដឹកនាំបារាំងមានមោទនភាព និងបន្តការគាបសង្កត់ខ្មែរតទៅទៀត។

ជំងឺខ្វះអធិបតេយ្យភាព ភាពក្រលំបាករបស់ប្រជាពលរដ្ឋខ្មែរបានកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃកាន់តែខ្លាំង។ ការនេះ មិនបានធ្វើអោយអ្នកជាតិនិយមយើងមួយចំនួនដេកបិទភ្នែកសំងំសុខឡើយ។ អ្នកទាំងនោះតែងប្រមូលគ្នាជាក្រុម ដូចជា ពួកខ្មែរឥស្សរៈជាដើម ដើម្បីវាយតបនឹងរបបគ្រប់គ្រងបារាំង។ ថ្វីត្បិតពួកនេះមិនបានយកជ័យជំនះលើបារាំងក៏ពិតមែន តែវាជាសញ្ញាមួយសំរាប់បារាំង ហើយធ្វើអោយបារាំងបារម្ភនិងភ័យខ្លាចខ្លះៗដែរ។ ទន្ទឹមនឹងនេះ ធ្វើអោយបារាំងបន្ធូរនយោបាយគាបសង្កត់ និងនឹកគិតដល់អធិបតេយ្យភាពខ្មែរទៀតផង។

ទើបនៅឆ្នាំ១៩៥៣ លោក នរោត្តម សីហនុ ដែលមានប្រជាពលរដ្ឋទូទាំងប្រទេសបានឯកភាពជាធ្លុងមួយ និងជាពិសេសការជួយឧបត្ថម្ភអំពីបណ្តាអ្នកស្នេហាជាតិយើងជាច្រើនទៀតបានប្រយុទ្ធយ៉ាងអង់អាចក្លាហាន និងស្វិតស្វាញ រហូតបានរំដោះប្រទេសជាតិ ចេញពីភាពរឹងរៃនៃរបបអាណានិគមនិយមបារាំងជាស្ថាពរ។ ក្រោមនយោបាយអព្យាក្រឹតរបស់លោក នរោត្តម សីហនុ ដោយគ្មានចំណាយនូវសាច់ឈាមខ្មែរមួយដំណក់នេះ បានធ្វើអោយប្រជាពលរដ្ឋខ្មែរមានមោទនភាពជាខ្លាំង ព្រោះក្នុងគ្រានោះ លទ្ធិសង្គមនិយម និងប្រជាធិបតេយ្យសេរីកំពុងប្រឈមមុខដាក់គ្នាទូទាំងពិភពលោក ក៏ដូចជាក្នុងអាស៊ីអាគ្នេយ៍។

## សង្គមរាស្រ្តនិយម (១៩៥៣)

ឯករាជ្យត្រូវបានលាតត្រដាង និងមានជីវិតនៅលើផ្ទៃប្រទេសខ្មែរនេះ គឺ ជាគុណបំណាច់មួយយ៉ាងអស្ចារ្យសំរាប់ប្រជាពលរដ្ឋខ្មែរ។ ឯករាជ្យជាតិនេះ ត្រូវបានប្រជាពលរដ្ឋខ្មែរទន្ទឹងរង់ចាំរាប់សតវត្សហើយ តែមិនដែលឃើញស្រមោលសោះ។ ឆ្នាំ១៩៥៣ ជាឆ្នាំដែលឯករាជ្យជាតិចាប់បដិសន្ធិនៅលើទឹកដីកម្ពុជាក្រោមពន្លឺដ៏ត្រចេះត្រចង់នៃនយោបាយអព្យាក្រឹតរបស់លោក នរោត្តម សីហនុ បានធ្វើអោយប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់វណ្ណៈសប្បាយរីករាយ មានទឹកមុខប្រឹមប្រិយ៍ប្រកបដោយសេចក្តីសង្ឃឹមនាពេលអនាគត។

វរជនជាច្រើនដែលបានចេញបង្កទ័ពតស៊ូដេកក្នុងព្រៃ ដើម្បីប្រឆាំងនិងរបបគ្រប់គ្រងបារាំងបានវិលមកចូលរួមព្រួតដៃជាមួយរដ្ឋាភិបាលសង្គមរាស្រ្តនិយម អព្យាក្រឹត ក្នុងបំណងកសាងជាតិមាតុភូមិអោយទាន់សម័យនិយម ទោះបីជាពេលកន្លងមកមាននិន្នាការខាងនយោបាយនិងគំនិតខ្វែងគ្នាក៏ដោយ។ នេះទើបហៅថា អ្នកជាតិនិយមកសាងពិតប្រាកដ ដែលមិនមែនអ្នកជាតិនិយមបំផ្លេចបំផ្លាញ។ គេមានឧត្តមគតិប្រឆាំងនឹងការបាត់បង់អធិបតេយ្យភាពរបស់ជាតិ ហើយក្រោយពីប្រទេសជាតិបានឯករាជ្យ ក៏នាំគ្នាត្រឡប់ចូលមករួមរស់ក្នុងសង្គមគ្រួសារនិងសង្គមជាតិវិញ ដោយទឹកចិត្តបរិសុទ្ធ។ ប្រជាពលរដ្ឋចូលប្រកបកិច្ចការរៀងៗខ្លួនទៅតាមមុខជំនាញពោរពេញទៅដោយស្មារតីជាតិខ្ពស់។ ប្រទេសជាតិទាំងមូលត្រូវបានរីកដុះដាលជាមួយល្បឿនយ៉ាងលឿន និងស្រស់បំព្រង សន្តិសុខមានគ្រប់គ្រាន់។ សមិទ្ធផលធំៗលើគ្រប់វិស័យ ដូចជា សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ វិស័យ



សិក្សាធិការ បានរីកត្រដែតគ្រប់ទិសទីពាសពេញផ្ទៃប្រទេស។ ស្នាដៃដ៏អស្ចារ្យមួយទៀត គឺនៅឆ្នាំ១៩៤៦ រដ្ឋាភិបាលសង្គមរាស្រ្តនិយមបានទាមទារយកបានមកវិញនូវខេត្តបាត់ដំបង និងសៀមរាបដែលប្រទេសសៀមបានដណ្តើមប្លន់យកពីខ្មែរ។

ទន្ទឹមនិងគុណសម្បត្តិនេះ មេដឹកនាំខ្មែរតែងមានចរិកមានះ ស៊ីជោរដំកើងខ្លួនចង់អោយលើសពីមនុស្សម្នាធម្មតាតាមច្បាប់ធម្មជាតិ ″ចង់ក្លាយជាអទិទេព″។ លោកធ្វើអ្វីស្រេចតែចិត្តនឹកឃើញ ទោះជាលក្ខខណ្ឌមិនតំរូវអោយធ្វើក៏ដោយ គឺធ្វើដោយមានះអូសទាញសង្កត់ប្រជាពលរដ្ឋតាមតណ្ហាអោយដើរតាមខ្លួន ហ៊ានយកស្រុកខ្មែរទាំងមូលនិងប្រជាពលរដ្ឋទាំងអស់ធ្វើជាសម្បត្តិកម្មសទ្ធិដាច់ថ្លៃរបស់ខ្លួនតែម្នាក់ឯង ចាប់ទុកពលរដ្ឋខ្មែរទាំងអស់ជាកូនក្មេង ចាត់ទុកសមត្ថភាពកូនខ្មែរមិនដល់ខ្លួន បង្គាប់អោយហៅខ្លួនថា″ឪ″។ តាមពិត តាៗ យាយៗខ្លះមានអាយុច្រើនជាងលោកសីហនុទៅទៀត ក៏ត្រូវហៅលោកសីហនុ "សម្តេចឪ″ ដែរ។ នេះសរបញ្ជាក់ថាលោក សីហនុជាអ្នកកាន់ព្រះពុទ្ធសាសនាក្លែងក្លាយ ហើយវាប្រាសចាកពីច្បាប់ធម្មជាតិទៀតផង(វាមិនដែលឪមានអាយុតិចជាងកូន ក្នុងធម្មជាតិ)។ មនុស្សប្រភេទនេះហើយ ដែលបារាំងលើកបន្តុបឡើងអោយធ្វើស្តេចខ្មែរ។ គំនិតមហិច្ឆតាបារាំងនេះ ធ្វើអោយប្រទេសខ្មែរទាំងមូល ប្រជាពលរដ្ឋខ្មែរទាំងអស់ ជួបការលំបាកមួយរយជំពូក សង្គ្រាម និងសោកនាដកម្មរហូតដល់សព្វថ្ងៃ។

របបសង្គមរាស្រ្តនិយម បានបង្កើតសាលារៀនតាំងពីថ្នាក់តូចរហូតដល់សាកលវិទ្យាល័យដើម្បីបណ្តុះបណ្តាលកូនខ្មែរ។ មានសាលារៀនស្ទើរគ្រប់ឃុំ និងថែមទាំងបានបញ្ជូននិស្សិត អោយទៅបន្តការសិក្សានៅឯ

បរទេសទៀតផងដូចជាប្រទេសបារាំងជាដើម។ ប៉ុន្តែ កូនខ្មែរដែលរៀនចេះដឹងប្រកបដោយចំណេះវិទ្យាសាស្ត្រខ្លាំងពូកែ និងជ្រៅជ្រះទាំងប៉ុន្មាន ត្រូវបានលោក នរោត្តម សីហនុ ចាត់ទុកជាសត្រូវរបស់ប្រទេសជាតិ និងតែងរកគ្រប់កលល្បិចដើម្បីកំចាត់។ នេះមានន័យថា លោក សីហនុ គ្មានបំណងអោយកូនខ្មែរណាម្នាក់ យកចំណេះដឹងវិទ្យាសាស្ត្រមកសាបព្រួសលើកូនខ្មែរដ៏ទៃទៀត ដើម្បីបានជាកំលាំងច្រើន ងាយស្រួលក្នុងការកសាងប្រទេសជាតិឡើយ។ ពេលកូនខ្មែរចេះដឹងច្រើន លោកខ្លាចខ្លួនមិនបានដើរតួជាអធិរាជលើនគរខ្មែរ។ ក្រុមនិស្សិតដែលបានទៅសិក្សានៅប្រទេសបារាំងប្រកបដោយចំណេះដឹងវិទ្យាសាស្ត្រខ្ពស់ៗ បន្ទាប់ពីបញ្ចប់ការសិក្សា បានត្រឡប់មកស្រុកវិញ ក្នុងសេចក្តីសង្ឃឹមនឹងយកចំណេះដឹងទាំងប៉ុន្មាន មកចូលរួមចំណែកកសាងប្រទេសជាតិប្រកបដោយឆន្ទៈខ្ពស់។ តែគួរអោយអនិច្ចាណាស់ ពេលមកដល់មាតុភូមិ ត្រូវលោក នរោត្តម សីហនុ ធ្វើជាមិនដឹងមិនលឺ ព្រមទាំងបញ្ជាអោយអាម៉ីអាថោង យកពួកនេះទៅដាក់គុកទៀតផង។ នេះគឺចំពោះអ្នកដែលគ្មានទេពកោសល្យខាងអែបអបរណប ឱនលំទោនចំពោះមុខលោក សីហនុ និងគ្រាន់តែសង្ស័យ និងខ្លាចក្រែងពួកនេះមានគំនិតជឿនលឿនជាងខ្លួននិងហ៊ានរិះគន់នឹងគំនិតរបស់ខ្លួនតែប៉ុណ្ណោះ ពិសេសខ្លាចពួកនេះមានប្រជាប្រិយភាពជាង។ ដោយអ្នកដឹកនាំមានចរិកបែបនេះ ធ្វើអោយប្រទេសទាំងមូលគ្រាន់តែរស់ មិនអាចលូតលាស់បាន ព្រោះខ្វះអ្នកចេះដឹងខ្ពស់ៗ។ មិនតែប៉ុណ្ណោះ ដោយសារអំពើនេះបណ្តាលអោយនិស្សិត បញ្ញវន្តដកសេចក្តីទុកចិត្តពីអ្នកដឹកនាំ ហើយក៏ជាកត្តាធ្វើអោយលេចផុះជាគំនិតកែប្រែរបបសង្គមឡើងដែរ។

ភាពលោភលន់មិនចេះស្កប់បានអូសទាញលោក សីហនុ អោយប្រ



ព្រឹត្តនូវនយោបាយ "លុយប្តូរជីវិតប្រជាពលរដ្ឋខ្មែរ"។ នៅឆ្នាំ១៩៦៦ មេដឹកនាំចិន ឈ្មោះលោក ជូ អេនឡាយ(CHOU EN LAI) បានសុំមកលោក សីហនុ ជាបុគ្គលផ្ទាល់ ដើម្បីប្រើប្រាស់កំពង់ផែកំពុងសោមសំរាប់អោយកប៉ាល់របស់ចិន ដឹកនាំគ្រឿងអាវុធនិងស្បៀងអាហារចូលមកតាមកំពង់ផែនេះ រួចដឹកជញ្ជូនតាមផ្លូវជាតិលេខ៤ ឆ្លងកាត់តាមភ្នំពេញឆ្ពោះទៅតំបន់ខាងកើតនៃប្រទេស ដើម្បីយកទៅផ្គត់ផ្គង់ដល់កងទ័ពយៀកកុងយួនខាងជើងដែលចូលមកហាត់ហ្វឹកហ្វឺនក្នុងប្រទេសខ្មែរ និងត្រៀមខ្លួនធ្វើការវាយលុកទៅយួនខាងត្បូងប្រឆាំងនឹងសហរដ្ឋអាមេរិក។ សំណើរបស់លោក ជូ អេនឡាយ នេះ មិនបានធ្វើអោយលោក សីហនុ អាចជ្រើសរើសរកផ្លូវដ៏ទៃបានទេ ព្រោះពីរភាគបីនៃការដឹកចូលមកនេះ ត្រូវបានទៅលើពួកយៀកកុងយួនខាងជើង និងចំណែកមួយភាគបី គឺសំរាប់គ្រួសាររបស់សីហនុខ្លួនឯងផ្ទាល់(William Shawcross S. 65)។ ចំពោះតំលៃនេះ គេអាចប្តូរនឹងភាពសុខសាន្តរបស់ប្រជាពលរដ្ឋទូទាំងប្រទេសរបស់គេបាន សំរាប់មេដឹកនាំដែលប្រកបដោយការលោភលន់ គ្រួសារនិយម ដូចលោក សីហនុ។ ក្នុងប្រវត្តិសាស្ត្រពិភពលោកយើងនេះ មិនដែលមានមេដឹកនាំនៃប្រទេសណាមួយ ដែលអនុវត្តការដឹកនាំប្រទេសទៅតាមតណ្ហាយ៉ាងក្រាស់ គ្មានវិចារណញ្ញាណ ដូចមេដឹងនាំខ្មែរទេ។ មេដឹកនាំខ្មែរយកតណ្ហាទៅដូរនិងអាយុជីវិតរបស់ប្រជាពលរដ្ឋខ្មែរ។ ដូចបានលើករួចមកហើយ ជ័យជេដ្ឋាទី២ ដើម្បីបំពេញកាមតណ្ហារបស់ខ្លួន បានយកទឹកដីដែលជាកម្មសិទ្ធរបស់ខ្មែរគ្រប់រូប និងជីវិតខ្មែរ ទៅដូរនិងស្រីយួន។ ឯលោក សីហនុ ដើម្បីបំពេញតណ្ហាអំណាចរបស់ខ្លួន បានយកសុខសន្តិភាពខ្មែរទៅដូរនិងគ្រាប់កាំភ្លើងអោយយួនសំលាប់ខ្មែរ និងដើម្បីយកប្រាក់ចំណេញពីជំនួញអាវុធនេះ មក

ដាក់ក្នុងហោប៉ៅគ្រួសារខ្លួន។ មានសេចក្តីបញ្ជាក់ថែមទៀតអំពីអំពើបំផ្លាញជាតិខ្មែរដោយគ្រួសារលោក នរោត្តម សីហនុ។ តាមសៀវភៅរបស់លោក ហ៊ិន ស៊ីថាន បានសរសេរនៅលើទំព័រ៩២ថា៖ "អតីតប៉ូលីសខេត្តកណ្តាលម្នាក់ដែលសព្វថ្ងៃរស់នៅក្រុងតាខ្មៅ បានអោយការថា៖ ខ្លួនគាត់ជាអ្នកទទួលបញ្ជាអោយទារលុយប្រចាំខែពីយួនយៀកកុង និងបញ្ជាពីចៅហ្វាយខេត្ត(ដែលទទួលបញ្ជាបន្តមកពីម្ចាងម៉ូនិច) អោយរាប់ចំនួនយៀកកុងដែលតាំងនៅលើទឹកដីខ្មែរ និងទារតំលៃពីរពាន់រៀលប្រចាំខែសំរាប់យៀកកុងម្នាក់"។ ឯសៀវភៅ War in Peace ក៏បានសរសេរដែរពីនិគមយួនម្នាក់ៗដែលចូលមករស់នៅតាមទូកតាមមាត់ទន្លេ ជាពិសេសតំបន់កំពង់ផ្សារតូចត្រូវបង់ជូនម្ចាង ម៉ូនិច ចំនួនប្រាំរយរៀលជារៀងរាល់ខែ។ នៅលើទំព័រ៨៤នៃសៀវភៅដដែលបានសរសេថា៖ "ទូតចិនបានទាក់ទងឈ្មួញឈ្មោះ គួច អាន នៅពេលនោះអោយទទួលដឹកអង្ករ ទៅផ្តល់អោយកងទ័ពយៀកកុងយួនខាងជើងនៅជប់ មេមត់។ ម្តងនេះឈ្មោះ គួច អាន បានសុំអោយទូតចិនក្របាមបញ្ជូនរូបិយវត្ថុទៅធនាគារហុងកុងវិញ ដែលគេបានចំណេញមួយជាពីរជាបីតាមតំលៃផ្សារងងឹត។ ក្នុងការដឹកអង្ករនេះ គេមានសំបុត្រអនុញ្ញាតពិសេសពីចំការមន ដែលគ្មាននរណាហ៊ានឆែកឆេរ រឺឃាត់បានឡើយ។ យប់មួយក្នុងឆ្នាំ១៩៦៥ ឪពុកខ្ញុំដែលត្រូវវេនទទួលខុសត្រូវជានាយល្បាត បានបំរុងឆែកឆេរឡានដឹកជាងម្ភៃកាំមីញ៉ុង តែដល់គេហុចលិខិតអនុញ្ញាតដឹកនាំពិសេសនោះមក ឪពុកខ្ញុំក៏មិនហ៊ានប៉ះពាល់ដែរ។ ប្រាក់ចំណេញដែលបានមកក្នុងការនាំអង្ករនេះ ឈ្មោះ គួច អាន លៃចែកទៅអ្នកម្ចាងម៉ូនិចនិងអ៊ុំ ម៉ាណូរិន ផងដែរ ទើបបានលិខិតអនុញ្ញាតពិសេសនោះ"។ សៀវភៅដដែលនេះបានសរសេរនៅលើទំព័រ១១៣ថា៖ "លើសពី



នេះទៀតនោះ អង្ករត្រូវចេញតាមផ្សារងងឹតដោយចិន គួច អាន ហ៊ុនគ្នាជាមួយម្ចាង ម៉ូនិច និងអ៊ុំ ម៉ាណូរិន នាំយកទៅលក់អោយពួកយួនយៀកកុងយកប្រាក់រៀលក្លែងក្លាយសុទ្ធសាធ"។

ចាប់ពីពេលនោះមករហូតដល់ឆ្នាំ១៩៧០ គ្រឿងសព្វាវុធទាំងប៉ុន្មានដែលពួកយួនយៀកកុងប្រើប្រាស់ ត្រូវបានដឹកចេញពីកំពង់ផែកំពង់សោមតាមផ្លូវជាតិលេខ៤ស្ទើរខ្វេងផ្លូវ។ សង្គ្រាមសំលាប់ខ្មែរ ក៏ចាប់ផ្តើមមានជីវិតរស់រវើកនៅលើទឹកដីកំណើតរបស់ខ្មែរ។ ឯយួនខាងជើងយៀកកុងដែលគ្រួសារសីហនុ បានផ្តល់ដីអោយនៅ និងផ្គត់ផ្គង់ស្បៀងនេះ គឺជាអ្នកមកក្តាប់សភាពការណ៍ក្នុងប្រទេសខ្មែរ និងទីបំផុតអ្នកប្រើល្បិចសំលាប់ខ្មែរ។

## លទ្ធិសីហនុនិយម និងសង្គ្រាមសំលាប់ខ្មែរ

រដ្ឋាភិបាលសង្គមរាស្ត្រនិយម ដែលប្រកាសខ្លួនជាអ្នកប្រកាន់នយោបាយអព្យាក្រឹត ទៅជាតក់ស្លុត ខ្លាចមិនបានជាអធិរាជតទៅទៀត ក៏តាំងឆ្លេឆ្លា ដូច មាន់រកពង។ ពេលនេះ បើសិនជាអ្នកអព្យាក្រឹតខ្មែរ មិនរំភើប និងការបាត់បង់អំណាច ហើយប្រកាន់យកអព្យាក្រឹតអោយបានត្រឹមត្រូវពិតប្រាកដ ប្រហែលជាប្រទេសខ្មែរមិនបានធ្លាក់ចូលក្នុងចំហាយភ្នក់ភ្លើងសង្គ្រាមយួនឡើយ។ អព្យាក្រឹត មាននៅលើតែបបូរមាត់ ឯអំពើប្រព្រឹត្តរបស់ខ្លួន ដូចស្លឹកឈើជ្រុះ។ នៅឆ្នាំ១៩៦៣លោក នរោត្តម សីហនុបាន បដិសេធឈប់ទទួលជំនួយរបស់សហរដ្ឋអាមេរិក ដែលឆ្នាំ១៩៦៣ មានចំនួនប្រហែល១៤ភាគរយនៃប្រាក់ចំណូលប្រចាំឆ្នាំ និងអាមេរិកបានផ្គត់ផ្គង់ប្រហែលជា៣០ភាគរយនៃប្រាក់ចំណាយលើយោធា(William Shawcross S. 59)។ ឯបាតុកម្មវាយស្ថានទូតអាមេរិកក្នុងឆ្នាំ១៩៦៣ សៀវភៅរបស់លោក ហ៊ុន ស៊ីថាន បានសរសេបញ្ជាក់នៅលើទំព័រ៥២ "កាលនោះ សម្តេចបញ្ជាអោយទាហានហ្លួងស្លៀកពាក់ស៊ីវិលចូលទៅក្នុងវិទ្យាល័យនានា នាំសិស្សចេញទៅវាយស្ថានទូតអាមេរិកកាំង មានលោក យឹម ទិត ជាអ្នកដឹកនាំធ្វើ"។ សៀវភៅនេះដដែលបានសរសេរនៅលើទំព័រ៨៣ថា៖ "ចាប់ពីឆ្នាំ១៩៦២ដល់១៩៦៩ លោក សីហនុ បានទទួលប្រាក់ជំនួយពីចិន និងយួនខាងជើង អោយស្ថាបនាផ្លូវលំចាក់គ្រួសក្រហមបន្តភ្ជាប់ផ្លូវលំហូជីមិញពីសេប៉ូនកាត់មកស្ទឹងត្រែង រតនគីរី មណ្ឌលគីរី ក្រចេះ កំពង់ចាម ព្រៃវែង ស្វាយរៀង កាត់តាមឧត្តុងចាក់ទៅផែកំពង់សោម"។

ដោយមហាប្រទេសធំៗ បានមើលឃើញនូវនយោបាយអព្យាក្រឹត



ក្លែងក្លាយរបស់រដ្ឋាភិបាលសង្គមរាស្ត្រនិយមនេះ គេចាប់ផ្តើមជ្រៀតជ្រែក និងដណ្តើមគ្នាលូកដៃចូលប្រទេសកម្ពុជា និងធ្វើអោយប្រទេសទាំងមូល ក្លាយជាសមរភូមិប្រយុទ្ធ ហុតឈាម រវាងមហាអំណាចដែលគេហៅថា លទ្ធិសង្គមនិយមនិងមូលធននិយម។ ចំណែកឯ ក្រុមនិស្សិត បញ្ញវន្តចាប់ពីឆ្នាំ១៩៦៣ ក្រោយពេលដែលលោក នរោត្តម សីហនុ បានបដិសេធឈប់ទទួលជំនួយរបស់សហរដ្ឋអាមេរិក ក៏ច្របូកច្របល់ ខ្លះរត់ចូលឆ្វេង ខ្លះរត់ចូលស្តាំគឺទៅតាមតែការឃោសនាអូសទាញរបស់ពួកបរទេស។ សហរដ្ឋអាមេរិកបញ្ជូនអ្នកស៊ើបការ(CIA)របស់គេ តាមរយៈខ្មែរដែលលោក សីហនុហៅថា ខ្មែរសេរី។ ឯប្រទេសចិន បញ្ជូនមនោគមន៍វិជ្ជារបស់គេតាមរយៈបក្សកុំមុយនីស្តឥណ្ឌូចិន ដែលមានយួនជាមេក្លោង និងក្រោយពីក្រុងហាណូយបែរទៅរកសូវៀតមកតាមរយៈពួកខ្មែរខាងឆ្វេង។ ចំណែកសូវៀតបានលូកចូលមកតាមរយៈយួនខាងជើងដែលមានសន្និសញ្ញាជាច្រើន រវាងក្រុងម៉ូស្គូនិងក្រុងហាណូយ។ ដូចនេះ បើយើងពិនិត្យពិច័យមើលលើសភាពការណ៍អោយច្បាស់ទៅ គឺប្រទេសខ្មែរស្ថិតក្នុងភាពចាប់ហែកដោយមហាអំណាចទាំងបី។

នៅក្នុងប្រទេសពីមួយថ្ងៃទៅមួយថ្ងៃ កំលាំងខាងឆ្វេង និងខាងស្តាំរីកដុះដាលកាន់តែខ្លាំង ហើយកំលាំងខាងឆ្វេងខ្លះចាប់ផ្តើមដកខ្លួនថយចេញពីរដ្ឋាភិបាល រួចរត់ចូលព្រៃ។ ឯលោក សីហនុ កាលបើដឹងថា កំលាំងលទ្ធិសង្គមនិយមមានការរីកចំរើនយ៉ាងខ្លាំងនៅក្នុងពិភពលោក ក៏ដូចជានៅក្នុងប្រទេសយ៉ាងនេះ គាត់បានទៅអោបបាតជើងមហាអំណាចសង្គមនិយមចិន ដើម្បីយកចិត្តពួកនេះអោយគេទុកខ្លួនសោយរាជ្យតទៅទៀត។ ទង្វើនេះមិនមែនមានន័យថា៖ លោក សីហនុចូលចិត្តនឹងលទ្ធិនេះទេ ទោះជា

គាត់នៅថ្ងៃទី៣ឧសភា១៩៦៥ ផ្តាច់ទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិកនិងនៅឆ្នាំ១៩៦៦ គាត់ធ្វើការទាក់ទងជាមួយប្រទេសចិនដាច់ផ្តាប់មុខក៏ដោយ។ តែមិនបានដូចចិត្ត នៅឆ្នាំ១៩៦៧ ឥទ្ធិពលនៃបដិវត្តន៍វប្បធម៌របស់ប្រធានម៉ៅ គឺជាពេលដែលពួកខ្មែរខាងឆ្វេងនៅសំឡូតបានផ្ទុះឡើង និងនៅមានកងឯកភាពតស៊ូខ្មែរផ្សេងៗទៀត ចិតនៅក្រោមអគ្គបញ្ជាការរបស់រដ្ឋមន្ត្រីរង នៃក្រសួងការពារជាតិសាធារណរដ្ឋប្រជាធិបតេយ្យយួន ឈ្មោះ តាក្វាងហ៊ីវ ធ្វើសកម្មភាពវិទ្ធង្សនា មិនឈប់ឈរ។ ហេតុការណ៍កើតឡើងនេះបានធ្វើអោយលោក នរោត្តម សីហនុ ដេកបារម្ភជាខ្លាំង ខ្លាចពួកប្រកាន់លទ្ធិកុំមុយនីស្តមិនទុកជីវិត ក៏តាំងខ្វែងដៃខ្វែងជើងតែម្នាក់ឯង។

នៅពេលពួកកុំមុយនីស្តយួន កំពុងតស៊ូប្រឆាំងនឹងសហរដ្ឋអាមេរិក និងដើម្បីបង្រួបបង្រួមយួនទាំងពីរ ទន្ទឹមនឹងនោះ សហរដ្ឋអាមេរិកបំរុងនឹងដកថយចេញពីប្រទេសយួនខាងត្បូង ព្រមទាំងលះបង់ប្រទេសលាវ កម្ពុជា រួមជាមួយការគំរាមកំហែងរបស់ពួកខាងឆ្វេង បំរុងនឹងទំលាក់គាត់ចេញពីដែលហៅថា ស្តេច បារាំងលើកបន្ទុប អាត្មានេះក្រាញននៀលនឹងរបបអំណាចអញនិយម បានទៅលួចឃុបឃិត ជាមួយពួកកុំមុយនីស្តយួនតែម្នាក់ឯង។ ឆ្នាំ១៩៦៦-៦៧ អនុញ្ញាតអោយពួកកុំមុយនីស្តយួនមកតាំងមូលដ្ឋានកងទ័ព មន្ទីរពេទ្យ មជ្ឈមណ្ឌលហ្វឹកហ្វឺន មូលដ្ឋានផ្ទុកភស្តុភា និងមជ្ឈមណ្ឌលរៀបចំកងទ័ពនៅក្នុងទឹកដីកម្ពុជា សំរាប់ធ្វើការវាយលុកទៅលើកងទ័ពអាមេរិកនៅយួនខាងត្បូង។ នៅថ្ងៃទី២៩មិនា១៩៧០ តាមបណ្តោយព្រំប្រទល់ខ្មែរខាងកើតចាប់ពីខេត្តរតនគីរីរហូតដល់ដែនសមុទ្រ មានកងទ័ពប្រដាប់អាវុធពួកកុំមុយនីស្តយួនចំនួន៦៥០០០នាក់(ស៊ីសុវត្ថិ សិរិមត: ផ្ញើលិខិតចំហចំពោះស្តេចសីហនុនាថ្ងៃទី២៧សីហា១៩៧៣)។ លោក សីហនុ



បានធ្វើសេចក្តីអនុញ្ញាតនេះដោយសំងាត់តាមទំនើងចិត្តផ្ទាល់ ពុំអោយរដ្ឋាភិបាលនិងសភាខ្មែរបានដឹងឡើយ។ ប្រហែលជាគាត់ប្រមើលយល់ថា កងទ័ពយួនដែលខ្លួនអនុញ្ញាតអោយចូលមកលុកលុយក្នុងប្រទេស ដោយស្ងាត់នេះ អាចធ្វើអោយគាត់ឆ្លៀតឱកាសយកស្លាប់រស់ជាមួយពួកខ្មែរប្រកាន់ឆ្វេង យ៉ាងណាក្តី ក៏យួនជួយការពារអំណាចអោយគាត់បាន។

ទន្ទឹមនិងការឃុបឃឹតជាមួយយួនខាងជើង លោក សីហនុ បានធ្វើការប្រឆាំងជាខ្លាំងទៅលើខ្មែរប្រកាន់ឆ្វេងនិងបានថ្កោលទោស បកអាក្រាតនយោបាយរបស់មេដឹកនាំចិនជាអ្នកឧបត្ថម្ភ។ ដូចមានសេចក្តីថ្លែងការណ៍របស់លោកសីហនុ ខាងក្រោមនេះ(ដកស្រង់ពីសេចក្តីថ្លែងការណ៍នៃលោកចេង ហេង នាថ្ងៃទី៥ខែកញ្ញាឆ្នាំ១៩៧៣)៖

- នៅថ្ងៃទី២២វិច្ឆិកា១៩៦៦ នៅខេត្តកំពង់ចាម គាត់បានថ្លែងថា គឺពួកខ្មែរក្រហមនេះឯងហើយ ដែលចង់អោយប្រទេសខ្មែរ ធ្លាក់ទៅជាខ្ញុំកញ្ជះនៃពួកកុំមុយនីស្ត។ ទោះបីជាអ្នកឯងធ្វើនេះដោយសតិសម្បជញ្ញៈ រឺក៏ទេនោះក្តី តែការពិតវាដូចនេះ។
- នៅថ្ងៃទី១៩កញ្ញា១៩៦៧ គាត់បានថ្លែងថា៖ យើងសុំអោយមិត្តចិនរបស់យើង បញ្ឈប់នូវសកម្មភាពវិទ្ធង្សនានៅប្រទេសខ្មែរជាបន្ទាន់។
- នៅថ្ងៃទី២៦កញ្ញា១៩៦៧ គាត់បានថ្លែងថា៖ ខ្ញុំមិនព្រមទាល់តែសោះនិងពួកម៉ៅនិយមក្នុងស្រុកដែលអះអាងថា ប្រជារាស្ត្រខ្មែរត្រូវតែបោះបង់របបយើងនេះចោលចេញគឺសង្គមនិយមព្រះពុទ្ធសាសនា ហើយត្រូវប្រកាន់យកកុំមុយនីស្តចិន ដើម្បីអោយបានរស់នៅដោយសប្បាយជាងសព្វថ្ងៃនេះទៅទៀត។
- នៅថ្ងៃទី៣១កញ្ញា១៩៦៧ គាត់បានថ្លែងថា៖ សុំអោយមិត្តចិនមេត្តា

អនុញ្ញាតអោយខ្ញុំជំរាបដោយត្រង់ៗនូវការដូចតទៅះ ប្រសិនបើលោកអាចទិញពួកបញ្ញវន្ត អ្នកមានៗមួយក្តាប់តូចដែលប្រកបដោយតណ្ហា លោភលន់នោះ ក៏លោកពុំអាចទិញរាស្ត្រខ្មែរបានដែរ។

- នៅថ្ងៃទី៣០កញ្ញា១៩៦៨ គាត់បានថ្លែងថាះ សហាជីវិន ហ៊ូ នឹម និងបក្សពួកខ្លួនមិនដឹងថាអ្នកដឹកនាំក្រុងប៉េកាំងសន្មត់ពួកលោកជាជនក្បត់ ជាពលរដ្ឋដែលគួរអោយមើលងាយ ដែលបានបាត់បង់នូវគំនិតជាអ្នកស្នេហាជាតិអស់រលីង។

- នៅថ្ងៃទី០១កុម្ភ:១៩៦៨ គាត់បានថ្លែងថាះ ខ្ញុំមិនញញើតនិងបញ្ជូនពួកខ្មែរក្រហមទាំងនោះទៅអោយតុលាការសឹកកាត់ទោសប្រហារជីវិត ខ្ញុំច្បាស់ជាអោយគេបាញ់ពួកនេះចោលជាមិនខាន សូមអោយអស់លោកឈប់ក្បត់និងមាតុប្រទេសរបស់ខ្លួន។

- នៅថ្ងៃទី២៨កុម្ភ:១៩៦៨ គាត់បានថ្លែងថាះ ដរាបណាខ្ញុំនៅកាន់អំណាច ខ្ញុំមិនអត់អោនអោយពួកខ្មែរក្រហមបំផ្លាញប្រទេសយើងឡើយ។

ទោះបីជាលោក សីហនុ ខិតខំបំប៉ោងបំពង់កយ៉ាងណាក៏ដោយ មិនអាចទប់ស្កាត់ចលនាដ៏ស្រួចស្រាវរបស់ពួកខ្មែរខាងឆ្វេង ដែលមានមេដឹកនាំក្រុងប៉េកាំង និងក្រុងហាណូយជួយឧបត្ថម្ភដែរ។ ពីមួយថ្ងៃទៅមួយថ្ងៃ មេដឹកនាំក្រុងប៉េកាំង នៅតែបន្តជួយដល់ពួកខ្មែរទាំងនេះ។ លោកសីហនុ មួរម៉ៅក្តៅក្រហាយនឹងមេដឹកនាំក្រុងប៉េកាំង ក៏រំលាយសមាគមមិត្តភាព-ខ្មែរ-ចិន ចោល(លោក ស៊ីសុវត្ថិ សិរិមត: ផ្ញើលិខិតចំពោះ សីហនុនាថ្ងៃទី២៧សីហា១៩៧៣)។

ឯការស្រមៃរបស់លោក នរោត្តម សីហនុ ដែលថា យួនយៀកកុងនឹងជួយដណ្តើមអំណាចអោយខ្លួននោះ មិនបានធ្វើអោយគាត់មានក្តីសង្ឃឹម



ដែរ គឺប្រៀបបាននឹងលាងពាងរង់ចាំត្រងទឹកភ្លៀងនារដូវប្រាំង។ ចំណែកឯកងទ័ពយួនយៀកកុង មកតាំងមូលដ្ឋាននៅមួយចំហៀងប្រទេស និងពួកខ្មែរប្រកាន់ឆ្វេងរីកដុះដាលពេញព្រៃ។ កងទ័ពយួនដែលលោក នរោត្តម សីហនុ អនុញ្ញាតអោយចូលមកនេះមិនបានជួយលោក និងថែមទាំងជួយពួកខ្មែរខាងឆ្វេង ដើម្បីផ្តួលរំលំរបបអំណាចអញនិយមរបស់គាត់ទៀត។ ដូចនេះ គំនិតផ្សងព្រេងរវើរវាយរបស់លោក នរោត្តម សីហនុ មិនអាចក្លាយជាការពិតបានឡើយ។

បើសិនជាលោក នរោត្តម សីហនុ មិនបានធ្វើតាមលទ្ធិអំណាចអញនិយមរបស់គាត់ទេ ប្រហែលជាយួនខាងជើងនិងយួនខាងត្បូងច្បាំងគ្នារហូតដល់ពេលនេះមិនទាន់ចប់ផង ហើយមូលហេតុដែលបណ្តាលអោយមានការភ័យខ្លាចគ្រោះថ្នាក់ ចំពោះជីវិតខ្មែរក៏ត្រូវបន្ថយដែរ ព្រោះថា កាលបើស្រុកយួនមានសង្គ្រាមនោះ យួនគ្មានពេលនឹងនឹកឃើញឈ្លានពានខ្មែរធ្វើអោយយើងមិនសូវបារម្ភពីទិសខាងកើត។

តើពេលនេះលោក សីហនុ ប្រមើលយល់ដូចម្តេចទៀតដើម្បីរក្សាការពារលទ្ធិអំណាចអញនិយមរបស់គាត់?។

អាមេរិកដឹងថា កំលាំងទ័ពយួនខាងជើងយៀកកុងទាំងអស់ដែលធ្វើការវាយលុកទៅលើទ័ពខ្លួននៅយួនខាងត្បូង គឺចេញមកពីប្រទេសកម្ពុជា។ នៅថ្ងៃទី២៤កុម្ភ:១៩៦៩ មេបញ្ជាការរបស់សហរដ្ឋអាមេរិកប្រចាំនៅប្រទេសយួនបានធ្វើពាក្យសុំទៅប្រធានាធិបតីខ្លួន ដើម្បីធ្វើការទំលាក់គ្រាប់បែកបេ-៥២ទៅលើតំបន់ពួកកុំមុយនីស្តយួននៅក្នុងប្រទេសកម្ពុជា។ នាថ្ងៃទី១៧មិនា១៩៦៩ ប្រធានាធិបតី និច សុន(NIXON) បានទទួលយល់ព្រមនូវសំណើនេះ ព្រោះមិនឃើញមានប្រតិកម្មតបចេញពីរដ្ឋាភិបាលខ្មែរសោះ

ហើយពេលនោះលោក សីហនុ គ្មានបានលើកឡើងពីការជំទាស់អ្វីដែរ។

ក្នុងពេលសហរដ្ឋអាមេរិកចាប់ផ្តើមទំលាក់គ្រាប់បែក  នៅតាមព្រំប្រទល់ខ្មែរ  ពួកកងទ័ពកុំមុយនីស្តយួនខាងជើង  បានរុលរំកិលមូលដ្ឋានទ័ពនិងមូលដ្ឋានផ្ទុកភស្តុភារបស់គេ  មកកាន់តែជ្រៅចូលក្នុងទឹកដីនៃប្រទេសកម្ពុជា  ព្រមទាំងបានពង្រឹង  និងពង្រីកកាន់តែធំឡើងៗដោយយកលេសរត់គេចពីការទំលាក់គ្រាប់បែកនេះ។

សូមបញ្ជាក់  អំពីការទំលាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកខ្លះៗ។ ពេលលឺសូរសំលេងយន្តហោះបេ-៥២(B-52)របស់សហរដ្ឋអាមេរិកមក ពួកកុំមុយនីស្តយួនយៀកកុងមួយនាក់រឺពីរនាក់ធ្វើជារត់ឆ្លេឆ្លារសេករសាច ចូលក្នុងភូមិនេះ ភូមិនោះ ចូលក្នុងសាលារៀន និងក្នុងវត្តអារាមជាដើម។ ដោយឃើញមានពួកយួនយៀកកុងយ៉ាងនេះ  យន្តហោះបេ-៥២តាមទំលាក់តាមបាញ់រហូតដល់ខ្ទេចកន្លែងនោះ និងស្លាប់តែប្រជាកសិករខ្មែរស្លូតត្រង់ ឆេះតែសាលារៀន វត្តអារាម គ្មានងាប់ពួកកុំមុយនីស្តយួនយៀកកុងណាម្នាក់។ ការទំលាក់គ្រាប់បែកនេះកាន់តែមានសភាពខ្លាំងឡើងៗ  មិនត្រឹមតែនៅតាមព្រំប្រទល់  គឺរាលដាលរហូតដល់ផ្ទៃក្នុងប្រទេស  ព្រោះពួកកុំមុយនីស្តយួនយៀកកុងចូលមកកាន់តែជ្រៅឡើងៗ។  គ្រាន់តែការទំលាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ធ្វើអោយមេដឹកនាំយួនមហាសែនចំណេញគឺៈ

១- យួនបានជាលេសធ្វើជាគេចគ្រាប់បែកអាមេរិក ចូលមកស្រុកខ្មែរកាន់តែជ្រៅ  ដែលជាមូលហេតុធ្វើអោយពួកគេកាន់តែអាចក្តាប់ភូមិសាស្ត្របានល្អ និងចាក់រឹសកាន់តែមាំក្នុងប្រទេសកម្ពុជា។

២-  សហរដ្ឋអាមេរិកទំលាក់គ្រាប់បែកនេះ  ស្លាប់តែខ្មែរ  ត្រូវខ្ទេចតែភូមិខ្មែរ ដីខ្មែរក្លាយជារណ្តៅគ្រាប់ ដែលធ្វើអោយប្រជាពលរដ្ឋខ្មែរជួបការលំបាកគ្រប់បែបយ៉ាង។  កក្តាទាំងនេះគឺធ្វើអោយមេដឹកនាំយួនរីកថ្លើមគ្មានអ្វីប្រៀប។  ចុះមេដឹកនាំខ្មែរអីក៏ល្ងង់ខ្លាំងម្លេះ  អោយគេចំណេញលើក្បាលទាំងភ្នែកស្រស់អញ្ចឹង។ ឱ ! លោកធំខ្មែរ



ការរួយគ្រាប់បែករបស់សហរដ្ឋអាមេរិកនៅលើទឹកដីខ្មែរនេះ មិនអាចបំបាត់បានទេ ដោយសារអំណាចរបស់លោក សីហនុ មកដល់ពេលនេះកំពុងថិតក្នុងការរាវែករវាងឆ្វេង និងស្តាំនៅឡើយ។ តែដោយសភាពការណ៍ជាទូទៅបញ្ជាក់ថា  អំណាចដែលលោក  សីហនុ  រង់ចាំទទួលពីពួកកុំមុយនីស្តយួននោះ មិនអាចធ្វើអោយគាត់មានសង្ឃឹមឡើយ។ ដូចនេះ គាត់ត្រូវផ្លាស់ប្តូរគំនិតក្នុងការស្វែងរកបង្គោលបង្អែកថ្មី។

ពេលដែលលោក  សីហនុ  អស់សង្ឃឹមនឹងដេញពួកកងទ័ពកុំមុយនីស្តយួនយៀកកុង  ចេញពីប្រទេសបាននោះ(ព្រោះអីពេលក្រោយៗមកគេសង្កេតឃើញមានសកម្មភាពជាច្រើន  ដែលគាត់ដើរស្រែកឡូឡាពីរឿងយួនក្នុងស្រុក  តែអ្នកដឹកនាំក្រុងហាណូយមិនខ្វីធ្វើដឹង)  និងមិនអាចបំបាត់ពួកខ្មែរប្រកាន់ឆ្វេងបាន  គាត់បណ្តោយអោយយន្តហោះបេ-៥២  ទំលាក់គ្រាប់ស្មើរសុះដីប្រទេសខ្មែរ  ទោះជាត្រូវស្លាប់ប្រជាកសិករខ្មែរយ៉ាងអនោចអធម្មក៏ដោយ ក៏លោក សីហនុ មិនខ្វីឈឺក្បាលដោយយកលេសសំអាងថាយន្តហោះបេ-៥២ទំលាក់គ្រាប់បែកនេះ  គឺដើម្បីសំលាប់ពួកកុំមុយនីស្តយួនយៀកកុង  និងពួកខ្មែរក្រហមដែលខ្លួនអស់សមត្ថភាពនឹងកំចាត់ចេញ។ នៅថ្ងៃទី១១មិថុនា១៩៦៩  លោក  សីហនុ  បានសុំធ្វើទំនាក់ទំនងជាផ្លូវការជាមួយសហរដ្ឋអាមេរិកវិញ  ក្នុងបំណងចង់អោយសហរដ្ឋអាមេរិកជួយកំចាត់ពួកកុំមុយនីស្តយួនយៀកកុងនិងពួកខ្មែរខាងឆ្វេង។  លោក  សីហនុ ដូចជាវែឆ្លាតលើគោកខំងាកមករកមហាអំណាចសហរដ្ឋអាមេរិក អោយ

ជួយដែរ តែដោយសារពេលនេះអាមេរិកគ្មានបំណងចង់សង្គ្រោះជីវិតខ្មែរទេ ព្រោះវាគ្មានបានចំណេញដល់ខ្លួន ទៅជាខំទំលាក់គ្រាប់បែកថែម។

នៅខែសីហា១៩៦៩ លោក សីហនុ បានបង្កើតរដ្ឋាភិបាលស្រោចស្រង់ជាតិ ដែលមានចំនួនពួកខ្មែរប្រកាន់ស្តាំជាច្រើន។ គ្រានេះ គាត់បានជ្រើសតាំងលោក លន់ នល់ អោយធ្វើជានាយករដ្ឋមន្ត្រី"Ministerpresident" (លោក លន់ នល់ ជាអតីត:ឧត្តមសេនីត្រី) ព្រោះលោក សីហនុ សង្ឃឹមថាពេលគាត់ងាកមករកពួកខ្មែរខាងស្តាំ អាចធ្វើអោយអាមេរិកពេញចិត្ត រួចពិតជាបញ្ជូនជំនួយផ្នែកសម្ភារៈយោធា មកប្រទេសកម្ពុជាយ៉ាងលឿន និងជាបន្ទាន់(Willian Shawcross S. 121)។ នយោបាយដេកសង្ឃឹមបានត្រឹមតែសង្ឃឹមប៉ុណ្ណោះ ឯលទ្ធផលបងប្អូននឹងជ្រាបនៅទំព័រខាងក្រោយ។

ដោយអំពើស្រេកឃ្លានរបបអំណាចអញនិយម រហូតដល់ហ៊ានលួចសំរេចកិច្ចការដែលជារឿងអាយុជីវិតរបស់ប្រទេសជាតិតែម្នាក់ឯង បានរុញច្រានប្រទេសទាំងមូល អោយចូលក្នុងភ្នក់ភ្លើងសង្គ្រាមសំលាប់ខ្មែរយ៉ាងវង្គាល។ ឯការទៅហៅយួនអោយចូលស្រុកនេះ គឺធ្លាប់មានរួចមកហើយក្នុងប្រវត្តិសាស្ត្រខ្មែរក្រោយសម័យអង្គរ។ ពេលកើតមានវិបត្តិក្នុងគ្រួសារ រឺវិបត្តិក្នុងប្រទេសដោយសារការចង់បានអំណាចផ្តាប់មុខតែម្នាក់ឯង និងការភ័យខ្លាចបាត់អំណាចរបស់ស្តេចខ្មែរ ក៏តាំងរត់រកយួន រកសៀមអោយមកជួយដណ្តើម រឺការពាអោយខ្លួន។ ទីបំផុត យួន សៀមប្រលះយកទឹកដីស្ទើរអស់ ព្រមទាំងសំលាប់ខ្មែរទៀតផង។ ដោយលោក នរោត្តម សីហនុ បង្កើតអោយមានវិបត្តិនយោបាយ និងវត្តមានកងទ័ពយួននៅមួយចំហៀងប្រទេស ដែលយួនអាចលេបយកប្រទេសខ្មែរបាននោះ ទើបមានការផ្លាស់ប្តូររបបសង្គមនៅថ្ងៃទី១៨មិនា១៩៧០។



## ព្រឹត្តការណ៍ជុំវិញថ្ងៃ១៨ មិនា ១៩៧០

ចុងឆ្នាំ១៩៦៩ លោកនាយករដ្ឋមន្ត្រី លន់ នល់ មានជំងឺប្រចាំកាយរួចធ្វើដំណើរទៅប្រទេសបារាំងដើម្បីព្យាបាល។ ក្នុងពេលនោះ លោកបានប្រគល់ដំណែងជានាយករដ្ឋមន្ត្រីទៅលោក ស៊ីសុវត្ថិ សិរិមត:។ (វង្សត្រកូលស៊ីសុវត្ថិ ត្រូវបានដកលែងអោយឡើងសោយរាជ្យចាប់តាំងពីឆ្នាំ១៩៤១មកម្ល៉េះ គឺនៅពេលដែលមេដឹកនាំបារាំងលើកត្រកូល នរោត្តមអោយឡើងគ្រងរាជ្យ។ ការពិត បើតាមប្រពៃណីដែលឡើងសោយរាជ្យតគ្នានោះ គឺត្រកូលស៊ីសុវត្ថិដែលត្រូវបានឡើងគ្រងរាជ្យបន្ត មិនមែនត្រកូលនរោត្តមឡើយ។ តែដោយមេដឹកនាំបារាំងចង់បង្កើតអោយមានវិបត្តិក្នុងវង្សគ្រួសារស្តេចខ្មែរ ដើម្បីងាយស្រួលនឹងឆ្លៀតពេលកាន់កាប់ប្រទេសកម្ពុជា ទើបបារាំងបំផ្លើសពង្វក់ស្រេចតែចិត្តយ៉ាងនេះ។ ចាប់តាំងពីពេលនោះមក គ្រួសាររបស់លោកស៊ីសុវត្ថិ សិរិមត: មិនសូវជាសប្បាយចិត្តនឹងរដ្ឋាភិបាលបារាំងប៉ុន្មានទេ។ ឯភាពខ្វែងគំនិតគ្នារវាងលោក ស៊ីសុវត្ថិ សិរិមត: និងលោក នរោត្តម សីហនុ កាន់តែកើនធំឡើងៗជារៀងរាល់ថ្ងៃ)។

ក្រោយពីបានទទួលដំណែងជានាយករដ្ឋមន្ត្រីមក លោក ស៊ីសុវត្ថិ សិរិមត: ក្លាយជាមនុស្សម្នាក់ដ៏សំខាន់ក្នុងនយោបាយខ្មែរនាខណ:នេះ។ លោកស៊ីសុវត្ថិ សិរិមត: បានធ្វើការជំទាស់នឹងផែនការរបស់លោកនរោត្តម សីហនុ ក្នុងការធ្វើសេដ្ឋកិច្ចសម្ភហភាព និងលោកបានគាំទ្រនយោបាយរបស់សហរដ្ឋអាមេរិកនៅតំបន់អាស៊ីអាគ្នេយ៍។ មិនតែប៉ុណ្ណោះ លោកបានវាយប្រហានូវការចូលចិត្តរបស់លោក សីហនុ ចំពោះពួកកុំមុយនីស្តយួនខាងជើងជានិច្ច។

នាខែមករា១៩៧០ លោក សីហនុ បានធ្វើដំណើរទៅប្រទេសបារាំងជាធម្មតាក្នុងការសំរាកកាយរបស់គាត់ ឯសុខភាពរបស់គាត់មិនសូវជាយ៉ាប់អ្វីប៉ុន្មានទេ។ ក្នុងពេលជាមួយគ្នានេះ ពួកយកការណ៍សេអ៊ីអា(CIA) របស់អាមេរិកជាច្រើន ត្រូវបានបញ្ជូនចូលមកក្នុងប្រទេសកម្ពុជាពីយួនខាងត្បូង។ ពួកCIAទាំងនេះមានទីស្នាក់ការនៅព្រៃនគរសំរាប់យកពត៌មានពីប្រទេសខ្មែរ។ សហរដ្ឋអាមេរិក មិនត្រឹមតែបញ្ជូនពួកCIA មកកម្ពុជាប៉ុណ្ណោះទេ ថែមទាំងជួយឧបត្ថម្ភដល់ក្រុមខ្មែរដែលលោក សីហនុ ហៅថា ខ្មែរសេរីទៀតផងក្នុងគោលបំណងផ្តួលរំលំរបបអំណាចអញនិយមរបស់សីហនុ។

លោក សីហនុ មកដល់ប្រទេសបារាំងនាខែមករា១៩៧០ ហើយគាត់បានជួបនិងលោកលន់ នល់។ លោក សីហនុ និងលោកនាយករដ្ឋមន្ត្រីបាននឹកឃើញនូវរូបមន្តមួយ ដើម្បីទទួលការជួយគាំទ្រពីសហភាពសូវៀតរឺមួយពីប្រទេសចិន ដោយបញ្ឈាក់ពីការជ្រៀតជ្រែកចូលនៃកងទ័ពយួនខាងជើងក្នុងប្រទេសកម្ពុជា។

លោក សីហនុ បានធ្វើគំរោងការត្រឡប់មកប្រទេសកម្ពុជាវិញដោយឆ្លងកាត់ក្រុងម៉ូស្គូនិងក្រុងប៉េកាំង។ ក្នុងពេលនោះ លោក លន់ នល់ ត្រូវនាំពត៌មាននេះមករៀបចំធ្វើបាតុកម្មប្រឆាំងពួកយួននៅទីក្រុងភ្នំពេញ ដើម្បីបង្ហាញនូវកំហឹង និងវិធានការរបស់ខ្មែរ អំពីការដែលយួនមិនគោរពអធិបតេយ្យភាពរបស់កម្ពុជា។ លោក សីហនុ ត្រូវទៅសុំមេដឹកនាំសូវៀត និងចិនអោយធ្វើការគាបសង្កត់ទៅលើរដ្ឋាភិបាលក្រុងហាណូយ អោយដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជា។ នេះបង្ហាញថា៖ ចាប់ពីដើមឆ្នាំ១៩៧០មក លោក សីហនុ មានការភ្ញាក់ផ្អើលជាខ្លាំងអំពីសង្គ្រាមដែលរីកដុះដាលចូលមកក្នុងប្រទេសកម្ពុជា និងបង្កើតការចងកំហឹងរបស់គាត់ជាចំហារប្រ



ឆាំងនិងពួកកុំមុយនីស្តយួន។

នៅខែកុម្ភៈ លោក លន់ នល់ បានធ្វើការកោះហៅអ្នកគ្រប់គ្រងនៅតាមខេត្តទាំងអស់ បើកសន្និសិទ្ធដើម្បីពិភាក្សាអំពីបញ្ហាកងទ័ពយួនយៀកកុងដែលបានមកតាំងមូលដ្ឋានក្នុងប្រទេសកម្ពុជា។ លោក លន់ នល់ បានបិទច្រកកំពង់ផែកំពង់សោម ឈប់អោយកប៉ាល់ដឹកនាំគ្រឿងអាវុធ និងភស្តុភារបស់ចិនដែលសំរាប់ជួយផ្គត់ផ្គង់ដល់ពួកកងទ័ពយួន។ នៅថ្ងៃទី៨មិនា លោក លន់ នល់ បានរៀបចំធ្វើបាតុកម្មមួយប្រឆាំងនិងវត្តមាននៃកងទ័ពយួនក្នុងប្រទេសកម្ពុជា។ នៅថ្ងៃទី១១មិនា និស្សិតរាប់ពាន់នាក់ ទាហាន ព្រះសង្ឃ បានប្រមូលគ្នានៅវិមានឯករាជ្យ និងការលុកលុយទៅលើស្ថានទូតយួន។ ចំណែក លោក សីហនុ នៅឯប៉ារីសបានធ្វើការផ្តន្ទាទោសដោយកំហឹងទៅលើពួកបាតុករទាំងនេះ និងបានប្រកាសថា៖ ពួកនេះ ត្រូវបានមានអ្នករៀបចំឡើង ដើម្បីបំផ្លាញនិងបំបែកបំបាក់មិត្តភាពរបស់កម្ពុជាជាមួយនឹងលទ្ធិសង្គមនិយម ព្រមទាំងអនុវត្តប្រទេសយើង អោយថិតក្នុងដៃនៃមហាអំណាចមូលធននិយម។

លោក សីហនុ ផ្ញើសារលិខិតមួយយ៉ាងលឿនមកមាតាគាត់ថា៖ "ខ្ញុំនឹងមិនធ្វើដំណើរទៅក្រុងម៉ូស្កូ និងប៉េកាំងទេ ហើយខ្ញុំនឹងត្រឡប់មកមាតុប្រទេសវិញជាប្រញាប់ដើម្បីកុំអោយប្រទេសខ្ញុំក្លាយជាប្រទេសលាវទីពីរ"។ បានដំណឹងនេះភ្លាម ក្នុងទីក្រុងភ្នំពេញត្រូវបានរៀបចំរង់ចាំទទួលការវិលត្រឡប់មកដល់របស់គាត់។ ប៉ុន្តែលោកនាយករដ្ឋមន្ត្រីរបស់គាត់នៅតែបន្តអនុវត្តការប្រឆាំងនឹងនយោបាយកុំមុយនីស្តយួនដដែល។ ពេលក្រោយមកលោក លន់ នល់ បានធ្វើការសុំទោសជាជាក់លាក់ក្នុងការដែលពួកបាតុករបានលុកលុយទៅលើស្ថានទូតយួន។ ទន្ទឹមនឹងនេះ លោកបានប្រកាស

អោយកងទ័ពយួនទាំងប៉ុន្មាន ដែលបានមកបោះទីតាំងក្នុងកម្ពុជាត្រូវតែលះបង់ប្រទេសកម្ពុជា ក្នុងរយៈពេល៧២ម៉ោងអោយអស់។ មកដល់ពេលនេះ ទំនងជាលោក លន់ នល់ មិនទាន់បានចូលរួមមតិក្នុងការទំលាក់លោក សីហនុ រឺយ៉ាងណាទេ។ នេះបង្ហាញថា៖ លោក លន់ នល់ បានពិភាក្សាជាមួយលោក សីហនុ ជាមុនក្នុងកាធ្វើបាតុកម្មនេះ។ ចំណែកលោក ស៊ីសុវត្ថិ សិរិមតៈ វិញមានគំរោងនឹងទំលាក់ លោក សីហនុ រួចទៅហើយ ដោយសារបាតុកម្មដែលរៀបចំឡើងដោយលោក ស៊ីសុវត្ថិ សិរិមតៈ និងក្រោមការជួយគាំទ្រពីលោក លន់ នល់ គឺជាការសាកល្បងផ្នែកនយោបាយជាមួយពួកកំលាំងរបស់លោក សីហនុ។ ឯកំលាំងកងទ័ពទាំងអស់ថិតក្នុងភាពប្រុងប្រយ័ត្នដើម្បីទំលាក់លោក សីហនុ ក្នុងករណីដែលលោក សីហនុ មកដល់ស្រុក ហើយបដិសេធមិនគាំទ្ររដ្ឋាភិបាលបច្ចុប្បន្ន រឺមួយធ្វើការគាបសង្កត់មកលើរដ្ឋាភិបាល។

ឥឡូវនេះលោក សីហនុ បានសម្រេច ថ្វីបើគាត់នៅប្រកាន់យកគំរោងផែនការរបស់គាត់ដែលត្រូវត្រឡប់មកផ្ទះវិញក៏ដោយ តែគាត់ត្រូវទៅទីក្រុងម៉ូស្គូ និងក្រុងប៉េកាំងសិន។ មុនពេលការចេញដំណើរនេះ លោក សីហនុ នៅឯប្រទេសបារាំងដូចការដែលអ្នកនៅភ្នំពេញបានគិតទុក គឺលោក សីហនុ ច្រឡោតខឹងតូងនៅក្នុងស្ថានទូតខ្មែរនាទីក្រុងប៉ារីស និងបានពោលពាក្យទ្រគោះបោះបោក ជេរដល់លោករដ្ឋមន្ត្រីរបស់គាត់ ព្រមទាំងគំរាមគំហែងជាមួយនិងការចាប់ដាក់គុត រហូតដល់ប្រហារជីវិត។

ក្រោយពេលដែលលោកស្ថានទូត បានបញ្ជូនពាក្យនេះមកដល់ភ្នំពេញ អ្នកនៅភ្នំពេញមានការភ្ញាក់ផ្អើលនិងមានសេចក្តីភ័យខ្លាចជាខ្លាំងក្នុងការិយាល័យគណរដ្ឋមន្ត្រី ហើយក៏ជាមូលហេតុជំរុញធ្វើអោយមានឆន្ទៈ



និងបំណងក្នុងការទំលាក់គាត់នេះឡើង។ ក្នុងសៀវភៅរបស់លោក Willian Shawcross នៅទំព័រ១២៧បានសរសេរ "ការច្រឡោតរបស់លោក សីហនុ នេះមិនអាចគណនាបាន(ein wuetender Sihanouk war unberechnen-bar)" ហើយសៀវភៅនេះបានសរសេរទៀត "ហេតុអ្វីបានជាលោក សីហនុ មានប្រតិកម្មយ៉ាងនេះ? ចំលើយថិតក្នុងភាពងងឹត(Warum Sihanouk so reagierte , ist unbekannt)"។

មើលទៅ វាគ្មានអ្វីគួរអោយពិបាកយល់នោះទេ។ ទីមួយ គឺជាចរិកមហិច្ឆតាធម្មជាតិរបស់គាត់។ ទីពីរ ប្រហែលជាគាត់ចងកំហឹងនឹងលោក ស៊ីសុវត្ថិ សិរិមតៈ ព្រោះគាត់បានពោល "បាតុកម្មនោះត្រូវបានរៀបចំឡើងដោយមនុស្សម្នាក់"។ ម្យ៉ាងទៀត ភាពខ្វែងគំនិតរវាងអ្នកទាំងពីរ ដូចបានលើកខាងលើហើយថា៖ លោក ស៊ីសុវត្ថិ សិរិមតៈ ធ្លាប់ជំទាស់និងនយោបាយរបស់លោក សីហនុ ដែរ។ នេះជាគំនិតគ្រួសារស្តេចខ្មែរតាំងពីក្រោយសម័យអង្គរមក គឺគំនុំគុំគួន សងសឹកគ្នា ដណ្តើមអំណាចក្នុងវង្សត្រកូលរកទីបញ្ចប់គ្មាន ដែលធ្វើអោយប្រជាពលរដ្ឋខ្មែរវេទនានិងប្រទេសខ្មែរហិនហោចរហូតដល់ថ្ងៃនេះ ក៏ដោយសារស្តេចក្លែងក្លាយនេះដែរ(ស្តេចក្លែងក្លាយ គឺស្តេចលើកបន្តុបដោយពួកបរទេស)។ សៀវភៅរបស់លោក Willian Shawcross បានសរសេរបន្តទៀត" បើសិនជាលោក សីហនុ ត្រឡប់មកភ្នំពេញអោយលឿន និងមិនច្រឡោត មកដោយស្ងៀមស្ងាត់ប្រហែលជាគាត់មានលទ្ធភាពធំក្នុងការបំបាត់ រឺយ៉ាងហោចណាស់ក៏អាចបន្ថយនូវគ្រោះថ្នាក់នេះបានខ្លះដែរ"។

ពីរ បីថ្ងៃក្រោយ លោកលន់ នល់ បានពិពណ៌នានៅចំពោះមុខអ្នកយកពត៌មានឈ្មោះ ឡុងដុងថែម(Londoner Time)ថា៖ បន្ទាប់ពីជំងឺឆ្កួត

របស់ស្តេចនៅទីក្រុងប៉ារីសមក បំណង និងចេតនារបស់យើងត្រូវបានប្រែប្រួលនិងឥឡូវនេះ សំរេចថា ជំនួសអោយការកែសំរួលរដ្ឋធម្មនុញដែលត្រូវកំណត់ព្រំដែនអំពីការអនុញ្ញាតអំណាចរបស់ស្តេចទៅជារដ្ឋប្រហារ។

ដូចបានគ្រោងនៅថ្ងៃទី១៣មិនា លោក សីហនុ បានធ្វើដំណើរទៅសហភាពសូវៀតដើម្បីទស្សនកិច្ចរយៈពេល៦ថ្ងៃ។ ប្រធានរដ្ឋរបស់សូវៀត លោក NIKOLAI PODGORNY(Der Praesident des Obersten Sowyet) ត្រូវតែមានកាតព្វកិច្ចទទួលគាត់នៅចំណតយន្តហោះ។ បន្ទាប់ពីបានទទួលភារកិច្ចជាផ្លូវការមក លោក NIKOLAI PODGORNY បាននិយាយថា "ព្រះអង្គម្ចាស់ស្ថានភាពក្នុងប្រទេសកម្ពុជាគ្រោះថ្នាក់ណាស់។ ប្រជាពលរដ្ឋរបស់លោកត្រូវការលោក។ លោកត្រូវតែត្រឡប់ទៅកម្ពុជាជាបន្ទាន់ កុំអោយពេលវេលាកន្លងផុត និងកុំទៅទស្សនកិច្ចនៅក្រុងប៉េកាំង។ យន្តហោះពិសេសមួយទុកសំរាប់លោករួចជាស្រេច លោកអាចទៅពេលណាក៏បាន លោកត្រូវតែក្លាហាន"។ ចំណែក លោក សីហនុ វិញគ្មានគិតពីការប្រែប្រួលគំរោងការរបស់គាត់ទេ។ សូវៀតមិនអាចបង្ខំភ្ញៀវកើត ដំណើរទស្សនកិច្ចត្រូវបានប្រព្រឹត្តទៅ។

នៅថ្ងៃទី១៨មិនា លោក សីហនុ បានស្តាប់ពត៌មានអំពីរដ្ឋប្រហារនេះនៅទីក្រុងម៉ូស្គូ គឺពេលដែលរដ្ឋមន្ត្រីទី១សូវៀតឈ្មោះលោក ALEXEJ KOSSYGIN (Premierminister)ជូនដំណើរមកកាន់ចំណតយន្តហោះក្រុងម៉ូស្គូ ដើម្បីធ្វើដំណើរមកកាន់ក្រុងប៉េកាំង។ គោលបំណងរបស់លោក សីហនុ ត្រូវបរាជ័យ ដោយលោកក្នុងគ្រានេះគ្មានសមត្ថភាពនឹងបង្ខំអោយមេដឹកនាំសូវៀត ជួយធ្វើការគាបសង្កត់ទៅលើរដ្ឋាភិបាលក្រុងហាណូយឡើយ ហើយលោក KOSSYGIN បានបង្ខំលោក សីហនុ នៅចំណតយន្ត



ហោះដោយគ្មានបង្ហាញពីការចង់ជួយដោះស្រាយ។

នៅក្នុងយន្តហោះឆ្ពោះមកកាន់ក្រុងប៉េកាំង លោក សីហនុ បានបដិសេធ នូវដំបូន្មានរបស់ប្រពន្ធគាត់ ម៉ូនិក ដែលចង់មករស់នៅប្រទេសបារាំងដោយស្ងៀមស្ងាត់។ ក្នុងពេលមកដល់ក្រុងប៉េកាំងភ្លាម គាត់មិនដឹងត្រូវធ្វើអ្វីទេក្នុងពេលខាងមុខ។ ប៉ុន្តែ គាត់មានទំនោរក្នុងការមកសុំការជ្រកកោននៅប្រទេសបារាំង។ ចំណែកខាងរដ្ឋាភិបាលចិនវិញមិនទាន់មានប្រតិកម្មអ្វីគួរអោយកត់សំគាល់ដែរក្នុងបញ្ហានេះ។ ពេលដែលលោក សីហនុ មកដល់ចំណតអាកាសយាន្តប៉េកាំងនាថ្ងៃទី១៩មិនា ត្រូវបានមេដឹកនាំចិន លោក ជូ អេនឡាយ ទទួលស្វាគមន៍ប្រៀបបាននឹងប្រធានរដ្ឋ (Staatoberhaupt)។ បន្ទាប់មក លោក សីហនុ បានទៅសួរស្ថានទូតបារាំងប្រចាំនៅក្រុងប៉េកាំង តើគាត់អាចត្រឡប់មកផ្ទះរបស់គាត់នៅប្រទេសបារាំងបានដែរទេ?។ លោកស្ថានទូតបារាំងបានឆ្លើយ ប្រទេសបារាំងចាត់ទុកជាមានសំណាងក្នុងការដែលអនុញ្ញាតអោយទទួលស្គាល់ការជ្រកកោននេះ។

ចំណែកនៅក្រុងភ្នំពេញវិញក្នុងពេលដំណាលគ្នានេះ បានធ្វើការបកអាក្រាតពីភាពពុករលួយរបស់គ្រួសារគាត់ និងនយោបាយរបស់គាត់ជាខ្លាំង។ កត្តានេះដែលធ្វើអោយលោក សីហនុ ប្តូរគំនិតរបស់គាត់និងទទួលយកភាពច្រឡោតដាក់ខ្លួន ព្រមទាំងបង្កើតនូវបំណងសងសឹក។ ចរិកប្រែប្រួលឥតព្រំដែនរបស់លោក សីហនុ មានគោលដៅតែម្យ៉ាងគត់គឺរក្សាអំណាចផ្ទាល់ខ្លួនប៉ុណ្ណោះ។

នៅថ្ងៃទី២១មិនា នាយករដ្ឋមន្ត្រីយួនខាងជើងឈ្មោះ ផាន់ វ៉ាន់ដុង (PHAN VAN DONG, Premierminister)បានធ្វើដំណើរជាសំងាត់មកទីក្រុងប៉េកាំង និងបន្ទាប់ពីបានពិភាក្សាជាមួយលោក ជូ អេនឡាយមក ស្រាប់តែ

លោក សីហនុ បានយល់ព្រមតាមក្នុងការបំបាត់នូវការមិនចូលចិត្តរបស់គាត់ជាមួយយួន ហើយព្រមទទួលយកការស្នាក់នៅក្នុងប្រទេសចិន និងទទួលដំណែង ជាមេដឹកនាំយ៉ាងសំខាន់នៃចលនាកុំមុយនីស្តរបស់កម្ពុជា ដែលពីមុនគាត់បានប្រឆាំងយ៉ាងល្វីងជូចត់នោះ។

តាមសៀវភៅរបស់លោក WINFRIED SCHARLAU, Vier Drachen am Mekong នៅលើទំព័រ២០៨បានសរសេរ "លោក ម៉ៅ(Mao) និងលោក ជូ(Zhou) បានបង្ខំលោក នរោត្តម សីហនុ អោយស្នាក់នៅក្រុងប៉េកាំង និងបង្ខំគាត់អោយចងសម្ព័ន្ធភាពជាមួយបដិវត្តន៍ប្រឆាំងនិងលោក លន់ នល់។ លោកទាំងពីរនេះ បាននិយាយទៅកាន់លោក សីហនុ បន្តទៀតថា៖ បើគ្មានការចូលរួមយ៉ាងសកម្មរបស់លោកទេ នោះរបបដែលបង្កើតឡើងដោយអាមេរិកនៅក្នុងប្រទេសកម្ពុជាមិនអាចទម្លាក់បានទេ"។ ការសងសឹកចំពោះអ្នកនៅភ្នំពេញ គឺជាបំណងប្រាថ្នាដ៏ខ្លាំងដែលលោក សីហនុ បត់បែនដោយគ្មានសង្ស័យ។ នៅថ្ងៃទី២៣មិនា នាពេលព្រលឹមលោក សីហនុ បានសុំអោយលោក ផាន់ វ៉ាន់ដុង មកផ្ទះរបស់គាត់ដើម្បីស្រស់ស្រូបអាហារពេលព្រឹក(petit dejeuner)។ លោក ផាន់ វ៉ាន់ដុងបានមកដល់យ៉ាងត្រឹមត្រូវនៅម៉ោង៨។ លោក សីហនុ បានពន្យល់អំពីការដែលគាត់ត្រៀមខ្លួនជាស្រេច ក្នុងការចងសម្ព័ន្ធភាពជាមួយយួន ដើម្បីប្រឆាំងនិងសហរដ្ឋអាមេរិក និងបរិវារនៅភ្នំពេញ។



# សាធារណរដ្ឋខ្មែរ

ប្រជាពលរដ្ឋខ្មែររួមជាមួយរដ្ឋាភិបាលស្រោចស្រង់ជាតិរបស់ខ្លួនបានក្រោកឡើងវិញជាធ្លុងមួយឈប់គាំទ្រលទ្ធិសីហនុនិយម និងដកសេចក្តីទុកចិត្តនៅថ្ងៃទី១៨មិនា១៩៧០។ សន្ទុះដែលបានផុសចេញឡើងនេះ គឺជាឆន្ទៈរបស់ពលរដ្ឋខ្មែរទាំងមូល។

ចាប់ពីឆ្នាំ១៩៧០មក ប្រជាពលរដ្ឋខ្មែរទាំងអស់បានរួមគ្នាយ៉ាងស្អិតរមួត និងទុកចិត្តទុកថ្លើមនឹងលោកធំ ព្រមទាំងដើរតាមក្រោយជានិច្ចដោយមានសេចក្តីសង្ឃឹមជឿជាក់ ជារបបមួយយុត្តិធម៌ និងពិតជាអាចកសាងប្រទេសជាតិឈានទៅកាន់ភាពរីកចំរើនមិនខាន។ គេម្នាក់ៗខិតខំបញ្ចេញអស់កំលាំងកាយចិត្តយ៉ាងមមាញឹក ក្នុងការបង្កបង្កើនផលដើម្បីចូលរួមការស្តារប្រទេសជាតិ។ ប៉ុន្តែ គួរអោយស្តាយជាទីបំផុត ដោយសេចក្តីសង្ឃឹមរបស់ខ្លួន ត្រូវលោកធំយើង មិនបានធ្វើអោយមានជីវិតជាអមតៈ។ បងប្អូននឹងបានជ្រាបនៅទំព័រខាងក្រោមនេះ។

ដំបូងអស់លោកគាត់ រួមគ្នាយ៉ាងជិតស្និទ្ធនិងធ្វើអ្វីៗ គឺដើម្បីផលប្រយោជន៍ជាតិពិតៗគួរជាទីសង្ឃឹមមែន។ តែចូលមកដល់ឆ្នាំ១៩៧១ យើងមើលគាត់ឈ្លោះគ្នា ប្រឆាំងគ្នាដូចមនុស្សមកពីប្រភពពីរផ្សេងគ្នា។ អស់លោកធំចែកអំណាចគ្នាដូចល្បែងលេង។ ពេលចែកមានការលើសខ្វះមិនសមនិងចិត្តមានៈ លោភលន់របស់ខ្លួន គេបកអាក្រាតគ្នា ដូចគ្មានសតិសម្បជញ្ញៈក្នុងខ្លួន។ ម្នាក់ថា ម្នាក់មិនកើត ម្នាក់ថាអញគ្រាន់បើជាង (ប៉ុណ្ណ ចន្ទម៉ុល ចរិកខ្មែរ)។ ចុះអីក៏មានគំនិតអសោចខុសពីអ្នកធំជាតិផ្សេងៗម្ល៉េះលោកធំខ្មែរ។

គេឈ្លោះគ្នាតែរឿងអំណាច មុនដំបូងគេជាមិត្តនិងគ្នា ធ្វើការជាមួយគ្នា ដល់ពេលចង់ឡើងធំរៀងខ្លួន ចូលមកក្នុងខែសីហា១៩៧២ ចាប់ផ្តើមបំបែកគ្នាជាបក្ស។ គណបក្សនីមួយៗសុទ្ធតែមានសារពត៌មានផ្សាយរៀងៗខ្លួន។ ពេលនេះ គេចាប់ផ្តើមបកអាក្រាតគ្នា។ ឯប្រជាពលរដ្ឋខ្មែរឡប់ស្មារតីមិនដឹងជាស្តាប់ខាងណាជឿខាងណា។ គ្រានេះលោកធំកាន់តែមើលមុខគ្នាលែងត្រង់ រីឯកូនចៅអាម៉ីអាថោងរបស់គណបក្សនីមួយៗកាន់ជើងចៅហ្វាយនាយ និងលើកជើងចៅហ្វាយនាយ ចំណែកចៅហ្វាយស៊ីជោថែមទៀត។ គេដើរស្រែកថ្កោលទោសទៅវិញទៅមកគ្មានត្រាប្រណី។ គេគ្មានយកគោលនយោបាយដឹកនាំប្រទេសមកពិភាក្សា ដើម្បីស្វែងរកសេចក្តីថ្លៃថ្នូរជូនជាតិមាតុភូមិឡើយ។ គេគ្មានគិត តើយើងទាំងអស់គ្នាធ្វើយ៉ាងណាទើបចំរើនរុងរឿងដល់ជាតិ?។ ចំពោះអ្នកណានៅក្រៅគណបក្សខ្លួនត្រូវចាត់ទុកអ្នកនោះជាសត្រូវរបស់ខ្លួនទាំងអស់។ នេះគឺជាគំនិតអន់ថយរបស់ខ្មែរយើង។

ដោយមូលហេតុខាងលើនេះដែលធ្វើអោយប្រជាពលរដ្ឋ វិលវល់វង្វេង លង់នៅតែលង់ គ្មានស្គាល់មាគ៌ានយោបាយស្រុកទេស។ បញ្ហាមិនចេះសាមគ្គីគ្នានេះ មានរួចមកហើយក្នុងសម័យតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំង។ ដោយខ្វះការរួបរួមគ្នានេះ ដែលមិនអាចយកជ័យជំនះលើពួកបារាំង ចុះហេតុអ្វីក៏មិនព្រមយកប្រវត្តិសាស្ត្រមកធ្វើជាមេរៀន?។ ផ្ទៃក្នុងបែកបាក់គ្នាជាហេតុធ្វើអោយរបបសង្គមទាំងមូលចុះខ្សោយ ហើយទាញប្រទេសជាតិអោយចូលក្នុងភាពអនាធិបតេយ្យ។ សណ្តាប់ធ្នាប់សង្គមធ្លាក់ក្នុងភាពចលាចល ដែលជាហេតុធ្វើអោយបរទេសមើលងាយ មើលថោកដល់ប្រទេសខ្លួន។ ពួកបរទេសនឹងងាយលូកដៃកកូរក្នុងនយោបាយ



កិច្ចការផ្ទៃក្នុងរបស់យើងទៀតផង។

សភាពការណ៍កាន់តែតានតឹងខ្លាំងឡើងៗ ពីមួយថ្ងៃទៅមួយថ្ងៃ។ ណាមួយពួកខ្មែរខាងឆ្វេង និងពួកយួនខាងជើងយៀកកុងបានធ្វើការវាយលុកយ៉ាងខ្លាំង និងដណ្តើមបានច្រើនតំបន់នៅតាមភូមិឃុំស្រុក។ ណាមួយទៀតគឺផ្ទៃក្នុងមិនសូវត្រូវចង្វាក់គ្នា ព្រោះលោកធំកំពុងដណ្តើមអំណាចគ្នា ឯពួកនាយធំៗគិតតែប្រណាំងគ្នាលួចលុយរដ្ឋ។ ម្យ៉ាងទៀត ប្រទេសនៅតំបន់នេះជាពិសេសប្រទេសកម្ពុជា គឺជាសេចក្តីប្រាថ្នារបស់សហរដ្ឋអាមេរិក។ សហរដ្ឋអាមេរិក មិនចង់អោយប្រទេសកម្ពុជាធ្លាក់ចូលក្នុងក្រញាំដៃនៃពួកកុំមុយនីស្តទេ។ ដោយហេតុនេះ នៅថ្ងៃទី៣០មេសា១៩៧០ ប្រធានាធិបតីសហរដ្ឋអាមេរិក និសុន(NIXON) បានសំរេចអោយកងទ័ពរបស់អាមេរិកនិងកងទ័ពយួនខាងត្បូង ដែលខ្មែរយើងហៅថា “ទាហានយួនធីវគី” ចូលមកលុកលុយក្នុងប្រទេសខ្មែរ ដើម្បីវាយកំទេចពួកកុំមុយនីស្ត ដោយគ្មានប្រាប់រដ្ឋាភិបាលខ្មែរជាមុន។ ការចូលមករបស់កងទ័ពយួនខាងត្បូងធីវគីនេះគឺដោយគ្មានការយល់ព្រមពីសំណាក់រដ្ឋាភិបាលខ្មែរឡើយ ព្រោះនៅថ្ងៃទី១ឧសភា លោក លន់ នល់ បានបរិហាថាះ លោកបានដឹងពីការលុកលុយរបស់កងទ័ពយួនខាងត្បូងធីវគី ហើយលោកមិនយល់ព្រមអោយពួកនេះចូលមករាតត្បាតក្នុងប្រទេសកម្ពុជាដែរ។ នេះគឺជាកំហុសមួយដ៏ធំបំផុតរបស់មេដឹកនាំអាមេរិក ដែលបានយកមេរោគមកវាយបង់លើប្រជាពលរដ្ឋខ្មែរ។ ទង្វើល្មើសនេះដែលធ្វើអោយខ្មែររងទុក្ខវេទនា និងសោកនាដកម្មមហាសែនធ្ងន់ដល់សព្វថ្ងៃ។

សូមបើកវង់ក្រចកបន្តិច ដោយចង់បញ្ជាក់អំពីជំហាររបស់សហរដ្ឋអាមេរិកតាំងពីឆ្នាំ១៩៥២មក។ សហរដ្ឋអាមេរិក មិនដែលមានការពេញចិត្ត

និងប្រទេសកម្ពុជាម្តងណាឡើយ ព្រោះតែខ្លួនចង់ទប់ស្កាត់ការរីកវាតទីនៃលទ្ធិសង្គមនិយម ហើយមកធ្វើបាបខ្មែរ។ សហរដ្ឋអាមេរិកមើលឃើញថាមានតែប្រទេសកម្ពុជាមួយទេដែលអាចធ្វើអោយខូចនយោបាយខ្លួន ព្រោះរដ្ឋាភិបាលលោក សីហនុ បានប្រកាសជាអព្យាក្រឹត។ សៀវភៅរបស់លោក William Shawcross បានសរសេរនៅលើទំព័រ៥២ "មេដឹកនាំសហរដ្ឋអាមេរិកមានការអាក់អន់ចិត្តនិងលោក នរោត្តម សីហនុ ពេលដែលលោក នរោត្តម សីហនុ ធ្វើដំណើរទស្សនកិច្ចនៅឆ្នាំ១៩៥២មកទីក្រុងវ៉ាស៊ីនតោន ដើម្បីកម្ពុជាអព្យាក្រឹត"។ ទីពីរ នៅឆ្នាំ១៩៥៤ លោក នរោត្តម សីហនុ បានសុំអោយសហរដ្ឋអាមេរិកជួយ បន្ទាប់ពីកងទ័ពយួនយៀកកុងឆ្លងកាត់តាមប្រទេសលាវ បានជ្រៀតជ្រែកចូលមកក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ១៩៥៨ កងទ័ពយួនខាងត្បូងបានចូលមកតាមព្រំប្រទល់ខ្មែរ មេដឹកនាំអាមេរិកបានប្រកាលថា អាវុធដែលសហរដ្ឋអាមេរិកបានជួយមកនោះ មិនត្រូវបានអនុញ្ញាតអោយប្រើប្រាស់ ដើម្បីប្រឆាំងនិងពួកយួនខាងត្បូងទេ(William Shawcross S. 54)។

ក្នុងរបបអំណាចអញនិយមរបស់លោក នរោត្តម សីហនុ កងទ័ពយួនខាងជើងកុំមុយនីស្ត បានមកបោះទីតាំងនៅមួយចំហៀងប្រទេសប៉ែកខាងកើត មកដល់របបសាធារណរដ្ឋរបស់លោក លន់ នល់ កងទ័ពយួនខាងត្បូងធីវគី ចូលមកនៅមួយចំហៀងប៉ែកខាងត្បូង។ សរុបមកកងទ័ពយួនចូលមកតាំងមូលដ្ឋាននៅស្ទើរពេញក្នុងប្រទេសខ្មែរ ដែលជាមូលហេតុធ្វើអោយរបបសាធារណរដ្ឋខ្មែរ មិនអាចរស់រានមានជីវិតតទៅទៀតបានឡើយ។



## ល្បិចយួនកំឡុងទសវត្សរ៍ឆ្នាំ១៩៧០ដែលយើងស្គាល់ថា យួនយៀកកុង និងយួនធីវគ

ដើម្បីលេបត្របាក់យកទឹកដីខ្មែរ ពួកមេដឹកនាំយួនអនុវត្តវិធីសាស្ត្រសម្លាប់ខ្មែរគ្រប់សម័យកាល ពេលគូភាគីខ្មែរមានជម្លោះផ្ទៃក្នុង ហើយទៅពឹងពាក់គេ(យួន)អោយជួយ។ ជាក់ស្តែងដូចក្នុងព្រឹត្តិការណ៍ឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ និយាយដោយឡែកនៅលើទឹកដីស្រុកសំរោងក្នុងខេត្តតាកែវ។

បងប្រុសម្នាក់ជាអតីតយុទ្ធជនកងរំដោះ បានរៀបរាប់រំលឹកអំពីព្រឹត្តិការណ៍ខ្លះៗដែលគាត់នៅចងចាំ ទាក់ទងនឹងនយោបាយពិសពុលរបស់មេដឹកនាំយួន មកលើខ្មែរ ដូចខាងក្រោមៈ

១- សមរភូមិប្រយុទ្ធភូមិជើងគួន ក្នុងស្រុកសំរោង ពួកទាហានធីវគី (យួនខាងត្បូង) បររថក្រោះកិនលេណដ្ឋានយុទ្ធជនកងទ័ពរំដោះនៅស្លាបទាំងសងខាង បណ្តាលឲ្យស្លាប់ជាច្រើននាក់ ឯខ្សែត្រៀមកណ្តាលដែលត្រៀមដោយពួកទាហានយួនយៀកកុង គឺគ្មានរថក្រោះទៅបៀតឡើយ។ ប៉ុន្តែពេលនោះ បែរជាមានទាហាន លន់ នល់ ថ្មើរជើងចូលទាំងងើល បានត្រូវយួនខាងជើងយៀកកុងបាញ់សន្ធប់ អោយរងការស្លាប់យ៉ាងរង្គៀល។ និយាយរួមឆាកប្រយុទ្ធបីយប់បួនថ្ងៃ ស្លាប់សុទ្ធតែខ្មែរទាំងសងខាង។

២- ភូមិណាដែលប្រជាជន ទទួលបាយទឹកឬផ្តល់ផ្ទះឲ្យកងទ័ពរំដោះដែលដឹកនាំបញ្ជាពីពួកយួនខាងជើងយៀកកុង ភូមិនោះត្រូវរងគ្រោះដោយគ្រាប់ផ្លោង និងយន្តហោះរបស់យួនខាងត្បូងធីវគីវាយប្រហារចំៗគោលដៅ បណ្តាលឲ្យរងគ្រោះទាំងជីវិតនិងផ្ទះសម្បែងជានិច្ច។ ជាក់ស្តែង ដូចជាៈ

- ភូមិព្រិចក្នុងឃុំស្លា ស្លាប់មនុស្សប្រុសស្រីជាង៣០នាក់ និងឆេះផ្ទះ

គ្មាននៅសល់ដោយការទំលាក់គ្រាប់បែក។

- ផ្ទះថ្មធំៗនៅភូមិស្លាលិចក្នុងឃុំស្លា ដែលយួនខាងជើងយៀកកុងធ្លាប់ស្នាក់នៅ ហើយបានប្រគល់អោយយុវជនកងសន្តិសុខ(ឈ្លប)ខ្មែរឈរជើងជំនួសក៏ត្រូវយន្តហោះវាយប្រហារ តែគ្មានប៉ះពាល់អាយុជីវិតមនុស្ស។

- ភូមិត្រពាំងស្តុកក្នុងឃុំរវៀង ក៏រងការទម្លាក់គ្រាប់បែកស្លាប់ប្រជាជនអស់ជាង១០នាក់ ដោយគ្រាន់តែទទួលបាយទឹកដល់កងទ័ពរំដោះ។

- វត្តភ្នំជីសូររងការបាញ់ផ្លោងពីទាហានអាធីវគី ដែលមានទីតាំងនៅស្វាយព្រៃ រួមទាំងយន្តហោះទម្លាក់គ្រាប់បែកជាច្រើនគ្រាប់បណ្តាលអោយសុគតព្រះសង្ឃពីរអង្គ និងខូចប្រាសាទយ៉ាងដំណំ។

៣- ការសម្លាប់នៅសមរភូមិក្រោយៈ មុខសញ្ញាសំខាន់របស់មេដឹកនាំយួន គឺមន្ត្រីរាជការ អ្នកចេះដឹង ឬអ្នកមានឥទ្ធិពលក្នុងមូលដ្ឋាន ដែលគេចោទថាជា គិញបង្កប់។ ជាក់ស្តែងយួនខាងជើងយៀកកុងផ្ទាល់សម្លាប់មនុស្សដែលគេចាត់តាំង អោយចូលទៅតំបន់ស្រោចស្រង់(កាន់កាប់ដោយរដ្ឋការ លន់ នល់) ដើម្បីទិញសម្ភារៈ មានថ្នាំពេទ្យជាដើមឲ្យពួកវា ដូចជាៈ

- ឈ្មោះ ជៀប អឿង និងភរិយា ឈ្មោះ ឆៃ និងភរិយា ឈ្មោះទាំងពីរគ្រួសារនេះ ស្ថិតនៅភូមិត្រពាំងស្រង់ ក្នុងឃុំស្លា និងឈ្មោះទ្រី អាន នៅភូមិក្រាំងឡុង ឃុំជើងគួន។ ប៉ុន្មានគ្រួសារខាងលើនេះសុទ្ធតែទទួលការចាត់តាំងរបស់យួនខាងជើងយៀកកុង រួចត្រូវបានសម្លាប់។

- សម្លាប់ព្រះសង្ឃ ព្រះនាម ប៊ី ស្បោង ជាចៅអធិការវត្តទួលរវៀងក្នុងឃុំស្លា និងព្រះសង្ឃ ព្រះនាម សយ វត្តអង្គលង្គុញ ក្នុងឃុំសំពោងបន្ទាប់ពីពួកគេបានអោយព្រះអង្គកសាងស្ពានបត់រការួចហើយ ដោយចោទថា ស្ទួលបង្កប់របស់សេអ៊ីអា។



- សម្លាប់ឈ្មោះ ក្រឹម វ៉ាន់ អតីតអ្នកកាសែតសម័យសង្គមរាស្ត្រនិយមក្នុងខណៈ ដែលពួកវាបានចាត់តាំងអោយធ្វើគណៈស្រុកព្រៃកប្បាសក្នុងទឹកដីរំដោះ ដោយចោទជាជនសេអ៊ីអា។

- សម្លាប់លោក ផៃ ស្រ៊ន ជាអតីតគ្រូបង្រៀនសម័យសង្គមរាស្ត្រនិយម ក្នុងខណៈដែលពួកវាចាត់តាំងជាខណៈឃុំស្លាចោទថា ជាខ្សែរយៈ ក្រឹម វ៉ាន់។

- សម្លាប់លោក សាយ ណាន ជាគណៈឃុំស្លា ដែលគណៈតំបន់៣៣បានចាត់តាំងមកពីភូមិភាគនីរតី ដោយចោទជាខ្សែរយៈ ក្រឹម វ៉ាន់។

សូមបញ្ជាក់ថាៈ ប៉ុន្មាននាក់ខាងលើនេះ គឺគ្រាន់តែបានចូលរួមហូបបាញ់ឆែវជាមួយ ក្រឹម វ៉ាន់ នាផ្ទះរបស់គាត់ក្នុងភូមិអង្គចង្អេរប៉ុណ្ណោះ។ តែមនុស្សទាំងនេះសុទ្ធតែមានប្រជាប្រិយខ្លាំងក្នុងមហាជន និងហានតវ៉ាការពារប្រជាជនគ្រប់ការរំលោភបំពាន។

- សម្លាប់ ជា សឿន ជាអនុប្រធានឃុំស្លា ជាមនុស្សមកពីបូព៌ា និងជាអាឌិតអ្នកតស៊ូទៀតផង ដោយធ្វើល្បិចអោយទាហានធីវគីចាប់អារកហើយដោតក្បាលនៅកណ្តាលផ្លូវជាតិលេខពីរត្រង់តំបន់បឹងកំប្រែម ពេលបំពេញការចាត់តាំងរបស់យួនខាងជើងយៀកកុងផ្ទាល់ទៅស៊ើបការណ៍ឆ្លងផ្លូវជូនថ្នាក់លើនៅទីនោះ។

- ក្រោយមកសម្លាប់ ស ហួន គណៈឃុំស្លា ដែលបានចាត់តាំងបន្ទាប់ពីសម្លាប់ សាយ ណាន ចោទថា ក្បត់។ ការពិត ស ហួន ជាមនុស្សដែលប្រជាជនស្រឡាញ់ពេញចិត្តគ្រប់ៗគ្នា។

- នៅឃុំសឹងនៅស្រុកសំពោងក៏មានបាញ់សម្លាប់ សាវ៉ាយ សាមឿនស្មៀនឃុំសឹង និងឈ្មោះ សែម ជាមេភូមិសឹងផងដែរ ដែលជាល្បិចរបស់

យួនខាងជើងយៀកកុង ប្រើអោយទៅស៊ើបការណ៍នៅផ្លូវជាតិលេខពីរ។ ពួកវាបាននិយាយតេអូ អោយទាហានធីវគីព័ទ្ធចាប់សម្លាប់យ៉ាងស្រួល។ ក្នុងឃុំសឹងនោះមានសម្លាប់សកម្មជនជាច្រើន ដោយចងឆ្កាងជាប់ក្បែរផ្លូវនៅទួលឆ្មា ដើម្បីបង្រ្កាបការចង់ងើបបណ្តេញយួនឆ្នាំ១៩៧៣។

សូមបញ្ជាក់ថា៖ ដល់ឆ្នាំ១៩៧៣ តំបន់រំដោះបានទូលំទូលាយលាតសន្ធឹងរហូតដល់ស្រុកភ្នំស្រួចទៅហើយ។ ទាហាន លន់ នល់ មានតែនៅលើផ្លូវជាតិលេខបី(ត្រាំខ្នារ) និងផ្លូវជាតិលេខពីរ លេខបួនប៉ុណ្ណោះ។ ពេលនោះហាក់បីដូចជាចង់ផ្ទុះអោយមានចលនាបណ្តេញយួន តាមតំបន់ខ្លះៗ។

- ឆ្នាំ១៩៧០ ឈ្មោះប៊ូ អតីតគ្រូបង្រៀននៅឃុំទ្រា ដែលយួនយៀកកុងចាត់តាំងធ្វើបញ្ជាការកងទ័ពស្រុកសំរោង ទទួលមុខសញ្ញាតាមផ្លូវជាតិលេខ២ ត្រូវយន្តហោះឧទ្ធម្ភាកចក្រទាហានធីវគី ដេញបាញ់ប្រហារជុំវិញទួលមួយស្ថិតក្នុងភូមិត្រពាំងអង្គ ឃុំកំពែងស្រុកព្រៃកប្បាស រហូតស្លាប់យ៉ាងអាណោចអធម ពេលដកថយពីស្រុកសំរោង។

- ក្រៅពីសម្លាប់នៅក្នុងមូលដ្ឋាន ក៏មានសកម្មភាពចាប់មនុស្សពីស្រុកប៉ែកខាងត្បូងដូចជា គីរីវង់ កោះអណ្តែត ភាគច្រើនជាខ្មែរកម្ពុជាក្រោមជាហូរហែរមកសម្លាប់នៅជើងភ្នំជីសូរ្យ ដោយកាប់និងកាំបិតក្រង៉ុកផ្ទាល់ដោយជនដៃដល់ម្នាក់ឈ្មោះ ស្រូយ ឡេង នៅភូមិត្រពាំងស្រង់ឃុំស្លាស្រុកសំរោង(បច្ចុប្បន្នស្លាប់)។ ប៉ុន្តែចំនួនប៉ុន្មាននាក់ យើងមិនបានដឹងប្រាកដទេ ដឹងគ្រាន់ថាមួយលើកៗ មិនតិចជាង១០នាក់ឡើយ។ ដោយឡែកឈ្លើយសឹក(ទាហាន) ត្រូវគេយកទៅវះយកប្រមាត់ក៏មានដែរ។

ទន្ទឹមនិងកលល្បិចសម្លាប់ខ្មែរខាងលើនេះ ទាហានយួនធីវគីបានប្រព្រឹត្តនូវអំពើព្រៃផ្សៃ យង់ឃ្នង ដូចបងប្អូនជនរួមឈាមបានដឹងដែរ។ នៅ



ពេលដែលពួកយួនខាងត្បូងធីវគី ចូលមកដល់ក្នុងទឹកដីខ្មែរភ្លាម ពួកវាធ្វើដូចជាជួយឈឺឆ្អាល ខឹងនិងពួកកុំមុយនីស្តយួនខាងជើងយៀកកុង និងធ្វើជាជួយខាងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរណាស់។ តែបើយើងសង្កេតអោយជ្រៅទៅ គឺទង្វើរបស់ទាហានធីវគីនេះ បង្កប់គ្រប់កលល្បិចពិសពុលយ៉ាងសាហាវក្រៃលែង។ ក្នុងពេលមួយនោះ(ប្រហែលក្នុងអំឡុងឆ្នាំ១៩៧១-៧២) គ្មានឃើញមានទាហានខ្មែរកុំមុយនីស្ត រឺយួនខាងជើងយៀកកុងណាម្នាក់សោះក្នុងភូមិ។ តែក្រោយពីលឺសន្ធឹករថក្រោះពួកយួនធីវគីមក ស្រាប់តែឃើញមានយួនខាងជើងយៀកកុងកុំមុយនីស្តម្នាក់-ពីរ មិនដឹងជាមកពីណាលួចរត់ចូលមកក្នុងភូមិ រួចពួកវាធ្វើជាបាញ់រប៉េះរប៉ោះពីរបីគ្រាប់ ហើយរត់គេចបាត់ចេញពីភូមិ។ មួយរយៈពេលដ៏ខ្លីក្រោយមក ស្រាប់តែពួកកងរថក្រោះទាហានធីវគីមកដល់ជ្រោង មានតាំងពីកាំភ្លើងតូចធំបាញ់ចូលសំរុកផង កាំភ្លើងធំបាញ់ផ្លោងដាក់ផង ធ្វើអោយខ្ទេចភូមិ ផ្ទះសំបែក ស្លាប់ទាំងប្រជាពលរដ្ឋខ្មែរ។ ភូមិខ្មែរក្លាយជាភូមិផេះផ្សង និងគ្មានស្លាប់ពួកអាយួនខាងជើងយៀកកុងកុំមុយនីស្តណាម្នាក់ឡើយ។ ក្រោយពីទទួលជ័យជំនះទាហានធីវគីធ្វើជាជ្រុះគ្រាប់រាយប៉ាយនៅទីនោះ រួចធ្វើដំណើរចេញទៅបាត់ដោយរំភើយ។ ឯពួកយួនខាងជើងយៀកកុងកុំមុយនីស្តដែលគេចខ្លួនពួនសម្ងំនៅក្បែរៗនោះ ក៏ចូលមកប្រមែរប្រមូលយកគ្រាប់រំសេវនោះអស់។ ក្រោយពីបានប្រមូលរួច ពួកយួនខាងជើងយៀកកុង ធ្វើដូចជាមានការឈឺចាប់ជំនួសប្រជាកសិករខ្មែរណាស់។ ពួកវាតែងដើរសួរសុខទុក្ខនិងនិយាយសន្យានឹងជួយការពារលោកអំ លោកពូ អ្នកមីង។

ក្រៅពីសំលាប់ប្រជាពលរដ្ឋខ្មែរ និងកំទេចភូមិខ្មែរដោយគ្រឿងអាវុធទាហានធីវគី បានបើករថក្រោះកិនកំទេចស្រូវសន្ទូងនារដូវស្រូវបែកគុម្ព

និងដើរប្លន់យកទ្រព្យ ធ្វើបាបទាំងចាស់ទាំងក្មេងទៀតផង។ ហេតុនេះនៅតាមភូមិឃុំនីមួយៗ ពេលលឺសូរសន្ធឹករថក្រោះមកពីចំងាយ ពួកប្រុសៗតែងរត់គេចលាក់ខ្លួនតាមព្រៃតាមបឹង ព្រោះពួកវាបានបើករថក្រោះសំដៅមករកតែភូមិអ្នកស្រុក។ ចំពោះអ្នកដែលរត់គេចមិនទាន់ ហើយត្រូវទាហានធីវគី ចាប់បានតែងចោទថា ត្រូវដៃជើងជាមួយពួកយួនយៀកកុងកុំមុយនីស្ត រួចយកទៅធ្វើបាបវាយដំនឹងស្នូកកាំភ្លើង សួរចំឡើយ ចងដៃទាំងពីរមកក្រោយបណ្តើរយកទៅបាត់ ជួនកាលបាញ់ចោលនៅមុខផ្ទះក៏មានទោះជាអ្នកនោះគ្មានទោសកំហុសអ្វីក៏ដោយ។ ពួកវាតែងយកកាំភ្លើងភ្ជុងសំឡុតចំពោះនារីភេទ សួររកប្តី រឺកូនប្រុសទៅណា។ ក្រៅពីនេះទៀត វាសំឡុតសួររករបស់ទ្រព្យនៅឯណា ត្រូវប្រាប់ពួកវា និងត្រូវយកមកអោយពួកវា ដូចជា មាស ប្រាក់ ពេជ្រ ព្រមទាំងរបស់ប្រើប្រាស់ល្អៗនិងមានតំលៃ។ ពួកវាប្លន់យកតែវត្ថុណាស្រាលៗដែលពួកវាអាចយកទៅបាន ឯវត្ថុធ្ងន់ៗដែលពុំអាចយកទៅបាន រឺយកទៅមិនកើត ដូចជា ស្រូវ អង្ករ ត្រូវពួកវាបើករថក្រោះកិនកំទេចចោល និងដុតហុយពេញភូមិ។ ពេលហូបបាយក្នុងវិធីបុណ្យសង្ឃទាននៅផ្ទះរបស់ខ្ញុំ ស្រាប់តែខ្វះចាន ខ្វះស្លាបព្រា គ្រានោះឪពុកខ្ញុំក៏លាន់មាត់ថា៖ ទាហានធីវគីបានទយគូថរថក្រោះរបស់វាចូលមកចំពីក្រោយផ្ទះ និងបានជញ្ជូនចាន ស្លាបព្រា ឆ្នាំង ទៅដាក់រថក្រោះពេញរួចចេញទៅបាត់ កុំអីមិនខ្វះទេ។ មិនតែប៉ុណ្ណោះពួកវាដើរដេញចាប់មាន់ ទា ជ្រូក គោ ក្របី យកទៅតាមអំពើចិត្ត។

កាលណាអ្នកណាម្នាក់មិនព្រមយកមកអោយពួកវា រឺឆ្លើយថាអត់មាន ទោះការដែលឆ្លើយនោះពិត ក៏ពួកវាមិនស្តាប់ វាវាយសំពងនឹងស្នូកកាំភ្លើង ធាក់សន្លប់បាត់មាត់ រួចពួកវាដើររើកកាយពេញផ្ទះ។ ឯនារីក្មេងៗ



ធំជំទង់ៗ ពួកវាចាប់រំលោភធ្វើបាបរហូតដល់ស្លាប់ក៏មាន។ ក្រោយពីធ្វើបាបនិងប្លន់យកទ្រព្យសម្បត្តិក្នុងភូមិមួយហើយ ទាហានធីវគីទៅរកភូមិមួយទៀតជាបន្ទាប់។ក្នុងពេលដែលទាហានយួនធីវគីកំពុងធ្វើបាបខ្មែរ គ្មានឃើញពួកអាយួនយៀកកុងកុំមុយនីស្តណាមកជួយខ្មែរឡើយ។ ពេលពួកទាហានយួនធីវគីចេញទៅបាត់ ទើបពួកអាយួនយៀកកុងកុំមុយនីស្តមកធ្វើជាឈឺចាប់ និងចងកំហឹងនឹងទាហានធីវគីចំពោះមុខប្រជាពលរដ្ឋខ្មែរ។

ទាហានយួនធីវគីចូលដល់ភូមិណា ភូមិនោះត្រូវខ្ទេច។ ដោយអំពើព្រៃផ្សៃឃោរឃៅរបស់ពួកទាហានយួនធីវគីនេះ ធ្វើអោយប្រជាពលរដ្ឋនៅតាមស្រែចំការ មានកំហឹងឈឺចាប់និងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរកាន់តែខ្លាំង ដោយពួកនេះបានប្រកាសខ្លួនថា៖ ពួកគេចូលមកជួយច្បាំងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ ប្រជាពលរដ្ឋលែងមានជំនឿទុកចិត្តលើរដ្ឋាភិបាល រួចបានរត់ចូលព្រៃ និងរួមជាមួយពួកអាយួនយៀកកុងកុំមុយនីស្តប្រឆាំងនឹងរដ្ឋាភិបាលវិញ ព្រោះពួកនេះមិនធ្វើបាបខ្លួននិងធ្វើជាជួយទៀតផង។

## ផ្នត់គំនិតរបស់មេដឹកនាំចិន ចំពោះខ្មែរ

មេដឹកនាំចិន បានប៉ុនប៉ងយកប្រទេសខ្មែរធ្វើជារណបតាំងពីរាប់សតវត្សមកហើយ និងតាមព្យាបាទខ្មែរ មិនឈប់មិនឈរ រហូតដល់ដូនតាយើងចងក្រងជារឿងព្រេងឡើង ដែលគាត់ចង់បញ្ជាក់ពីកលល្បិចដ៏ពិសពុលរបស់មេដឹកនាំចិននេះ។ បើសិនជាយើងអនុញ្ញាតអោយយករឿងខាងក្រោមនេះជារឿងពិត ដែលអាចអោយយើងលើកយកមកបញ្ជាក់បាន ដូចជា រឿងធនជ័យ (សូមអានរឿង ធនជ័យ) និងជាពិសេសមានភស្តុតាងស្រាប់គឺភ្នំអដ្ឋរឹស។ តាមអបិយជំនឿរបស់ហោរាសាស្ត្រចិន គឺភ្នំនេះនឹងនាំមកនូវភាពរុងរឿងរីកចំរើន ដែលអាចអោយប្រទេសខ្មែរក្លាយជាមហាអំណាចនៅអាស៊ី(តាមលោកគ្រូម្នាក់និយាយប្រាប់)។ ដើម្បីសំរេចគំនិតនេះ មេដឹកនាំចិនបានខិតខំបន្តការព្យាបាទ ធ្វើសកម្មភាពវិទ្ធង្សនា ញុះញង់ខ្មែរអោយឈ្លោះគ្នា បង្កសង្គ្រាមគ្រប់បែបយ៉ាងក្នុងប្រទេសខ្មែរ។ មេដឹកនាំក្រុងប៉េកាំង បានខំបំបែកបំបាក់ខ្មែរ គួរមុខខ្មែរ រួចដាក់អោយខាំគ្នាដូចមានសេចក្ដីដកស្រង់ខាងក្រោមនេះ៖

១- ក្នុងសៀវភៅរបស់លោកWinfried Scharlau បានសរសេរនៅលើទំព័រ២១២ថា៖ ពេលកន្លងមកសាធារណរដ្ឋប្រជាមានិតចិនមិនត្រឹមតែរក្សាទំនាក់ទំនងដ៏ល្អជាមួយលោក សីហនុ ទេ ជាពិសេសគឺជាមួយប្រធានប៉ូលីស(Polizeichef) និងរដ្ឋមន្ត្រីក្រសួងការពារជាតិលោក លន់ នល់។ នៅឆ្នាំ១៩៦៥ លោក លន់ នល់ ក្នុងនាមជារដ្ឋមន្ត្រីក្រសួងការពារជាតិ បានធ្វើដំណើរទស្សនកិច្ចផ្លូវការនៅប្រទេសចិន និងត្រូវបានទទួលការកោតសរសើរពីលោកម៉ៅ(Mao)។ នៅឆ្នាំ១៩៦៩ លោកលន់ នល់ ជានាយករដ្ឋមន្ត្រី



(Premierminister)ត្រូវបានការអញ្ជើញទៅក្រុងប៉េកាំងជាលើកទី២។ នៅពេលនោះ គេបានប្រគល់លទ្ធភាពអោយលោក លន់ នល់ ទៅមើលផ្នូរខ្មោចតារបស់គាត់នៅខេត្ត Fujan។

២- សៀវភៅដដែលនោះនៅលើទំព័រ២៤៣បានសរសេរថា៖ លោកនរោត្តម សីហនុ បានចងភ្ជាប់មិត្តភាពយ៉ាងស្និទ្ធជាមួយប្រទេសចិន។ ជារៀងរាល់ឆ្នាំ គឺស្របទៅតាមការសុំរបស់លោក ជូ អេនឡាយ ក្នុងការរៀបចំដឹកនាំសព្វាវុធឆ្លងកាត់កំពង់ផែកំពង់សោមទៅអោយយួនខាងជើងយៀកកុង។ ក្នុងពេលជាមួយគ្នានេះ អ្នកមានតួនាទីខ្ពស់ៗនៃបក្សរបស់ចិន បានធ្វើការជំនុំជាមួយមេដឹកនាំខ្មែរក្រហមដែលបានសំរេចថា៖ ត្រូវតែចាប់ផ្ដើមបំពាក់អាវុធតស៊ូប្រឆាំងនឹងរបបលោក សីហនុ។ នៅលើទំព័រ២៩២នៃសៀវភៅនេះបានសរសេរថា៖ លោក ប៉ុល ពត បានធ្វើដំណើរនៅខែធ្លាក់ទឹកកកឆ្នាំ១៩៦៥-៦៦ទៅក្រុងហាណូយ រួចចេញពីក្រុងហាណូយទៅប៉េកាំងដើម្បីបង្ហាញខ្លួនក្នុងនាមជាលេខាបក្ស(Generalsekreter) របស់បក្សកុំមុយនីស្តកម្ពុជា។ ក្នុងការធ្វើដំណើរនោះ មានលោក អៀង សារី និងប្រពន្ធរបស់គាត់ ខៀវ ធារិទ្ធ(Khieu Thirit)។ លោក ប៉ុល ពត និងអ្នកជូនដំណើរនោះ បានស្នាក់នៅទីនោះជាច្រើនខែ ដើម្បីពិភាក្សាជាមួយសមមិត្តមេដឹកនាំនៃប្រទេសចិន។ ក្នុងពេលនោះដែរ អ្នកដែលមានឋានៈធំៗនៃបក្សដឹកនាំរបស់ចិន បានបើកការជំនុំជាមួយពួកដឹកនាំខ្មែរក្រហម ហើយបានសំរេចថា ត្រូវចាប់ផ្ដើមបំពាក់អាវុធតស៊ូប្រឆាំងនឹងរបបស្ដេច។ ក្រុមមេដឹកនាំចិនបាននិយាយថា បដិវត្តន៍គឺត្រឹមត្រូវជានិច្ច(Die Revolution hat immer recht)។ ដោយសារទស្សនកិច្ចនៅក្រុងប៉េកាំងដែលធ្វើអោយលោក ប៉ុល ពត ក្លាយជាជនប្រកាន់យកគំនិតជ្រុលនិយម"Radikal"ដែលមិនអាចទប់ស្កាត់បាន។

៣- ចំណែកនៅក្នុងសៀវភៅរបស់លោក បិន យៀនិន បានសរសេរនៅលើទំព័រ២៣៩ថា៖ សូម្បីតែលោក សីហនុ ក៏ដូចនេះដែរ គឺគ្មានអ្នកណាមួយបានដឹងពីវត្តមានរបស់លោក ប៉ុល ពត នៅទីក្រុងប៉េកាំងក្នុងកំឡុងពេល ទៅទស្សនកិច្ចនោះទេ។ ចំពោះមេដឹកនាំចិន និងលោក ប៉ុល ពត គឺសំខាន់ណាស់ក្នុងការមិនអោយលោក សីហនុ រឺអ្នកណាដែលមានសមានចិត្តខ្លាំងជាមួយលោក សីហនុ បានដឹងពីទំនាក់ទំនងរវាងមេដឹកនាំចិន និងលោក ប៉ុល ពត។

៤- ក្នុងសៀវភៅរបស់លោក Winfried Scharlau បានសរសេរនៅទំព័រ២១៥ "លោក ជូ អេនឡាយ(ZHOUENLAI) បានជំរុញលោក សីហនុ ជារៀងរាល់ពេល ដើម្បីអោយចងសម្ព័ន្ធភាពជាមួយក្រុមលោក ប៉ុល ពត"។ មេដឹកនាំក្រុងប៉េកាំងបានសិក្សាដឹងថា៖ ដើម្បីផ្តួលរំលំរបបលោក លន់ នល់ បានគឺមានតែការជួយនិងការចូលរួមរបស់លោក សីហនុ ប៉ុណ្ណោះ។

៥- សៀវភៅរបស់លោក ហ៊ិន ស៊ីថាន បានសរសេរនៅលើទំព័រ១២៤-១២៥ ដែលមានសេចក្តីដូចតទៅ៖ នៅថ្ងៃទី១៣មិនា១៩៧០ លោក សីហនុ សំរេចចិត្តយាងចេញពីក្រុងប៉ារីសទៅក្រុងម៉ូស្គូដើម្បីសុំជំនួយគាំទ្រ។ ពួកមេដឹកនាំសូវៀត បានឃាត់លោក សីហនុ អោយនៅក្រុងម៉ូស្គូ កុំយាងទៅក្រុងប៉េកាំង តែលោក សីហនុ មិនព្រម ព្រោះមេដឹកនាំសូវៀតគ្មានបានសន្យានឹងយកអំណាចមកអោយគាត់វិញសោះ។ លោក សីហនុ ក៏សំរេចចិត្តបន្តដំណើរឆ្ពោះទៅក្រុងប៉េកាំងតែម្តង។ កាលនោះមេដឹកនាំចិននៅទ្រឹងដែរដោយទុកអោយពួកទូតចិននៅភ្នំពេញ ធ្វើការតថ្លៃគ្នាជាមួយលោក លន់ នល់ បន្តិចទៀតសិន ក្រែងបានផល។ ក្រោយថ្ងៃទី១៨មិនា១៩៧០ មេដឹកនាំចិននៅមិនទាន់ផ្តាច់ចំណងទូតជាមួយប្រទេសខ្មែរនៅឡើយទេ។



អ្នកដំណាងការទូតចិន បានធ្វើការទាក់ទងជួបតថ្លៃជាមួយលោក លន់ នល់ ជាច្រើនដង ស្នើសុំអោយរដ្ឋាភិបាលខ្មែរនៅបន្តជួយកងទ័ពយួនខាងជើងយៀកកុងតទៅទៀត ដូចដែលរដ្ឋាភិបាលខ្មែរសម័យលោក សីហនុ បានធ្លាប់ធ្វើកាលពីមុនមកនោះ។ តំណាងទូតចិនបាននិយាយថា៖ ការទំលាក់លោក សីហនុ ជារឿងផ្ទៃក្នុងរបស់ខ្មែរ ក្រុងប៉េកាំងនឹងមិនរវីរវល់ជាមួយលោក សីហនុ ទេ ហើយចិននឹងនៅតែបន្តការគោរពរដ្ឋអំណាចខ្មែរតទៅទៀត បើ៖

ក- ខ្មែរព្រមអនុញ្ញាតបន្តផ្តល់សំភារៈសឹក សាស្ត្រាវុធ ថ្នាំពេទ្យពីប្រទេសចិន ទៅអោយកងទ័ពយួនខាងជើងយៀកកុង ដូចដែលប្រទេសខ្មែរបានធ្លាប់ធ្វើពីមុនមកដើម្បីអោយយួនអាចបន្តធ្វើសង្គ្រាមប្រឆាំងអាមេរិកាំងវាយយកយួនខាងត្បូងអោយបាន។

ខ- ខ្មែរនៅតែអនុញ្ញាតអោយកងទ័ពយួនខាងជើងយៀកកុងតាំងនៅលើដែនដីខ្មែរតទៅទៀត។

គ- ខ្មែរនៅតែបន្តឃោសនាគាំទ្រមិត្តយួនយៀកកុងដូចមុនទៀត

ក្រោយពីជួបចរចារជាមួយលោក លន់ នល់ ជាច្រើនដង រហូតមកដល់ថ្ងៃទី៥ឧសភា១៩៧០ គឺមួយខែម្ភៃថ្ងៃក្រោយទំលាក់លោក សីហនុ រួចតំណាងទូតចិនយល់ឃើញថា គ្មានការរីកចំរើនគួរជាទីពេញចិត្តសោះនោះ តំណាងទូតចិន អោយដំណឹងទៅមេដឹកនាំក្រុងប៉េកាំងៗ ក៏សំរេចប្រកាសផ្តាច់ចំណងទូតជាមួយប្រទេសខ្មែរ រួចហើយមេដឹកនាំចិនងាកមកគាំទ្រទទួលស្គាល់ និងសន្យាថា នឹងយកអំណាចមកជូនលោក សីហនុវិញ។ តែលោក សីហនុ ត្រូវគោរពលក្ខ័ណ្ឌមួយ គឺត្រូវចូលរួមដៃគ្នាជាមួយពួកយួនខាងជើងយៀកកុង និងជាមួយបនខ្មែរក្រហម។

ប៉ុន្មានចំណុចខាងលើនេះ អាចសរបញ្ជាក់អំពីផ្នត់គំនិតដ៏កខ្វក់របស់មេដឹកនាំចិនចំពោះជីវិតខ្មែរដែលយើងមិនបានគិតដល់។ មេដឹកនាំចិនបានប្រើវិធីបញ្ចុះបញ្ចូល លួងលោម បញ្ឆោរ បង្ខំ ហើយគាំទ្រទាំងនយោបាយឧបត្ថម្ភសម្ភារៈ និងថវិកាដោយមិនស្តាយស្រណោះដល់ជនខ្មែរណាមួយដើម្បីអោយបំផ្លាញជាតិខ្មែរ។ ពិសេសមេដឹកនាំចិនតែងស្វាបស្វង់រកជនខ្មែរណា ដែលមានគំនិតបំផ្លាញជាតិខ្មែរខ្លួនឯង ដើម្បីយកទៅប្រើ មិនថាអ្នកប្រកាន់ឆ្វេង ប្រជាធិបតេយ្យ រាជានិយម រឺពួកអំណាចអញនិយមឡើយ។ មេដឹកនាំចិនទាក់ទាញមនុស្សខ្មែរមួយមិនបាន បែរទៅរកមនុស្សខ្មែរផ្សេងទៀត។ ចុះមនុស្សខ្មែរ(លោក សីហនុ) អីក៏អំណាចតណ្ហាក្រាសម្ល៉េះ គេគ្រាន់តែសន្យាលើកបន្តុបអោយកាន់អំណាចសោះ ទៅជាលក់ខ្លួនអោយគេ ដោយមិនគិតពីផលវិបាកនៃប្រទេសជាតិខ្លួន។ គឺមេដឹកនាំក្រុងប៉េកាំងនេះហើយដែលលេងល្បែងមុខពីរ "រដ្ឋនិងបក្ស" ជានិច្ច ដើម្បីបំបែកបំបាក់ខ្មែរ បំផ្លាញខ្មែរ។



## សាធារណរដ្ឋខ្មែរត្រូវរលំ

ការមួមៅក្តៅក្រហាយ ដោយសារការបាត់បង់អំណាចរបស់លោកនរោត្តម សីហនុ បានក្លាយទៅជាការពន្យុះអោយខ្មែរសំលាប់ខ្មែរ អោយយួនសំលាប់ខ្មែរយ៉ាងគគ្រឹកគគ្រេង។ ចាប់ពីចុងខែមិនា១៩៧០មក លោកនរោត្តម សីហនុ បានយកការសងសឹកមកធ្វើជារឿងតស៊ូរំដោះជាតិ។

នាថ្ងៃទី១៨មិនា១៩៧០ ប្រជាពលរដ្ឋខ្មែរបានរួមមតិគ្នាទំលាក់លោកនរោត្តម សីហនុ ចេញពីប្រធានរដ្ឋ។ ថ្ងៃទី២៣មិនា គាត់សំរេចចិត្តនឹងស្នាក់នៅក្រុងប៉េកាំង ដោយមិនបានគ្រោងទុកជាមុន គឺតាមការបញ្ឆោរ និងបង្ខំរបស់មេដឹកនាំចិន។ សួរថា៖ ហេតុអ្វីបានជាមេដឹកនាំចិនលួងលោមបញ្ឆោរបង្ខំលោក សីហនុ អោយព្រមស្នាក់នៅក្នុងប្រទេសរបស់ខ្លួន? បើតាមនយោបាយរបស់លោក សីហនុ គឺចិនមិនអាចទទួលចិញ្ចឹមគាត់ឡើយ ព្រោះចាប់ពីឆ្នាំ១៩៦៦-៦៧មក លោក សីហនុ បានចោទប្រកាន់របបគ្រប់គ្រងក្រុងប៉េកាំងយ៉ាងខ្លាំងអំពីអំពើវិច្ឆេទកម្មទាំងឡាយ ក្នុងប្រទេសកម្ពុជារហូតរំលាយសមាគមមិត្តភាពខ្មែរ-ចិន។ លោក សីហនុ បានបរិហារ "រដ្ឋអធិបតេយ្យនៃសាធារណរដ្ឋប្រជាមានិតចិន ជំទាស់មិនអោយរដ្ឋអធិបតេយ្យខ្មែរមានសិទ្ធជាម្ចាស់នៃខ្លួនឯង" និងមានសុន្ទរកថាជាច្រើនទៀតដែលលោកបានប្រកាសឡើង អំពីអំពើជ្រៀតជ្រែករបស់ក្រុមមេដឹកនាំក្រុងប៉េកាំងចំពោះប្រទេសខ្មែរ ដូចបានលើកនៅត្រង់ "លទ្ធិសីហនុនិយម និងសង្គ្រាមសំលាប់ខ្មែរ"។ តើមេដឹកនាំក្រុងប៉េកាំងភ្លេចរឺ? ដោយក្រុងប៉េកាំងមានមហិច្ឆតាវាតទីយកតំបន់នេះមកដាក់ក្រោមចំណុះខ្លួន ហើយវត្តមានរបស់អាមេរិកនៅទីនេះ មិនបានធ្វើអោយមេដឹកនាំក្រុងប៉េកាំងដេកលក់

ស្រួលទេ។ ក្រុងប៉េកាំងតែងរុករកគ្រប់វិធី ដូចជា មេដឹកនាំក្រុងប៉េកាំងជួយឧបត្ថម្ភដល់ពួកយួនខាងជើងយៀកកុងកុំមុយនីស្ត ក្នុងការប្រឆាំងនឹងសហរដ្ឋអាមេរិកជាដើម ហើយពេលនេះ មេដឹកនាំចិនចង់បានលោក សីហនុ ដើម្បីចំហៀវគាត់ជាផលប្រយោជន៍ខ្លួនតែប៉ុណ្ណោះ។ មេដឹកនាំចិនបានប្រមើលឃើញអំពីគុណប្រយោជន៍របស់លោក សីហនុ។ បើគ្មានការចូលរួមយ៉ាងសកម្មរបស់លោកសីហនុទេគឺរបបរបស់លោក លន់ នល់ មិនអាចផ្តួលរំលំបានឡើយ។ មេដឹកនាំចិនដឹងទៀតថា៖ លោក សីហនុ ឆ្លាតវៀងវៃខាងសំលាប់ខ្មែរគ្នាឯងដើម្បីដណ្តើម និងរក្សាអំណាច ហើយពេលនេះគាត់ទ័លច្រក នឹងពិតជាអាចប្រើបាន។ កត្តាមួយទៀត ដែលមេដឹកនាំចិនត្រូវតែលួងលោម បញ្ជោរ និងត្រូវតែអោបលោក សីហនុ គឺដើម្បីធ្វើអោយប្រជាពលរដ្ឋខ្មែរទទួលរងទុក្ខវេទនា និងដើម្បីបំផ្លាញប្រទេសខ្មែរអោយដល់រឹសគល់។ ឯលោក សីហនុ ខ្លួនឯង ក៏ត្រូវតែអោបបាតជើងចិនដើម្បីអោយចិនជួយដណ្តើមរបបអំណាចអញនិយមអោយខ្លួនវិញ។

ពេលដែលលោក សីហនុ ទៅដល់ក្រុងប៉េកាំង មេដឹកនាំចិនទទួលដៃពីរ និងបានប្រគល់ផ្ទះមួយអោយនៅ។ មកដល់មិនទាន់បាត់ពុលផ្សែងយន្តហោះផង នាថ្ងៃទី២៣មិនា១៩៧០ គឺក្រោយពេលដែលនាយករដ្ឋមន្ត្រីយួនផាន់ វ៉ាន់ដុង មកទីក្រុងប៉េកាំងជាសំងាត់ និងបានពិភាក្សាជាមួយមេដឹកនាំចិនលោក ជូ អេនឡាយ មក លោក សីហនុ បានប្រកាសនៅក្រុងប៉េកាំងថា៖ គាត់បានសហការជាមួយពួកដែលគាត់ហៅថា "ខ្មែរក្រហម" បង្កើតជារណសិរ្សរួបរួមជាតិកម្ពុជាដើម្បីប្រឆាំងនិងរដ្ឋាភិបាល លន់ នល់ និងមានសារសំខាន់ក្នុងការរំដោះប្រទេសជាតិ។ ក្រោយពីការប្រកាសរបស់លោក សីហនុ នេះភ្លាម មេដឹកនាំយួនបានធានានូវការជួយឧបត្ថម្ភដល់រណសិរ្ស



នេះ និងបានប្រកាសជួយផ្គត់ផ្គង់សព្វគ្រប់បែបយ៉ាងដល់ខ្មែរក្រហម។

នៅថ្ងៃទី៥ឧសភា លោក សីហនុ បានប្រកាសនៅទីក្រុងប៉េកាំងពីការបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិខ្មែរក្រៅប្រទេស។ គ្រាន់តែប្រកាសភ្លាម មេដឹកនាំយួន និងមេដឹកនាំចិនប្រកាសទទួលស្គាល់ភ្លាមដែរ។ ក្រោយពេលប្រកាសទទួលស្គាល់ រាជរដ្ឋាភិបាលក្រៅប្រទេសរបស់លោកសីហនុស្អែកឡើង គឺថ្ងៃទី៦ឧសភា១៩៧០ មេដឹកនាំនៃប្រទេសទាំងពីរបានកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយកម្ពុជា។ លោក សីហនុ ដែលក្លាយជាជនភៀសខ្លួនស្នាក់នៅទីក្រុងប៉េកាំង ដេកមិនសុខ នឹកខឹងក្តៅក្រហានិងប្រជាពលរដ្ឋខ្មែរដែលបានទំលាក់ខ្លួន ម្យ៉ាងទៀតដោយខ្លួនមានទំលាប់ឆេវឆាវស៊ីជោរស្រាប់ផង ក៏តាំងឆ្លេឆ្លាស្រែកហៅកំលាំងបរទេស អោយមកសំលាប់ខ្មែរគ្នាឯងជាបងប្អូនរួមជាតិ។ កំលាំងបរទេស គឺយួននេះឯងដែលអង្គុយសំកុកបើកភ្នែករង់ចាំតែឱកាសដើម្បីច្របាច់កខ្មែរស្រាប់។

នាថ្ងៃទី២៧តុលា១៩៧១ កងទ័ពយួនយៀកកុងបានធ្វើការវាយលុកមកលើកងកំលាំងរបស់លោក លន់ នល់។ រហូតដល់ឆ្នាំ១៩៧៣ ពួកដែលលោក នរោត្តម សីហនុ ហៅថា ខ្មែរក្រហម និងពួកយួនយៀកកុង ក្រោមការជួយរបស់ក្រុងហាណូយ បានវាយយកតំបន់មួយចំនួនធំ។ នេះហើយដែលមេដឹកនាំចិន និងយួន ឆ្លៀតប្រើការសងសឹករបស់លោក សីហនុ ចំពោះប្រជាពលរដ្ឋខ្មែរ អោយបំរើមហិច្ឆតារបស់គេ។ នេះជាលើកទីពីរ ដែលលោក សីហនុ បានហៅយួនអោយមកសំលាប់ខ្មែរ។ លោកសីហនុ ក៏ដូចជាស្តេចមុនៗដែរ ដែលកាលណាចង់បានអំណាចដើម្បីជិះជាន់សង្កត់កខ្មែរ តែងទៅហៅយួនអោយមកសំលាប់ខ្មែរ។ ទន្ទឹមនឹងនេះ លោក នរោត្តម សីហនុនៅក្រុងប៉េកាំងដដែលបានអំពាវនាវអោយកូនចៅ(កូនចៅ

គឺជាពាក្យរបស់លោកសីហនុសំរាប់ហៅប្រជាពលរដ្ឋខ្មែរ) រត់ចូលព្រៃតស៊ូប្រឆាំងនឹងរបប លន់ នល់ ដែលជាបរិវាចក្រព័ត្តិអាមេរិក។ ប្រជាពលរដ្ឋខ្មែរដែលមិនបានវិភាគវែងឆ្ងាយអំពីនយោបាយស្រុកទេស ដែលជាមូលហេតុមិនបានមើលឃើញនូវការលោភលន់របស់លោក សីហនុ ក៏ជឿតាមការអំពាវនាវនេះ។ម្យ៉ាងទៀតនៅកំឡុងឆ្នាំហុកសិបប្លាយ គាត់ដើរធ្វើប្រជាភិថុត គឺយកក្រណាត់ ខោអាវ បោះចែកពីលើឧទ្ធម្ភាគច័ក្រដល់កូនចៅ។ រីឯកូនចៅរត់ទៅដណ្តើមគ្នា ជាន់គ្នាបាក់ដៃបាក់ជើងស្ទើររស់ទំរាំរើសបានក្រណាត់មួយអាវ អ្នកខ្លះរត់ទៅដណ្តើមជិតស្លាប់នឹងគេដែរ តែរើសមិនបានក៏មាន។ ប្រជាកសិករនឹកស្មានថាលោក នរោត្តម សីហនុ មានសប្បុរសធម៌ចំពោះខ្លួន។ ដូចនេះ ឪនិយាយយ៉ាងណា គឺត្រឹមត្រូវទាំងអស់។ គាត់មិនបានចោទសួរ តើលោក សីហនុ បានលុយ បានក្រណាត់នេះមកពីណា?។ ហេតុនេះគ្រាន់តែលឺការអំពាវនាវភ្លាម ប្រជាកសិករខ្លះរត់ចូលព្រៃសុខចិត្តស៊ីអត់ស៊ីឃ្លាន ខ្វះមុខ ខ្វះក្រោយយ៉ាងអនោចអធម្ម។

បន្ទាប់ពីលោក នរោត្តម សីហនុ ចេញសារអំពាវនាវអោយយុវជនរត់ចូលព្រៃមគ្គីដើម្បីធ្វើការតស៊ូវាយចក្រព័ត្តអាមេរិក មានយុវជនជាសិស្សនិសិ្សត គ្រូបង្រៀន បានចូលរួមចលនាតស៊ូនៅតាមជនបទយ៉ាងភ្លូកទឹកភ្លូកដី។ ប៉ុន្តែអ្វីដែលគួរអោយសោកស្តាយនោះគឺ វាសនាអ្នកតស៊ូទាំងអស់ត្រូវស្លាប់ក្នុងសមរភូមិផង និងទទួលការចំរាញ់ប្រវត្តិរូប ហើយចោទប្រកាន់ពីបក្សកុំមុយនីស្តយកទៅសម្លាប់ស្ទើរគ្មានសល់ ក្រោមផ្លាកបោកប្រាសថា "អង្គការហៅទៅរៀនសូត្រ"។

ការទំលាក់គ្រាប់បែករបស់អាមេរិក បានផ្តល់ភាពមហន្តរាយយ៉ាងខ្លាំងចំពោះប្រជាពលរដ្ឋខ្មែរ។ ក្នុងសៀវភៅរបស់លោក បិន យៀនិន "តើ



ប៉ុល ពត ចូលកាន់អំណាចបែបណា?" នៅលើទំព័រ៣៧០បានសរសេរថា៖ នៅខែមករានិងខែកុម្ភៈឆ្នាំ១៩៧៣ មានការទំលាក់គ្រាប់បែកយ៉ាងខ្លាំងពីយន្តហោះបេ-៥២ ទៅលើតំបន់នោះ(តំបន់២១)។ នៅក្នុងខែមិនា ការទំលាក់គ្រាប់បែកនោះបានចាប់ផ្តើមរាលដាលពេញទាំងផ្ទៃប្រទេស ប៉ុន្តែភូមិភាគបូព៌ានៅតែធ្ងន់ធ្ងរជាងគេ។ ពីខែមេសាដល់ខែមិថុនា ការទំលាក់គ្រាប់បែកនេះប្រមូលផ្តុំខ្លាំងបំផុតនៅភូមិភាគនិរតី និងភូមិភាគឧត្តរ។ ខែមេសាឃើញមានការទំលាក់គ្រាប់បែកធ្ងន់ជាងគេនៅភូមិភាគឦសាន។ នៅជុំវិញក្រុងភ្នំពេញក្នុងខែមិនា ពលរដ្ឋស៊ីវិលចំនួន៣ពាន់នាក់ស្លាប់ក្នុងរយៈពេល៣អាទិត្យ។ របាយការណ៍របស់ទីភ្នាក់ងារសារពត៌មាន UPI នៅពេលនោះថា៖ អ្នកភៀសខ្លួន បាននាំគ្នារត់ចូលរដ្ឋធានីពីតំបន់ទំលាក់គ្រាប់បែកដោយនិយាយថា៖ ភូមិជាច្រើនបានត្រូវបំផ្លាញ និងប្រជាពលរដ្ឋចំនួនពាក់កណ្តាលត្រូវស្លាប់ រឺកំបុតដៃជើងនៅក្នុងការទំលាក់គ្រាប់បែកថ្មីៗនេះ។ ប៉ុន្មានថ្ងៃក្រោយមក ការទំលាក់គ្រាប់បែករបស់អាមេរិក កាន់តែថែមខ្លាំងឡើងរហូតដល់ទៅកំរិត៣៦០០តោនក្នុងមួយថ្ងៃ។ នៅភូមិចំការអង្គ ឃុំកូសស្រុកត្រាំកក់ក្នុងខេត្តតាកែវ(តំបន់១៣) ប្រជាជនជាង៨០នាក់បានស្លាប់នៅពេលដែលយន្តហោះបេ-៥២ បានទំលាក់ត្រូវភូមិនោះនិងត្រូវវត្ត។

យើងក្រលេកមើលព្រឹត្តិការណ៍នៅទីក្រុងម្តង។ ភាពពុករលួយបានផ្ទុះឡើងដល់កំពូល ពួកមេៗទាហានខំបូមប្រណាំងគ្នា ប្រជែងគ្នាទិញឡានហ៊ឺហា។ គេលែងគិតពីការការពារដែលធ្វើអោយប្រទេសជាតិកាន់តែធ្លាក់ចុះដុនដាបនិងធ្វើអោយប្រជាពលរដ្ឋឆ្អែតចិត្ត។ ហេតុការណ៍នៅក្នុងទីក្រុងភ្នំពេញលេចឡើងជាបន្តបន្ទាប់ដែលជាទំរង់ច្របូកច្របល់។ ឆ្នាំ១៩១៧ជាលើកដំបូងបង្អស់ ប្រទេសរុស្សីចាប់ផ្តើមកសាងជាប្រទេសសង្គមនិយម។

បន្ទាប់មកទ្រឹស្តីនេះ មានការរីកចំរើនដុះដាលនៅប្រទេសអ៊ឺរ៉ុប អាស៊ី និងអាហ្វ្រិក។ ឥទ្ធិពលនៃលទ្ធិសង្គមនិយមនេះ បានជ្រាបចូលមកក្នុងប្រទេសកម្ពុជាយើងបន្តិចម្តងៗ ចាប់តាំងពីឆ្នាំ១៩៣០តាមរយៈបក្សកុំមុយនីស្តឥណ្ឌូចិនដែលបង្កើតឡើងដោយលោក ហូ ជីមិញ ជនជាតិយួន។ បក្សកុំមុយនីស្តនេះមានយួនជាមេក្លោង ហើយកម្ពុជានិងលាវជាបរិវា។ រហូតដល់ឆ្នាំ១៩៦០ មាននិស្សិតខ្មែរមកសិក្សានៅប្រទេសអ៊ឺរ៉ុប និងក្រោយពីបញ្ចប់ការសិក្សាបានវិលត្រឡប់មកកាន់មាតុភូមិវិញ ព្រមទាំងបានពាំនាំនូវមនោគមន៍នេះមកជាមួយផង រួចបានផ្សព្វផ្សាយដល់អ្នកនៅក្នុងស្រុក។

មកដល់ឆ្នាំ១៩៧០ ទ្រឹស្តីនេះបានរីកសុះសាយខ្លាំងលើពិភពលោក និងមានប្រទេសមួយចំនួនត្រូវបានរំដោះចូលក្នុងលទ្ធិនេះទៀតផង។ យ៉ាងណាមិញនៅក្នុងប្រទេសខ្មែរក៏យ៉ាងដូចនេះដែរ ទាំងគ្រូ ទាំងសិស្ស ហើយនិងសាស្ត្រាចារ្យ និងនិស្សិត បានយល់ជ្រាបនូវលទ្ធិនេះមុនគេ រួចបានចាប់ផ្តើមធ្វើសកម្មភាពពាសពេញទីក្រុង។ អ្នកខ្លះទៀតមិនបានដឹង មិនបានយល់ធ្វើដើម្បីអ្វីផង គ្រាន់តែលឺគេនិយាយព្រៀងៗ ស្រាប់តែរួមប្រលូកនិងគេដែរ គឺធ្វើដោយងងឹតគ្មានទិសដៅ និងថែមទាំងទៅកំទេចទ្រព្យសម្បត្តិសាធារណៈទៀតផង។ នៅថ្ងៃទី២៦មេសា ក្រុមបាតុកររាប់ពាន់នាក់បានថិតនៅមុខមហាវិទ្យាល័យច្បាប់ មានមីក្រូស្រែកដៀមដាមអោយរដ្ឋាភិបាល។ នៅវេលាម៉ោង១៧ ពួកគេបាននាំគ្នាចោលដុំថ្មមកលើកងអាវុធហត្ថ។ ខាងរដ្ឋាភិបាលក៏ចោលគ្រាប់បែកផ្សែងព្រមទាំងស្ទូរកាំភ្លើងអស់៥នាទីបណ្តាលអោយពួកបាតុកររត់ខ្ចាត់ខ្ចាយ។ ស្អែកឡើងមានការបាញ់គ្នានៅទីនោះទៀត។ ពេលនោះប្រហែលជាមានជនជាតិយួនចូលបន្លំក្នុងក្រុមបាតុករនិងបានបាញ់ខ្មែរដើម្បីបង្កើតចលាចលអោយកាន់តែរីករវខ្លាំង។ ឯខ្មែរមិនបាន



ដឹង មិនបានចាប់អារម្មណ៍និងបញ្ហានេះរឹតតែចងកំហឹងចំពោះខ្មែរគ្នាឯងខ្លាំងឡើង។ នាថ្ងៃទី២៨ខែមេសា បាតុកម្មយ៉ាងធំនៅវិមានឯករាជ្យ ដើម្បីចូលរួមមរណៈទុក្ខចំពោះជនរងគ្រោះ ដែលពួកគេបានចោទប្រកាន់ទៅលើកងអាវុធហត្ថ ព្រមទាំងបានថ្កោលទោសដល់រដ្ឋាភិបាល។

នេះគឺជាកំហុសរបស់ខ្មែរ ក្នុងការត្រិះរិះមិនបានល្អិតល្អន់ដើម្បីរកឲ្យឃើញការពិត និងហេតុផលច្បាស់លាស់មុននឹងធ្វើអ្វីមួយ ហើយបើយើងធ្វើបាតុកម្ម ចុះចាំបាច់ទៅចោលដុំថ្ម ដំបង រឺចាំបាច់ទៅបំផ្លាញសម្បត្តិសាធារណៈ អោយជ្រុលហួសហេតុពេកយ៉ាងនេះ។ យើងទាំងអស់គ្នាជាខ្មែរ។ ខ្មែរនិយាយខ្មែរ ប្រាកដជាស្តាប់គ្នាបាននិងយល់គ្នា។ ខ្មែរមានបញ្ហាអី ត្រូវពិភាក្សាគ្នា កុំចាំតែចាប់កំហុសគ្នាទៅមក និងមិនត្រូវធ្វើសកម្មភាពណាដែលបណ្តាលអោយជនជាតិដទៃ អាចឆ្លៀតឱកាសជ្រៀតជ្រែកចូលក្នុងរឿងនោះឡើយ និងមិនត្រូវបំផ្លាញសម្បត្តិខ្មែរទេ បើអ្នកជាខ្មែរដែរនោះ។ បន្ទាប់មក មានកូដកម្មរបស់បុគ្គលិកសិក្សាទាមទារតំឡើងប្រាក់ខែ ធ្វើឲ្យរដ្ឋាភិបាលល្វឹងមុខរាល់ថ្ងៃ។ ភាពច្របូកច្របល់នេះ គឺបណ្តាលមកពីការរីកដុះដាលនៃទ្រឹស្តីសង្គមនិយមទាំងក្រៅក៏ដូចក្នុងប្រទេស។

សរុបមក គឺសកម្មភាពរបស់លោក សីហានុផង ភាពរីកសុះសាយនៃលទ្ធិសង្គមនិយម ព្រមទាំងការទំលាក់គ្រាប់បែកបេ-៥២របស់អាមេរិក និងអំពើព្រៃផ្សៃធ្វើទុកបុកម្នេញ មកលើប្រជាពលរដ្ឋខ្មែររបស់ពួកទាហានយួនធីវគី ដែលធ្វើអោយប្រជាពលរដ្ឋខ្មែរ មានការឈឺចាប់និងមន្ត្រីរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ រួចរត់ចេញទៅតស៊ូរួមជាមួយពួកយួនយៀកកុង-ខ្មែរក្រហម ដូចបានរៀបរាប់មកខាងលើទាំងអស់នេះ ដែលជាមូលហេតុធ្វើអោយកំលាំងរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ចុះខ្សោយបន្តិចម្តងៗរហូតទទួល

បរាជ័យនៅថ្ងៃទី១៧មេសា១៩៧៥។ តែទោះជាយ៉ាងណា របបសាធារណរដ្ឋខ្មែរនេះ បានដោះស្រាយបញ្ហាជនជាតិយួនអស់ពីទឹកដីខ្មែរ និងបានបង្ហាញនូវពន្លឺរបបប្រជាធិបតេយ្យខ្លះៗ សំរាប់ជាបទពិសោធន៍ចំពោះយើងដែរ។ គុណសម្បត្តិដ៏ធំធេងមួយទៀតគឺសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិជាពិសេស សេរីភាពរបស់អ្នកនិពន្ធ។ មានស្នាដៃជាច្រើនរបស់អ្នកនិពន្ធខ្មែរយើង ដែលត្រូវបានអនុញ្ញាតអោយនិយាយការពិត ដែលក្នុងរបបមុនបានចាត់ទុកពួកអ្នកចេះដឹងទាំងនេះជាសត្រូវរបស់ខ្លួន។



# កម្ពុជាប្រជាធិបតេយ្យ

របបសាធារណរដ្ឋខ្មែរ ត្រូវបានផ្តួលរលំនៅថ្ងៃទី១៧មេសា១៩៧៥ របបថ្មីមួយបានចូលមក និងត្រូវប្រកាសជាកម្ពុជាប្រជាធិបតេយ្យ។ មុននឹងនិយាយអំពីរបបនេះ យើងក្រឡេកមើលព្រឹត្តិការណ៍ដែលជាប់ទាក់ទងទៅនិងលោក នរោត្តម សីហនុ ក្រោយថ្ងៃ១៧មេសា១៩៧៥បន្តិច។

ក្រោយពីត្រូវបានប្រជាពលរដ្ឋ ដកហូតសេចក្តីទុកចិត្ត លោក សីហនុ ចេញតស៊ូ និងរួបរួមជាមួយខ្មែរដែលគាត់ធ្លាប់បានចោទ ជាមេខ្មែរក្រហម ដូចជា លោក ហ៊ូ នឹម លោក ហ៊ូ យន់និងលោក ខៀវ សំផន ជាដើម។ អស់លោកទាំងនេះ បានចេញតស៊ូតាំងពីឆ្នាំ១៩៦៧ប្រឆាំងនឹងរបបអំណាចអញនិយមរបស់លោក សីហនុ ដែលពួកគេមើលឃើញ ជារបបហុតឈាមគាបសង្កត់ គ្មានផ្តល់សេរីភាពអោយប្រជាពលរដ្ឋ ហើយមូលហេតុដែលបណ្តាលអោយពួកទាំងនេះរត់ចូលព្រៃ មកពីលោក សីហនុ តាមប្រម៉ាញ់រកចាប់ដែរ។

ជ័យជំនះថ្ងៃទី១៧មេសា១៩៧៥ គឺជាជ័យជំនះរបស់លោក នរោត្តម សីហនុ និងលោក ហ៊ូ នឹម លោក ហ៊ូ យន់ និងលោក ខៀវ សំផន ពីព្រោះៈ

១- លោក ហ៊ូ នឹម លោក ហ៊ូ យន់ និងលោក ខៀវ សំផន មានប្រជាប្រិយភាពខ្លាំងក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ដោយសារពួកគាត់មានឧត្តមគតិជាតិ សមត្ថភាពខ្ពស់ និងមនសិការជាតិ។

២- លោក នរោត្តម សីហនុៈ

- មានទុនប្រជាប្រិយភាព (គាត់បានធ្វើប្រជាភិថុតក្នុងទសវត្ស៦០)
- យកក្រុងប៉េកាំងជាបង្គោលបង្អែក និងជួយសំភារៈសឹក

- ហៅកងទ័ពយួនអោយមកជួយច្បាំង

បើលោក សីហនុ គ្មានមូលដ្ឋានទាំង៣នេះ និងមិនបានចូលរួមក្នុងចលនានោះទេ ក្រុមលោក ប៉ុល ពត មិនអាចយកជ័យជំនះលើរបបសាធារណរដ្ឋខ្មែរបានទេ ព្រោះអីប្រជាពលរដ្ឋខ្មែរភាគច្រើននៅតាមស្រុកភូមិ ពុំបានមើលឃើញភាពមិនគប្បីរបស់លោក សីហនុ។ គាត់ធ្លាប់តែបានរត់ដណ្តើមក្រណាត់របស់លោក សីហនុ។ គាត់ពុំបានយល់ច្បាស់ពីនយោបាយប្រទេសជាតិ ក៏ជឿតាមសំលេងអំពាវនាវតាមវិទ្យុរបស់លោក សីហនុ នាំគ្នាចេញតស៊ូប្រឆាំង និងធ្វើវិទ្ធង្សនាគ្រប់បែបយ៉ាងជំទាស់នឹងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ មូលហេតុដែលប្រជាពលរដ្ឋទូទៅមិនបានដឹង មិនបានមើលឃើញពីបញ្ហានយោបាយស្រុកទេស ពីធាតុពិតនៃសមត្ថភាពក្នុងការដឹកនាំរបស់លោក សីហនុ ដោយសារតែការបំបិទសិទ្ធអ្នកនិពន្ធ បញ្ញវន្តដែលយល់ដឹងពីបញ្ហានេះ មិនអោយនិយាយ មិនអោយសរសេរ មិនអោយបញ្ចេញយោបល់។

បន្ទាប់ពីជ័យជំនះនៅថ្ងៃទី១៧មេសា១៩៧៥ លោក ប៉ុល ពត និងក្រុមរបស់ខ្លួន បានប្លន់យកអំណាចផ្តាច់មុខពីអ្នកនោះ។ ចំណែកឯលោកនរោត្តម សីហនុ ក៏អ្នកកាន់អំណាចថ្មីនេះ គ្មានកន្លែងសំរាប់គាត់ដែរ ក្រោយពីទទួលបានជ័យជំនះភ្លាម។ លោក សីហនុ ងរតើង រួចធ្វើដំណើរដោយសោះកក្រោះទៅសុំការជ្រកកោននៅប្រទេសកូរ៉េខាងជើង ព្រោះមេដឹកនាំប្រទេសនោះត្រូវជាមិត្តសំឡាញ់របស់លោក និងឈប់ត្រឡប់មកប្រទេសកម្ពុជាវិញ ដោយពេលនោះ លោក សីហនុ បានតែងចំរៀងមួយក្រោមចំណងជើង ADE KAMBODSCHA មានន័យថា "លាហើយកម្ពុជា"។ ឯក្រុមមេដឹកនាំខ្មែរក្រហម ក៏គ្មានបំណងរង់ចាំការវិលត្រឡប់មកវិញរបស់



លោក សីហនុ ដែរ។ ប៉ុន្តែក្រោយមកដោយសារការគាបសង្កត់ពីមេដឹកនាំចិន(លោក ជូ អេនឡាយ) ទើបលោក ខៀវ សំផន ធ្វើដំណើរទៅព្យុងយ៉ាង (PyongYang) ដើម្បីជួបលោក សីហនុ និងបានសន្យាអោយលោក សីហនុ ធ្វើជាប្រធានរដ្ឋរហូតអស់មួយជីវិត។ ដោយមានការភ័យខ្លាចចំពោះលោក ជូ អេនឡាយ នោះលោក សីហនុ បានយល់ព្រមតាមការសន្យានេះ។ លោក ជូ អេនឡាយ បានស្វាគមន៍លោក សីហនុ ទៅលើការក្លាហាននិងសេចក្តីស្នេហាជាតិរបស់លោក សីហនុ។ នៅថ្ងៃទី៩កញ្ញា១៩៧៥ លោក សីហនុនិងប្រពន្ធម៉ូនិកបានធ្វើដំណើរត្រឡប់មកប្រទេសកម្ពុជា ហើយបាននិយាយទៅកាន់មិត្តភ័ក្រគាត់ថា៖ ការត្រឡប់មកកម្ពុជារបស់ខ្ញុំនេះ មិនមែនបានសេចក្តីថា ខ្ញុំចូលរួបរួមនឹងនយោបាយដ៏ព្រៃផ្សៃរបស់ពួកខ្មែរក្រហមទេ ប៉ុន្តែខ្ញុំត្រូវតែធ្វើពលីកម្មខ្លួនខ្ញុំ ដើម្បីគំនិតរបស់ខ្ញុំ និងការគោរពរបស់ខ្ញុំចំពោះប្រទេសចិន និងជាពិសេសចំពោះលោក ជូ អេនឡាយ ដែលជាមនុស្សដ៏ឆ្នើមរបស់ខ្ញុំ ដែលបានជ្រោមជ្រែងជាច្រើនមកលើប្រទេសកម្ពុជា និងរូបខ្ញុំផ្ទាល់។

នៅខែកុម្ភៈ១៩៧៦ លោក ជូ អេនឡាយ ដែលជាមិត្តដ៏មហិមារបស់លោក សីហនុ និងជាបង្អែកលោកផ្ទាល់ ត្រូវទទួលមរណៈភាព។ ឥឡូវនេះលោក សីហនុ អស់មានអ្នកការពារ ហើយក្រោយមកនៅទីក្រុងប៉េកាំង គេបានបើកសន្និសីទមួយ ដកហូតដំណែងប្រធានរដ្ឋពីគាត់ និងប្រគល់ដំណែងនេះទៅអោយលោក ខៀវ សំផន វិញ។ បានសេចក្តីថា៖ ការសន្យារបស់លោក ខៀវ សំផន ជាមួយលោក នរោត្តម សីហនុ នៅឯទីក្រុងព្យុងយ៉ាង ត្រូវបំភ្លេចចោល។

យើងបែរមករករបបខ្ញុំចិននិយមរបស់លោក ប៉ុល ពត។ យើងត្រូវ

ដឹងថា ក្រុមលោក ប៉ុល ពត បានធ្វើដំនើរទៅទីក្រុងប៉េកាំងឆ្នាំ១៩៦៥-៦៦ និងបានស្នាក់នៅទីនោះជាច្រើនខែ ដើម្បីធ្វើការពិភាក្សាជាមួយក្រុមមេដឹកនាំចិន និងនៅដើមឆ្នាំ១៩៧០លោក ប៉ុល ពត បានធ្វើដំណើរជាសំងាត់ម្តងទៀតទៅក្រុងប៉េកាំង។ នេះសរបញ្ជាក់ថា ក្រុមលោក ប៉ុល ពត តែងទៅយកដំបូន្មានជានិច្ចពីក្រុមមេដឹកនាំក្រុងប៉េកាំង។

មេដឹកនាំចិនបានដឹងថា ខ្មែរមានអរិយធមិខ្ពស់តាំងពីរាប់សតវត្សមករហូតធ្វើអោយចិនភ័យ ខ្លាចខ្មែរក្លាយជាមហាអំណាចនៅអាស៊ីទៀតផង ហើយអរិយធម៌ដ៏ខ្ពង់ខ្ពស់នេះ មានមូលដ្ឋានធំបំផុតនៅតាមវត្តអារាម និងព្រះសង្ឃ ព្រោះមេដឹកនាំចិនបានបទពិសោធន៍ពីជំនាន់អាណានិគមបារាំងមកធ្វើជាមេរៀន។ ដូចបាននិយាយរួចមកហើយក្នុងទំព័រមុនថា បារាំងបានដាក់អាណានិគមមកលើកម្ពុជា។ ក្នុងពេលនោះ មេដឹកនាំបារាំងមានផែនការបំបាត់ជីវិតនៃត្រី:នេះដែរ ដូចជា នៅតាមសាលារៀន បារាំងអោយបង្រៀនតែភាសាបារាំង មិនអនុញ្ញាតអោយកូនខ្មែរនិយាយភាសាខ្មែរក្នុងសាលាជាដើម។ ចុះហេតុអ្វីបានជាភាសាខ្មែរ មិនបាត់សាបសូន្យ? ដោយសារព្រះសង្ឃនៅតាមវត្តអារាមនេះឯងដែលបានលួចលាក់ និងរក្សាទុកព្រមទាំងបានក្រោកប្រឆាំងយ៉ាងស្វិតស្វាញ ទល់និងការរំលោភគំរាមកំហែងរបស់បារាំង។ ខាងក្រោមនេះ គឺជាស្នាដៃរបស់ក្រុមលោក ប៉ុល ពត ក្នុងរយៈពេលនៃការដឹកនាំប្រទេស។

របបថ្មីនេះមកដល់ភ្លាម ស្រាប់តែព្រឹត្តិការណ៍កើតឡើងយ៉ាងចំឡែកដែលប្រវត្តិសាស្ត្រមនុស្សលោកមិនដែលមាន។ ពួកគេចាប់ផ្តើមដេញប្រជាពលរដ្ឋទាំងអស់ចេញពីទីក្រុងភ្នំពេញ និងក្រុងផ្សេងទៀត អោយដើរគ្មានគោលដៅទៅនៅតាមជនបទ ក្នុងគោលបំនងបំបែកកំលាំងប្រមូលផ្តុំ ព្រោះ



បើទុកប្រជាពលរដ្ឋអោយនៅផ្តុំគ្នា ដូចជាទីក្រុងភ្នំពេញនេះ ពិតជាមិនស្របតាមនយោបាយរបស់ក្រុមខ្លួននិងអាចរួមគ្នាងើបប្រឆាំង។ ក្នុងការដេញប្រជាពលរដ្ឋទាំងអស់ចេញពីទីក្រុងនេះ ពួកគេបានប្រើនយោបាយថា៖ អង្គការត្រូវការធ្វើការបោសសំអាតទីក្រុង និងរៀបចំឡើងវិញក្នុងរយៈពេលមួយអាទិត្យ រួចអនុញ្ញាតអោយបងប្អូនត្រឡប់មកវិញ។ ដោយលឺយ៉ាងនេះ គ្រួសារខ្លះគ្មានបានយកទ្រព្យសម្បត្តិ រឺរបស់របរមកជាមួយទេ រឺក៏យកមកជាមួយតែបន្តិចបន្តួចសំរាប់តែរយៈពេល៧ថ្ងៃប៉ុណ្ណោះ។ គ្រួសារខ្លះទៀតបានដឹងពីឧបាយកលនេះ បានយករទេះ រ៉ឺម៉ក ស៊ីក្លូ ដាក់របស់របរទាំងនេះរុញច្រានតំរង់មករកបងប្អូន គ្រួសារញាតិមិត្តដែលនៅតាមស្រុកភូមិ។

រយៈពេលប៉ុន្មានខែមកទៀត ក្រោយពីប្រជាពលរដ្ឋបានធ្វើដំណើរមកដល់កន្លែងដែលខ្លួនត្រូវសំរាកហើយ អង្គការមានផែនការចំរាញ់យកអ្នកដែលធ្លាប់ធ្វើការចាស់ៗពីជំនាន់មុន អ្នកដែលរៀនចេះដឹងទៅសំលាប់។ អង្គការបានប្រើនយោបាយបោកប្រាស់ថា៖ បងប្អូន មីង ពូណាដែលធ្លាប់ធ្វើការចាស់ ត្រូវអង្គការយើងទទួលយកអោយធ្វើការតាមកន្លែងដើមវិញ ដូចជា គ្រូបង្រៀន គ្រូពេទ្យ និងអ្នករដ្ឋការផ្សេងៗជាដើម។ ពេលនោះកងទ័ពឈ្លបដែលមានអាយុក្រោម២០ឆ្នាំ នៅតាមភូមិដើរសួរនិងកត់ត្រាយកឈ្មោះ។ ចំពោះអ្នកខ្លះដែលមិនបានយល់ពីកលល្បិចនេះ បានឆ្លើយប្រាប់តាមការពិត អ្នកខ្លះបានដឹងមុនក៏នៅស្ងៀម។ ក្រោយពីបានប្រមូលរួច ពេលល្ងាចឡើងមានឡាន មកដឹកយកទៅបាត់។

ក្នុងឆ្នាំដំបូង អង្គការបានធ្វើការបោសសំអាតតែទៅលើប្រជាពលរដ្ឋដែលធ្លាប់រស់នៅក្នុងទីក្រុង ដែលអង្គការហៅថា "ពួក១៧មេសា"។ ពួក១៧មេសា គឺជាប្រជាពលរដ្ឋដែលរស់នៅទីក្រុងរហូតដល់ថ្ងៃអង្គការទទួលជ័យ

ជំនះ។ អង្គការចាត់ទុកពួកទាំងនេះសុទ្ធតែពួកជិះជាន់ហុតឈាមសង្គម។ បន្ទាប់មក បានបញ្ជូនពួកនេះទៅនៅតាមតំបន់ដែលមានជំងឺគ្រុនចាញ់ប៉ែកខាងជើងនៃប្រទេស។ មួយឆ្នាំក្រោយមកទៀតប្រហែលជា១៩៧៧ អង្គការចាប់ផ្តើមធ្វើការបោសសំអាត ចំពោះប្រជាពលរដ្ឋដែលមានភាសាអង្គការហៅថា "ពួកអ្នកមូលដ្ឋាន"។ ពួកអ្នកមូលដ្ឋានគឺជាប្រជាពលរដ្ឋដែលរស់នៅតាមភូមិ ស្រុករហូតដល់ថ្ងៃ១៧មេសា១៩៧៥។ អង្គការបានបែងចែកអ្នកមូលដ្ឋានជាបីស្រទាប់ទៀត គឺពួកពេញសិទ្ធ ពួកត្រៀម និងពួកបញ្ញើ។ ពួកពេញសិទ្ធ គឺប្រជាពលរដ្ឋដែលមានកូន រឺបងប្អូនជាអ្នកតស៊ូ រឺបំរើក្នុងកងទ័ព អ្នកដែលជាកសិករសុទ្ធ។ ក្រុមនេះដែលអង្គការបានសន្មត់ "ក្រុមដែលត្រូវគេជិះជាន់" ហើយក្រុមនេះជាភ្នែកជាច្រមុះរបស់អង្គការ។ ប្រភេទនេះ អង្គការប្រមូលអោយទៅនៅភូមិមួយដោយឡែក និងអង្គការជួយឧបត្ថម្ភខ្លះៗ ដូចជា សំលៀកបំពាក់ ជាដើម។ ក្រុមត្រៀម និងក្រុមបញ្ញើ គឺប្រជាពលរដ្ឋដែលធ្លាប់រៀនចេះដឹង ដែលជាកសិករផង និងក្រៅពីរដូវធ្វើស្រែចំការ ឆ្លៀតឱកាសរកស៊ីលក់ដូរផង។ ក្រុមនេះត្រូវអង្គការសន្មត់ "អ្នកមាននាយទុនជិះជាន់គេ"។ ក្រុមត្រៀម គឺគ្រាន់បើជាងក្រុមបញ្ញើបន្តិច។ ក្រុមទាំងពីរនេះត្រូវអង្គការប្រមូលអោយទៅនៅភូមិមួយដោយឡែក។ ឯក្រុមបញ្ញើក្អែក គឺគ្មានតម្លៃចំពោះអង្គការទេ។ ក្រុមនេះ អង្គការចង់យកទៅសំលាប់ម៉ោងណាក៏បាន។ ក្រោយពីសំលាប់ក្រុមបញ្ញើស្ទើរអស់ អង្គការធ្វើការចំរាញ់យកក្រុមត្រៀមមកដាក់ភូមិបញ្ញើ រួចចំរាញ់ពីភូមិពេញសិទ្ធមកដាក់ក្នុងភូមិត្រៀម។ អង្គការធ្វើរបៀបនេះរហូតស្ទើរអស់ប្រជាពលរដ្ឋទូទាំងប្រទេស។ ក្នុងភូមិត្រៀម និងភូមិបញ្ញើ អង្គការសំលាប់ដោយបង្អត់អាហារផង និងសំលាប់ដោយយកទៅវាយនិងដំបងផង។ ឯភូមិពេញសិទ្ធ



មិនសូវសំលាប់ដោយការបង្អត់អាហារទេ ច្រើនតែយកទៅសំពងផ្ទាល់កាលណាអង្គការមានការសង្ស័យ។ ប្រភេទនីមួយៗ មិនអនុញ្ញាតអោយដើរទាក់ទងគ្នា រឺសួរសុខទុក្ខគ្នាឡើយ ទោះត្រូវជាបងប្អូនសាច់ញាតិមានធុរៈ។ អង្គការបង្កើតជាក្រុមជាកងដែលមានឈ្មោះ "កងយុវជន កងយុវនារី កងបុរស កងម៉ែៗ និងកងកុមារ"។ កងនីមួយៗមានកន្លែងស្នាក់នៅ និងត្រូវបំពេញភារៈកិច្ចរៀងៗខ្លួនដែលអង្គការបានកំណត់។ ក្រុមគ្រួសារ ឪពុកម្តាយ កូនត្រូវរស់នៅបែកគ្នា និងអនុញ្ញាតអោយជួបគ្នាតិចដងណាស់ក្នុងមួយឆ្នាំ ទោះបីជាប្តីប្រពន្ធ រឺកូនត្រូវឈឺក៏ដោយ មិនអនុញ្ញាតអោយមកមើល រឺថែទាំដែរ។

នៅរដូវប្រាំង កងនីមួយៗមានភារកិច្ចជីកព្រែ ជីកប្រឡាយ លើកទំនប់ លើកភ្លឺស្រែ ដោយប្រើកំលាំងមនុស្សសុទ្ធសាធ និងគ្មានតាមលក្ខណៈវិទ្យាសាស្ត្រ។ ពេលរដូវភ្លៀងធ្លាក់ កងនីមួយៗត្រូវត្រឡប់មកធ្វើស្រែចំការវិញ។ ការងារចាប់ផ្តើមពីព្រលឹមស្រាងៗ ប្រហែលម៉ោង៤រឺ៥ រហូតដល់ពេលល្ងាចយប់មើលមុខគ្នាលែងស្គាល់។ ក្នុងចន្លោះពេលធ្វើការ អង្គការអនុញ្ញាតអោយសំរាកប្រហែលមួយម៉ោង ក្រោយពេលបរិភោគរួច។ ពេលខែភ្លឺ ក្រុមទាំងអស់ត្រូវទៅធ្វើការទាំងយប់ទៀត។ ការងារទាំងអស់ ដូចជាជីកព្រែក លើកទំនប់ ត្រូវបានអង្គការវាស់ចែកទៅតាមក្រុមតូចៗទៀតដើម្បីធ្វើការប្រឡងប្រណាំងគ្នា (ប្រឡងប្រណាំងជាពាក្យរបស់អង្គការប្រើដើម្បីបង្ខំប្រជាពលរដ្ឋអោយធ្វើការ និងដើម្បីយកធ្វើជាលេសងាយស្រួលនឹងចោទប្រកាន់យកទៅសំលាប់)។ បើក្រុមណាមួយធ្វើហើយមុន ត្រូវបានការសរសើរពីមាត់អង្គការ។ ឯក្រុមណាមិនបានសំរេចតាមផែនការរបស់អង្គការ ត្រូវបានគំរៀមកំហែងយកទៅសំលាប់។

ចាប់ពីដើមឆ្នាំ១៩៧៧មក អ្វីៗទាំងអស់ត្រូវបានប្រមូលដាក់រួម តាំងពីចាន ឆ្នាំង ស្លាបព្រា។ល។ មិនអនុញ្ញាតអោយដាំស្លនៅតាមផ្ទះឡើយ ដែលអង្គការអោយពាក្យ "ត្រូវលះបង់កម្មសិទ្ធឯកជន"។ ម្ហូបអាហារទាំងអស់ត្រូវបានប្រមូលដាំស្លជាសមូហភាពតាមភូមិនីមួយៗ។ ដល់ពេលបាយគេតែងវាយជួង ដែលធ្វើអំពីខ្នងកង់ឡានចាស់ៗជាសញ្ញា។ ពេលលឺសូរសំលេងជួងបន្លឺឡើង ត្រូវប្រញាប់ដើរទៅរករោងបាយសហករ បើទៅមិនទាន់ប្រាកដជាដាច់អាហារ។ ក្នុងរដូវច្រូតកាត់ប្រមូលផលស្រូវ អង្គការអនុញ្ញាតអោយបរិភោគបាយប្រហែលមួយខែ។ ក្រោយមក អង្គការមិនអនុញ្ញាតអោយដាំបាយទេ ត្រូវដាំបបរដោយអង្គការប្រើពាក្យ"យើងសន្សំសំចៃអោយបានកំរិតខ្ពស់"។ រហូតដល់រដូវភ្លៀងជារដូវស្ទូងដកនៅតាមរោងបាយសហករណ៍ គ្មានទាំងអង្ករសំរាប់ដាំបបរទៀតផងក៏មាន។ ក្នុងមួយខ្ទះ មានអង្ករប្រហែល០,២៥គីឡូក្រាម ហេតុនេះត្រូវថែមបន្លែ ស្លឹកឈើស្លឹកព្រៃបន្ថែមដើម្បីអោយពេញខ្ទះ។ ចំណែកឯ សាច់ក្នុងមួយខ្ទះស្ទើរគ្មានដែលមិនអាចគណនាកើត។ ជួនកាលដាច់ជាតិអង្ករ រហូតដល់កន្លះខែ រឺមួយខែក៏មាន។ ប្រជាពលរដ្ឋបរិភោគស្លឹកឈើ រឺសឈើ ដើម្បីបំបាត់ការទៀមទាររបស់ក្រពះតែប៉ុណ្ណោះ។ ការរស់នៅដោយគ្មានជីវជាតិគ្មានសាច់ គ្មានឈាម។

ឯក្មេងៗ ត្រូវអង្គការអប់រំនៅតាមកង តាមក្រុមដែលអង្គការហៅថា "កងកុមារ"។ កងកុមារ ត្រូវអង្គការអប់រំទៅតាមការដែលអង្គការចង់បាន និងធ្វើការងារជាទំងន់ផង។ កងកុមារ មានភារកិច្ច ពេលថ្ងៃធ្វើជីធម្មជាតិដូចជា កាប់ស្លឹកឈើ និងប្រមូលលាមកដាក់ក្នុងរណ្តៅ រួចរែកយកទៅដាក់តាមស្រែចំការ។ បន្ទាប់ពីពេលបាយថ្ងៃត្រង់ អង្គការអោយសំរាកកន្លះម៉ោង រឺមួយម៉ោង។ ក្នុងពេលសំរាកនេះ អង្គការមានកម្មវិធីបង្រៀនកុមារ



នៅក្រោមដើមឈើ ដែលជាកន្លែងការដ្ឋានអោយចេះអានអក្សរខ្លះៗ។ ក្រៅពីនេះ គេអប់រំកុមារអោយស្រឡាញ់អង្គការ ស្មោះត្រង់និងអង្គការ ហ៊ានរាយការណ៍ពីអ្នកដទៃជូនអង្គការ។ ពេលយប់ កងកុមារមានភារកិច្ចដើរស៊ើបការ ដើរលបស្តាប់តាមផ្ទះប្រជាពលរដ្ឋ និងឪពុកម្តាយ បងប្អូនខ្លួនដើម្បីយកពត៌មានជូនអង្គការ។

អង្គការបានរៀបចំប្រជាពលរដ្ឋអោយក្លាយជាកសិករទាំងអស់ គ្មាននិស្សិត គ្មានបញ្ញវន្ត និងបង្ខំទាំងកំលាំងអោយធ្វើស្រែចំការដោយមិនអនុញ្ញាតអោយប្រើតាមរបៀបវិទ្យាសាស្ត្រ។ បើអ្នកណាហ៊ានជំទាស់មួយមាត់នឹងអង្គការ ត្រូវយកទៅសំលាប់ភ្លាម។

រដ្ឋាភិបាលដែលមានលោក ប៉ុល ពត ជាអ្នកកាន់កាប់អំណាច មិនអនុញ្ញាតអោយប្រជាពលរដ្ឋខ្មែរមានជំនឿលើសាសនា កំទេចវត្តអារាម និងដេញព្រះសង្ឃទាំងអស់អោយសិក។ សាលារៀនទាំងអស់ត្រូវបិទ ប្រពៃណីទំនៀមទំលាប់ដែលមានតាំងពីរាប់សតវត្សមកហើយនោះ ត្រូវបានហាមឃាត់ និងមិនអោយខ្មែរគោរព។ យើងសួរថា៖ ជនជាតិមួយដែលគ្មានប្រពៃណី ទំនៀមទំលាប់ តើគេអាចសំគាល់ជនជាតិនោះថាជាជនជាតិអ្វីបានរឺទេ?។ ប្រពៃណីទំនៀមទំលាប់នេះដែលជាខ្លឹម ដែលជាព្រលឹងរបស់ជនជាតិនីមួយៗ។ ឧទាហរណ៍ យើងអាចស្គាល់ថា៖ នេះជាផ្លែអំពិលបានដោយសាររូបរាងខាងក្រៅរបស់វា ដែលយើងអាចមើលឃើញដោយសារចក្ខុរបស់យើង និងរស់ជាតិជូរ រឺផ្អែមរបស់វាដែលយើងអាចដឹងដោយសារជីវ្ហាវិញ្ញាណរបស់យើង។ ទាំងនេះគឺជាខ្លឹមរបស់ផ្លែអំពិល។ អ្វីៗដែលបានបាត់បង់ខ្លឹមរបស់ខ្លួនហើយ មិនអាចរកឃើញប្រភពដើមវាឡើយ គេអាចអោយឈ្មោះទៅតាមការដែលគេចង់។

លើសពីនេះទៀត របបលោកប៉ុលពតអនុវត្តផែនការបង្កើត "មនុស្សថ្មី"។ មនុស្សថ្មីគឺជាមនុស្សដែលក្រុមលោក ប៉ុល ពតបានកំណត់ រួចសំលាប់មនុស្សចាស់។ មនុស្សចាស់ក៏ដូចនេះដែរ គឺអង្គការជាអ្នកកំណត់។ នយោបាយរបស់ពួកគេអប់រំអោយកូនសំលាប់ម្តាយ ឪពុក បងប្អូន និងអប់រំខ្មែរអោយសំលាប់គ្នាៗគ្នាដោយប្រើនយោបាយថា មិនស្មោះត្រង់នឹងអង្គការ។ បញ្ជាអោយខ្មែរចេះតាមដានរាយការណ៍ពីគ្នាទៅវិញទៅមក ជូនអង្គការក្នុងគោលបំណងយកធ្វើជាលេសដើម្បីយកទៅសំលាប់។

ប្រជាពលរដ្ឋ បង្កបង្កើនផលបាន មិនអោយបរិភោគទៅតាមសេចក្តីត្រូវការទេ បែរជាប្រមូលយកអស់ ធ្វើអោយប្រជាពលរដ្ឋរាប់ពាន់រាប់ម៉ឺននាក់ត្រូវស្លាប់ ដោយអត់អាហារ និងមួយចំនួនទៀតទទួលរងគ្រោះស្លាប់ដោយសារជំងឺរាតត្បាត គ្មានពេទ្យត្រឹមត្រូវតាមបែបវិទ្យាសាស្ត្រ។ ខ្វះថ្នាំសង្កូវ ក៏អង្គការមហាលោតផ្លោះ មិនឈឺក្បាល។ ថ្នាំដែលមកពីប្រទេសជឿនលឿនលើពិភពលោក ត្រូវអង្គការបដិសេធ (ពាក្យដែលអង្គការបានប្រើគឺរបស់ចក្រព័ត្រ អង្គការមិនត្រូវការឡើយ)។ គេត្រូវការតែថ្នាំគីនីន "CHININ" ដែលនាំមកពីប្រទេសចិន។ ប្រជាពលរដ្ឋ៨០ភាគរយ ត្រូវទទួលគ្រោះថ្នាក់ដោយជំងឺគ្រុនចាញ់ និងមួយចំនួនទៀតស្លាប់ដោយបង្ខំអោយធ្វើការទាំងយប់ទាំងថ្ងៃស្ទើរគ្មានពេលសំរាក និងបង្អត់អាហារ។

ភ្នំពេញស្ទើរក្លាយជាក្រុងខ្មោច។ ទូទាំងប្រទេសមិនអនុញ្ញាតអោយមានការលក់ដូរនិងប្រាក់កាសឡើយ។ ក្នុងទីក្រុង មានកម្មករបន្តិចបន្តួចសំរាប់បំរើការអោយមេដឹកនាំរបស់អង្គការថ្នាក់លើ ដែលភាសាអង្គការហៅថា "នីរសា"។ គមនាគមន៍ក្នុងស្រុកត្រូវអង្គការកញ្ច្រាំចោលម៉ត់។ ក្នុងការធ្វើទំនាក់ទំនងជាមួយបរទេសគឺតាមរយៈយន្តហោះ១៩ថ្ងៃម្តងទៅក្រុងប៉េកាំង។



គ្រប់ស្ថាប័នរដ្ឋទាំងអស់ រឺស្ទើរតែទាំងអស់ត្រូវអង្គការមហាលោតផ្លោះកំទេចចោល។ បើទុកក៏អនុញ្ញាតអោយអនុវត្តតាមបែបចាស់កំរិល ប្រហែលរាប់ពាន់ឆ្នាំមុន ដូចជា ក្នុងវិស័យអប់រំ អង្គការបិទសាលារៀនចោល រឺយកសាលាធ្វើជាកន្លែងមន្ទីរឃុំឃាំង"គុក" ចំពោះអ្នកដែលគ្មានកំហុសសោះ គឺគ្រាន់តែអង្គការសង្ស័យប៉ុណ្ណោះ ហើយយកកុមារទៅបង្រៀននៅក្រោមដើមឈើក្នុងព្រៃ។ ប្រហែលជាកំឡុងឆ្នាំ១៩៧៧ ក៏ឈប់អោយមានការបង្រៀននេះទៅទៀត។ នៅតាមរោងចក្រដែលអង្គការបានទុកបន្តិចបន្តួច និងនៅតាមកំពង់ផែ អង្គការយកសុទ្ធតែក្មេងៗ កុមារតូចៗអោយលីសែងជាទំងន់។ នេះ គឺជាគោលបំណងបំបាក់កំលាំងកាយកំលាំងប្រាជ្ញាដល់កូនខ្មែរ។ យើងពិចារណារមើល សំលាប់អ្នកចេះដឹង មនុស្សចាស់ចោលអស់ កំទេចអស់រាល់ឯកសារដែលជាព្រលឹងជាតិ និងយកកុមារតូចៗទៅពង្វក់ដោយបង្ខំអោយធ្វើការហួសកំលាំង មិនអនុញ្ញាតអោយរៀនសូត្រ តើក្នុងពេលអនាគតប្រទេសនឹងក្លាយទៅជាយ៉ាងណា?។

សរុបលទ្ធផលជាផ្លែផ្កាក្នុងកំឡុងពេល ដែលក្រុមលោក ប៉ុល ពតកាន់អំណាច ពីឆ្នាំ១៩៧៥ដល់១៩៧៩ គឺជីវិតប្រជាពលរដ្ឋរាប់លាននាក់ត្រូវបាត់បង់ដោយអនោចអធម្ម រចនាសម្ព័ន្ធប្រទេសទាំងមូលធ្លាក់បាតដី។ អ្នកដែលនៅសល់ពីការសំលាប់ មានតែបាតដៃទទេ និងខោអាវមួយចង្កេះព្រមទាំងជំងឺខ្វះជីវជាតិរ៉ាំរ៉ៃក្នុងប្រាណ និងជាពិសេស គឺជំងឺបាក់ស្បាត។

## វិធីយួនសំលាប់ខ្មែរកំឡុងថ្ងៃ៧មករា១៩៧៩

ការសំលាប់ខ្មែរយ៉ាងរង្គៀលរបស់មេដឹកនាំខ្មែរ ដើម្បីផ្គាប់ផ្គន់ចៅហ្វាយចិនរបស់ខ្លួននេះ បានធ្វើអោយមេដឹកនាំយួនជ្រួលច្របល់ ខ្វល់ខ្វាយដេកមិនលក់ ដោយខ្លាចចិនលេបយកកម្ពុជាបានមុន។ ទន្ទឹមនិងការអន្ទះសារនេះ ក៏បានធ្វើអោយមេដឹកនាំយួនដេកញញឹម សប្បាយយ៉ាងរំភើយរួចទៅហើយដែរ។ ញញឹមក្នុងន័យថា ប្រាកដជាខ្មែរស្លាប់អស់ ប្រទេសខ្មែរនឹងធ្លាក់ចូលក្នុងកណ្តាប់ដៃគេយ៉ាងស្រួល ហើយមិនបាច់រវល់នឿយនឹងសំលាប់ខ្មែរដោយផ្ទាល់នាំអោយខូចឈ្មោះផង។

ដើម្បីអាចលេបសង្គ្រប់យកប្រទេសខ្មែរពីកណ្តាប់ដៃចិន រដ្ឋាភិបាលយួនបានខិតខំខ្នះខ្នែងខាងនយោបាយការបរទេស ក្នុងការស្វែងរកជំនួយទាំងនយោបាយនិងសម្ភារៈពីសហភាពសូវៀតដើម្បីធ្វើជាបង្អែក។ បន្ទាប់ពីប្រទេសយួនបានទទួលជ័យជំនះលើសហរដ្ឋអាមេរិក ខែមេសា១៩៧៥ សូវៀតបានប្រកាសជួយកសាងប្រទេសយួនច្រើនជាងចិន។ រវាងខែសីហានិងធ្នូ១៩៧៥ មានសន្ធិសញ្ញាជាច្រើនអំពីការជួយខាងផ្នែកសេដ្ឋកិច្ចរបស់សូវៀតសំរាប់កសាងប្រទេសយួន។ សេចក្តីសំរេចរបស់មេដឹកនាំយួនឆ្នាំ១៩៧៧ក្នុងការអនុវត្តកំលាំងទ័ព ដើម្បីចូលកាន់កាប់ប្រទេសខ្មែរបានធ្វើអោយការវិវឌ្ឍនៃចំណងមិត្តភាពរវាងសហភាពសូវៀត និងប្រទេសយួនចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧មក កើនឡើងកាន់តែខ្ពស់ ព្រោះវាស្របនឹងបំណងរបស់សហភាពសូវៀតដែលសូវៀតចាប់ផ្តើមរៀបចំពង្រីកមហិទ្ធិឫទ្ធិកុំមុយនីស្តរបស់ខ្លួននៅតំបន់នេះតាំងពីកំឡុងឆ្នាំ១៩៦០មកម្លេះ។ សហភាពសូវៀតបានត្រៀមខ្លួនជាស្រេច ដើម្បីគាំទ្រដល់នយោបាយអនុត្តរភាព



របស់យួនមកលើកម្ពុជានិងលាវ។ នៅថ្ងៃទី៣វិច្ឆិកា១៩៧៨ មានការចុះសន្ធិសញ្ញាអំពីមិត្តភាព និងសហប្រតិបត្តិការរវាងសហភាពសូវៀត និងប្រទេសយួនសំរាប់រយៈពេល២៥ឆ្នាំ។ នៅក្នុងសន្ធិសញ្ញានោះ ទទួលយកនូវការវាយលុករបស់យួនចូលក្នុងប្រទេសកម្ពុជា ហើយតាមគំនិតមេដឹកនាំយួនគឺលើកពួកកុំមុយនីស្តកម្ពុជាអោយកាន់អំណាច។ ក្រោយពីចុះសន្ធិសញ្ញានេះ មេដឹកនាំយួនបានចាប់ផ្តើមប្រមូលពួកខ្មែរយៀកមិញអោយដឹកនាំមុខក្នុងការបង្កើត ជាកំលាំងចលនាមួយដែលមេដឹកនាំយួនអោយឈ្មោះថារណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ តាមប្រភពម្នាក់ស្គាល់លោក ប៉ែន សុវណ្ណ បានប្រាប់ដូចខាងលើនេះដែរថា៖ មេដឹកនាំយួនជាអ្នកមានគំនិតផ្តើមបង្កើតរណសិរ្សនេះដើម្បីប្រឆាំងនឹងក្រុមលោក ប៉ុល ពត ព្រោះក្រុមនេះបានធ្វើអោយប្រទេសខ្មែរឃ្លាតឆ្ងាយពីដើមទ្រូងរបស់គេ(យួន)។ ប្រភពនោះបានបន្ថែមទៀតថា៖ ដើម្បីកុំអោយអន្តរជាតិថ្កោលទោស មេដឹកនាំយួនបានជ្រើសតាំងពួកអតីតខ្មែរយៀកមិញអោយឈរឈ្មោះ ហើយមេដឹកនាំយួនជាអ្នកក្តាប់ពីលើ។ ក្រុមអតីតខ្មែរយៀកមិញដែលមានលោក ប៉ែន សុវណ្ណ លោក ចាន់ ស៊ី លោក ជា សុត និងលោក សាយ បូថង បានព្រមចូលរួមបង្កើតរណសិរ្សនេះនាថ្ងៃ២ធ្នូ១៩៧៨នៅក្រែកមេមត់ ជប់។ ក្នុងពេលនោះ មេដឹកនាំក្រុងហាណូយបានសន្យាថា៖ នេះគឺជាមិត្តភាពរវាងប្រទេសកម្ពុជា និងប្រទេសយួនសុទ្ធសាធ។ ប្រភពនេះបានបន្តទៀតថា៖ ដំបូង គ្មានក្រុមអតីតខ្មែរក្រហមថិតក្នុងជួរថ្នាក់ដឹកនាំរណសិរ្សនេះទេ។ ក្រុមខ្មែរក្រហម ដូចជា លោក ហ៊ុន សែន លោក ជា ស៊ីម និងលោក ហេង សំរិន បានរត់ភៀសខ្លួនទៅប្រទេសយួនដែរ តែរដ្ឋាភិបាលយួនបានចាប់ឃុំទុកនៅព្រៃនគរដើម្បីមើលជំហារសិន និងមិនទាន់ដាក់បញ្ចូលក្នុងរណសិរ្ស

ទេ ព្រោះមិនទាន់ទុកចិត្ត។ ក្រោយពីបំពាក់ជំហរួចមក មេដឹកនាំយួនក៏បញ្ចូលក្រុមនេះទៅក្នុងរណសិរ្ស រួចប្រគល់តួនាទីតែម្តង។ បន្ទាប់ពីបានប្រកាសបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាជាមូលដ្ឋាន ក្រុមមេដឹកនាំយួនបានរៀបចំទ័ព២០កងពល(ប្រហែល២០០០០០នាក់) ដើម្បីធ្វើការវាយលុកចូលកាន់កាប់ក្នុងប្រទេសកម្ពុជា។

ដើម្បីសម្រេចនូវយុទ្ធសាស្ត្រសម្លាប់ខ្មែរ មេដឹកនាំយួនមានយុទ្ធវិធីប្លែកៗជាថ្មីទៀត។ បងប្រុសជាអតីតយុទ្ធជនកងរំដោះ បាននិយាយរំលឹកអំពីហេតុការណ៍ខ្លះៗ ដែលទាក់ទងនឹងយុទ្ធវិធីសម្លាប់ខ្មែររបស់មេដឹកនាំយួន ដូចខាងក្រោមៈ

ចុងខែធ្នូឆ្នាំ១៩៧៨ កងទ័ពយួនបានបើកការបាញ់សន្ធាប់យ៉ាងខ្លាំង ទាំងកាំភ្លើងដៃ និងអមដោយកាំភ្លើងធ្លោង នៅពេលព្រលប់ប្រមាណជាម៉ោង៨ទៅ៩ មកលើភូមិពីរក្នុងឃុំស្លា គឺភូមិកញ្ចាង និងភូមិស្រីប្រសើរ ក្នុងខណៈមានតែប្រជាជន គ្មានកងទ័ពខ្មែរក្រហមម្នាក់ឡើយ ព្រោះគេ(ខ្មែរក្រហម) បានរត់ទៅទិសខាងលិចច្រើនថ្ងៃមកហើយ។ ការបាញ់នេះបណ្តាលឲ្យស្លាប់ប្រជាជនឈ្មោះហ៊ឺម្នាក់ នៅភូមិស្លាលិច ហើយបានទៅរស់នៅភូមិស្រីប្រសើរ ឋានៈជាភូមិបញ្ញើ និងរបួសជាច្រើនទៀត តែយើងនៅចាំបានម្នាក់ឈ្មោះ ឡាន់ ខុំ ភេទប្រុសនៅភូមិស្លាកើត ដែលត្រូវបានទៅរស់នៅភូមិបញ្ញើនេះដែរ។

បន្ទាប់ពីបានបោះទីតាំងឈរជើងនៅភូមិអំពិលជាប់ភ្នំជីសូរ កងទ័ពយួនចាប់ផ្តើមចាត់តាំងរដ្ឋអំណាចបណ្តោះអាសន្ន ហើយធ្វើការតាមដានចាប់ខ្លួនប្រជាជនមាននិន្នាការ ប៉ុល ពត និងចាប់ជនដែលវិលត្រឡប់ពីខ្មែរក្រហមកៀរយកទៅ ដោយខ្លះក៏ត្រូវបានបាញ់ចោលភ្លាមៗ ហើយខ្លះទៀត



ត្រូវបញ្ជូនទៅអប់រំ ហើយបាត់ខ្លួនរហូតសព្វថ្ងៃនេះ។ ក្នុងនោះមានឈ្មោះជនរងគ្រោះដូចតទៅៈ

១- ឈ្មោះ គុច ភេទប្រុស នៅភូមិអារោង ក្នុងឃុំស្លាត្រូវចាប់ចងយកទៅសម្លាប់នៅក្បែរជើងភ្នំជីសូរ។

២- ឈ្មោះ យន់ ភេទប្រុស នៅភូមិកញ្ចាង ក្នុងឃុំស្លា ក៏ត្រូវសម្លាប់ក្បែរជើងភ្នំជីសូរដែរ។

៣- ឈ្មោះ ញឹម សារិន ភេទប្រុសនៅភូមិត្រពាំងស្វង ក្នុងឃុំរវៀងរួមទាំងមនុស្សមួយចំនួនទៀត ដែលមិនតិចជាង៥០នាក់ត្រូវបញ្ជូនទៅអប់រំតែបាត់ខ្លួនរហូតសព្វថ្ងៃ។

ក្នុងរយៈពេលដ៏ខ្លី កងទ័ពយួនបានធ្វើការវាយលុកសំរុកមកពាសពេញភូមិជនបទ និងបានកាន់អំណាចទាំងស្រុង។ បន្ទាប់មក ប្រជាពលរដ្ឋខ្មែរ បាននាំគ្នាទៅយកស្រូវ អង្ករ អំបិល គោ ក្របី ជ្រូក មាន់ ទា នៅតាមជង្រុក រឺទ្រុងដែលក្រុមសហករណ៍ពីមុនបានប្រមូលដាក់ជាទ្រព្យសម្បត្តិរួម ដ្បិតពេលនោះក្រុមទាហានប៉ុល ពត បានរត់បាត់អស់ដែរ ដើម្បីផ្គត់ផ្គង់ការស្រេកឃ្លានរបស់ខ្លួន។ កងទ័ពយួនទៅដល់ភូមិណា តែងជ្រើសរើសប្រធានភូមិ និងកងស្វ័យត្រានដើម្បីយាមភូមិ។

ពាក់កណ្តាលខែកុម្ភៈ កងទ័ពយួនបានវិលទៅស្រុកយួនវិញ ដើម្បីចូលរួមបុណ្យចូលឆ្នាំថ្មី(ជាលេស) ស្របពេលនោះ បានដឹកជញ្ជូនជ័យផលដែលខ្មែរក្រហមប្រមូលទុកនៅទីប្រជុំជនបត់រកា មានដែកសសៃធំតូច រាប់តោន ក្រណាត់សំពត់ ប្រេងឥន្ធនៈ និងគ្រឿងបរិភោគផងដាក់តាមកាណូតទាំងអស់។ ទង្វើនេះបានធ្វើឲ្យពួកខ្មែរក្រហមខឹងសម្បារយ៉ាងខ្លាំង។

ក្រោយពីកងទ័ពយួនដកថយចេញទៅវិញ ដោយគ្មានប្រាប់ជាមុន

សោះបាត់អស់ ក្រុមកូនទាហាន ប៉ុល ពត ដែលបានលាក់ខ្លួនក្បែរៗនោះ បានត្រឡប់ចូលមកវិញ។ គ្រានេះគេសំលាប់ប្រជាពលរដ្ឋសាហាវខ្លាំង លើសជាងមុនៗទៅទៀត ទាញសំពង ទាញបាញ់សំលាប់នៅក្នុងភូមិក្បែរ ផ្ទះ មិនយកទៅឆ្ងាយនាំអោយខាតពេលឡើយ។ ពួកគេគ្រាន់តែចោទថា៖ អ្នកឯងបានទៅលួចទ្រព្យសម្បត្តិសហករណ៍ និងជាដៃជើងសមគំនិតជាមួយពួកយួន ដោយគ្មានការសួររកវីសគល់ រឺហេតុផលអ្វីឡើយ។ ពិសេសប្រធានភូមិ និងកងស្ម័យគ្រានជាមុខព្រួញទីមួយត្រូវសំលាប់។ ប្រជាពលរដ្ឋប្រុស ស្រី ក្មេង ចាស់នៅក្នុងភូមិនីមួយៗរកតែពុទ្ធាញ័រញាក់ដូចកូនសត្វ គ្មានហ៊ានហើបមាត់បន្តិចឡើយ។

ប្រហែលជាប៉ុន្មានថ្ងៃក្រោយមក ទើបកងទ័ពយួនវាយសំរុកត្រឡប់ចូលមកវិញ។ ពេលនោះ មានការប៉ះទង្គិចបាញ់គ្នារប៉េះរប៉ោះខ្លះ ជាមួយក្រុមកូនទាហាន ប៉ុល ពត រួចពួកនោះរត់គេចបាត់អស់។ ដោយមានការប៉ះទង្គិចគ្នាយ៉ាងនេះ ពួកកងទ័ពយួនបានជាលេសចោទប្រកាន់ប្រជាពលរដ្ឋខ្មែរថា៖ អ្នកឯងត្រូវដៃ ត្រូវជើង និងផ្សំគំនិតជាមួយពួកទាហាន ប៉ុល ពត ជួយលាក់ទាហាន ប៉ុល ពត រួចយកអ្នកនោះទៅសំលាប់ ធ្វើបាបទៀតទៅ។ ប្រជាពលរដ្ឋខ្មែរដេករង់ចាំតែការចោទប្រកាន់ទាំងកំពោល និងការយកទៅសំលាប់យ៉ាងអយុត្តិធម៌។ ប្រជាពលរដ្ឋខ្មែរមិននឹកស្មានថា ខ្លួនបានរួចពីទ្រុងខ្លាមកចូលក្នុងអាងក្រពើសោះ។

ហេតុអ្វីបានជាកងទ័ពយួនចូលមកបានបួន-ប្រាំថ្ងៃរួចដកថយទៅវិញ ដោយមិនប្រាប់ខ្មែរជាមុន?។ នេះមកពីមេដឹកនាំយួនបានប៉ាន់ស្មានចំនួនប្រជាពលរដ្ឋខ្មែរខុស មុននឹងខ្លួនចូលមកក្នុងប្រទេសកម្ពុជា។ ប្រហែលជាមេដឹកនាំយួនយល់ថា ពេលនេះ ក្រុមលោក ប៉ុល ពត បានសំលាប់ខ្មែរ



ស្ទើរអស់ទៅហើយ។ ដូចនេះ កងទ័ពយួនខំវាយសង្គ្រប់លេបយកក្នុងរយៈពេលដ៏ខ្លីតែម្តង។ តែពេលចូលមកដល់ ឃើញខុសពីការប៉ាន់ស្មាន ក៏ដកថយទៅវិញដើម្បីផ្តល់ឱកាសអោយក្រុមកូនទាហាន ប៉ុល ពត ចូលមកសំលាប់ខ្មែរម្តងទៀត។ បើមេដឹកនាំយួនដឹងថា ខ្មែរទើបស្លាប់មួយចំនួន នៅសល់ច្រើនដែរ នោះគេមិនទាន់មកសង្គ្រប់ទេ។ នេះគឺជាល្បិចមួយរបស់មេដឹកនាំយួនក្នុងការខ្ចីដៃពួកខ្មែរនិយមចិន អោយសំលាប់ខ្មែរ។

# សាធារណរដ្ឋប្រជាមានិតកម្ពុជា(១៩៧៩)

នៅថ្ងៃ៧មករា១៩៧៩ របបថ្មីត្រូវបានប្រកាសជាសាធារណរដ្ឋប្រជាមានិតកម្ពុជា និងអនុវត្តកសាងប្រទេសតាមលទ្ធិម៉ាក្សលេនីន ឆ្ពោះទៅកាន់សង្គមនិយមជាជំហានៗដែលមានលោក ហេង សំរិន ជាប្រធានរដ្ឋ និងលោក ប៉ែន សុវណ្ណ ជានាយករដ្ឋមន្ត្រី។ ប្រជាពលរដ្ឋខ្មែរអបអរសាទរ និងគាំទ្រយ៉ាងក្រៃលែង។

ប្រជាពលរដ្ឋបានធ្វើដំណើរមករកភូមិកំណើតរៀងៗខ្លួន និងដើរសួររកបងប្អូន កូនចៅផៅសន្តានដែលរបបមុនបានបំបែក។ អ្នកខ្លះបានជួបកូន ជួបញាតិមិត្តគ្រួសារវិញ ខ្លះទៀតបានជួបកូន តែបាត់ប្តី រឺប្រពន្ធ ខ្លះក្លាយជាកូនកំព្រា។ មានសព្វ មានគ្រប់ គឺគ្មានគ្រួសារណាមួយដែលបានជួបជុំមូលញាតិទាំងអស់នោះឡើយ។ ក្រោយពីបានដើររកបងប្អូនញាតិមិត្តរួច គេនាំគ្នាទៅរស់នៅតាមភូមិកំណើត រឺកន្លែងដែលអាចរស់នៅបានតាមការចង់។ ប្រជាពលរដ្ឋចាប់ផ្តើមកសាងជីវភាពថ្មីពីបាតដៃទទេ ប្រកបដោយសេចក្តីសង្ឃឹមក្នុងការស្តារ និងកសាងប្រទេសជាតិមាតុភូមិអោយស្រស់បំព្រង។ ក្រៅពីនេះ ប្រជាពលរដ្ឋបានចូលរួមយ៉ាងស្រស្រាក់ស្រស្រាំប្រកបដោយទឹកចិត្តស្រឡាញ់ជាតិមាតុភូមិពិតៗ ជាមួយរដ្ឋាភិបាលក្នុងការស្តារប្រទេសពីសូន្យដែលបន្សល់ទុកដោយរបបខ្ញុំចិននិយមរបស់លោក ប៉ុល ពត។

បន្ទាប់ពីរបបខ្ញុំចិនដួលរលំទៅ រដ្ឋអំណាចថ្មីឡើងកាន់អំណាច ដែលប្រកាសជាសាធារណរដ្ឋប្រជាមានិតកម្ពុជា តែថិតនៅក្រោមការត្រួតត្រាពីសំណាក់មេដឹកនាំយួន។ ទោះបីស្ថិតក្នុងស្ថានភាពយ៉ាងនេះក្តី ក៏បញ្ញវន្តនិងអ្នកចេះដឹងខ្មែរដែលសេសសល់ពីការកាប់សម្លាប់ បានរួមសាមគ្គីគ្នាជា



ធ្លុងមួយ ចូលរួមក្នុងអង្គការចាត់តាំងថ្មីនេះ ទៅតាមសមត្ថភាពរៀងៗខ្លួនដើម្បីកសាងជាតិមាតុភូមិ ដោយគ្មានគិតពីផលប្រយោជន៍សួនតួឡើយ។ សាស្ត្រាចារ្យ គ្រូបង្រៀន បញ្ញវន្ត មន្ត្រីរដ្ឋការ បានធ្វើដំណើរមករកកិច្ចការតាមមុខជំនាញ ទោះជាមានការលំបាកខ្លះក៏ដោយ។ ការលំបាកទាំងនេះគ្មានអ្វីក្រៅពីត្រូវប្រកបរបរដើម្បីចិញ្ចឹមជីវិត និងត្រូវទៅចូលរួមបំរើសេចក្តីត្រូវការរបស់ប្រទេសជាតិផង ព្រោះពេលដំបូងនេះ រដ្ឋាភិបាលពុំទាន់មានថវិកាគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ រឺផ្តល់ប្រាក់ខែអោយនៅឡើយ។

កំឡុងឆ្នាំ១៩៧៩-៨០ មន្ត្រីរដ្ឋការ គ្រូបង្រៀនបានទទួលប្រាក់បំណាច់របស់ខ្លួន ជាអង្ករ សាប៊ូ អំបិល ស្ករ ប្រេងសណ្តែក ជូនកាលជាសៀវភៅ ប៊ិច ខ្មៅដៃ ដែលជាជំនួយរបស់អង្គការមនុស្សធម៌ពិភពលោកបន្តិចបន្តួចតែប៉ុណ្ណោះ។ ក្នុងខែខ្លះមិនបានទទួលអ្វីសោះក៏មាន។ ទើបក្រោយមក បានទទួលប្រាក់ខែជាទឹកប្រាក់ តែនៅមិនគ្រប់គ្រាន់សំរាប់ចិញ្ចឹមជីវិត។ ទោះបីមានការលំបាក ខ្វះខាតក្នុងជីវភាពប្រចាំថ្ងៃយ៉ាងនេះក្តី មន្ត្រីរដ្ឋការ កម្មករ សាស្ត្រាចារ្យ គ្រូបង្រៀន ខិតខំបញ្ចេញអស់កំលាំងកាយចិត្ត ក្នុងការលើកស្ទួយមាតុភូមិជាទីស្នេហាប្រកបដោយទឹកចិត្តខ្ពង់ខ្ពស់ឧត្តុងឧត្តម។ ទឹកចិត្តនេះកើតមានឡើង ក៏ដោយសាររជនយើងខាងលើមានការស្មោះចំពោះប្រទេសជាតិនិងធ្វើការដើម្បីជាតិពិតៗ។

បងប្រុសជាអតីតគ្រូបង្រៀន ដែលជាអ្នកចាប់ផ្តើមបង្រៀនក្នុងឆ្នាំសិក្សា(១៩៧៩-៨០)ដំបូងបង្អស់ក្នុងស្រុកសំរោងបានរំលឹកដូចខាងក្រោម៖

មានអតីតគ្រូបង្រៀន និស្សិត សិស្ស បានយកចិត្តទុកដាក់បើកថ្នាក់រៀន សំរាប់កុមារា កុមារីដែលមិនចេះអក្សរអោយបានចូលរៀនគ្រប់ៗគ្នា។ អ្វីដែលគួរអោយកត់សំគាល់នោះ ជាលើកដំបូងបង្អស់ក្នុងឆ្នាំសិក្សាទី១

(១៩៧៩-៨០)គឺមានតែឃុំស្លាទេ ក្នុងទូទាំងស្រុកសំរោងដែលត្រូវបានបើកថ្នាក់រៀនបឋមសិក្សាមុនគេ ហើយដែលមានសិស្សជាបេក្ខជនបានទៅប្រលងយកវិញ្ញាបណ្ណបត្រ នាមណ្ឌលប្រលងអង្គរុនក្នុងឃុំចំបក់ស្រុកបាទី។ ក្នុងនោះបេក្ខជនពីស្រុកសំរោងមានឃុំស្លា២៨នាក់ ឃុំជើងកួន៤នាក់ និងឃុំខ្វារ២នាក់។ លទ្ធផលសំរេចបាននេះគឺជាការស្នេហាជាតិខ្ពស់របស់លោកគ្រូ អ្នកគ្រូបានខិតខំអស់កំលាំងកាយចិត្តពុះពារគ្រប់ការលំបាក ដូចជាការដើរស្វែងរកឯកសារ សៀវភៅសំរាប់បង្រៀនដោយយកអង្ករទៅដោះដូរនៅឯភ្នំពេញ ព្រោះរដ្ឋពុំទាន់បានផ្តល់សំភារៈឬកម្មវិធីសិក្សាគ្រប់គ្រាន់នៅឡើយ។ ម៉្យាងទៀត ការឧបត្ថម្ភរបស់រដ្ឋគឺគ្មានប្រាក់បៀវត្សទេ មានតែការផ្តល់ម្តងម្កាលនូវម្សៅមី ម្សៅទឹកដោះគោ គ្រាប់ពោតក្រហម ឬអង្ករស្រូវសាឡីបន្តិចបន្តួចប៉ុណ្ណោះ។ ឯអាគារសិក្សាវិញក៏គ្មាន រៀនតាមផ្ទះបាយរបស់សហករណ៍សម័យប៉ុល ពត ខ្លះរៀនតាមកុដិ ឬសាលាឆាន់របស់ព្រះសង្ឃដែលនៅសល់ គ្មានតុអង្គុយ គ្មានក្តារខៀន។ តែជាបណ្តើរៗត្រូវបានលោកគ្រូ អ្នកគ្រូដើរប្រមែប្រមូល ជួសជល់រហូតបានមានសំភារៈសំរាប់សិស្សខ្លះៗ ហើយឈានទៅប្រមូលផ្តុំតាមសាលារហូតសព្វថ្ងៃ។

ឯកសិករមានការមមាញឹកក្នុងការបង្កបង្កើនផល ដើម្បីដោះស្រាយជីវភាពផ្ទាល់ខ្លួនផង និងចូលរួមក្នុងការពង្រីកសេដ្ឋកិច្ចជាតិដោយគ្មានគិតពីការនឿយហត់។ គួររំលឹកថា វិស័យកសិកម្ម គឺអនុវត្តរបៀបជាក្រុមសាមគ្គីដែលមួយក្រុមមានមនុស្សចំនួនពី១០ទៅ១៥គ្រួសារ តាមចំនួនមនុស្សជាក់ស្តែង។ គឺធ្វើរួមក្នុងក្រុម ហើយចែកផលទៅតាមមាត់សមាជិកក្រុមនីមួយៗ ហូបចុកតាមគ្រួសារ។ ឆ្នាំ១៩៨៤បំបែកធ្វើលក្ខណៈជាក្រុមប្រវាស់ដៃ ហើយក្រោយបន្តិចមកក៏ក្លាយទៅជាឯកជនសុទ្ធសាត ដោយចែកដីក្នុង



មួយនាក់បាន១០អាជាទូទៅ។ ភោគផលកសិករផលិតបាន គឺត្រូវលក់ជូនរដ្ឋតាមការកំណត់ផែនការរបស់រដ្ឋ ដោយអនុវត្តតាមពាក្យស្លោក "លក់ស្រូវជូនរដ្ឋ គឺស្នេហាជាតិ"។

ដោយស្មារតីទទួលខុសត្រូវខ្ពស់របស់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស និងមានទិសដៅរួមយ៉ាងស្អិតរមួតរវាងប្រជាពលរដ្ឋ និងថ្នាក់ដឹកនាំខាងលើ បានធ្វើអោយមានសន្ទុះរីកចំរើនមិនឈប់ឈរនៃការកសាង និងស្តាបនា។ ក្រោយពីថ្ងៃ៧ខែមករាឆ្នាំ១៩៧៩ ប្រទេសខ្មែរបានរីកចំរើនស្ទើរគ្រប់វិស័យយ៉ាងលឿន ថ្វីបើរដ្ឋាភិបាលយើងបិតនៅក្រោមការគ្រប់គ្រង និងបញ្ជារបស់មេដឹកនាំយួន គឺអ្នកជំនាញការយួននៅត្រួតពិនិត្យតាំងពីមជ្ឈឹមរហូតដល់ភូមិឃុំចុងកាត់មាត់ញក។ តែខ្មែរមានឈាមជាខ្មែរបានព្រួតដៃគ្នាយ៉ាងណែនបំរើជាតិខ្មែរ មិនសូវជាយកចិត្តទុកដាក់ស្តាប់បទបញ្ជាដើម្បីបង្ហិនបង្ខោចខ្មែររបស់អ្នកជំនាញការយួនប៉ុន្មានទេ ខ្មែរគិតតែពីកសាងៗមាតុភូមិជាទីស្រឡាញ់របស់ខ្លួន។ សាលារៀនដែលនៅសល់ពីការបាក់បែកទាំងប៉ុន្មាន ត្រូវបើកទ្វារអោយកូនខ្មែរបានចូលរៀននិងចាប់ផ្តើមជួសជុលជាបណ្តើរៗតាំងពីទីក្រុងខេត្តរហូតដល់ភូមិ និងខ្លះទៀតបានសង់បន្ថែម។ មន្ទីរពេទ្យត្រូវបានជួសជុល និងបើកទ្វារអោយគ្រូពេទ្យចូលព្យាបាលជំងឺជាធម្មតា។ រោងចក្រ សហគ្រាសនិងសិប្បកម្មនានាដែលនៅសល់ បានបើកអោយមានដំណើរការឡើងវិញ និងជួសជុលជាបន្តបន្ទាប់។

ជីវភាពប្រជាពលរដ្ឋជាទូទៅ មានការធូរស្រាលគ្រាន់បើជាងមុន។ ភាពរស់ឡើងវិញប្រកបដោយការវិវឌ្ឍន៍ផ្នែកជីវភាព និងសង្គមមិនឈប់ឈរ និងឈានទៅរកភាពរុងរឿងនេះ មិនបានធ្វើអោយពួកមេដឹកនាំយួនសប្បាយចិត្តទេ។ តើមេដឹកនាំយួនប្តូរនយោបាយដូចម្តេចនៅពេលនេះ?

## មេដឹកនាំយួនប្រើរូបមន្តចាស់

ការមិនសប្បាយចិត្ត ចំពោះការរស់រានមានជីវិតរបស់ប្រជាពលរដ្ឋខ្មែរប្រកបដោយការវិវឌ្ឍន៍ផ្នែកជីវភាព និងសង្គមមិនឈប់ឈរនេះ ធ្វើអោយក្រុមមេដឹកនាំយួននឹកដល់រូបមន្តចាស់នៅឆ្នាំ១៨៩០មកប្រើ គឺរូបមន្តបំបែកបំបាក់ ដោយការលើបន្តុបអោយកាន់អំណាចទាំងមិនសមរម្យ។

នៅឆ្នាំ១៩៨២ លោក ប៉ែន សុវណ្ណ ជានាយករដ្ឋមន្ត្រីខ្មែរត្រូវបាត់ខ្លួនដោយមិនដឹងមានមូលហេតុជាផ្លូវការ។ ក្រោយមកលេចលឺថា លោកត្រូវមេដឹកនាំយួនចាប់ដាក់គុកនៅប្រទេសយួន។ បន្ទាប់មក លើកបន្តុប លោក ចាន់ ស៊ី ឡើងជំនួសកន្លែងនោះ។ មិនដឹងជាមានហេតុការណ៍អ្វីស្រាប់តែនាថ្ងៃទី៣១ធ្នូ១៩៨៤ លោក ចាន់ ស៊ី ត្រូវបានស្លាប់មុនអាយុទៅទៀត (លោក ចាន់ ស៊ី និងលោក ប៉ែន សុវណ្ណ ជាអតីតខ្មែរយៀកមិញ)។

នៅដើមខែមករា១៩៨៥ ពួកមេដឹកនាំក្រុងហាណូយបានលើកបន្តុបលោក ហ៊ុន សែន ដែលមានអាយុ៣៤ឆ្នាំនិងមានដំណែងជារដ្ឋមន្ត្រីក្រសួងការបរទេសឡើងជានាយករដ្ឋមន្ត្រីជំនួសលោកចាន់ ស៊ី។ លោកហ៊ុនសែនមានតួនាទីតាំងពីខែឧសភា១៩៨១ ជាសមាជិកការិយាល័យនយោបាយនិងជាលេខាមជ្ឈឹមបក្សនៃបក្សប្រជាជនបដិវត្តកម្ពុជា(លោក ហ៊ុនសែន ជាអតីតកូនទាហានខ្មែរក្រហម)។ ចាប់ពីពេលដែលលោក ហ៊ុន សែន បានកាន់ដំណែងជានាយករដ្ឋមន្ត្រីមក ក្រុមជាអតីតខ្មែរក្រហម បានពង្រីកកំលាំងរបស់ខ្លួនក្នុងជួរអ្នកដឹកនាំកាន់តែខ្លាំង។ ក្រសួងសំខាន់ៗត្រូវក្រុមអតីតខ្មែរក្រហម យកមកកាន់កាប់ទាំងអស់។ ក្នុងនោះមានក្រសួងការពារប្រទេស ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងហិរញ្ញវត្ថុ និងពាណិជ្ជកម្ម



(ក្រសួងទាំងនេះពីមុន គឺអតីតខ្មែរយៀកមិញជាអ្នកកាន់កាប់)។ ចាប់ពីឆ្នាំ១៩៨៥មក កំលាំងរបស់អតីតខ្មែរយៀកមិញត្រូវថយចំនួនចុះក្នុងក្រុមបក្សដឹកនាំ ហើយចំនួនអតីតខ្មែរក្រហមកើនច្រើនលើសលប់ ក្នុងការិយាល័យនយោបាយ និងលេខាមជ្ឈឹមបក្ស។

ការប្តូរនយោបាយរបស់មេដឹកនាំយួន គឺកាលពីមុនឆ្នាំ១៩៨៥ មេដឹកនាំយួនទុកចិត្តពួកអតីតខ្មែរយៀកមិញ ព្រោះពួកនេះមានប្រវត្តិតស៊ូតាំងពីឆ្នាំ១៩៣០ ជាមួយគណបក្សកុំមុយនីស្តឥណ្ឌូចិន ដែលមានមេដឹកនាំយួនជាមេក្លោង។ ម្យ៉ាងទៀត អតីតខ្មែរយៀកមិញត្រូវបានមេដឹកនាំយួនបីបាច់ថែរក្សាចិញ្ចឹមតាំងពីតូចៗមកម្លេះ ដូចជា លោក ប៉ែន សុវណ្ណ ជាដើម។ ពួកនេះបានរស់នៅប្រទេសយួនខាងជើងរហូតដល់ឆ្នាំ១៩៧០ ទើបត្រឡប់មកប្រទេសកម្ពុជាវិញ។ មេដឹកនាំក្រុងហាណូយប្រាកដជាយល់ថា ពួកនេះនឹងពិតជាបំរើផលប្រយោជន៍ដែលខ្លួនបានប៉ុនប៉ង។ តែប្រហែលជាផ្ទុយនិងគំនិតរបស់ខ្លួន បានជាចាប់ពីឆ្នាំ១៩៨៥ ពួកអតីតខ្មែរយៀកមិញត្រូវដកចេញពីដំណែង ហើយជ្រើសរើសពួកអតីតខ្មែរក្រហមនិងអ្នកដែលទុកចិត្តអោយឡើងកាន់កិច្ចការនោះវិញ។ មេដឹកនាំយួនតែងស្រាវជ្រាវរកអ្នកណាដែលមិនស្មោះត្រង់នឹងខ្លួន គឺអ្នកដែលប្រឆាំងនឹងផែនការនយោបាយរបស់ខ្លួន ដើម្បីទំលាក់ចេញពីដំណែង រឺធ្វើជាអោយទៅរៀនសូត្ររហូតដល់ចាប់ដាក់គុក។ មេដឹកនាំយួនជ្រើសរើសយកតែអ្នកណាដែលមានទំនាក់ទំនងល្អ ជិតស្និទ្ធ អ្នកណាដែលមិនចេះប្រឆាំងនឹងនយោបាយខ្លួនដែលប៉ិនប្រសប់រាយការណ៍ប្រាប់ខ្លួនពីរឿងខ្មែរ ដែលចង់តែឡើងធ្វើធំអោយឡើងជាលោកធំខ្មែរ។ ជំនាន់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាងាយស្រួលឡើងអង្គុយធ្វើលោកធំណាស់ ចំពោះអ្នកដែលស្រឡាញ់អំ

ណាច ក្បត់និងជាតិឯង។ ដោយមូលហេតុនេះ បានជាចាប់ពីឆ្នាំ១៩៨៥មក ប្រជាពលរដ្ឋខ្មែរដែលធ្លាប់តែសាមគ្គីគ្នា មានទិសដៅរួមដើម្បីលើកស្ទួយប្រទេសជាតិទៅជាបែកបាក់គ្នា និងលែងមានជំនឿទុកចិត្តគ្នា រហូតដល់ខ្លាចមិនហ៊ាននិយាយការពិតប្រាប់គ្នា។ អ្នកដែលដឹងការពិតសុខចិត្តតែដេកខាំមាត់សង្កត់ចិត្តម្នាក់ឯង ព្រោះមានខ្មែរភ្លីភ្លើខ្លះចង់បានតែអំណាចលើកបន្តុបដើម្បីដើរពើងទ្រូងសំលុតអ្នកដទៃ បានទៅអែបអបយកចិត្តយកថ្លើមរាយការណ៍សំលាប់ខ្មែរគ្នាឯង និងយករឿងខ្មែរទៅប្រាប់ជំនាញការយួនដើម្បីប្រជែងឡើងធ្វើលោកធំ ទាំងងងឹតងងល់ដែលបណ្តាលអោយមានការស៊ីសំណូក ប្រកាន់បក្សពួកក្រុមគ្រួសារញាតិមិត្តនិយម។ បើគ្មានស្គាល់លោកធំណាម្នាក់ ក្នុងចំណោមលោកធំលើកបន្តុបនោះទេ មិនសូវសង្ឃឹមនឹងបានកន្លែងធ្វើការឡើយ។ ចំពោះអស់លោកដែលមានជំនាញការយួនការពារពីក្រោយ ទោះជាធ្វើអំពើច្រងេងច្រងាង គ្មានស្គាល់ច្បាប់មកលើប្រជាពលរដ្ឋខ្មែរក៏ដោយ គ្មានខ្មែរណាមានសិទ្ធ រឺហ៊ាននិយាយតវ៉ាទេ។ បើអ្នកណាមានយោបល់ក្នុងរឿងនេះ ពិតជាត្រូវបាត់ខ្លួនដោយចោទថា ខ្មែរក្រហម រឺជនមុខពីរ (ពាក្យចោទប្រកាន់ដែលរបបនេះប្រើដើម្បីយកទៅសំលាប់)។ អ្នកដែលត្រូវបានចោទបែបនេះ មិនសូវជានៅយូរប៉ុន្មានទេ គឺត្រូវព្រាត់ពីគ្រួសារភ្លាម។ ការបាត់ខ្លួននេះ អាចស្លាប់រឺជាប់គុក។

លោកធំដែលគ្មានដឹងខ្យល់អីនោះ ចេះតែឡើងធំជានិច្ចដូចឡើងកាំជណ្តើរតាមការលើកបន្តុប ធ្វើការគ្មានបានសាច់ការជូនខ្មែរ មានតែការបំផ្លាញខ្មែរថែម។ ចំពោះអ្នកមិនបំរើនយោបាយខ្លួនត្រូវដកចេញ(ដែលមានពាក្យក្នុងរបបនេះគេប្រើ គឺដកដូចកូនស្ពែ)ដូចជាលោក ប៉ែន សុវណ្ណ រហូតដល់ឆ្នាំ១៩៨២ជានាយករដ្ឋមន្ត្រីខ្មែរ។ បើតាមលឺថា លោកមានផែនការទប់



ស្កាត់ការហូរចូលដោយខុសច្បាប់នៃជនជាតិយួន មកក្នុងប្រទេសកម្ពុជា។ ម្យ៉ាងទៀត លោកមានផែនការធ្វើទំនាក់ទំនងផ្ទាល់ជាមួយបណ្តាប្រទេសដូចជា អតីតសហភាពសូវៀតជាដើម ដោយមិនបាច់ឆ្លងកាត់តាមរយៈរដ្ឋាភិបាលយួន រឺត្រូវទៅបង្ហាញខ្លួនជាមុនចំពោះមេដឹកនាំយួន។ បងប្រុសម្នាក់ស្គាល់លោក ប៉ែន សុវណ្ណ បានបញ្ជាក់ដូចខាងលើដែរ៖ ១- លោកបានបង្ហាញពីការមិនសប្បាយចិត្តរបស់គាត់ចំពោះយួន។ គាត់និយាយថា មេដឹកនាំយួនធ្វើអ្វីៗ ក្បត់និងពាក្យសន្យា។ ២- លោកបានជំទាស់និងផែនការកាប់ព្រៃរបស់មេដឹកនាំយួន(ផែនការ "ក៥")។ ៣- លោកចង់ធ្វើសេដ្ឋកិច្ចមួយដោយមិនថិតនៅក្រោមការត្រួតពិនិត្យរបស់មេដឹកនាំយួន។

ផែនការនេះប្រាកដជាត្រឹមត្រូវ យុត្តិធម៌ ក្នុងនាមជាម្ចាស់ប្រទេស តែវាពិតជាផ្ទុយនឹងគំនិតរបស់មេដឹកនាំក្រុងហាណូយ។ បន្ទាប់មកមេដឹកនាំយួនលើកបន្តុបលោក ចាន់ ស៊ី អោយកាន់ដំណែងជានាយករដ្ឋមន្ត្រីនោះម្តង។ មិនយូរប៉ុន្មានលោក ចាន់ ស៊ី ត្រូវបានស្លាប់មុនអាយុដោយអាថ៌កំបាំងទៅទៀតនៅឆ្នាំ១៩៨៤។ តាមលឺសូរថា លោក ចាន់ ស៊ី បានប្រឆាំងជំទាស់នឹងបញ្ហារបស់មេដឹកនាំក្រុងហាណូយជាច្រើន ដូចជា ផែនការ "ក៥" ដែលត្រូវអោយប្រជាពលរដ្ឋខ្មែរទៅកាប់បំផ្លាញព្រៃឈើរបស់ខ្មែរជាដើម។

ដោយឃើញស្លាកស្នាមជាច្រើនទៀត ដែលមានទំរង់ដូចខាងលើនេះ ខ្មែរដែលមានគំនិតចង់ការពារឧត្តមប្រយោជន៍ខ្មែរ និងមានគំនិតចង់ស្រង់ប្រទេសខ្លួនដែរនោះ ក៏លែងហ៊ានកំរើក ដេកឈឺចិត្តម្នាក់ឯង។ ឯអ្នកខ្លះទៀតសំងំសុខដើម្បីរស់នៅថ្ងៃស្អែក។ ចំពោះខ្មែរដែលគ្មានខួរក្បាលបំរើផលប្រយោជន៍អោយខ្មែរនោះ តែងសប្បាយលោតកញ្ឆេងនឹងអំណាចលើកបន្តុប ដូច មេខ្លាឃ្លោកដែលគេក្រឡុកក្នុងចាន។

# សាធារណរដ្ឋប្រជាមានិតុកម្ពុជា(១៩៨៥)

សមាសភាពអ្នកដឹកនាំខ្មែរថ្មី បន្ទាប់ពីមរណភាពរបស់លោក ចាន់ ស៊ី ដែលមេដឹកនាំក្រុងហាណូយបានជ្រើសរើស ចំរាញ់យ៉ាងត្រឹមត្រូវ បន្តុបឡើង សូមលើកយកតែពីរនាក់៖

១- លោក ហ៊ុន សែន មានអាយុ៣៤ឆ្នាំជារដ្ឋមន្ត្រីក្រសួងការបរទេស ត្រូវបន្តុបជានាយករដ្ឋមន្ត្រី។ លោក ហ៊ុន សែន មានតួនាទីតាំងពីខែ ឧសភា១៩៨១ ជាសមាជីកការិយាល័យនយោបាយនិងជាលេខាមជ្ឈឹម បក្សនៃបក្សប្រជាជនបដិវត្តកម្ពុជា (លោក ហ៊ុន សែន ជាអតីតកូនទាហាន លោក ប៉ុល ពត)។

២- អ្នកស្រី ម៉ែន សំអន មានអាយុ៣២ឆ្នាំដែលជាអតីតស្នងការ នយោបាយក្នុងកងទ័ពរបស់លោក ប៉ុល ពត ត្រូវបានបន្តុបជា៖

- សមាជិកការិយាល័យនយោបាយ ជួរ៧ "Rang 7"

- លេខាមជ្ឈឹមបក្ស ជួរ៤ "Rang 4"

- សមាជិកនៃគណកម្មការត្រួតពិនិត្យរបស់បក្សប្រជាជនបដិវត្ត កម្ពុជា ជួរ២ "Rang 2"

- នាយកផ្នែករៀបចំចាត់ចែងមជ្ឈឹមបក្ស

- នាយកផ្នែកអប់រំ និងឃោសនាមជ្ឈឹមបក្ស

នេះមិនខុសពីការលើកបន្តុបកូនក្មេងអោយឡើងគ្រងរាជ្យ គ្រាន់ជា រូបចំឡាក់បញ្ជាក់ថា ប្រទេសខ្មែរមានឈ្មោះមេដឹកនាំជាខ្មែរតែប៉ុណ្ណោះ។ ចុះយើងពិចារណាមើល អាយុប៉ុនហ្នឹង តើរៀនបានប៉ុន្មាន? ចេះអ្វីខ្លះ? ហើយកាន់កិច្ចការដ៏កំពូលរបស់ប្រទេសជាតិ តើសមរឺទេ?។ នេះគឺជាយុទ្ធ



វិធីដូចការដែលខ្លួនបានអនុវត្តកាលពីឆ្នាំ១៨៤០ លើកបន្តុបក្មេងអាយុ៨ឆ្នាំ អោយឡើងសោយរាជ្យ និងឆ្នាំ១៩៤១ មេដឹកនាំបារាំងលើកបន្តុបក្មេង អាយុ១៨ឆ្នាំអោយឡើងធ្វើជាស្តេចដែរ។

ក្រោយពីឆ្នាំ១៩៨៥ គឺពេលដែលក្រុមមេដឹកនាំយួនជ្រើសរើសចំរាញ់ មនុស្សរបស់ខ្លួនបានត្រឹមត្រូវហើយ នយោបាយដែលបានគ្រោងទុកនោះ ត្រូវបានអនុវត្តយ៉ាងរលូន។ អ្វីដែលធ្វើអោយប្រជាជនជួបក្តីវេទនាត់តក់ស្លុត ក្នុងការរស់នៅ គឺផែនការចាប់បង្ខំយុវជនអោយចូលបំរើកងទ័ព និងផែន ការ"ក៥" ដែលផែនការទាំងពីរនេះ ពុំមានការអនុគ្រោះឡើយ។ ផែនការ នេះអូសបន្លាយរហូតដល់ឆ្នាំ១៩៩៣ ទើបត្រូវបានបញ្ចប់។ ផែនការ"ក៥" គឺជានយោបាយកាប់បំផ្លាញព្រៃឈើខ្មែរ ដែលឥឡូវនេះក្លាយជាផែនការ យ៉ាងក្តៅចំពោះប្រជាពលរដ្ឋខ្មែរ។ ប្រជាពលរដ្ឋខ្មែរ មានកាតព្វកិច្ចទៅកាប់ ព្រៃឈើរបស់ខ្លួនចោល។ នេះគឺមេដឹកនាំយួនអនុវត្តនយោបាយ "អោយ ខ្មែរបំផ្លាញខ្មែរខ្លួនឯង"។ ការកាប់ព្រៃឈើនេះគឺយួនបានចំណេញយ៉ាង ខ្លាំង ព្រោះឈើល្អៗ មានតំលៃត្រូវដឹកទៅប្រទេសយួន។ ទី២ការកាប់ព្រៃ ឈើនេះ គឺធ្វើអោយអាកាសធាតុប្រចាំឆ្នាំប្រែប្រួល ដូចជា ការខ្វះទឹកភ្លៀង ជាដើម ដែលធ្វើអោយវិស័យកសិកម្មជួបការលំបាក។ មិនតែប៉ុណ្ណោះ មេ ដឹកនាំយួនបញ្ជាអោយខ្មែរកាប់ព្រៃឈើលិចទឹកជាកន្លែងត្រីពង និងជាជំរក ត្រីនៅតាមដងទន្លេ ក្នុងបំណងអោយត្រីខ្វះជំរកនៅ ក៏ចុះតាមដងទន្លេទៅ ក្រោម(ប្រទេសយួន)។ យើងគិតមើលគ្រាន់លទ្ធផលនៃការកាប់ព្រៃនេះ អាចអោយយើងសួរបានថា៖ តើពេលខាងមុខប្រទេសខ្មែរនឹងក្លាយទៅជា យ៉ាងណា?(នយោបាយសំរាប់ថ្ងៃស្អែករបស់មេដឹកនាំយួន)។

រដ្ឋាភិបាលខ្មែរគ្មានខួរជាខ្មែរ បានកេណ្ឌប្រជាពលរដ្ឋខ្មែរទូទាំងប្រ

ទេស អោយទៅកាប់ព្រៃឈើខ្មែរចោល តាមការបញ្ជារបស់មេដឹកនាំយួន ដោយមិនបើកភ្នែក គ្មានពិចារណា ជាដំណាក់ការដូចតទៅ៖

ដំណាក់ការទី១៖ ជ្រើសយកតែកំលាំងយុវជន និងបុរសទើបនឹងរៀបការមានកូនមួយរឺពីរ។ កំលាំងទាំងនេះត្រូវធ្វើការចាប់ឆ្នោត តើអ្នកណាត្រូវទៅមុខ រឺក្រោយ?។

ដំណាក់ការទី២៖ កំលាំងយុវជននិងបុរសកូនមួយ រឺពីរអស់ស្វាត់ពីភូមិ គេក៏ចាប់ផ្តើមយកកំលាំងបុរសទាំងអស់ដែលមានអាយុនៅក្រោម៥០ឆ្នាំ។ ហេតុនេះ ពីមួយឆ្នាំទៅមួយឆ្នាំនៅតាមភូមិនីមួយៗនៅសល់តែតាចាស់ៗជរាស្ទើរធ្វើការលែងកើត និងស្ត្រីមេម៉ាយ។ គេយកការកាប់ព្រៃឈើនេះគ្រាន់ធ្វើជាខែលដើម្បីបំភ័ន្តភ្នែកខ្មែរតែប៉ុណ្ណោះ ដែលការពិតមេដឹកនាំយួនធ្វើនយោបាយសំលាប់ខ្មែរ ដោយប្រើអ្នកដែលត្រូវសំលាប់នោះអោយទៅស្លាប់ខ្លួនឯង។ នេះគឺ "វិធីសំលាប់ប្រយោល" ហើយមេដឹកនាំយួនយល់ថា គេជាអ្នកសំលាប់គ្មានកំហុសអ្វីឡើយ។ ព្រៃទាំងនេះបានក្លាយជាចំការមីន និងគ្រាប់គ្រប់ធន់ដែលត្រូវបានកប់ក្នុងសម័យសង្គ្រាមដណ្តើមអំណាចគ្នា។ ទីពីរទៀត ទីនោះជាតំបន់គ្រុនចាញ់ និងទីបីជាតំបន់ប្រឈមមុខរវាងកងទ័ពទាំងពីរ។ ដោយកក្តាទាំងបីខាងលើនេះ អ្នកដែលត្រូវទៅកាប់ព្រៃឈើនេះពុំមានសង្ឃឹមនឹងបាននៅមានជីវិតត្រឡប់មកភូមិកំណើតវិញទេ។ តាមការពិតវាមែន គ្រួសារខ្លះមិនបានឃើញទាំងខ្មោចកូន រឺប្តីរបស់ខ្លួនផង។ ភាគតិចណាស់ដែលនៅមានជីវិតបានត្រឡប់មកផ្ទះវិញ តែពុំមានលក្ខណៈជាមនុស្សម្នានិងគេទេ ព្រោះខ្លះត្រូវបាត់ជើង បាត់ដៃ ខ្លះត្រូវរបួសពេញខ្លួនក្លាយជាជនពិការ និងខ្លះទៀតស្លេកស្លាំងស្គមគ្របដណ្តប់ ដោយជំងឺគ្រុនចាញ់ញាក់ទទ្រើកប្រចាំកាយ។ ឯគ្រួសារក្រ គ្មានប្រាក់ គ្មានថ្នាំព្យា



បាល រហូតដល់ស្លាប់ពេលក្រោយៗមកក៏មាន។ អ្នកដែលមានជីវិតត្រឡប់មកវិញ គ្មានវាសនានឹងប្រកបការងារអ្វីកើតដើម្បីចិញ្ចឹមជីវិតដែរដែលបន្ទុកនេះត្រូវធ្លាក់មកលើគ្រួសារដែលត្រូវរងទាំងស្រុង។ អ្នកដែលរងនោះគឺស្ត្រីតែម្តង។ តើអោយគ្រួសារនេះធ្វើយ៉ាងណា? បើគ្នាមានតែពីរនាក់ប្តីប្រពន្ធព្រមទាំងកូនតូចៗនៅឡើយ ឯប្តីក្លាយជាមនុស្សពិការ។

រដ្ឋាភិបាលលោក ហ៊ុន សែន គ្មានអើពើឈឺក្បាលនឹងទុក្ខវេទនារបស់ប្រជាពលរដ្ឋប្រភេទនេះទេ។ រដ្ឋាភិបាលដឹងតែប្រើ ត្រង់ប្រជាពលរដ្ឋឈឺ ស្លាប់ ដោយគ្មានថ្នាំព្យាបាលនោះ ពុំដឹងលឺឡើយ។ នេះហើយមេដឹកនាំលើកបន្តុបជំនាន់សតវត្សទី២០។ យ៉ាងហោចណាស់ក៏រដ្ឋាភិបាលត្រូវគិតថា ប្រទេសយើងជាប្រទេសកសិកម្មនៅអន់ថយនៅឡើយ ដែលអ្វីទាំងអស់នៅប្រើកំលាំងមនុស្សសុទ្ធសាធ។ តើស្ត្រីនិងតាចាស់ជរា អាចធ្វើស្រែចំការបានរឺទេ? បើមិនបាន តើសេដ្ឋកិច្ចជាតិ ធ្លាក់ដល់កំរិតណា?។ ម្យ៉ាងទៀតបើប្រទេសមួយគ្មានកំលាំងយុវជននិងបុរសនោះ តើវាសនានៃប្រទេសជាតិក្នុងពេលអនាគត នឹងក្លាយទៅជាយ៉ាងណា?។ នេះគឺជាគ្រោះថ្នាក់នឹងធ្លាក់ដល់ប្រទេសជាតិ ហើយក៏ជាគំនិតរបស់មេដឹកនាំយួនដើម្បីសំរេចនូវនយោបាយរបស់គេ ដែលខំព្យាយាមរាប់សតវត្សមកដែរ។

បងប្រុសជាអតីតពលករ "ផែនការ ក៥" ដែលត្រូវបានកេណ្ឌអោយទៅកាប់ព្រៃនៅតំបន់ប៉ៃលិន បានបញ្ជាក់ខាងក្រោម៖

អ្នកស្លាប់ដោយជាន់មីននោះភាគច្រើន (មីនដែលបង្កប់ដោយកងទ័ពយួន) រួមទាំងចម្រូងដែលការពារស្នាក់ការគេ(យួន) ហើយពេលរើចេញទៅគេ(យួន)មិនបានដោះចេញវិញទេ។ ពេលពលករ ឬសេនាជនខ្មែរទៅឈរជើងនៅទីនោះ ក៏ត្រូវជាន់មីនបណ្តាលអោយស្លាប់ផង និងរបួស គ្រប់វគ្គ

គ្រប់ជំនាន់។ មួយចំនួនទៀត ត្រូវរងការចោទប្រកាន់ថាជាខ្មាំងបង្កប់ នៅពេលសែងអ្នករបួស ឬអ្នកជម្ងឺកងទ័ពយួនពីសមរភូមិមុខមកក្រោយ ហើយត្រូវរអិល ឬជំពុបជើងដួលដោយអចេតនា។ វាសនាអ្នកសែងនោះភាគតិចណាស់ ដែលគេចផុតពីការធ្វើទារុណកម្មសម្លាប់។ មានមួយចំនួនត្រូវកាត់ទោសភ្លាមៗនៅសមរភូមិ តែមួយចំនួនទៀតត្រូវរាយការណ៍ មកអាជ្ញាធរខ្មែរមូលដ្ឋានខាងក្រោយ ធ្វើទណ្ឌកម្ម ក៏មិនស្ទើរដែរ។

ក្នុងរបបខ្ញុំចិននិយមរបស់លោក ប៉ុល ពត សំលាប់ខ្មែរដោយរូបភាពផ្ទាល់ ក្នុងរបបអាយ៉ងយួននិយមរបស់លោកហ៊ុន សែន សំលាប់ដោយស្ងាត់និងប្រយោល តើជីវិតពូជខ្មែរអាចនៅមានតទៅទៀតទេនាពេលអនាគត? បើចុះទឹកក្រពើ ឡើងលើខ្លាយ៉ាងនេះ។

យើងមើលកិច្ចការក្រៅប្រទេសរបស់របបលោក ហ៊ុន សែន។ ផ្នែកទំនាក់ទំនងជាមួយបរទេសក្រៅពីប្រទេសយួន ប្រទេសលាវ និងប្រទេសអតីតសង្គមនិយម របបលោក ហ៊ុន សែន គ្មានទំនាក់ទំនងការទូតជាមួយប្រទេសលើពិភពលោកទេ។ ប្រទេសជឿនលឿនលើពិភពលោក និងអង្គការសហប្រជាជាតិ មិនទទួលស្គាល់របប ហ៊ុន សែន ដោយផ្អែកលើមូលហេតុថា ជារដ្ឋាភិបាលអាយ៉ងរបស់មេដឹកនាំយួន។ អង្គការសហប្រជាជាតិបានបើកសម័យប្រជុំពេញអង្គរបស់ខ្លួន ដើម្បីពិភាក្សាអំពីតំណាងកម្ពុជានៅអង្គការសហប្រជាជាតិដែលនៅក្នុងទស្សនាវដ្តីអាល្លឺម៉ង់ Suedostasien aktuell Juli 1987 s.384 បានចុះផ្សាយដូចខាងក្រោម៖

លទ្ធផលនៃការបោះឆ្នោត ក្នុងប្រជុំពេញអង្គរបស់អង្គការសហប្រជាជាតិអំពីតំណាងរបស់កម្ពុជា នៅអង្គការសហប្រជាជាតិដោយកម្ពុជាប្រជាធិបតេយ្យ



| | ១៩៨០ | ១៩៨១ | ១៩៨២ |
|---|---|---|---|
| ចំនួនស្រប | ៧៤ | ៧៩ | ៩០ |
| ចំនួនប្រឆាំង | ៣៥ | ៣៦ | ២៩ |
| អនុបវាទ | ៣២ | ៣០ | ២៦ |
| គ្មានការចូលរួមបោះឆ្នោត | ១៣ | ១១ | ១២ |
| ចំនួនសមាជិកសរុបអសប | ១៥៤ | ១៥៦ | ១៥៧ |

និងអង្គការសហប្រជាជាតិ បានបើកប្រជុំពេញអង្គ ដើម្បីពិភាក្សាអំពីការដកកងទ័ពបរទេសទាំងអស់ចេញពីកម្ពុជាដែលនៅក្នុងទស្សនាវដ្តីអាល្លឺម៉ង់ Suedostasien aktuell Juli 1987 s.384 បានចុះផ្សាយដូចខាងក្រោម៖

លទ្ធផលនៃការបោះឆ្នោត ក្នុងប្រជុំពេញអង្គរបស់អង្គការសហប្រជាជាតិអំពីការដកកងទ័ពបរទេសទាំងអស់(កងទ័ពយួន) ចេញពីកម្ពុជា

| | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ | ១៩៨៥ | ១៩៨៦ |
|---|---|---|---|---|---|---|
| ចំនួនស្រប | ១០០ | ១០៥ | ១០៥ | ១១០ | ១១៤ | ១១៥ |
| ចំនួនប្រឆាំង | ២៥ | ២៣ | ២៣ | ២២ | ២១ | ២១ |
| អនុបវាត | ១៩ | ២០ | ១៩ | ១៨ | ១៦ | ១៣ |
| គ្មានការចូលរួមបោះឆ្នោត | ១២ | ៩ | ១១ | ៩ | ៨ | ១០ |
| ចំនួនសមាជិកសរុបអសប | ១៥៦ | ១៥៧ | ១៥៨ | ១៥៩ | ១៥៩ | ១៥៩ |

ដោយយោងតាមលទ្ធផលនៃសន្លឹកឆ្នោតខាងលើ គឺមានប្រទេសជាច្រើន មិនគាំទ្ររដ្ឋាភិបាល ហ៊ុន សែន ដូចនេះបានជា៖

១- រដ្ឋាភិបាល ហ៊ុន សែន គ្មានកៅអីនៅអង្គការសហប្រជាជាតិ

២- អង្គការសហប្រជាជាតិបានផ្តាច់ទំនាក់ទំនង ដូចជាៈ

- គ្រប់ទំនាក់ទំនងរវាងអង្គការសហប្រជាជាតិ ជាមួយនឹងរដ្ឋាភិបាល ហ៊ុន សែន
- សន្ធិសញ្ញាអន្តរជាតិ និងពត៌មានសំរាប់កិច្ចសហប្រតិបត្តិការ លើផ្នែកវប្បធម៌ និងបច្ចេកទេស
- សន្ធិសញ្ញាអំពីទូរស័ព្ទសំរាប់ការទាក់ទងក្រៅប្រទេស គមនាគមន៍ និងប្រៃសនីយ៍ ផ្លូវអាកាស ផ្លូវទឹក
- ការជួយដោយអង្គការសហប្រជាជាតិ
- ការជួយផ្ទាល់របស់បណ្តាប្រទេសជឿនលឿនខាងលិច

នេះហើយដែលហៅថា លោកធំខ្មែរ ដឹកនាំប្រទេស តាំងពីគេស្គាល់ខ្មែរ រហូតដល់ពិភពលោកគេឈប់ចង់រាប់អានខ្មែរ ហើយនៅតែតាំងខ្លួនជាអ្នកខ្លាំងពូកែទៀត ឱ!លោកធំ។ ទោះបីជាសហគមអន្តរជាតិមានប្រតិកម្មយ៉ាងនេះក្តី ក៏រដ្ឋាភិបាល ហ៊ុន សែន មិនខ្វីអើពើចូលរួមដោះស្រាយវិបត្តិនេះតាមនយោបាយ ហើយបែរជាខំប្រឹងតែខាងផ្នែកការពារអំណាចច្រើនជាងផ្នែកកសាងប្រទេស។ ទស្សនាវដ្តីអាល្លឺម៉ង់ឈ្មោះ Suedostasien aktuell November 1989 s.548 បានសរសេរថាៈ ប្រហែល៦០ភាគរយនៃប្រាក់ចំណូលជាតិ ត្រូវចំណាយទៅលើការទិញគ្រឿងសព្វាវុធ។ ប្រហែល២០ភាគរយចំណាយទៅលើអ្នកបំរើការរដ្ឋ វិស័យអប់រំ និងបុគ្គលិក។ បន្ទាប់ពីក្រុមបណ្តាប្រទេសសង្គមនិយមនៅអឺរ៉ុប ត្រូវបាក់បែក និងដួលរលំ ធ្វើអោយជំនួយមកពីប្រទេសទាំងនេះត្រូវដាច់ បណ្តាលអោយកង្វះថវិកាកាន់តែខ្លាំង។ ប្រាក់ចំណូលតិចជាងប្រាក់ចំណាយ បណ្តាលអោយទំនិញឡើង



ថ្លៃ។ ឯរដ្ឋាភិបាលខ្វះប្រាក់ដើម្បីទិញសព្វាវុធ ត្រូវការបោះពុម្ពបន្ថែម ដែលធ្វើអោយតំលៃប្រាក់រៀលធ្លាក់ចុះ៥៥០ភាគរយ "Suedostasien aktuell Juli 1991 s. 381"។

កំឡុងឆ្នាំ១៩៩០ ប្រជាពលរដ្ឋទូទាំងប្រទេសធ្វើស្រែ មិនបានគ្រប់គ្រាន់ដោយភ្លៀងធ្លាក់មិនទៀងទាត់និងដីស្រែខ្វះជីជាតិ។ ភាពអាសន្ននៃការអត់ឃ្លាន ត្រូវបានរីកខ្លាំងឡើង ព្រមជាមួយនេះ បញ្ហាត្រូវការដឹវី "Devisen"សំរាប់ទិញប្រេងឥន្ធនៈដើម្បីបំរើតំរូវការរបស់កងទ័ព។ ប្រជាពលរដ្ឋប្រហែលចំនួន១៨០០០០ បានបោះបង់ភូមិកំណើតរបស់ខ្លួនមកទីក្រុងភ្នំពេញ"Suedostasien aktuell Juli 1991 s. 381 "។ ថ្វីបើធាតុពិតប្រជាពលរដ្ឋអត់បាយ អត់ដំបូលជ្រកដ៏អនោចអធម្ម ក៏រដ្ឋាភិបាល ហ៊ុន សែន បានអះអាងថា ផលិតផលស្រូវបានច្រើន ទោះជាទូទៅទទួលបានផលតិចក៏ដោយ។ រដ្ឋាភិបាល ហ៊ុន សែន ខំបំប៉ោងបរិមាណ គ្មានគុណភាពរបៀបនេះ គឺក្នុងគោលបំណងបង្អួតថា ខ្លួនជាមេដឹកនាំខ្លាំង ហើយដើម្បីទប់ស្កាត់ជំនួយរបស់អង្គការសហប្រជាជាតិ និងពួកបរទេសទៀតផង។ នេះគឺជានយោបាយបង្អត់ប្រជាពលរដ្ឋឯងរបស់លោក ហ៊ុន សែន អោយតែកិត្យានុភាពនៃរបបងងឹតងងល់ខ្មៅកខ្វក់របស់ខ្លួននៅរស់ និងជាពិសេសដើម្បីផ្គាប់ផ្គុនបំពេញគោលបំណងរបស់មេដឹកនាំយួន ដោយមិនគិតពីការស្លាប់នៃប្រជាពលរដ្ឋខ្មែរ។ កំឡុងឆ្នាំ១៩៨៤-៨៥ អ្នកយកពត៌មានយួន វ៉េអ៊ិនអា បានផ្សាយថា ២លានតោន ថ្វីបើទិន្នផលក្នុងប្រទេសខ្មែរបានប្រហែល១,១លានតោន តាមការប៉ាន់ស្មានរបស់អ្នកឯកទេសខាងលិច "Suedostasien aktuell Maerz 1986 S. 159"។

ប្រជាពលរដ្ឋនៅតាមជនបទស្រុកភូមិ មានការលំបាកពីមួយថ្ងៃទៅ

មួយថ្ងៃ ធ្វើស្រែបានផលមិនគ្រប់គ្រាន់ដោយគ្រោះធម្មជាតិ ដូចជា ភ្លៀងធ្លាក់មិនទៀងទាត់ តែជួនមានទឹកក្នុងស្រែបរិបូរ តែគ្មានកំលាំងធ្វើដោយកូនប្រុស រឺប្ដីរបស់ខ្លួន ត្រូវរដ្ឋាភិបាល ហ៊ុន សែន កេណ្ឌយកទៅធ្វើទ័ព និងទៅអោយកាប់ព្រៃផែនការ"ក៥"។ ទីពីរទៀត ជីវភាពរបស់ខ្លួនរស់នៅដាច់ដោយឡែកពីរដ្ឋាភិបាល។ រដ្ឋាភិបាល ហ៊ុន សែន មិនដែលយកចិត្តទុកដាក់ដោះស្រាយជីវភាព និងគ្មានឈឺក្បាលនឹងទុរគតភាពរបស់ប្រជាពលរដ្ឋម្ដងណាឡើយ ដូចជា ការខ្វះខាតសព្វគ្រប់បែបយ៉ាងតាំងពីមធ្យោបាយផលិតកម្ម និងផ្នែកសុខភាពឡើង។

នៅក្នុងទីក្រុងភ្នំពេញ រីកស្គុះស្គាយលាយនិងភាពច្របូកច្របល់ទៅដោយចោរកម្ម និងភាពតោកយ៉ាក។ នៅទីផ្សារពោរពេញទៅដោយរបស់របរ និងទំនិញគ្រប់ប្រភេទទំនើបៗនាំចូលមកពីបរទេស។ នេះគឺទំរង់សេដ្ឋកិច្ចថ្មីដែលលោកធំខ្មែរ បានរកឃើញឈ្មោះថា យើងធ្វើរោងចក្រអត់ផ្សែងបានចំណេញច្រើន។ ចំណេញមែន លោកធំមួយៗ បានឡើងកាន់អំណាចតាំងពីបាតដៃទទេ តែប៉ុន្មានឆ្នាំប៉ុណ្ណោះ ស្រាប់តែក្លាយជាមហាអ្នកមានយ៉ាងល្បី ឯប្រទេសនៅក្រល្ហាម។ កាសែតអាល្លឺម៉ង់ឈ្មោះFrankfurter Allgameine Zeitung 9 Juli 1993 បានចុះផ្សាយថា ការប្លន់យកសម្បត្តិកម្ពុជាត្រូវបានចូលរួមដោយថៅកែមកពីសឹង្ហបូរី តៃវ៉ាន់ សៀម និងកូរ៉េខាងត្បូង។ ដៃគូដែលពួកនេះចូលចិត្តរកស៊ីជាមួយគឺអ្នករដ្ឋការខ្ពស់ៗ និងរដ្ឋមន្ត្រីនៃរដ្ឋាភិបាលហ៊ុន សែន នៅភ្នំពេញ។ រដ្ឋមន្ត្រីនៃរដ្ឋាភិបាលហ៊ុន សែន មិនត្រឹមតែលក់សម្បត្តិធម្មជាតិទេ គឺលក់តាំងពីសំណង់របស់រដ្ឋ ក្រសួងមន្ទីរ រួចយកលុយដាក់ក្នុងហោប៉ៅរបស់ខ្លួន។ កាសែតនោះបានសរសេរបន្តទៀត គ្រួសាររបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន និងប្រធានគណបក្សប្រ



ជាជនកម្ពុជា លោក ជា ស៊ីម ក្លាយជាមហាមហាសេដ្ឋីដុល្លា(Die Familie des Ministerpresidenten Hun Sen und Chefs der Kambodschanischen Volkspatei, Chea Sim, sollen mehrfache Dollarmillionaere sein)។ ចោរប្លន់គ្រប់ទីកន្លែង រថយន្តធ្វើដំណើរត្រូវបានប្លន់ អ្នកដំណើរត្រូវបានសំលាប់។ ចំណែកនៅភោជនីដ្ឋានមានម៉ាស៊ីនត្រជាក់ ពួកអស់លោកធំអង្គុយស្រស់ស្រូបយ៉ាងរំភើយ គ្មានយកភ្នែក និងសន្ដានចិត្តទុកដាក់ដល់កសិករឈរនៅពីមុខហាងសុំទាន។ នៅតាមផ្លូវសាធារណៈ ក្បែរផ្សារ ក្បែរលំនៅដ្ឋានពោរពេញទៅដោយភាពមួយរយក្រខ្វក់ និងគំនរសំរាម។ ក្មេងទុរគតគ្មានអាហារ ដើរសុំទាន ដើររើសតាមធុងសំរាមនៅតាមទីផ្សារ។ ពេលល្ងាច លោកធំស្លៀកពាក់ហ៊ឺហារ ដើរស៊ីផឹកតាមកន្លែងរាំរែក "បារ"។ ពួកទាហានពិការខ្លះបាត់ដៃ ខ្លះបាត់ជើង ខ្លះទៀតដងខ្លួនសុះទៅដោយគ្រាប់អំបែងឈរនៅតាមមាត់ទ្វារចូល និងបង្ហាញលោកធំដែលដើរចូល។ ពេលពាក់កណ្ដាលយប់ ចរាចរត្រូវបិទ តែលោកធំនៅដើរស៊ីផឹកតាមហាងរហូតដល់ស្រវឹង ខ្លះទាញកាំភ្លើងបាញ់គ្នា គ្មានស្គាល់ច្បាប់ គ្មានសុជីវធម៌ជាមនុស្សទេ លោកធំលើកបន្ទុបក្នុងរបប ហ៊ុន សែន។ លុយអាចទិញក្បាលលោកធំទាំងនេះបាន និងអំពើស្មោគរោកគ្រប់ប្រភេទ។ លិខិតឆ្លងដែនមួយតំលៃ២០០ទៅ៥០០ដុល្លាអាមេរិក និងដើម្បីអាចចូលទៅសិក្សានៅមហាវិទ្យាល័យវេជ្ជសាស្ត្របាន លុះត្រាយកលុយទៅអោយអស់លោកធំចំនួន២ម៉ឺនដុល្លាអាមេរិក (Der Spiegel 15\1991)។

ឆ្នាំ១៩៨៩ រដ្ឋាភិបាល ហ៊ុន សែន បានលប់បំបាត់សេដ្ឋកិច្ចសង្គមនិយមនិងអនុញ្ញាតអោយមានម្ចាស់កម្មសិទ្ធទៅលើដីធ្លី។ អស់លោកធំមានខ្នងតែងប្រើអំណាចដើរដណ្ដើមដី ផ្ទះសំបែងពីប្រជាពលរដ្ឋធម្មតា ដែល

បានចូលមកបោសសំអាតនៅក្រោយថ្ងៃ៧មករា១៩៧៩ មកធ្វើជាកម្មសិទ្ធផ្ទាល់ខ្លួន។ កាសែតអាល្លឺម៉ង់ឈ្មោះFrankfurter Allgameine Zeitung 9 Juli 1993 បានសរសេរថា Ein General namem Hang Sithi hat die Huetten einfacher Leute in Phnom Pehn einreissen lassen, weil er das Gruendstuek an theilandischen Interresenten vermitteln wollten។ ប្រែថា "លោកឧត្តមសេនីយ ហាង ស៊ីធី បានកំទេចផ្ទះប្រជាពលរដ្ឋធម្មតានៅភ្នំពេញចោល ពីព្រោះគាត់ចង់ជួលដីនោះទៅអោយឈ្មួញសៀម"។ ប្រទេសទាំងមូលគ្មានផលិតអ្វីទាំងអស់ របស់របរប្រើប្រាស់ក្នុងស្រុក ត្រូវបាននាំចូលពីប្រទេសសៀម។ រដ្ឋាភិបាលរបស់លោក ហ៊ុន សែន បានបញ្ចូលសេដ្ឋកិច្ចសេរីដោយគ្មានប្រព័ន្ធពន្ធដារ និងភាពចាំបាច់នៃទំរង់សេដ្ឋកិច្ចច្បាស់លាស់។ ដោយការធ្វើបែបនេះ បណ្តាលអោយឈ្មួញគ្រប់គ្រងសេដ្ឋកិច្ចរដ្ឋបានទាំងមូល ដែលជាហេតុធ្វើអោយរដ្ឋាភិបាលបាត់បង់អធិបតេយ្យភាពរបស់ខ្លួន។ ក្នុងពេលដែលពួកឈ្មួញធ្វើអ្វីបានតាមអំពើចិត្ត ដូចជា ក្នុងការតំឡើងតំលៃទំនិញ បណ្តាលអោយពលរដ្ឋពិបាករស់នៅ ក៏តាំងបាត់ការទុកចិត្តទៅលើរដ្ឋាភិបាល ហើយដែលជាមូលហេតុធ្វើអោយមានភាពអាណាធិបតេយ្យក្នុងសង្គម។ នៅក្រុងភ្នំពេញ គ្រួសារមួយមានកូនពីរនាក់ត្រូវការប្រាក់ សំរាប់ជីវភាពជាមធ្យមប្រហែល៥ម៉ឺនរៀល(៧៦ដុល្លាអាមេរិក)ក្នុងមួយខែ។ ទន្ទឹមនឹងនេះ អ្នកធ្វើការក្នុងក្រសួងមន្ទីរបានទទួលប្រាក់ខែតែ៥ពាន់រៀលប៉ុណ្ណោះ។ បុគ្គលិកម្នាក់ៗដើម្បីរស់របស់គ្រួសារខ្លួនត្រូវការជំនួយពីខាងក្រៅ ដែលភក្តីភាពខ្លួនចំពោះរដ្ឋាភិបាល ត្រូវបានបែងចែក។ បុគ្គលិកធ្វើការបំរើរដ្ឋ១០ភាគរយនិង៩០ភាគរយសំរាប់ឈ្មួញថៅកែរឺក្រុមហ៊ុនដែលចិញ្ចឹមខ្លួន។ រដ្ឋាភិបាលខ្វះសមត្ថភាព នាំអោយបុគ្គលិក



មន្ត្រីរដ្ឋការនិងទាហានគ្មានសណ្តាប់ធ្នាប់។ បញ្ហានេះ គេអាចមើលឃើញច្បាស់ បើសិនជាគេធ្វើដំណើរទៅកាន់ខេត្តនានា។ ទាហាន យាមសន្តិសុខតាមផ្លូវ តាមស្ពាន តែងហៅរថយន្តតូចធំដឹកអ្នកដំណើរឈប់ដើម្បីសុំលុយសុំបារី។ ពេលអោយមិនពេញចិត្តតាមការចង់បានរបស់ខ្លួន សំឡុតរករឿងយកកាំភ្លើងផ្ទុងទាំងកំរោល ជួនកាលទៀតមិនទាំងសុំផង គឺប្លន់យកតែម្តង។ មូលហេតុបណ្តាលអោយក្រុមទាហាន ប៉ូលីសធ្វើយ៉ាងនេះ ដោយសារតែរដ្ឋាភិបាល ហ៊ុន សែន មិនយកចិត្តទុកដាក់ជួយផ្គត់ផ្គង់អោយមានជីវភាពគ្រប់គ្រាន់។ ចំណែកលោកធំនៅភ្នំពេញយកសម្បត្តិជាតិដែលនៅសេសសល់ពីរបបមុនៗមក ដូចជា ត្បូងពេជ្រ មាស ប្រាក់ ធ្វើជារបស់ជ័យភ័ណ្ឌ(លោកធំខ្មែរក្នុងរបប ហ៊ុន សែន ហៅថា សម្បត្តិជ័យភ័ណ្ឌបដិវត្តិ) ទៅចែកគ្នាតាមថ្នាក់តាមជាន់។ បងប្រុសម្នាក់បានបញ្ចេញអោយដឹងថា លោក ប៉ែន សុវណ្ណ បានប្រាប់គាត់ កាលដែលគាត់(ប៉ែន សុវណ្ណ)នៅជាអគ្គលេខាមជ្ឈឹមបក្ស(១៩៧៩-១៩៨២) មានមាសប្រហែល១២តោន និងលុយដុល្លាយ៉ាងច្រើនដែលទុកជាសម្បត្តិជាតិនៅក្នុងបន្ទប់គាត់(ប៉ែន សុវណ្ណ)ធ្វើការ។ ក្រោយមក ប្រហែលក្នុងឆ្នាំ១៩៨៩ (JIM 1) ក្រុមលោក ហ៊ុន សែន លោក ជា ស៊ីម លោក សាយ ភូថង និងលោក ហេង សំរិន យកទៅចែកគ្នាអស់។

## យួនូបនីយកម្ម(១៩៧៩)

ក្រុមមេដឹកនាំយួនតែងអនុវត្តវិធីសាស្ត្រគ្រប់បែបគ្រប់យ៉ាង និងគ្រប់សម័យកាលដើម្បីលេបត្របាក់យកទឹកដីខ្មែរ។ ត្រង់នេះ ត្រឡប់មកបង្ហាញពីនយោបាយរបស់មេដឹកនាំយួនចាប់ពីឆ្នាំ១៩៧៩ ក្នុងការធ្វើយួនូបនីយកម្ម ដែលទស្សនាវដ្តីភាសាអាល្លឺម៉ង់ឈ្មោះSuedostasien aktuell ចេញផ្សាយខែវិច្ឆិកាឆ្នាំ១៩៨៩នៅទំព័រ៥១៩។ អ្នកនិពន្ធសំរាប់ទស្សនាវដ្តីនេះបានធ្វើការតាមដាន និងសិក្សាអំពីរបៀបចាត់ចែងជាប្រព័ន្ធរបស់មេដឹកនាំយួនក្នុងប្រទេសកម្ពុជា រួចបានបោះពុម្ពផ្សាយ ដោយដាក់ចំណងជើងជាភាសាអាល្លឺម៉ង់ដូចខាងក្រោម៖

Die Vietnamisierung-These

Nach pessimistischer Einschaetzung verfolgt Vietnam mit seiner Vietnamisierung von Kambodscha ein neues Kolonialismusmodell, das vor allem auf drei Ebene greifte namlich durch:

1- Vietnamisierung des Machtapparats

2- Vietnamisierung des Wirtschaftsystems

3- Vietnamisierung des Bevolkerungsstruktur

យួនូបនីយកម្ម-អំណះអំណាង

បន្ទាប់ពីវាយតំលៃដោយទុទិដ្ឋិនិយម យួនបានសម្រេចយួនូបនីយកម្មមកលើប្រទេសកម្ពុជាតាមទំរង់ថ្មីនៃអាណានិគមដែលជាពិសេស បានចូលកាន់កាប់ចាត់ចែងរៀបរចនាសម្ព័ន្ធសង្គមជាមូលដ្ឋានសំខាន់៣ដូចជា៖

១- យួនូបនីយកម្មនៃឧបករណ៍អំណាច



២- យួនូបនីយកម្មនៃប្រព័ន្ធសេដ្ឋកិច្ច

៣- យួនូបនីយកម្មនៃទំរង់ប្រជាពលរដ្ឋ

១- យួនូបនីយកម្មនៃឧបករណ៍អំណាច

បន្ទាប់ពីការវាយលុកចូលមកកម្ពុជាឆ្នាំ១៩៧៩ មេដឹកនាំយួនបានបង្កើតជាបន្ទាន់នូវរដ្ឋាភិបាលជាអាយ៉ងមួយ និងមានទាហានយួនប្រហែល១៧០០០០ទៅ១៨០០០០នាក់ក្នុងប្រទេសកម្ពុជា"Suedostasien aktuell Mai 1986 s.285"។ មេដឹកនាំយួនបានទទួលជ័យជំនះក្នុងការដាក់នឹមអាណានិគមមកលើកម្ពុជាតាមរយៈការធ្វើជាបង្កើតអ្នកជំនាញការយួន ដែលតាមពិតគឺអ្នកត្រួតពិនិត្យ។ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៨២មក មេដឹកនាំយួនបានដំឡើងយុទ្ធសាស្ត្រតាមភូមិថែមទៀត គឺក្នុងភូមិខ្មែរនីមួយៗ មានលោកជំនាញការយួនរហូតដល់៦នាក់ដែលគ្មានទីតាំងពិតប្រាកដ។ លោកជំនាញការយួនដឹកនាំនៅគ្រប់ស្ថាប័នរដ្ឋបាលជុំវិញរដ្ឋាភិបាលខ្មែរ។ រយៈពេលខ្លីបន្ទាប់ពីការចូលមកក្នុងប្រទេសកម្ពុជា មេដឹកនាំយួនបានបង្កើតគណៈកម្មាធិការការងារមួយនៅទីក្រុងភ្នំពេញ ដើម្បីសំរបសំរួលសកម្មភាពឈ្លានពានកម្ពុជា។ នៅក្នុងស្ថាប័ននៃគណៈកម្មាធិការខ្លះ អង្គុយដោយអ្នកជំនាញការយួនដែលត្រួវពិនិត្យផ្ទាល់នូវរបប ហ៊ុន សែន តាំងពីការងារមជ្ឈឹមរហូតដល់ភូមិឃុំ និងក្តាប់យ៉ាងជាប់។ មេដឹកនាំយួនជាអ្នកជ្រើសរើសអ្នកដែលត្រូវធ្វើការក្នុងរដ្ឋាភិបាលខ្មែរ ដូចជា ក្នុងការលើកអោយកាន់អំណាច និងទំលាក់ចេញពីដំណែង។ ខ្មែរណាធ្វើសកម្មភាពនៅក្រោមការសង្ស័យ រឺបង្ហាញនូវមនោសញ្ចេតនាស្រលាញ់ជាតិខ្មែរ ចង់ធ្វើការបំរើខ្មែរអោយរីកចំរើន ត្រូវបានដេញចេញជាបន្ទាន់ពីការងាររបស់ខ្លួន។ ខ្លះទៀតរហូតចាប់ដាក់គុក បើពុំដូចនេះទេ ត្រូវយកទៅអប់រំនៅសាលាបក្ស។

សកម្មភាពនយោបាយ និងយោធានៃលោកជំនាញការយួន គឺគេធ្វើទៅតាមការរៀបចំផ្ទាល់ខ្លួន។ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៨៩ មានមូលដ្ឋានទ័ពយួនធំនៅខេត្តសៀមរាប។ តាមធម្មតា គ្រប់កងវរៈសេនាតូចខ្មែរមានលោកជំនាញការយួនទាំងផ្នែកនយោបាយ និងយោធានៅជាមួយ។ លោកជំនាញការយួនធ្វើការនៅក្នុងគ្រប់កងឯកភាពខ្មែរ និងជាអ្នកធ្វើផែនការចុះយុទ្ធនាការ។

ទន្ទឹមនឹងអំពើខាងលើនេះ មេដឹកនាំយួនបានប្រមូលកូនកំព្រាខ្មែរចំនួនប្រហែល២០០០០០នាក់យកទៅអប់រំ។ ពួកក្មេងកំព្រាទាំងនេះ ទទួលនូវកម្មវិធីអប់រំនៅស្រុកយួនរាងរាល់៦ខែម្តង។

ផ្នែកការទូតះ គ្រប់ស្ថានទូតខ្មែរទាំងអស់ ថិតនៅក្រោមការត្រួតពិនិត្យរបស់ស្ថានទូតយួនដែលមានទីតាំងនៅទីនោះជាមួយគ្នា។ អ្នកធ្វើការខ្មែរក្នុងស្ថានទូតខ្មែរ និងគ្រប់សំបុត្រចេញចូល ត្រូវបានលោកជំនាញការយួនពិនិត្យមើលទាំងអស់។ នៅក្នុងក្រសួងការបរទេសខ្មែរ ជាទៀងទាត់មានវត្តមានលោកជំនាញការយួនពី២០ទៅ៤០នាក់ ដែលជាអ្នកលុកលុយទៅលើកិច្ចការខ្មែរ។ ក្នុងពេលជាមួយគ្នានេះ ជនជាតិយួនចូលមកតាំងទីលំនៅពាសពេញកម្ពុជា ជាពិសេស ក្នុងខេត្តសៀមរាប កំពង់ធំ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង និងកំពង់ចាម។ ពួកយួនស៊ីវិលទាំងនេះ ត្រូវបានមេដឹកនាំយួនរៀបចំជាក្រុម ឃុំ ស្រុក សង្កាត់ និងក្រុងរួចជាស្រេច។

២- យួនូបនីយកម្មនៃប្រព័ន្ធសេដ្ឋកិច្ច

ក្នុងខែកុម្ភៈ១៩៨៤ មេដឹកនាំយួនបានធ្វើសន្និសិទ្ធមួយនៃប្រទេសទាំងបី។ អ្វីដែលសន្និសិទ្ធនោះបានសំរេចគឺការប្តូរមិនស្មើគ្នា ដោយបង្កើតលក្ខខណ្ឌជំនួញជាផលប្រយោជន៍ដល់យួន″Ausgestaltung der Terms



of Trade zugunsten Vietnams″ ដូចជា ការដឹកនាំផលិតផលត្រី ស្រូវចេញពីកម្ពុជាទៅស្រុកយួនជាដើម។ ម្យ៉ាងទៀតតាំងពីឆ្នាំ១៩៨៣ មេដឹកនាំយួនបានបង្កើតខេត្តដៃគូរវាងខេត្តខ្មែរនិងខេត្តយួន។ រវាងខេត្តដៃគូនេះ ក៏មានការប្តូរមិនស្មើគ្នាដែរ។ នេះមិនមែនជាការចៃដន្យទេ ដែលមេដឹកនាំយួនបានរៀបចំយកខេត្តបាត់ដំបង ដែលជាខេត្តសំបូររបស់ខ្មែរទៅធ្វើជាខេត្តដៃគូនឹងខេត្តយួន Quang Nam ដែលជាខេត្តមានពលរដ្ឋដ៏ច្រើនលើសលប់នោះ។ ជារៀងរាល់ឆ្នាំ ស្រូវជាច្រើនត្រូវដឹកចេញពីខេត្តបាត់ដំបង ឆ្ពោះទៅខេត្តជាដៃគូ Quang Nam ហើយដឹកចេញពីខេត្តជាដៃគូមកវិញ គឺកង់និងស៊ីម៉ង់។ ខេត្តសៀមរាប ផ្គត់ផ្គង់ខេត្តជាដៃគូ Binh Tri Thien នូវគ្រាប់ពូជស្រូវ ពោត គ្រាប់ឈូកនិងបន្លែ។ ក្រុងភ្នំពេញ ត្រូវមេដឹកនាំយួនភ្ជាប់ធ្វើជាដៃគូនឹងក្រុង Ho-Chi-Minh ″ក្រុងព្រៃនគរ″។ ខេត្តកំពង់ចាម ត្រូវមេដឹកនាំយួនភ្ជាប់ធ្វើជាដៃគូនឹង Tay Ninh។ កំពុងសោម ត្រូវមេដឹកនាំយួនភ្ជាប់ធ្វើជាដៃគូនឹង Ha Tien។

មេដឹកនាំយួនរៀបចំរបៀបនេះ ដើម្បីអោយថ្នាក់ខេត្ត-ក្រុងយួនតាមដានរាល់សកម្មភាព និងកិច្ចការអនុវត្តប្រចាំថ្ងៃរបស់ថ្នាក់ខេត្ត-ក្រុងខ្មែរដោយផ្ទាល់ ឯថ្នាក់ជាតិយួនដែលមានទំរង់ជាលោកជំនាញការ ត្រួតពិនិត្យនិងដឹកនាំកិច្ចការទូទៅរបស់ខ្មែរតាំងពីថ្នាក់ជាតិខ្មែររហូតដល់ថ្នាក់ភូមិខ្មែរ។

៣- យួនូបនីយកម្មនៃទំរង់ប្រជាពលរដ្ឋ

ទំរង់ទី៣នៃយួនូបនីយកម្ម គឺការមកវាតតាំងទីលំនៅ។ រវាងឆ្នាំ១៩៧៩ និង១៩៨៩ មានជនជាតិយួនប្រហែល១,២៥លាន(Millionen)មកតាំងទីលំនៅក្នុងប្រទេសកម្ពុជា។ មានតែជនជាតិយួនមកពីទីក្រុងហាណូយទេ ដែលជាភ្នាក់ងារពិសេសរបស់រដ្ឋាភិបាលយួននៃការបែងចែក

លេខ៧៧០៤ (Spezialagenten der Division Nr.7704)។ បញ្ហានេះ យើងជាខ្មែរមិនបានដឹងអ្វីទាំងអស់ ។ ជនជាតិយួនដែលមកតាំងលំនៅនេះ មានលទ្ធភាពរស់ ធ្វើដំណើរ និងប្រកបរបរជាងជនជាតិខ្មែរ។ ជនជាតិយួនទាំងនេះមិនថិតនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាលខ្មែរទេ និងពិសេស អត់ត្រូវបង់ពន្ធ និងគ្មានជាប់កំណែនទាហានឡើយ។ បច្ចុប្បន្ន ជនជាតិយួនទាំងនេះ មានការប្រជុំក្នុងមួយអាទិត្យម្តងក្នុងការជួបគ្នាជាសំងាត់យ៉ាងទៀងទាត់។ ប្រព័ន្ធនៃការមកវាតទីតាំងលំនៅនៃជនជាតិយួននេះ ត្រូវបានដឹកនាំដោយមេដឹកនាំក្រុងហាណូយផ្ទាល់ ដែលជាផ្នែកមួយនៃដំណើរវិវឌ្ឍន៍យួនូបនីយកម្ម។ ក្នុងពេលជាមួយនឹងយួនូបនីយកម្មនេះ មេដឹកនាំយួនបានកំចាត់ប្រព័ន្ធស្នេហាជាតិខ្មែរជាបណ្តើរៗ។

ក្នុងទីក្រុងភ្នំពេញ និងតំបន់ខាងកើតនៃប្រទេសមានជនជាតិយួន៦០ភាគរយនៃប្រជាពលរដ្ឋខ្មែរ។ ពួកយួនដែលមកតាំងទីលំនៅនេះ មិនត្រឹមតែក្នុងទីក្រុងទេ ជាពិសេសមានការរីកដុសដាលរហូតដល់ជនបទចុងកាត់មាត់ញកទៀតផង ព្រមទាំងធ្វើការជាមួយពួកកងទ័ពយួនជាសំងាត់យ៉ាងជិតស្និទ្ធ(Suedostasien aktuell Mai 1986 s.285)។ ប្រជាពលរដ្ឋខ្មែររាប់ពាន់នាក់ត្រូវបានបាត់បង់ជំរក ដីធ្លី អាជីវកម្ម និងកន្លែងនេសាទរបស់ខ្លួនដោយសារជនជាតិយួនដែលចូលមកនោះដណ្តើមយក។

ទន្ទឹមនឹងកន្សោមធំទាំង៣ខាងលើ ដែលក្នុងទស្សនាវដ្តីអាល្លឺម៉ង់បានចុះផ្សាយនោះ នៅមានចំណាត់ការ៥ផ្សេងទៀតដែលយួនបញ្ជាតាមរយៈរដ្ឋាភិបាលខ្មែរគឺ៖

- ការដឹកជញ្ជូនយកទ្រព្យសម្បត្តិខ្មែរ

បន្ទាប់ពីបានចូលលុកលុយក្នុងប្រទេសខ្មែរ មេដឹកនាំយួនបានឃុប



ឃឹតជាមួយក្រុមអាយ៉ងរបស់ខ្លួន ដើម្បីលួចដឹកយកទ្រព្យសម្បត្តិខ្មែរទាំងប៉ុន្មានដែលរបប ប៉ុល ពត បានប្រមូលដាក់ក្នុងឃ្លាំងទៅស្រុកយួនអស់។

- ការកំទេចធនធានធម្មជាតិខ្មែរ

មេដឹកនាំយួន បានបញ្ជារដ្ឋាភិបាលខ្មែរអោយកេណ្ឌប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសទៅកាប់ព្រៃឈើខ្មែរដែលគេហៅថាផែនការ"ក៥"។ ផែនការ"ក៥" គឺជានយោបាយសំលាប់ខ្មែរដោយអោយអ្នកដែលត្រូវសំលាប់នោះទៅស្លាប់ខ្លួនឯង ព្រោះព្រៃទាំងនេះបានក្លាយជាចំការមីន គ្រាប់គ្រប់ធន់ តំបន់គ្រុនចាញ់ និងតំបន់ប្រឈមមុខរវាងកងទ័ពផង។ គ្រាន់តែតាមរយៈផែនការ"ក៥"នេះ ធ្វើអោយប្រជាពលរដ្ឋខ្មែរស្លាប់និងរបួសរាប់ម៉ឺននាក់។ ម៉្យាងទៀត ផែនការ"ក៥" ក៏បានបំផ្លាញបរិដ្ឋាន ធ្វើអោយអាកាសធាតុប្រែប្រួល និងភ្លៀងធ្លាក់មិនទៀងទាត់ និងដើម្បីប្រមូលយកឈើល្អៗនិងមានតំលៃដឹកទៅស្រុកយួនផង។ មេដឹកនាំយួនបញ្ជាអោយកាប់ទាំងព្រៃលិចទឹកដែលជាជំរកត្រី និងជាកន្លែងត្រីពងនារដូវទឹកឡើង។ គេធ្វើយ៉ាងនេះដើម្បីអោយត្រីខ្វះជំរក ក៏ចុះតាមដងទន្លេទៅក្រោម(ស្រុកយួន)។

- ការបំបាក់ស្មារតី

ដើម្បីកុំអោយខ្មែរនៅមានគំនិត ស្មារតីការពារផលប្រយោជន៍ខ្មែរ គេបង្កើតពាក្យជាលេសដើម្បីចោទប្រកាន់ថា"ជនមុខពីរ រឺខ្មែរក្រហម"។ បើគេចង់សំលាប់ខ្មែរណា គ្រាន់តែចោទយ៉ាងនេះជាការស្រេច។

- ការបំបាត់ប្រវត្តិសាស្ត្រខ្មែរ

ក្រោយថ្ងៃ៧មករា៧៩ ខ្មែរបានរស់ក៏ពិតមែន តែបានរស់តែសំបកខ្លួន ចំណែកព្រលឹងខ្មែរ មេដឹកនាំយួនមិនអនុញ្ញាតអោយរស់មកជាមួយទេ ហើយថែមទាំងព្យាយាមរំលាយប្រលឹងខ្មែរតាមរូបភាពផ្សេងៗ។ មេដឹកនាំ

យួនមិនអោយកូនខ្មែររៀនអំពីប្រវត្តិសាស្ត្រខ្មែរ និងបង្ខំអោយកូនខ្មែររៀនភាសាយួនក្នុងសាលា។ ទីពីរទៀត ពេលចូលមកដល់ប្រទេសខ្មែរភ្លាម យួនបានដើរទិញក្រដាសគ្រប់ប្រភេទទាំងអស់ពីស្រុកខ្មែរ។ ខ្មែរយើងទើបងើបពីអត់ស្រាប់ផង តែងដើរប្រមែប្រមូលក្រដាសនៅតាមសាលា សារមន្ទីរគ្រប់ច្រកល្ហក ដើម្បីលក់យកលុយទិញអង្ករនៅប្រទេសយួនទទួលទាន។ ក្រដាសខ្លះ សុទ្ធតែឯកសារសំខាន់ៗ ដែលជាព្រលឹងខ្មែរ ខ្លះទៀតសុទ្ធតែជាប់ទាក់ទងទៅនឹងបញ្ហាប្រទេសជាតិ និងជាអាយុជីវិតខ្មែរផ្ទាល់ ដែលជាកេរ្តិ៍មរតកដ៏មានតំលៃរបស់វីរជនខ្មែរកាលពីជំនាន់ដើម ហើយដែលនៅពេលនេះ យើងទាំងអស់គ្នាជាខ្មែរកំពុងព្រួតដៃគ្នាកំទេចដោយមិនដឹងខ្លួន។ ក្នុងរបបលោក ប៉ុល ពត បានបំផ្លាញចោលអស់មួយចំនួនធំ ឯនៅសេសសល់បន្តិចបន្តួចត្រូវយួនប្រមូលទិញអស់ តើខ្មែរនៅសល់អ្វីទៀតក្រៅពីសំបកខ្លួន?។ នេះគឺជាល្បិចមេដឹកនាំយួនក្នុងការចង់បំបាត់ភស្តុតាងនៃប្រវត្តិជីវិតពូជខ្មែរ។ យើងជាខ្មែរត្រូវតែមានសតិសម្បជញ្ញៈ គិតគូរពីបញ្ហានេះចាប់ពីពេលនេះទៅ កុំគិតអោយតែបានរស់ថ្ងៃនេះ មិនគិតថ្ងៃស្អែកនោះ។

- បន្តសង្គ្រាមសំលាប់ខ្មែរ

មេដឹកនាំយួនតែងប្រើល្បិចញុះញង់ និងឧបត្ថម្ភក្រុមលោក ហ៊ុន សែន អោយធ្វើសង្គ្រាមប្រឆាំងនិងខ្មែរក្នុងស្រុកខ្មែរ ព្រោះថាសង្គ្រាមជាប្រភពនៃការបាត់បង់ជីវិតនិងទុក្ខវេទនា។ កាលបើសង្គ្រាមក្នុងប្រទេសខ្មែរនៅតែបន្ត នោះជីវិតខ្មែរចេះតែហោច និងជីវភាពខ្មែរកាន់តែយ៉ាប់យ៉ឺនដែលអាចធ្វើអោយខ្មែរធុញទ្រាន់និងខ្មែរ ឈប់ចង់រំដោះខ្លួនមករស់ជាខ្មែរ និងព្រមទទួលយកយួនដោយសុទ្ធចិត្ត ធ្វើជាអាណាព្យាបាលស្របតាមបំណងមេដឹកនាំយួន។



## ខ្មែរជាអ្នកបង្កើតលក្ខខណ្ឌអោយបរទេសឈ្លានពាន

ប្រទេសដែលមានមហិច្ឆតាឈ្លានពានយកទឹកដីខ្មែរ បានខំព្យាយាមសិក្សារកចំណុចខ្សោយរបស់ខ្មែរជាច្រើនសតវត្សមកហើយ។ គេបានរកឃើញថា៖

- ខ្មែរចង់ធ្វើតែលោកធំដោយឥតចេះអៀនខ្មាស់ ទោះបីលោកធំលើកបន្តុបក៏ដោយ

- ខ្មែរច្រើនតែសប្បាយភ្លេចខ្លួន

ចំណុចខ្សោយទាំងនេះគឺជាលក្ខខណ្ឌ ដែលពួកបរទេសប្រើដើម្បីចូលមកឈ្លានពានយកទឹកដីខ្មែរបាន តាំងពីសតវត្សទី១៣មករហូតដល់សព្វថ្ងៃនេះ។ ការបាត់បង់ទឹកដីនេះបានធ្វើអោយខ្មែរមានការឈឺចាប់ខ្លោចផ្សារ ហើយចោទប្រកាន់ប្រទេសយួន និងសៀម បានប្លន់យកពីខ្មែរទៅវិញ។ នេះជាការត្រឹមត្រូវ ព្រោះទឹកដីខ្មែរសព្វថ្ងៃដែលបាត់ទៅនោះគឺថិតក្នុងកណ្តាប់ដៃនៃប្រទេសទាំងពីរ ដែលបានប្លន់យកមែន។ ប៉ុន្តែខ្មែរមិនបានសួរខ្លួនឯងថា៖ តើនៅពេលណាខ្មែរបាត់បង់ទឹកដី? ប្រទេសខ្មែរត្រូវបរទេសជ្រៀតជ្រែកចូលមកតាមរបៀបណា? តើបរទេសប្លន់យកដោយវិធីណា?។ បើយើងនឹកគិតដល់សំណួរទាំងនេះ ទើបយើងជាខ្មែរប្រកបដោយវិចារណញ្ញាណ ត្រូវខ្មាស់ពួកបរទេស។

នេះគឺធម្មតាក្នុងធម្មជាតិទាំងមនុស្សទាំងសត្វ។ គ្រួសារនីមួយៗ តែងចង់អោយគ្រួសាររបស់ខ្លួនរស់នៅខ្ពង់ខ្ពស់ជាងមួយទៀត ទោះតាមវិធីណាក៏ដោយ។ បើគ្រួសារណាមួយផ្តល់នូវលក្ខខណ្ឌ ដែលអាចអោយគ្រួសារមួយទៀតប្រើប្រាស់ ដើម្បីបំពេញមហិច្ឆតារបស់គេបាន នោះគ្រួសារនោះ

ប្រាកដជាមិនទុកអោយពេលវេលាកន្លងផុតទៅឡើយ។ តែទោះជាយ៉ាងណា ក៏មនុស្សក្នុងលោកនេះមានសតិសម្បជញ្ញៈ ចេះខ្មាស់អៀន និងនឹកគិតដល់កិត្តិយស។ តែមានមនុស្សខ្លះ ដោយលោភលន់ខ្លាំងពេក សុខចិត្តបោះបង់សីលធម៌ និងភាពថ្លៃថ្នូរ ហើយរងចាំតែឱកាសនិងលក្ខខណ្ឌ រឺចេះតែរកល្បិចខូចគ្រប់បែបយ៉ាង ដើម្បីបំពានទៅលើអ្នកដ៏ទៃ។ បើសិនជាមានមនុស្សបែបនេះរស់នៅទីណា រឺកន្លែងណា អ្នកដែលនៅក្បែរនោះ មិនត្រូវធ្វេសប្រហែសវិនាទីណាឡើយ។ ឯបញ្ហាខ្មែរយើងក៏ដូចនេះដែរ គឺខ្មែរយើងទេដែលជាអ្នកផ្តល់នូវលក្ខខណ្ឌនេះអោយយួន និងសៀមដែលអាចអោយប្រទេសទាំងពីរនេះ ប្រើដើម្បីរំលោភឈ្លានពានកាត់យកទឹកដីយើងបាន។ មើលចុះខ្មែរ ជាពិសេសប៉ុន្មានទសវត្សរ៍ថ្មីៗនេះ គ្រាន់តែបរទេសលើកបន្តុបអោយធ្វើជាលោកធំ ហើយញុះញុងអោយសំលាប់ខ្មែរគ្នាឯង ក៏សំលាប់ដោយមិនរើសមុខ។ អោយតែបានធ្វើលោកធំហើយ គាត់គិតតែសប្បាយនិងអំណាច ស្រី និងទ្រព្យសម្បត្តិ ទោះជាបរទេសកាត់យកទឹកដីក៏មិនខ្វីរវល់ ក៏មិនខ្វីធ្វើដឹង ធ្វើឃើញ។

ដូចនេះ បើយើងមិនចង់អោយគេសំរេចទិសដៅក្នុងការរំលោភឈ្លានពានកាត់យកទឹកដីខ្មែរបានតទៅទៀត គឺយើងទាំងអស់គ្នាជាខ្មែរត្រូវតែខិតខំព្យាយាមឈប់បង្កើតលក្ខខណ្ឌនោះ ធ្វើម៉េចបើមហាគ្រួសារខ្មែរយើងមានវាសនា ត្រូវមកថិតនៅក្បែរ គ្រួសារពីរប្រេកបដោយមហិច្ឆតាឥតខ្មាស់យ៉ាងនេះ។



# មូលហេតុនៃសង្គ្រាម

ដូចជនរួមជាតិបានដឹងស្រាប់ថា ប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ សង្គ្រាមរវាងខ្មែរនិងខ្មែរបានធ្វើអោយប្រទេសជាតិយើងធ្លាក់ក្នុងអន្លង់ទុរ្ភិក្សដ៏សែនជ្រៅរហូតដល់បច្ចុប្បន្ន។ កាលបើយើងសួររកមូលហេតុនៃសង្គ្រាមនេះឡើង ទើបយើងមើលឃើញថា៖ តើលោកធំខ្មែរមានឧត្តមគតិជាតិ សតិសម្បជញ្ញៈ មនសិការជាតិ និងសមត្ថភាពក្នុងការដឹកនាំប្រទេសរឺទេ?។ បើមានសមត្ថភាព ចុះហេតុអ្វីបានជាមិនដឹងខ្លួនថា បរទេសយកខ្លួនធ្វើជាកូនអុកដើម្បីដោះស្រាយភាពទ័លច្រកនិងដើម្បីបំរើមហិច្ឆតារបស់គេ ហើយគេប្រើខ្លួនអោយបំផ្លាញខ្មែរឯង ញុះញង់អោយខ្លួនឈ្លោះគ្នា។ បើមានឧត្តមគតិជាតិពិតប្រាកដ ចុះហេតុអ្វីបានជាដឹកនាំប្រជាពលរដ្ឋខ្មែរ ធ្វើសង្គ្រាមសំលាប់ខ្មែរគ្នាឯង កំទេចសម្បត្តិវប្បធម៌ខ្មែរស្ទើរសាបសូន្យយ៉ាងនេះ តាំងពីសម្បត្តិវប្បធម៌ផលិតកម្ម រហូតសម្បត្តិវប្បធម៌ធម្មជាតិ គ្មានគិតពីការកសាងជាតិ។ សតិសម្បជញ្ញៈថិតនៅត្រង់ណា បើមានៈ តណ្ហា ហឹង្សាអញនិយម គ្មានខ្មាស់ធម្មជាតិបន្តិចសោះជាតិជាមនុស្ស។ មនសិការជាតិយ៉ាងម៉េច បើគ្មានគិតប្រយោជន៍ជាតិជាធំបន្តិចសោះ។ ចំណែកឯ អស់លោកដឹកនាំប្រទេសតាំងពីខ្លួនក្រ រហូតដល់ខ្លួនក្លាយជាមហាសេដ្ឋីដុល្លា។

នេះមិនមែនមានន័យថា៖ ជនជាតិខ្មែរទាំងអស់សុទ្ធតែដូចក្នុងករណីខាងលើនោះទេ។ មានមនុស្សខ្មែរច្រើនណាស់ដែលមានសមត្ថភាពប្រកបដោយលក្ខណៈសម្បត្តិថ្លៃថ្នូរ សីលធម៌ ដែលស័ក្តិសមជាអ្នកនយោបាយអាចដឹកនាំប្រទេសជាតិបានរីកចំរើនរុងរឿងនិងជាទីសង្ឃឹមរបស់ប្រជាពលរដ្ឋខ្មែរ។ តែខ្មែរទាំងនេះ ពុំដែលមានឱកាសបានបំរើជាតិមាតុភូមិអោយ

បានពេញលេញទេនិងច្រើនតែវិនាសអន្តរធានដោយសារក្រុមលើកបន្តុប។ ម្យ៉ាងទៀត ប្រជាពលរដ្ឋខ្មែរពុំដែលមានសំណាងដើម្បីជ្រើសរើសចំរាញ់មេដឹកនាំខ្លួនដោយខ្លួនឯងផ្ទាល់ដែរ គឺពួកបរទេសផ្គូរផ្គងចៃចូរជ្រើសរើសចំរាញ់បន្តុបមកពីនាយហើយជាស្រេច រួចបង្ខំអោយប្រជាពលរដ្ឋខ្មែរព្រមទទួលយកអ្នកដែលគេលើកបន្តុបនោះជាមេដឹកនាំរបស់ខ្លួន។

*សូមខ្មែរចងចាំថា៖ ពួកបរទេសនឹងលើកបន្តុបមនុស្សខ្មែរដែលប្រកបដោយសមត្ថភាព ឧត្តមគតិជាតិ មនសិការជាតិនិងសតិសម្បជញ្ញៈអោយសោះ។ វាទាល់តែអ្នកនោះគ្មានលក្ខណៈទាំងនេះ ទើបបានគេលើកបន្តុប។*

សង្គ្រាមក្នុងប្រទេសខ្មែរដ៏រាំរ៉ៃ ដែលបានកើតឡើងនាប៉ុន្មានទសវត្សរ៍ចុងក្រោយនេះដោយសារ៖

១- ជំលោះរវាងខ្មែរនិងខ្មែរ

ជំលោះនេះ លេចចេញមកពីបុគ្គលល្មោភអំណាច បុគ្គលទំនាស់និងបុគ្គល មនោគមវិជ្ជា និងពួកបរទេសញុះញង់អោយខ្មែរឈ្លោះគ្នា។ យើងបានឃើញក្នុងទំព័រមុនៗពីព្រឹត្តិការណ៍មួយទៅមួយ តើពេលណាសង្គ្រាមកើតឡើងដោយសារអ្វីនោះ?។ សង្គ្រាមនេះបានបណ្តាលអោយខ្មែរបែកបាក់គ្នា លែងទុកចិត្តគ្នាកាន់តែខ្លាំងដែលក្លាយជាលក្ខខណ្ឌសំខាន់បំផុតនិងជាកត្តាធ្វើអោយពួកបរទេសរឹតតែមានឱកាសដណ្តើមគ្នា ទន្ទ្រានចូលក្នុងប្រទេសខ្មែរ និងពួកបរទេសឈ្លោះគ្នាដោយសារចង់ត្រួតត្រាលើខ្មែរ។

២- ជំលោះរវាងរដ្ឋក្នុងតំបន់អាស៊ីអាគ្នេយ៍

ជំលោះនេះកើតឡើងដោយសារប្រទេសសៀម និងយួនបានអនុវត្តនយោបាយពង្រីកទឹកដី គឺប្រទេសទាំងពីរនេះមានមហិច្ឆតាយកប្រទេសខ្មែរមកកាន់កាប់ដូចគ្នា។



៣- ប្រទេសចិននិងយួនឈ្លោះគ្នាដោយសារដណ្តើមគ្នាត្រួតខ្មែរ

មេដឹកនាំក្រុងប៉េកាំងមិនសប្បាយចិត្តទេ ពេលដែលមេដឹកនាំក្រុងហាណូយលាតត្រដាងមហិទ្ធិរិទ្ធរបស់ខ្លួននៅកម្ពុជា។ ក្នុងពេលដែលយួនខាងជើងកំពុងតស៊ូប្រឆាំងនិងសហរដ្ឋអាមេរិក ក្រុមមេដឹកនាំចិនបានជួយឧបត្ថម្ភទាំងគ្រឿងសព្វាវុធនិងស្បៀងដល់ប្រទេសយួន ដោយសារតែក្រុងប៉េកាំងមានគំនិតបំបាត់ឥទ្ធិពលសហរដ្ឋអាមេរិក ដើម្បីខ្លួនក្លាយជាអធិរាជនៅតំបន់នេះ។ តែបន្ទាប់ពីជ័យជំនះទៅលើសហរដ្ឋអាមេរិកឆ្នាំ១៩៧៥មកមេដឹកនាំយួនបានងាកទៅរកមហាអំណាចថ្មី គឺសហភាពសូវៀត រួចប្រទេសទាំងពីរចាប់ផ្តើមមានទំនាក់ទំនងនិងគ្នាកាន់តែស្និទ្ធ។ មូលហេតុដែលមេដឹកនាំយួនបែរទៅរកសហភាពសូវៀត ដោយសារតែអ្នកនយោបាយយួនមានឧត្តមគតិ សតិសម្បជញ្ញៈ និងសមត្ថភាពពិតប្រាកដ បានដឹង និងស្គាល់យ៉ាងច្បាស់អំពីផ្នត់គំនិតរបស់មេដឹកនាំចិនដែរ។ ម្យ៉ាងទៀតមេដឹកនាំយួនមានទិសដៅច្បាស់លាស់ និងយល់ច្បាស់ណាស់អំពីប្រវត្តិសាស្រ្តរវាងប្រទេសយួន និងចិន ព្រោះប្រទេសយួនធ្លាប់ចិតនៅក្រោមការត្រួតត្រាដ៏ជូរចត់របស់អធិរាជចិន អស់ដប់មួយសតវត្សមកហើយ (ហ៊ុន ស៊ីថាន នរណាជាឃាតករ ទំព័រ១៨៨)។ សូមបើកវង់ក្រចកត្រង់នេះបន្តិចដោយចង់បញ្ជាក់ពីកិច្ចសហប្រតិបត្តិរវាងប្រទេសយួន និងសហភាពសូវៀត។ បន្ទាប់ពីការឈ្នះរបស់យួនកុំមុយនីស្តចុងខែមេសា១៩៧៥ មេដឹកនាំសូវៀតបានប្រកាសជួយ ចំពោះការកសាងប្រទេសយួនច្រើនជាងចិន។ រវាងខែសីហានិងធ្នូ១៩៧៥ មានសន្និសញ្ញាជាច្រើនអំពីការជួយខាងផ្នែកសេដ្ឋកិច្ចរបស់សូវៀតសំរាប់ប្រទេសយួន។ សេចក្តីសំរេចរបស់មេដឹកនាំយួនឆ្នាំ១៩៧៧ក្នុងការអនុវត្តកំលាំងទ័ពដើម្បីគ្រប់គ្រងតំបន់នេះ បានធ្វើអោយការវិវឌ្ឍន៍

នៃចំណងមិត្តភាពរវាងសហភាពសូវៀត និងយួនចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៧មក កើនឡើងកាន់តែខ្ពស់ ត្បិតសូវៀតបានត្រៀមខ្លួនជាស្រេច ដើម្បីគាំទ្រដល់នយោបាយអនុត្តរភាពរបស់មេដឹកនាំយួនប្រឆាំងកម្ពុជានិងលាវ។ នៅថ្ងៃទី៣វិច្ឆិកា១៩៧៨ មានការចុះសន្ធិសញ្ញាអំពីមិត្តភាពនិងសហប្រតិបត្តិការរវាងសូវៀតនិងយួនសំរាប់រយៈពេល២៥ឆ្នាំ។ ក្នុងសន្ធិសញ្ញានោះបានទទួលយកនូវការវាយលុករបស់ប្រទេសយួន ចូលក្នុងប្រទេសកម្ពុជា និងតាមគំនិតយួនគឺលើកពួកកុំមុយនីស្តកម្ពុជាអោយកាន់អំណាច។ នៅថ្ងៃទី២៥ធ្នូ១៩៧៨ គឺបន្ទាប់ពីសន្ធិសញ្ញានេះ កងទ័ពយួនបានបើកការលុកលុយកម្ពុជា និងផ្តួលរំលំរបបខ្ញុំចិននិយមរបស់លោក ប៉ុល ពត ហើយថ្ងៃទី៨មករា១៩៧៩ បានបង្កើតរដ្ឋាភិបាលក្រោមចំណុះខ្លួននៅភ្នំពេញ។ បើសិនជាគ្មានសន្តិសុខនៅពីក្រោយខ្នង ដោយសារតែជំនួយដ៏ក្រាសទាំងខាងនយោបាយនិងសម្ភារៈរបស់សូវៀត គឺមេដឹកនាំយួនមិនហ៊ានសម្រេចចិត្តលុកលុយ និងកាន់កាប់កម្ពុជាឡើយ។

ឯក្រុងប៉េកាំងប្រហែលជាក្តៅច្រមុះ បានផ្តាច់ជំនួយឈប់បញ្ជូនទៅអោយក្រុងហាណូយ។ នៅក្នុងសៀវភៅរបស់លោក Michael Sontheimer ត្រង់ទំព័រទី១០២បានសរសេរថា " បន្ទាប់ពីមេដឹកនាំចិនជួយរំដោះយួនអស់រយៈពេលជាច្រើនឆ្នាំដែលចំណាយទឹកប្រាក់អស់ប្រហែល២០ Milliarden US-Dollarមក មេដឹកនាំចិនបានពោលថា យួនគឺជាឆ្កែមិនស្គាល់គុណនិងមានបេះដូងខ្មៅ"។ ក្នុងពេលជាមួយគ្នានោះ ក្រុងប៉េកាំងចាប់ផ្តើមជំរុញនិងឧបត្ថម្ភដល់កងទ័ពកម្ពុជា ក្នុងគោលបំណងប្រើប្រាស់ទឹកដីកម្ពុជាជាមូលដ្ឋាន ដើម្បីបំបែកបំបាក់យួនទាំងពីរ (យួនខាងត្បូងនិងយួនខាងជើង) និងបំបាត់អនុភាពក្រុងហាណូយនៅតំបន់នេះ។ យើងសង្កេតឃើញថា ចាប់



ពីពេលនោះមក ក្រុងប៉េកាំងតែងរកគ្រប់មធ្យោបាយដើម្បីបង្កើតជំលោះបន្តទៅទៀតរវាងរដ្ឋក្នុងតំបន់។

៤- កម្ពុជាជាឈ្នាន់សំរាប់ដោះស្រាយជំលោះរវាងសៀម យួននិងចិន

ប្រទេសសៀមចូលជាសមាជិកនៃប្រទេសអាស៊ាននៅឆ្នាំ១៩៦៧ ក្នុងបំណងទប់ស្កាត់ប្រទេសសៀមកុំអោយប្រទេសសង្គមនិយមទាំងពីរទន្ទ្រានចូល(ប្រទេសចិននិងប្រទេសយួន)។ នៅពេលដែលដឹងថា៖ មេដឹកនាំយួននឹងដកកងទ័ពខ្លួនចេញពីប្រទេសកម្ពុជា មេដឹកនាំសៀមបានខិតខំសំរួចពួកខ្មែរដែលតស៊ូប្រឆាំងនិងវត្តមាននៃកងទ័ពយួនក្នុងប្រទេសកម្ពុជា នៅតាមព្រំប្រទល់ខ្មែរ-សៀមកាន់តែខ្លាំង។ មូលហេតុដែលមេដឹកនាំសៀមប្រកាន់យកឥរិយាបថបែបនេះ គឺមេដឹកនាំសៀមចង់យកវិបត្តិខ្មែរធ្វើជាកូនសោរ ដើម្បីឈានទៅដោះស្រាយទំនាក់ទំនងនយោបាយរបស់ខ្លួនជាមួយនឹងប្រទេសចិន និងយួន។ ក្នុងពេលដែលអន្តរជាតិកំពុងសំរួលអោយវិបត្តិកម្ពុជាត្រូវបានដោះស្រាយជាវិជ្ជមាន មេដឹកនាំសៀមបានទប់ស្កាត់ចលនានេះដោយទុកប្រទេសខ្លួនអោយក្រុងប៉េកាំងប្រើប្រាស់ ក្នុងការជួយឧបត្ថម្ភដល់ក្រុមលោក ប៉ុល ពត ដែលកំពុងតស៊ូនៅតាមព្រំដែន ហើយមេដឹកនាំសៀមបានប្រយុទ្ធខាងផ្លូវនយោបាយយ៉ាងសកម្ម ដើម្បីបង្កើតទំនាក់ទំនងជាមួយចិន និងដើម្បីរកភាពស្របគ្នាអោយកាន់តែល្អជាមួយយួនដែលមានសេចក្តីបញ្ជាក់ ដូចជា នៅក្នុងទស្សនាវដ្តីអាល្លឺម៉ង់ Suedostasien aktuell ខែមិនា១៩៨៩នៅលើទំព័រ១៥៦ បានសរសេរនៅក្រោមចំណងជើងថា៖ " ទស្សនកិច្ចរបស់រដ្ឋមន្ត្រីក្រសួងការបរទេសសៀមនៅយួន" គន្លឹះកើតឡើងគឺដំណើរទស្សនកិច្ចរបស់លោក SIDDHI Savetsilas នៅទីក្រុងហាណូយ។ លោកបានជួបពិភាក្សាជាមួយលោក NGUYEN Cothach នៅថ្ងៃទី១០-១១

មករា។ លោកទាំងពីរបានយល់ស្របគ្នាថា ទ័ពយួនត្រូវតែបញ្ចប់ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជា។ លោក TACHបានលើកជាសញ្ញាមិត្តភាពនូវនយោបាយនៃនាយករដ្ឋមន្ត្រីសៀម CHATICHAI CHOONHAVANS (Ministerpresidenten)។ ទស្សនាវដ្ដីនេះបានសរសេរនៅក្រោមចំណងជើងមួយទៀត "ការសំរួលរវាងប្រទេសសៀមនិងចិន"។ នៅថ្ងៃទី១០-១១កុម្ភៈ ១៩៨៩ លោករដ្ឋមន្ត្រីក្រសួងការបរទេសសៀម SIDDHI SAVETSILAS បានទៅទស្សនកិច្ចនៅប្រទេសចិន និងបានពិភាក្សាជាមួយលោក QIAN QICHEN អំពីដំណោះស្រាយវិបត្តិកម្ពុជា។ ទាំងពីរខាងនេះ បានបង្ហាញដោយសេចក្ដីសង្ឃឹមទុកចិត្តថា មេដឹកនាំយួននឹងរក្សាការសន្យារបស់គេ គឺនឹងដកទ័ពចេញពីប្រទេសកម្ពុជារហូតដល់ចុងខែកញ្ញា។ នៅថ្ងៃទី២៤-២៥ មករា លោករដ្ឋមន្ត្រីក្រសួងការពារជាតិចិន QIN JIWEI បានទៅសួរសុខទុក្ខស្ដេចសៀម និងបានពិភាក្សាអំពីវិបត្តិកម្ពុជា។

៥- ជីវិតខ្មែរជាយុទ្ធសាស្ត្ររបស់អាមេរិក អតីតសហភាពសូវៀត និងចិន

នៅឆ្នាំ១៩៥០-១៩៦០ សហរដ្ឋអាមេរិកបានរៀបចំតំបន់នេះដើម្បីទប់ស្កាត់ការរីកដុះដាលរបស់ពួកកុំមុយនីស្ត។ ចំណែកសូវៀតបានចាប់ផ្ដើមរៀបចំកងទ័ពរបស់ខ្លួននៅកំឡុងឆ្នាំ៦០ ដើម្បីលូកដៃ និងពង្រីកលទ្ធិសង្គមនិយមខ្លួនក្នុងតំបន់នេះដែរ។ ម្យ៉ាងទៀតជំលោះរវាងមហាអំណាចកុំមុយនីស្តទាំងពីរ (សូវៀត និងចិន) តាំងពីឆ្នាំ១៩៦០រហូតជិតដល់ក្បែរសង្គ្រាមបរិមាណូ ដោយសារតែមនោគមវិជ្ជាផ្សេងគ្នា (Ideologische Ebene auf allem anderer Eben)។ ដើម្បីសំរួលការប្រឈមមុខដ៏តានតឹងនេះ មេដឹកនាំក្រុងប៉េកាំង បានទាញយកបញ្ហាកម្ពុជា មកធ្វើជាខែលសំរាប់ធ្វើការពិភាក្សាជាមួយមេដឹកនាំក្រុងម៉ូស្គូ។ ក្នុងរឿងនេះ មេដឹកនាំក្រុងប៉េកាំងបាន



លើកឡើងពីការដកទ័ពយួនចេញពីប្រទេសកម្ពុជា គឺជាលក្ខខណ្ឌពិសេសចាំបាច់បំផុតសំរាប់មេដឹកនាំក្រុងម៉ូស្គូ ដែលចង់ធ្វើអោយមានទំនាក់ទំនងជាធម្មតាឡើងវិញ។

ចំណែកសហរដ្ឋអាមេរិកដែលប្រឈមមុខ និងប៉េកាំងពីមុន ដូចបានលើកពីខាងលើមកហើយថា៖ មេដឹកនាំក្រុងប៉េកាំងមានទិសដៅបំបាត់វត្តមានរបស់អាមេរិកនៅតំបន់នេះ។ ដូចនេះ បានជាមេដឹកនាំក្រុងប៉េកាំងជាអ្នកជួយឧបត្ថម្ភទាំងស្បៀងនិងគ្រឿងអាវុធដល់ប្រទេសយួនក្នុងការប្រឆាំងនិងអាមេរិក។ ឯសហរដ្ឋអាមេរិកខំបញ្ជូនកងទ័ពមកយួនខាងត្បូងដើម្បីតទល់នឹងមហិច្ឆតារបស់ប្រទេសចិន។ នៅខែកុម្ភៈ១៩៦៨ លោកប្រធានាធិបតី NIXON បានប្រកាសថា៖ បេសកកម្មរបស់អាមេរិកនៅប្រទេសយួនគឺជាផ្នុក មិនអោយឥទ្ធិពលចិនរីកដុសដាលនៅអាស៊ី (William Shawcross S.89)។ តែពេលនេះចំពោះការដកកងទ័ពយួនចេញពីប្រទេសកម្ពុជាបានធ្វើអោយសហរដ្ឋអាមេរិកពេញចិត្តជាខ្លាំង ដោយសារការដកទ័ពនេះ គឺជាការបង្រួញកិត្យានុភាពរបស់មេដឹកនាំក្រុងហាណូយ ក៏ដូចជាក្រុងម៉ូស្គូក្នុងតំបន់នេះ និងការគ្រោះថ្នាក់ដល់បណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ដែលជារណបប្រទេសលោកខាងលិច ត្រូវបន្ថយ។ ម្យ៉ាងទៀតយើងដឹងហើយថា៖ ក្នុងខណ:នេះ មហាអំណាចទាំងបីកំពុងប្រឈមមុខដាក់គ្នាយ៉ាងតានតឹង ហើយអាមេរិកតែងរិះរកគ្រប់មធ្យោបាយ ដើម្បីទាញយកមួយក្នុងចំណោមមហាអំណោចទាំងពីរមកខាងខ្លួន។ ដូចនេះ សហរដ្ឋអាមេរិកធ្វើជាគាំទ្រនូវគំនិតផ្ដួចផ្ដើមរបស់មេដឹកនាំក្រុងប៉េកាំង ចំពោះវិបត្តិកម្ពុជាក្នុងគោលបំណងកម្សោយឥទ្ធិពលនៃនយោបាយរបស់មេដឹកនាំក្រុងម៉ូស្គូ។ នៅលើទំព័រខាងក្រោយ យើងនឹងឃើញឥរិយាបថរបស់មេដឹកនាំក្រុងវ៉ាស៊ីនតោន

ចំពោះមេដឹកនាំក្រុងប៉េកាំងក្នុងវិបត្តិកម្ពុជា បន្ទាប់ពីមេដឹកនាំក្រុងម៉ូស្គូប្តូរបេបនយោបាយ។ ដើម្បីសំរេចទិសដៅនេះ សហរដ្ឋអាមេរិកបានដាក់ទណ្ឌកម្ម និងកាត់ផ្តាច់សេដ្ឋកិច្ចយួនចេញពីបណ្តាប្រទេសជឿនលឿន ព្រមទាំងបានទាត់ចោលនយោបាយរបស់មេដឹកនាំក្រុងហាណូយ ចេញពីឆាកអន្តរជាតិទៀតផង។ បន្ថែមលើនេះ សហរដ្ឋអាមេរិកក៏បានជួយឧបត្ថម្ភគ្រឿងអាវុធដល់ក្រុមខ្មែរ ដែលកំពុងតស៊ូប្រឆាំងនិងវត្តមាននៃកងទ័ពយួនក្នុងប្រទេសកម្ពុជា នៅតាមព្រំប្រទល់ខ្មែរ-សៀម ដែលមានក្រុមតស៊ូរបស់លោក នរោត្តម សីហនុ និងក្រុមតស៊ូរបស់លោក ស៊ីន សាន ជាដើម។



## គំនិតផ្តួចផ្តើម សំណូមពរដើម្បីបញ្ចប់សង្គ្រាម និងការបរាជ័យ

មូលហេតុនៃសង្គ្រាមដែលបានរៀបរាប់ខាងលើនេះ បានបញ្ឆេះជាសង្គ្រាមរាប់ទសវត្សរ៍ក្នុងប្រទេសកម្ពុជា ហើយពីមួយថ្ងៃទៅមួយថ្ងៃ ការរងទុក្ខសោក វេទនា ទុរគតរបស់ប្រជាពលរដ្ឋខ្មែរកាន់តែកើនឡើងជាប្រចាំ។ ដោយហេតុនេះ មានគំនិតផ្តួចផ្តើមនិងសំណូមពរជាច្រើនដើម្បីរកដំណោះស្រាយបញ្ចប់សង្គ្រាមនិងសន្តិភាពជូនពលរដ្ឋខ្មែរ។ អង្គការសហប្រជាជាតិបានបើកសន្និសិទ្ធស្តីពីកម្ពុជានៅខែកក្កដា១៩៨១ក្នុងទីក្រុងញូយ៉កនិងបានធ្វើគំរោងផែនការដើម្បីបញ្ចប់សង្គ្រាមដែលមានចំណុចដូចខាងក្រោម៖

- បទឈប់បាញ់និងការដកកងទ័ព
- វិធានការឆ្លងកាត់អន្តរកាល
- រៀបចំបោះឆ្នោតក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ
- ការបង្កើតរដ្ឋាភិបាលថ្មី

តែគួរអោយអនិច្ចាណាស់ ចំពោះគំនិតផ្តួចផ្តើមដ៏វិសេសវិសាលប្រកបដោយមនុស្សធម៌ និងមានអត្ថន័យដ៏ខ្ពង់ខ្ពស់សំរាប់ប្រជាពលរដ្ឋខ្មែរបែរជាឥតន័យចំពោះមេដឹកនាំលើកបន្តុបខ្មែរទៅវិញ។ គេម្នាក់ៗចង់បានអំណាច ចង់បានការឈ្នះរបស់គេដោយការបង្ហូរឈាមនិងដោយចុងអាវុធទើបមានន័យចំពោះអ្នកនយោបាយខ្មែរជំនាន់សតវត្សទី២០។ ជាពិសេសមេដឹកនាំយួន មានមោទនភាពលើកងកំលាំងប្រដាប់អាវុធរបស់ខ្លួន ហើយនៅតែបន្តរក្សាកងទ័ពរបស់គេក្នុងការប្រយុទ្ធទៅទៀត ដោយធ្វើជាមិនចាប់អារម្មណ៍នូវគំរោងការរបស់អង្គការសហប្រជាជាតិនេះ។ គេនៅតែបើកយុទ្ធនាការប្រយុទ្ធនៅលើទឹកដីខ្មែរភូមិកំណើតខ្មែរ។

ចូលមកដល់ឆ្នាំ១៩៨៥ គឺមានសំណូមពរជាច្រើន។ នៅដើមខែមេសា១៩៨៥ ប្រទេសម៉ាឡាយូបានធ្វើសំណូមពរពិភាក្សាជាប្រយោលរវាងបក្សត្រីភាគី និងរដ្ឋាភិបាលលោក ហ៊ុន សែន ក្នុងគោលបំណងបង្រួបបង្រួមជាតិខ្មែរ។ បន្ទាប់មក បណ្តាប្រទេសអាស៊ានបានធ្វើសំណូមពរដែលគេហៅថា ការពិភាក្សាជាប្រយោលដែលក្នុងនោះភាគីខ្មែរទាំងបួនត្រូវតែចូលរួម។ សំណើទាំងនេះត្រូវបានប្រទេសជាច្រើនដែលចង់ចូលរួមដោះស្រាយវិបត្តិកម្ពុជា គាំទ្រនិងចូលរួមចំណែកយ៉ាងសកម្ម ហើយប្រទេសទាំងនេះខំខ្នះខ្នែង ខំជំរុញ និងជួយរៀបចំអោយខ្មែរទាំងបួនបក្សបានជួបជុំគ្នាដើម្បីពិភាក្សាដោះស្រាយរកផ្លូវបញ្ចប់ការកាប់សំលាប់ខ្មែរ នៅកម្ពុជា ដូចជា ប្រទេសបារាំង អូស្ត្រាលី ឥណ្ឌូនេស៊ី ជាដើម។ ចាប់ពីពេលនោះមក មានបើកសន្និសិទ្ធជាញឹកញាប់ស្តីពីបញ្ហាកម្ពុជា នៅទីក្រុងប៉ារីសប្រទេសបារាំង និងនៅទីក្រុងយាកាតាប្រទេសឥណ្ឌូនេស៊ីដែលគេហៅថា៖ JIM 1, JIM 2, JIM 3, JIM 4 (JIM=Jakarta Informal Meeting)។

JIM 1ប្រព្រឹត្តទៅនៅថ្ងៃទី២៥ដល់២៦មិថុនា១៩៨៨ ក្នុងនោះអ្នកបានចូលរួមមានភាគីខ្មែរទាំងបួនបក្ស និងអ្នកដំណាងរបស់ប្រទេសយួន លាវ និងបណ្តាប្រទេសអាស៊ាន។ កិច្ចការដែលត្រូវពិភាក្សាក្នុងពេលនោះ គឺសំណូមពររបស់លោក នរោត្តម សីហនុ ដូចខាងក្រោមនេះ៖

- ការបង្កើតរដ្ឋាភិបាលដែលមានបក្សទាំងបួនចូលរួម
- ការបង្កើតកងទ័ពដែលកើតឡើងពីបក្សទាំងបួន
- ការបង្កើតការគ្រប់គ្រងដែលកើតឡើងពីបក្សទាំងបួន
-ការចូលរួមរបស់អង្គការសហប្រជាជាតិក្នុងដំណោះស្រាយសន្តិភាព

កិច្ចពិភាក្សានៅ JIM 1 នេះ បានទទួលលទ្ធផលជាអវិជ្ជមាន ព្រោះ៖



១- ខាងរដ្ឋាភិបាលលោក ហ៊ុន សែន មិនព្រមទទួលយកនូវសំណើស្តីពីការបង្កើតរដ្ឋាភិបាលដែលមានបក្សទាំងបួនចូលរួម។

២- ជាពិសេស លោក ហ៊ុន សែន បានទាមទារអោយស្ថានភាពចាស់នៅដដែល "រដ្ឋអំណាចរបស់ខ្លួន" ត្រូវរក្សាទុករហូតដល់ពេលបោះឆ្នោតជ្រើសរើសសភា ហើយរដ្ឋាភិបាលលោក ហ៊ុន សែន មិនចង់ដឹងពីកងទ័ពដែលកើតឡើងពីបក្សទាំងបួនឡើយ។

JIM 2 បានប្រារព្ធឡើងនៅថ្ងៃទី១៩-២០កុម្ភៈ១៩៨៩។ ចំណុចដែលត្រូវពិភាក្សាមានលក្ខណៈប្រហែលនិង JIM 1 ដែរ។ ជំហានពិសេសបន្ទាប់មកទៀត គឺសន្និសិទ្ធអន្តរជាតិនៅទីក្រុងប៉ារីសចាប់ពីថ្ងៃទី៣០កក្កដា រហូតដល់ថ្ងៃទី៣០សីហា១៩៨៩។ អ្នកដែលចូលរួមក្នុងនោះ គឺភាគីខ្មែរទាំងបួនបក្ស សមាជិកអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិ សមាជិកប្រទេសអាស៊ានទាំងប្រាំមួយ ប្រទេសយួន ប្រទេសលាវ អូស្ត្រាលី ឥណ្ឌា ជប៉ុន កាណាដា និងដំណាងប្រទេសមិនចូលបក្សសម្ព័ន្ធស៊ីមបាវេ។ នៅចុងបញ្ចប់នៃសន្និសិទ្ធ គេបានយល់ព្រមគ្នានូវប្រាំពីរចំណុច៖

- ភាពចាំបាច់នៃការដោះស្រាយជាទូទៅ
- ការដកកងទ័ពបរទេស
- ការកសាងកម្ពុជាទៅតាមគោលការឯករាជ្យ សន្តិភាព អព្យាក្រឹត
- ការដោះស្រាយបញ្ហាផ្ទៃក្នុងដោយភាគីខ្មែរ
- ការបោះឆ្នោតដោយសេរីក្រោមការត្រួតពិនិត្យរបស់អន្តរជាតិ
- ការធានារបស់អន្តរជាតិដើម្បីឯករាជ្យ និងអព្យាក្រឹតរបស់កម្ពុជា
- ការជួយឧបត្ថម្ភរបស់អន្តរជាតិក្នុងការកសាងប្រទេសឡើងវិញ

ក្រៅពីនេះ នៅមានបញ្ហាខ្លះទៀតដែលសន្និសិទ្ធមិនទាន់ឯកភាព

គ្នា។ ពិសេសគឺការបញ្ចូលក្រុមខ្មែរក្រហមទៅក្នុងស្ថាប័នរួម។ ប៉ុន្តែ អ្នកដែលមានវត្តមាននៅក្នុងសន្និសិទ្ធនោះ បានព្រមព្រៀងគ្នាកំណត់ថា៖

- បញ្ហាជំលោះនេះ ត្រូវតែដោះស្រាយតាមផ្លូវនយោបាយ មិនដោះស្រាយតាមកំលាំងទ័ព

- អង្គការសហប្រជាជាតិត្រូវទទួលភារកិច្ចសំខាន់នេះនាអនាគត

នៅពាក់កណ្តាលខែកុម្ភៈ១៩៩០ នៅទីក្រុងយ៉ាកាតាប្រទេសឥណ្ឌូនេស៊ី គណបក្សទាំងបួនបានបើកការពិភាក្សាគ្នាដែលគេហៅថា JIM 3 អំពីសំណើរបស់ប្រទេសអូស្ត្រាលីស្តីពីការរំលាយរដ្ឋាភិបាលលោក ហ៊ុន សែន និងកៅអីនៅអង្គការសហប្រជាជាតិ ត្រូវទុកអោយរដ្ឋាភិបាលដែលកើតឡើងដោយគណបក្សទាំងបួន។ លទ្ធផលនៃការពិភាក្សានេះ គឺអវិជ្ជមាន ព្រោះលោក ហ៊ុន សែន មិនចង់ដឹងពីការរំលាយរដ្ឋាភិបាលរបស់ខ្លួន។

ក្រោយពេលបន្ទាប់មកទៀត សមាជិកអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិបានជួបគ្នាជាញឹកញាប់នៅក្រុងប៉ារីស និងញ៉ូយ៉កបន្តបន្ទាប់គ្នា ដើម្បីធ្វើការពិភាក្សាទៅលើចំណុចជាច្រើន ដែលត្រូវដោះស្រាយបញ្ហានៅកម្ពុជា។ នៅថ្ងៃទី២៨សីហា១៩៩០ គេបានបញ្ចេញសេចក្តីថ្លែងការរួមក្នុងនោះមានប្រាំចំណុចស្តីពីដំណោះស្រាយនយោបាយទូទៅរបស់កម្ពុជា៖

- រដ្ឋាភិបាលចន្លោះអន្តរកាល មានន័យថា ត្រូវតែបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់និងអ៊ុនតាក់(UNTAC= United Nation Transitional Authority in Cambodia)

- អ៊ុនតាក់ ត្រូវធានារាប់រងខាងច្បាប់ យោធា និងការដកទ័ពបរទេស

- បោះឆ្នោតដោយសេរី ក្រោមការរៀបចំរបស់អង្គការសហប្រជាជាតិ

- ការការពារសិទ្ធិមនុស្ស



- ការធានារបស់អន្តរជាតិ ដើម្បីឯករាជ្យនិងអព្យាក្រឹតរបស់កម្ពុជានាពេលអនាគត

នៅថ្ងៃទី៩-១០កញ្ញា១៩៩០ រដ្ឋមន្ត្រីក្រសួងការបរទេសបារាំង និងឥណ្ឌូនេស៊ី ជាអ្នកដឹកនាំរួមនៅក្នុងសន្និសិទ្ធអន្តរជាតិស្តីពីកម្ពុជានៅប៉ារីស និងអ្នកដំណាងគណបក្សទាំងបួន បានជួបគ្នានៅទីក្រុងយ៉ាកាតា។ ការជួបគ្នាលើកនេះ គេកំណត់ JIM 4។ ចំណុចដែលត្រូវពិភាក្សាពេលនោះមាន៖

- ការអោយដំបូន្មាន ស្តីពីសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិកាលពីថ្ងៃទី២៨សីហា១៩៩០

- ការបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់

ក្នុងការពិភាក្សានេះបានទទួលលទ្ធផលជាទីពេញចិត្ត គឺគណបក្សទាំងបួន បានយល់ព្រមទៅលើផែនការទាំងប្រាំរបស់អង្គការសហប្រជាជាតិ និងការបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់។ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់នេះត្រូវតំណាងអោយប្រទេសកម្ពុជាក្នុងទំនាក់ទំនងក្រៅប្រទេស និងទទួលកៅអីនៅអង្គការសហប្រជាជាតិ។ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់នេះកើតឡើង៖

- ៦ នាក់តំណាងខាងគណបក្សលោក ហ៊ុន សែន

- ២ នាក់តំណាងខាងគណបក្សលោក នរោត្តម សីហនុ

- ២ នាក់តំណាងខាងគណបក្សលោក ស៊ឺន សាន

- ២ នាក់តំណាងខាងគណបក្សលោក ខៀវ សំផន

លោក នរោត្តម សីហនុ ត្រូវបានជ្រើសតាំងជាប្រធាន។ តែលោក ហ៊ុន សែន បានបដិសេធមិនយល់ព្រមអោយគណបក្សលោក ខៀវ សំផន ចូលរួមក្នុងក្រុមប្រឹក្សាជាតិជាន់ខ្ពស់នេះឡើយ។

រយៈពេល១០ថ្ងៃក្រោយពីការជួបគ្នានៅយ៉ាកាតាមក មានការជួបគ្នា

នៅទីក្រុងបាងកកប្រទេសសៀម។ ក្នុងការពិភាក្សានេះខាងគណបក្សទាំងបី(ដែលគេកំណត់ឈ្មោះថា រដ្ឋាភិបាលត្រីភាគី ក្នុងនោះមានគណបក្សលោក នរោត្តម សីហនុ គណបក្សលោក ស៊ឺន សាន និងគណបក្សកម្ពុជាប្រជាធិបតេយ្យដែលលោក ខៀវ សំផន ជាតំណាង។ រដ្ឋាភិបាលត្រីភាគីនេះ ត្រូវបានបង្កើតឡើងដោយសារការគាបសង្កត់ពីប្រទេសអាស៊ាន និងប្រទេសចិន។ លោកនរោត្តម សីហនុ ត្រូវបានលើកអោយធ្វើជាប្រធាននៃរដ្ឋាភិបាលនេះ) បានសំណូមពរអោយលោក នរោត្តម សីហនុ ធ្វើជាប្រធាននៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់នេះ។ ប៉ុន្តែ សំណូមពរនេះត្រូវបាន លោក ហ៊ុន សែន បដិសេធចោលទាំងស្រុង ព្រោះលោក ហ៊ុន សែន ចង់ធ្វើជាប្រធានដែរ។ សរុបមក ការជួបជុំគ្នាលើកនេះ បានត្រឹមតែដំឡើងសរសៃកដាក់គ្នាប៉ុណ្ណោះ ដោយសារតែការដណ្តើមគ្នាធ្វើប្រធាន។ លោកធំខ្មែរគ្មានពេលពិភាក្សា ត្រូវធ្វើយ៉ាងណាដើម្បីចាប់ដៃគ្នាបញ្ឈប់ការបង្ហូរឈាមខ្មែរ ការសំលាប់ខ្មែរ និងដោះស្រាយសេដ្ឋកិច្ចជាតិរបៀបណាដើម្បីស្រង់ប្រទេសអោយផុតពីភាពក្រីក្រ។ គេចំណាយពេលវេលា ចំណាយប្រាក់ជិះយន្តហោះទៅឈ្លោះគ្នា ដណ្តើមអំណាចគ្នានៅបរទេសដោយឥតអៀនខ្មាស់ចំពោះជនបរទេស។ នេះហើយដែលហៅថា អ្នកស្រលាញ់ជាតិរឺ?។ ឱ! លោកធំ អីក៏ល្មោភអំណាចខ្លាំងម្ល៉េះ គ្មានអាណិតអាសូរប្រទេសជាតិទេរឺ? តើអំណាចមានន័យអ្វីចំពោះរូបលោក បើសិនជាជាតិត្រូវរលាយនោះ។

ដោយឈរលើគោលការយល់ព្រមរបស់គណបក្សទាំងបួនពីថ្ងៃទី១០កញ្ញា១៩៩០ ពួកអ្នកដឹកនាំរួម (រដ្ឋមន្ត្រីក្រសួងការបរទេសបារាំង និងឥណ្ឌូនេស៊ី) និងសមាជិកអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិបានសំរេចធ្វើគំរោងកិច្ចសន្យាមួយដែលគេហៅថា ការព្រមព្រៀងគ្នាផ្លូវនយោបាយទូលំ



ទូលាយ(Comprehensiv Political Settlement)។ គំរោងកិច្ចសន្យានេះត្រូវបានរៀបចំរួចរាល់នៅថ្ងៃទី២០វិច្ឆិកា១៩៩០ និងត្រូវដាក់អោយគណបក្សទាំងបួន ធ្វើសេចក្តីសំរេច ក្នុងការជួបជុំគ្នានៅទីក្រុងប៉ារីសនាថ្ងៃទី២១-២២ធ្នូ១៩៩០ ។ ចំណុចសំខាន់នៃសេចក្តីព្រមព្រៀងនោះមាន៖

- អ៊ុនតាក់ត្រូវធ្វើការជាមួយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ក្នុងកំឡុងពេលពីរឆ្នាំក្នុងកម្ពុជា
- អ៊ុនតាក់កាន់អំណាចទៅលើក្រសួង៥សំខាន់ៗ ក្រសួងការបរទេស ការពារប្រទេស មហាផ្ទៃ ហិរញ្ញវត្ថុ និងក្រសួងពត៌មាន
- អង្គការសហប្រជាជាតិជាអ្នកចំណាយប្រាក់ក្នុងការរៀបចំនោះ

នាថ្ងៃទី២១-២២ធ្នូ១៩៩០នៅក្រុងប៉ារីស សន្និសិទ្ធិត្រូវបានប្រារព្ធឡើងតាមការកំណត់។ សភាពការណ៍លើកនេះមានការតានតឹងជាខ្លាំងគឺដំណាងខាងបក្សទាំងបីបានទទួលយល់ព្រមនិងសំណើនេះ តែខាងលោក ហ៊ុន សែន បានប្រកែក និងបដិសេធ។ ជាពិសេសលោក ហ៊ុន សែន ជាអ្នកធ្វើអោយស្ទះ និងទទឹងរឹងរូសទៅលើសំណើដើម្បីសន្តិភាពរបស់អង្គការសហប្រជាជាតិ អំពីកងទ័ពរបស់បក្សនីមួយៗ ត្រូវដកហូតអាវុធចេញ។ ម្យ៉ាងទៀតលោក ហ៊ុន សែន បានទាមទារអោយអង្គការសហប្រជាជាតិយកពាក្យប្រល័យពូជសាសន៍របស់របបប៉ុល ពតដាក់ក្នុងគំរោងសន្តិភាព។

សរុបសេចក្តីមក មូលហេតុចុងបញ្ចប់នៃការប្រឹងប្រែងខិតខំស្វែងរកសន្តិភាពរបស់អង្គការសហប្រជាជាតិសំរាប់ប្រជាពលរដ្ឋខ្មែររហូតដល់ថ្ងៃទី២២ធ្នូ១៩៩០សន្និសិទ្ធិនៅទីក្រុងប៉ារីស មិនបានលទ្ធផលជាវិជ្ជមានដោយសារតែការចោទប្រកាន់ទាំងកំរោលរឹងរូសដដែលៗ និងដោយងងឹតងងល់របស់ក្រុមលោក ហ៊ុន សែន ប្រឆាំងនិងគណបក្សលោក ខៀវ សំផន។ ការ

ចោទប្រឆាំងដោយគ្មានមូលដ្ឋាននេះ គឺគ្រាន់តែជាលេសរបស់ក្រុមលោក ហ៊ុន សែន ដែលត្រូវតែប្រកាន់យកដើម្បីពន្យាពេលនៃការកាន់អំណាចរបស់ខ្លួនផង និងដើម្បីផ្គាប់ផ្គុនយកចិត្តចៅហ្វាយយួនផង ព្រោះថា បើគ្មានមេដឹកនាំយួនជាបង្អែកទេ ក្រុមលោកហ៊ុន សែន មិនអាចការពារអំណាចនោះដោយខ្លួនឯងបានឡើយ។ ពិសេសមេដឹកនាំយួន ចង់ពន្យាសង្គ្រាមសំលាប់ខ្មែរ។ ក្នុងការបង្ហាញនូវភក្តីភាពនិងភាពឥតងាករេរបស់ខ្លួនចំពោះមេដឹកនាំយួន ក្រុមលោក ហ៊ុន សែន បានកេណ្ឌប្រជាពលរដ្ឋខ្មែរអោយទៅស្លាប់ អោយទៅរបួសដោយខ្លួនឯងអស់រាប់ម៉ឺននាក់ដូចជាក្នុងការកេណ្ឌធ្វើទាហានដើម្បីការពារអំណាចរបស់ខ្លួន និងកេណ្ឌអោយទៅកាប់ព្រៃដែលពួកគេហៅថា ផែនការ "ក៥"។ លើសពីនេះទៀត ក្រុមលោក ហ៊ុន សែន បានអនុញ្ញាតអោយជនជាតិយួនរាប់សែនរាប់លាននាក់មកតាំងលំនៅពាសពេញផ្ទៃប្រទេស និងទុកអោយយួនរំកិលព្រំដែនយកដីខ្មែរស្រេចចិត្ត។ ទន្ទឹមនិងការពន្យាពេលធ្វើសង្គ្រាមសំលាប់ខ្មែរ ក្រុមលោក ហ៊ុន សែន បានខិតខំប្រើអំណាចនេះជាមធ្យោបាយ ដើម្បីបំផ្លាញមរតកជាតិគ្មានសល់។ សម្បត្តិជាតិខ្មែរទាំងមូលស្ទើររលាយអស់ ដោយសារតែក្រុមគេយកទៅចែកគ្នាធ្វើជារបស់កម្មសិទ្ធផ្ទាល់ខ្លួន និងមួយចំនួនទៀតធ្វើជាកម្មសិទ្ធរបស់បក្សពួកគេ។ ក្រុមលោក ហ៊ុន សែន តែងយកសំណង់អាគារ ក្រសួងមន្ទីរដែលជារបស់រដ្ឋទៅលក់អោយឈ្មួញ ក្រុមហ៊ុនស្ទើរគ្មានសល់រហូតដល់គ្រួសាររបស់ក្រុមលោក ហ៊ុន សែន ក្លាយជាមហាសេដ្ឋីដុល្លាដ៏សំបើម។ ដោយក្រុមលោក ហ៊ុន សែន បានចំណេញទាំងការកាន់អំណាចបានយូរ និងទ្រព្យសម្បត្តិយ៉ាងនេះ បានជាពួកលោក ហ៊ុន សែនខំអោបបាតជើងមេដឹកនាំយួនគ្មានទីបញ្ចប់។ ឯក្រុមមេដឹកនាំយួនត្រូវ



តែជួយទំនប់បំរុងលើកដំកើងក្រុមលោក ហ៊ុន សែន ដើម្បីអោយក្រុមនេះអនុវត្តនយោបាយពន្យាសង្គ្រាមសំលាប់ខ្មែរនិងទៅយកជនជាតិយួនអោយមករស់ក្នុងកម្ពុជាតទៅទៀត។ យើងឃើញថា ពួកគេទាំងពីរបានផលប្រយោជន៍ពីប្រជាពលរដ្ឋខ្មែរដូចគ្នា។ ដោយហេតុនេះបានជាក្រុមលោក ហ៊ុន សែន និងក្រុមមេដឹកនាំយួន រឹតចំណងនិងគ្នាលុះអវសាន ដូច ក្រុមលោក ហ៊ុន សែន បានកំណត់ថា "ចំនងមិត្តភាព-កម្ពុជា-វៀតណាមម៉ឺនឆ្នាំ"។ បើប្រទេសខ្មែរមានសង្គ្រាមដែលបង្កដោយក្រុមលោក ហ៊ុន សែន និងក្រុមមេដឹកនាំយួននៅពីក្រោយ ហើយផ្តល់ផលអោយយួនយ៉ាងនេះ យើងសួរថា៖ តើមេដឹកនាំយួនអាចបោះបង់ក្រុមលោក ហ៊ុន សែនចោលរឺទេ? តើមេដឹកនាំយួនចង់អោយខ្មែររស់ក្នុងសន្តិភាពរឺទេ?។

ទន្ទឹមនិងការចរចារកសន្តិភាពតាមផ្លូវនយោបាយនេះ ការបាញ់ប្រយុទ្ធគ្នានៅតំបន់ព្រំប្រទល់ខ្មែរ-សៀមក៏មានសន្ទុះខ្លាំងក្លាណាស់ដែរ។ ខាងបក្សនីមួយៗនិយាយតែពីរឿងជ័យជំនះនិងការដែលគេសំលាប់ខ្មាំងបាន។ តែពួកគេមិនថាបានសំលាប់ខ្មែរទេ ដូចជា ចូលមកដល់ឆ្នាំ១៩៩១ លោក ហ៊ុនសែនបានប្រកាសក្នុងមួយភាគបួននៃឆ្នាំ១៩៩១នេះយើងបានសំលាប់ខ្មាំងចំនួន១៤៧៨នាក់ ចាប់រស់បានចំនួន២១០នាក់ និងបានទទួលការសុំចុះចូលចំនួន៨៨៨នាក់(Suedostasien aktuell Juli 1991 S.378)ដែលភាសារបស់រដ្ឋាភិបាលហ៊ុន សែនហៅថា "ជនសារភាព"។ អស់លោកគាត់មិនព្រមទទួលស្គាល់ខ្មែរ ដែលហ៊ានសុខចិត្តលះបង់អាវុធចោល ព្រោះតែខ្មែរនឿយណាយនឹងសង្គ្រាម និងឈប់ចង់សំលាប់ខ្មែរគ្នាឯងតទៀតទេ ចង់បានសន្តិភាព ចង់រួមគ្នាកសាងជាតិ បែរជាហៅ "ជនសារភាព"ទៅវិញ។ ក្រុមលោក ហ៊ុន សែន ប្រើពាក្យ "ជនសារភាព"នេះ គឺសំដៅទៅលើភាព

ខ្លាំងរបស់ក្រុមគេ។ ដោយយោងទៅតាមការប្រើពាក្យថា"សារភាព" យើងអាចសន្និដ្ឋានបានថា ក្រុមលោក ហ៊ុន សែន ប្រមូលផ្ដុំដោយក្រុមអ្នកលេងសុទ្ធសាធ។ ចំណែកខាងបក្សកម្ពុជាប្រជាធិបតេយ្យវិញ បានប្រកាសថានៅថ្ងៃទី២មិនា១៩៨៦ ពួកគេបានបាញ់កាំភ្លើងធំចំនួន១០៧គ្រាប់ចូលទៅទីក្រុងភ្នំពេញ និងក្រោយមកទៀតបានប្រកាសថា ពួកគេបានវាយយកតំបន់ប៉ៃលិនបាន។ គេសំដែងរិទ្ធ អួតតែពីរឿងជ័យជំនះទាំងសងខាង។ តើនរណាជាអ្នកចាញ់? ពិតជាប្រជាពលរដ្ឋខ្មែរជាអ្នកចាញ់ជាអ្នករងទុក្ខវេទនាជាអ្នកស្រក់ទឹកភ្នែក ជាអ្នកទុរគត។ លោកធំខ្មែរនិយាយតែពីការសំលាប់ខ្មាំងបានរាប់ក្បាល។ តើនរណាជាខ្មាំងសំរាប់នរណា? ពួកដែលគេហៅថាខ្មែរក្រហមក៏ជាខ្មែរ ហើយពួកលោក ហ៊ុន សែន ក៏ជាខ្មែរ។ បើរវល់តែចោទខ្មែរសុទ្ធតែជាខ្មាំងនោះ គឺលទ្ធផលជាខ្មោច បានសេចក្ដីថា ប្រជាពលរដ្ឋខ្មែរទេដែលក្លាយជាខ្មោច ជាអ្នកស្លាប់។ ស្លាប់ដោយសារតែលោកធំលើកបន្តុបខ្មែរស្រលាញ់អំណាច ទាំងកំពោលមួយចំនួនតូចប៉ុណ្ណោះ ដែលបានកេណ្ឌអោយទៅច្បាំង អោយទៅស្លាប់ដើម្បីដណ្ដើមនិងការពារអំណាចអោយក្រុមខ្លួន។ មានតែលោកធំលើកបន្តុបខ្មែរ ប្រកបដោយមហាសែនមហិច្ឆតាអំណាចទេដែលចោទប្រជាពលរដ្ឋខ្មែរថា"ខ្មាំង"។ បើលោកធំខ្មែរប្រកាន់ចរិកបែបនេះ តើគាត់បំរើនរណា?។ សូមពលរដ្ឋខ្មែរទាំងអស់ភ្ញាក់ឡើង និងត្រូវប្រកាន់ថា ខ្មែរមិនមែនជាខ្មាំងចំពោះខ្មែរណាឡើយ ឈប់ជឿតាមការបោកប្រាស់របស់លោកធំលើកបន្តុបប្រភេទនេះ ទើបពូជអំបូរខ្មែរអាចនៅមានជីវិត។

រហូតដល់ឆ្នាំ១៩៩០ ការស្វែងរកសន្តិភាពតាមផ្លូវនយោបាយ ត្រូវបរាជ័យ សង្គ្រាមនៅតែបន្តរស់រវើក ព្រោះតែមេដឹកនាំខ្មែរ អញនិយមជ្រុល



ហួសហេតុលើខ្មែរគ្នាឯង ហើយជ្រើសរើសយកបរទេសធ្វើជាចៅហ្វាយ។ លោកធំខ្មែរមុននិងធ្វើអ្វី មុននិងសំរេចអ្វីដែលជារឿងប្រទេសជាតិខ្លួន និងអាយុជីវិតរបស់ពលរដ្ឋខ្លួន ចាំបាច់មានការយល់ព្រមពីចៅហ្វាយសិន។ លោកធំខ្មែរ គោរពយ៉ាងអស់ពីបេះដូងចំពោះចៅហ្វាយរបស់ខ្លួន និងមិនគោរពទេប្រជាពលរដ្ឋខ្មែរដែលជាខ្មែរដូចគ្នា។ នេះចង់បញ្ជាក់ថា ការដែលយើងមានបញ្ហា មានអាសន្នតែងទៅរកគេអោយជួយជាការត្រឹមត្រូវ។ តែមិនមែនបានសេចក្ដីថា យកខ្លួនយកក្បាលទៅលក់អោយគេនោះទេ។ ត្រូវយល់ថា ការដែលគេជួយយើង គឺជារឿងមនុស្សធម៌របស់គេ។ ក្នុងប្រវត្តិសាស្ត្រពិភពលោក មិនដែលមានមេដឹកនាំណា ដូចមេដឹកនាំខ្មែរនាប៉ុន្មានទសវត្សរ៍ចុងក្រោយនេះទេ គឺទុកអោយបរទេសបញ្ជា ទុកអោយបរទេសធ្វើចៅហ្វាយ ទុកអោយបរទេសលើកបន្តុបដោយឥតអៀនខ្មាស់។

ចាប់ពីឆ្នាំ១៩៨៥ដល់ឆ្នាំ១៩៩០ លោក ហ៊ុន សែន បានកំណត់ថាជាដំណាក់ការចរចារ និងប្រយុទ្ធយកស្លាប់រស់ផងនោះ ឯការប្រយុទ្ធនៅតែរ៉ាំរ៉ៃដដែល។ ចំណែកការចរចារ មិនបានសំរេច ខាតអស់តែប្រាក់ និងពេលវេលា មិនបានផលប្រយោជន៍អ្វីជូនប្រជាពលរដ្ឋខ្មែរ។ គិតមើល តើលោកធំខ្មែរជិះយន្តហោះប៉ុន្មានដងទៅធ្វើសន្និសិទ្ធ ដេកនៅទីនោះប៉ុន្មានថ្ងៃ ចំណាយពេលវេលាអស់ប៉ុន្មានឆ្នាំ ធ្វើអោយប្រទេសជាតិកាន់តែក្រទៅៗ។ ឯប្រជាពលរដ្ឋរស់នៅក្រោមភាពតោកយ៉ាក និងអស់ជំនឿទៅលើមេដឹកនាំ។ ថ្ងៃនេះលឺសូរបាញ់គ្នាភូមិនេះ ស្អែកឡើងលឺសូរបាញ់ភូមិនោះ។ រហូតដល់ថ្ងៃនេះ ជនពិការរាប់ម៉ឺននាក់គ្មានមុខរបរ ធ្វើស្រែចំការមិនកើត។ ឱ! លោកធំ ហេតុអ្វីបានជាលោកមិនចង់អោយខ្មែររស់ក្នុងភាពសុខសាន្ត។

## សន្តិភាពចិតលើមេដឹកនាំចិន យួន និងសៀម

ការស្វែងរកដំណោះស្រាយតាមនយោបាយ ដើម្បីសន្តិភាពសំរាប់ប្រទេសខ្មែរ ត្រូវទទួលបរាជ័យគឺចិតនៅត្រង់ប្រទេសចិន សៀម និងយួន មិនទាន់បានទាញយកផលប្រយោជន៍របស់ខ្លួនពីបញ្ហានេះ ដូចការដែលខ្លួនបានគ្រោងទុក។ គេដឹងថា ដំណាក់ការនេះ ដោយមានអង្គការសហប្រជាជាតិ គេមិនអាចលេបយកប្រទេសខ្មែរទាំងកំរោលដោយស្រួលបានទេ។ ដោយមូលហេតុនេះ ទើបគេប្រែពីការលេបយកទឹកដីដោយប្រើកំលាំងបាយទៅជាការដោះស្រាយវិបត្តិដែលកើតមាននៅជុំវិញខ្លួនគេសិន។ គេយកជីវិតប្រជាពលរដ្ឋខ្មែររាប់លាននាក់ទៅប្រលែងនឹងគ្រាប់កាំភ្លើង មកធ្វើជាគន្លឹះដើម្បីដោះស្រាយទំនាស់ខាងនយោបាយ និងសេដ្ឋកិច្ចរបស់គេដោយងងើល។

ប្រទេសចិន មិនទាន់បានជោគជ័យក្នុងការដោះស្រាយនូវទំនាស់ខ្លួនជាមួយប្រទេសយួន សូវៀត និងប្រទេសអាស៊ាន។ មេដឹកនាំចិននៅតែបន្តឧបត្ថម្ភផ្តល់ជំនួយសព្វាវុធអោយក្រុមលោក ប៉ុល ពត។ ទន្ទឹមនិងនេះមេដឹកនាំក្រុងប៉េកាំង ខំធ្វើការដោះស្រាយតាមផ្លូវនយោបាយជាខ្លាំង។ នៅក្នុងទស្សនាវដ្តីអាល្លឺម៉ង់ Suedostasien aktuell ចេញខែមិនា១៩៨៩ បានសរសេរនៅលើទំព័រ១៦៧ក្រោមចំណងជើង "ការពិភាក្សារវាងក្រុងប៉េកាំង និងក្រុងហាណូយ"៖ បរិយាកាសរវាងប៉េកាំងនិងហាណូយចាប់ផ្តើមធូរស្រាល។ នៅថ្ងៃ៣១មករា រដ្ឋទូតយួនប្រចាំនៅប្រទេសចិនឈ្មោះ NGUYEN MINH PHU បានធ្វើការអញ្ជើញអ្នកមុខអ្នកការចិនដើម្បីជួបគ្នាក្នុងនាមបុណ្យចូលឆ្នាំថ្មីជាប្រពៃណី និងបានទទួលលទ្ធផលជាផ្លែផ្កា។ ជា



ភ្ញៀវ គឺមានអ្នកតំណាងខាងក្រសួងការបរទេសចិន អង្គការសំរាប់មិត្តភាពជាមួយបរទេស និងអង្គការផ្សេងទៀតរបស់ចិន។ ក្នុងថ្ងៃជាមួយគ្នានោះ រដ្ឋទូតចិនប្រចាំនៅទីក្រុងហាណូយ LI SHICUN បានរៀបចំធ្វើការបញ្ចាំងបង្ហាញពីភ្ញៀវយួនជាច្រើន។ ជាពិសេស ប្រទេសចិន និងយួនបានធ្វើការប្តូរក្នុងវិធីបុណ្យចូលឆ្នាំថ្មីរបស់គេនូវជនជាប់ជាឈ្លើយសង្គ្រាម។ មេដឹកនាំយួនបានប្រគល់ជនជាតិចិនចំនួន១៣នាក់ ឯមេដឹកនាំចិនបានប្រគល់ជនជាតិយួនចំនួន៩នាក់។ រដ្ឋាភិបាលយួន បានបញ្ចប់ចាប់ពីឆ្នាំ១៩៨៩ ឈប់ឃោសនាប្រឆាំងនិងប្រទេសចិន។ នៅតាមវិទ្យុរបស់ក្រុងហាណូយ មានកម្មវិធីថ្មីដែលមានចំណងជើងថា យួន-ចិន-មិត្តភាព។ ចំណុចសំខាន់ទៅលើការលូតលាស់ថ្មី គឺការពិភាក្សារបស់តំណាងក្រសួងការបរទេស DINH NHOLIEN ក្នុងក្រុងប៉េកាំងពីថ្ងៃទី១៥រហូតដល់ថ្ងៃទី២០មករា១៩៨៩ ជាមួយ LIU SHUGING។ ចំណុចធំនៅក្នុងការពិភាក្សានោះគឺវិបត្តិកម្ពុជា។

ចំពោះមេដឹកនាំយួន គ្មានបំណងចូលរួមដោះស្រាយបញ្ហាកម្ពុជាទេ ព្រោះមេដឹកនាំយួន គ្មានគោលនយោបាយ គ្មានទិសដៅនឹងដកកងទ័ពរបស់គេចេញពីកម្ពុជាឡើយ។ ក្រុមមេដឹកនាំយួនបានសំរេចដល់គោលដៅដែលបានគ្រោងទុកជាយូរគឺកម្ពុជានិងប្រទេសលាវ ត្រូវចិតនៅក្រោមការត្រួតត្រារបស់យួនតាមគំនិត និងផែនការលោក ហូ ជីមិញ។ មានសេចក្តីបញ្ជាក់ជាច្រើន ដែលបង្ហាញអំពីការដែលមេដឹកនាំយួន គ្មានបំណងដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជាដូចខាងក្រោម៖

១- ក្នុងសៀវភៅរបស់លោកMichael Sontheimer បានសរសេរនៅលើទំព័រ២១០ "នៅខែវិច្ឆិកា១៩៧៩ លោករដ្ឋមន្ត្រីក្រសួងការបរទេសយួន NGYUEN COTHACH បានពន្យល់ពីស្ថានការណ៍នៅកម្ពុជាថា៖ ស្ថានភាព

មិនត្រូវធ្វើអោយថយក្រោយ។ រាល់ការរិះរកដើម្បីបង្ខំអោយដោះស្រាយតាមផ្លូវនយោបាយ រឺដើម្បីកោះហៅមកបើកសន្និសិទ្ធអន្តរជាតិស្តីពីវិបត្តិកម្ពុជា គឺជាការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រជាពលរដ្ឋកម្ពុជា"។

២- នៅក្នុងទស្សនាវដ្ដីអាល្លឺម៉ង់Suedostasien aktuell ចេញខែកក្កដា ១៩៨៧នៅលើទំព័រ៣៧៩ បានសរសេរ "ថ្វីបើសេដ្ឋកិច្ចយួនត្រូវជួបការលំបាកយ៉ាងណាក៏ដោយ ក៏មេដឹកនាំយួនមិនព្រមទទួលយកភាពស្របគ្នាក្នុងបញ្ហាកម្ពុជាដែរ។ នៅខែធ្នូ១៩៨០ អ្នកនយោបាយយួនឈ្មោះTRUONG CHINH បានប្រកាសថា៖ ទោះជាស្ថានភាពសេដ្ឋកិច្ចរបស់យើង និងជីវិតរបស់យើងជួបការលំបាកយ៉ាងណា យើងត្រូវតែបង្កើនសមត្ថភាពការពាររបស់យើងដើម្បីការពារមាតុភូមិរបស់យើង និងដើម្បីបំពេញករណីយកិច្ចអន្តរជាតិ ជាពិសេសប្រទេសកម្ពុជា និងលាវ"។

៣- នៅក្នុងទស្សនាវដ្ដីអាល្លឺម៉ង់Suedostasien aktuell ចេញខែកក្កដា ១៩៨៧នៅលើទំព័រ៣៧៨ បានសរសេររៀបរាប់ពីទិសដៅរបស់មេដឹកនាំក្រុងហាណូយដែលមាន៩ចំណុច៖

ក- ការផ្ដាច់ឥទ្ធិពលរបស់មេដឹកនាំក្រុងប៉េកាំងនិងឥទ្ធិពលមកពីក្រៅទាំងអស់មកលើប្រទេសម្ពុជា និងលាវ និងយកប្រទេសទាំងពីរសង់ខ្សែក្រវាត់ការពារសន្តិសុខទាំងខាងនយោបាយ និងយោធាសំរាប់ប្រទេសយួន។

ខ- ដើម្បីធានាដល់ការចិញ្ចឹមជីវិតចំពោះជនជាតិយួនដោយយកស្រូវ និងត្រីពីប្រទេសកម្ពុជា។

គ- ការប្រើប្រាស់ទឹកដី និងសម្បត្តិធម្មជាតិរបស់ប្រទេសលាវដើម្បីរោងចក្រប្រទេសយួន។

ឃ- ការសំរេចនូវកន្លែងរស់នៅបន្ថែមសំរាប់ជនជាតិយួនដែលមានចំ



នួនដ៏លើសលប់។

តាំងពីកងទ័ពយួនចូលកាន់កាប់ប្រទេសកម្ពុជាមក ចំនួនជនជាតិយួនបានកើនឡើងជានិច្ច។ ជនជាតិយួនដែលចូលមករស់នៅក្នុងប្រទេសកម្ពុជាទាំងនោះ មាន៣ប្រភេទ៖

១- ទាហាន

២- អ្នកជំនាញការ

៣- ប្រជាជនធម្មតា (ក្នុងនោះមានអ្នករកស៊ី អ្នកនេសាទ អ្នកធ្វើជាងអ្នកបើកភោជនីដ្ឋាន)។

ដោយយល់បញ្ហានេះច្បាស់ និងដើម្បីធ្វើការគាបសង្កត់ទៅលើមេដឹកនាំយួនអោយប្តូរនយោបាយរបស់ខ្លួន ប្រទេសជឿនលឿនលើពិភពលោកបានដាក់ទណ្ឌកម្មផ្នែកនយោបាយ និងសេដ្ឋកិច្ចដល់ប្រទេសយួន ដែលធ្វើអោយនយោបាយនិងសេដ្ឋកិច្ចយួនថិតក្នុងសភាពឯកោ។ មេដឹកនាំយួនបានដឹងដែរថា មតិអន្តរជាតិបានថ្កោលទោសដល់នយោបាយ និងដាក់ទណ្ឌកម្មសេដ្ឋកិច្ចរបស់ខ្លួន ដោយសារការលុកលុយកាន់កាប់កម្ពុជានេះឯង។ ដូចនេះ អ្វីដែលមេដឹកនាំយួនត្រូវសំរេចចិត្តគឺ តើត្រូវនៅបន្តកាន់កាប់ប្រទេសកម្ពុជារហូត ហើយសុខចិត្តជាប់ចំណងនយោបាយនិងសេដ្ឋកិច្ចរបស់សហគមអន្តរជាតិ រឺត្រូវចាកចេញពីប្រទេសកម្ពុជាដើម្បីអោយរបូតចំណងនោះ។ តែដោយមហិច្ឆតាចង់បានទាំងពីរ គឺទាំងការកាន់កាប់កម្ពុជា និងរួចពីការហ៊ុំព័ទ្ធរបស់សហគមអន្តរជាតិផង បានជាមេដឹកនាំយួនហាក់ដូចជាមិនអើពើ ធ្វើមិនដឹងធ្វើមិនលឺ។ ចំណែកឯ សហគមអន្តរជាតិនៅតែបន្តគាបសង្កត់មេដឹកនាំយួនអោយលះបង់កម្ពុជា។ ដោយសារសំពោធធ្ងន់ឡើងៗដែលធ្វើអោយមេដឹកនាំយួនចង់ឆ្លើយតបជាវិជ្ជមាន ចំពោះសំ

ណើរបស់សហគមអន្តរជាតិខ្លះដែរ ដើម្បីអោយនយោបាយនិងសេដ្ឋកិច្ចរបស់ខ្លួនមានជីវិតលើឆាកអន្តរជាតិឡើងវិញ។ តែអ្វីដែលមេដឹកនាំយួនពារ៉ែកនោះ អាចអោយយើងលើកជាសំណួរថា ហេតុអ្វីបានជាក្រុមមេដឹកនាំយួនមិនព្រមទទួលស្គាល់ដំណោះស្រាយតាមផ្លូវនយោបាយ ដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជា? ប្រហែលមេដឹកនាំយួនបារម្ភថា បើខ្មែរមានសន្តិភាពឯករាជ្យ ខ្មែរចាប់ផ្តើមកសាងប្រទេសប្រកបដោយភាពស្ងប់ស្ងាត់ ខ្មែរមាននយោបាយនឹងនរ មានជីវភាពគ្រាប់គ្រាន់ ពិតជាសេដ្ឋកិច្ចជាតិខ្មែររីកចំរើនទៅមុខ។ កត្តានេះវាអាចធ្វើអោយសេដ្ឋកិច្ចយួនជួបប្រទះការលំបាក រឺមានការយឺតយ៉ាវមួយផ្នែកទៅអនាគត។ ម្យ៉ាងទៀត ប្រាកដជាខ្មែរធ្វើការដោះស្រាយបញ្ហាជនជាតិយួន ដែលហូរចូលមកដោយខុសច្បាប់ និងព្រំប្រទល់ខ្មែរ-យួន ព្រោះអីក្នុងឱកាសខ្មែរកំពុងវក់សំលាប់ខ្មែរគ្នាឯង ប្រទេសខ្មែរកំពុងដុនដាប នឹងសង្គ្រាមដណ្តើមអំណាចរវាងលោកធំខ្មែរនឹងលោកធំខ្មែរ មេដឹកនាំយួនបានសំងំពង្រីកដីចូលមកក្នុងប្រទេសកម្ពុជា។ មេដឹកនាំយួនបានអោយរដ្ឋាភិបាលលោកហ៊ុន សែនចុះសន្ធិសញ្ញាខុសច្បាប់ ប្រគល់ទឹកដីខ្មែរអោយទៅប្រទេសយួនជាច្រើនលើក។ ដូចសៀវភៅរបស់លោក ហ៊ិន ស៊ីថាន បានសរសេរនៅទំព័រឈ និងញ ដែលមានសេចក្តីខាងក្រោម "សន្ធិសញ្ញាកាត់បន្ថយព្រំដែនខ្មែរ"៖

- សន្ធិសញ្ញាចុះថ្ងៃទី១៨ខែកុម្ភៈឆ្នាំ១៩៧៩

ជាសន្ធិសញ្ញាសហប្រតិបត្តិការក្នុងរយៈ២០ឆ្នាំ និងបន្តយជាសំងាត់ក្នុងរវាង១០ឆ្នាំម្តង។ ត្រង់ខទី៤នៃសន្ធិសញ្ញានេះ បានបញ្ជាក់ពីការកំរិតព្រំដែនមិត្តភាពដែលគ្រោងថា នឹងពិនិត្យពិភាក្សាឡើងវិញដោយយកព្រំដែនបច្ចុប្បន្នធ្វើជាគោល។



- សន្ធិសញ្ញាចុះថ្ងៃទី០៧ខែកក្កដាឆ្នាំ១៩៨២

ជាសន្ធិសញ្ញាកាត់បន្ថយដែនសមុទ្រខ្មែរ តំបន់កោះសេះដែលមានប្រេងកាត ត្រូវរបប ហេង សំរិន និងហ៊ុន សែន ប្រគល់ទៅអោយយួន។

- សន្ធិសញ្ញាចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៨៣

ស្តីពីការកាត់បន្ថយព្រំដែនខ្មែរ ប្រគល់ទៅប្រទេសយួនជាថ្មីទៀត។

- ឆ្នាំ១៩៨៤: ឡេ ឌឹកថូ សមាជិកការិយាល័យនយោបាយរបស់ប្រទេសយួនបានមកធ្វើទស្សនកិច្ចនៅកម្ពុជា ហើយបានពន្យល់ណែនាំដល់លោក ហេង សំរិន និងលោក ហ៊ុន សែន ថា៖ គោងអោយមានគ្រួសារយួនមួយគ្រួសារក្នុងចំណោមគ្រួសារខ្មែរបួនគ្រួសារនៅទីជនបទនិងគ្រួសារយួនមួយគ្រួសារក្នុងចំណោមគ្រួសារខ្មែរពីរគ្រួសារនៅតាមទីប្រជុំជននិងទីក្រុងនានា។

- សន្ធិសញ្ញាខែធ្នូឆ្នាំ១៩៨៥

សន្ធិសញ្ញាកំណត់ព្រំដែន បន្ថយដីខ្មែរជាថ្មីទៀត និងការយល់ព្រមអោយនិគមយួនចូលមកតាំងទីលំនៅលើដែនដីខ្មែរ អោយខ្មែរជួយផ្គត់ផ្គង់សព្វយ៉ាងដល់និគមយួនថ្មីៗនេះ មានការយកផ្ទះខ្មែរ ដេញម្ចាស់ចេញ ដកដីធ្លីអោយទៅនិគមយួនទាំងនោះផង។

- ឆ្នាំ១៩៨៥: មេដឹកនាំយួនបានប្រកាសថា៖ សន្ធិសញ្ញាមួយស្តីពីការលប់បំបាត់ព្រំដែនរវាងប្រទេសយួន និងកម្ពុជា។ សន្ធិសញ្ញានេះ ជាមធ្យោបាយរបស់យួនដើម្បីអោយនិគមយួនថ្មីៗ ចូលមកតាំងទីនៅដោយស្របច្បាប់លើដែនដីខ្មែរថែមលើចំនួននិគមយួនចាស់ជាងពីរលាននាក់ កាលពីមិនទាន់មានសន្ធិសញ្ញានេះ។

- សន្ធិសញ្ញាចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៨៨

លោក ហ៊ុន សែន និងលោក ង្វៀង កូថាច់ បានចុះហត្ថលេខាលើ

សន្ធិសញ្ញានេះដែលស្តីពីការរកដំណោះស្រាយវិវាទព្រំប្រទល់ដែន រវាងសាធារណរដ្ឋសង្គមនិយមយួន និងសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយលើលក្ខន្តិកៈ ស្តីពីព្រំដែនថ្មីនៃប្រទេសទាំងពីរ។

ជាពិសេសទៀតនោះ គឺរឿងទឹកដីកម្ពុជាក្រោមដែលជារឿងថ្មីនៅឡើយ។ ក្នុងយប់ថ្ងៃទី២១ឧសភា១៩៤៩ សភាបារាំងបានអនុម័តភ្ជាប់ទឹកដីនេះទៅប្រទេសយួនយ៉ាងងងើល។ រដ្ឋាភិបាលបារាំងមិនព្រមបង្វិលទឹកដីនោះ មកអោយខ្មែរវិញ សមតាមសេចក្តីសន្យារបស់លោក អាប៊ីរាល់ដឺឡាក្រង់ឌីយែរ (ក្នុងឆ្នាំ១៨៦៤ ព្រះបាទសម្តេច ព្រះនរោត្តម បានយាងទៅជួបលោក LAGRANDIERE ដើម្បីសុំអោយប្រទេសបារាំងបង្វិលខេត្តដែលមេដឹកនាំយួនបានយក អោយខ្មែរវិញ។ លោកLAGRANDIEREបានសន្យាថ្វាយព្រះអង្គថា នឹងបង្វិលខេត្តទាំងនោះមកអោយខ្មែរវិញ។ ព្រះករុណាបានយាងត្រឡប់មកកម្ពុជាវិញ)។ ក្រុមមេដឹកនាំបារាំងបានបង្ខំអោយរដ្ឋាភិបាលខ្មែរយល់ព្រមប្រគល់ទឹកដីនោះទៅប្រទេសយួន។ សៀវភៅរបស់លោក ហ៊ុន ស៊ីថាន បានសរសេរនៅលើទំព័រ៩២ថា តើកាលយួនយកដែនដីកម្ពុជាក្រោមនោះ យួនមានខូចបាត់បង់កិត្តិយស់រឺទេ? តើសម្តេចមានវិប្បដិសារីរឺទេ? ដែលមិនបានធ្វើការតវ៉ាអ្វីសោះ កាលសភាបារាំងសំរេចប្រគល់ដីកម្ពុជាក្រោមទៅអោយយួន ក្នុងយប់ថ្ងៃទី២១ឧសភាឆ្នាំ១៩៤៩ និងការដែលទ្រង់បានរាំងឃាត់មិនអោយលោក ទ្រៀង កាង ធ្វើការទាមទារកម្ពុជាក្រោមនៅតុលាការអន្តរជាតិ រឺមួយកាលនោះ សីហនុ ជឿជាក់ថា៖ យួននឹងទុកអោយទ្រង់សោយសុខលើកម្ពុជាមួយជីវិត។ ក្នុងការចុះហត្ថលេខាប្រគល់ទឹកដីនេះ មានតែខ្មែរពីរនាក់ទេដែលបានយល់ព្រម និងខ្មែរ



ម្នាក់ទៀតមិនទទួលយល់ព្រមចុះហត្ថលេខានេះឡើយ។ តាមលោកគ្រូម្នាក់និយាយប្រាប់ គឺលោក អៀវ កើស ព្រោះលោកជាប្រធានរដ្ឋសភានាសម័យនោះ ហើយពេលក្រោយមក ត្រូវគេលួចធ្វើឃាដស្លាប់។ ដូចនេះទឹកដីកម្ពុជាក្រោមមិនទាន់កន្លងផុតនៅឡើយ យើងត្រូវតែគិតឡើងវិញ។

ហេតុនេះ បានជាមេដឹកនាំយួនត្រូវតែរិះរកលេសគ្រប់បែបយ៉ាងក្នុងការបន្លាយសង្គ្រាមស្រុកខ្មែរអោយកាន់តែយូរឆ្នាំ ដើម្បីអោយប្រវត្តិសាស្ត្រទឹកដីកម្ពុជាក្រោមកាន់តែកន្លងផុតទៅ ក្រែងខ្មែរឈប់នឹកនា និងដើម្បីអោយខ្មែរមានការនឿយណាយនឹងខ្មែរកាន់តែខ្លាំង ឈប់ចង់រំដោះខ្លួនមករស់ជាខ្មែរ ហើយព្រមទទួលយកការរស់នៅក្រោមការត្រួតត្រារបស់យួន។ អ្វីដែលរដ្ឋាភិបាលលោកហ៊ុន សែន បានអនុវត្តក្នុងការចចារគ្នានោះគឺជាកលល្បិច និងបំណងរបស់មេដឹកនាំយួនសុទ្ធសាធ។

ចំណែកប្រទេសសៀមវិញ តើក្រុមមេដឹកនាំសៀមបានធ្វើអ្វីខ្លះសំរាប់ខ្មែរ? សូមអានត្រង់ផ្នែក "ផ្នត់គំនិតរបស់មេដឹកនាំសៀមចំពោះខ្មែរ"។

## ផ្នត់គំនិតរបស់មេដឹកនាំសៀមចំពោះខ្មែរ

នៅឆ្នាំ១៩៣២ អ្នកជាតិនិយមសៀមម្នាក់ឈ្មោះ វិជិត្រ វ៉ាន់កាន បានសរសេរទ្រឹស្តីនិយមសៀមមួយដែលបានវាយតំលៃខ្ពស់ ទៅលើសាសន៍សៀម ក្នុងចំណោមជនជាតិនៅលើតំបន់នេះ។ ទ្រឹស្តីនេះរហូតទៅអោយដណ្តើមយកមកបញ្ចូលក្នុងប្រទេសសៀម នូវដែនដីកម្ពុជាទាំងមូលដោយសំអាងថា "ទឹកដីកម្ពុជាជារបស់សៀម" ហើយទ្រឹស្តីនេះត្រូវអាជ្ញាធរសៀមទទួលសន្មត់ជាទ្រឹស្តីផ្លូវការតាំងពីឆ្នាំ១៩៣៩សម័យដែល ភីបុល សង្គ្រាមឡើងកាន់អំណាចក្នុងឋានៈជានាយករដ្ឋាភិបាលសៀម។ ជាពិសេសទៅទៀត ទ្រឹស្តីនេះត្រូវបានគ្រប់មជ្ឈដ្ឋាននៃជនជាតិសៀមគាំទ្រទៀតផង។ ទ្រឹស្តីនេះគឺវាផ្ទុយពីការពិត តែការដែលអ្នកជាតិនិយមសៀមហ៊ានសរសេរយ៉ាងនេះ ដោយសារតែគេយល់ពីភាពទន់ខ្សោយរបស់មេដឹកនាំខ្មែរដែរ ព្រោះរាល់ការឈ្លានពានរបស់ពួកគេមកលើទឹកដីខ្មែរ គឺបានសំរេចស្ទើរតែរាល់លើក តាំងពីឆ្នាំដែលសៀមបានប្រមូលកើតជារដ្ឋឡើងមកម្លេះ។ ក្នុងឆ្នាំ១៧៩៥ ដោយសារអំពើក្បត់របស់មន្ត្រីខ្មែរឈ្មោះ ប៉ែន ពួកសៀមបានដណ្តើមកាត់ផ្តាច់ពីអាណាចក្រខ្មែរនូវខេត្តជាច្រើន ដូចជា៖ ខេត្តបាត់ដំបងអង្គរ មង្គលបុរីសេរីសោភ័ណ្ឌនិងនគររាជជាដើម។ ក្នុងឆ្នាំ១៨១៤ សៀមបានវាយលុកយកខេត្ត ម្លូព្រៃ ទន្លេរពៅ និងស្ទឹងត្រែង។ល។ ទើបនៅឆ្នាំ១៩០៧ ខេត្តទាំងនេះ៖ បាត់ដំបង សៀមរាប សេរីសោភ័ណ្ឌ ម្លូព្រៃ ទន្លេពៅ និងស្ទឹងត្រែងត្រឡប់ចូលមកក្នុងមហាគ្រួសារខ្មែរយើងវិញ ដោយសារអន្តរាគមន៍តាមផ្លូវសឹកនៃអាណានិគមនិយមបារាំងនៅតំបន់នេះ។

បើសិនជាមេដឹកនាំយួនមានភាពទន់ខ្សោយ ដូចអ្នកដឹកនាំខ្មែរនោះ



ប្រហែលជាអ្នកជាតិនិយមសៀមសរសេរបំផ្លើសទៀតថា ទឹកដីយួនក៏ជារបស់សៀមដែរមើលទៅ។ តែដោយដឹងថា អ្នកដឹកនាំយួនមានឧត្តមគតិជាតិ និងសមត្ថភាពខ្ពស់ ទើបសៀមបន្ថយមហិច្ឆតារបស់ខ្លួនមកត្រឹមតែចែកកម្ពុជាជាពីរ គឺម្ខាងអោយទៅយួន និងម្ខាងទៀតបានមកសៀម។ សួរថា តើទ្រឹស្តីនេះអ្នកនយោបាយសៀមបំភ្លេចហើយរឺនៅសព្វថ្ងៃ?

នៅឆ្នាំ១៩៤០ ក្រោមការជួយគាំទ្រយ៉ាងខ្លាំងទាំងផ្លូវនយោបាយ និងយោធាពីមេដឹកនាំជប៉ុន ធ្វើអោយរដ្ឋាភិបាលសៀម នឹកដល់ទឹកដីកម្ពុជាភ្លាម។ នៅថ្ងៃទី១១កញ្ញា១៩៤០ នាយករដ្ឋមន្ត្រីសៀមបញ្ជូនលិខិតផ្លូវការទៅរដ្ឋាភិបាលបារាំងនៅទីក្រុងវីស៊ី។ ក្នុងលិខិតនោះ បានទាមទារអោយទឹកដីកម្ពុជាវិលត្រឡប់ចូលមកក្នុងប្រទេសសៀមវិញ។ នៅថ្ងៃទី១៨កញ្ញា រដ្ឋាភិបាលក្រុងវីស៊ី បានប្រកាសទាត់ចោល នូវអនុសាសន៍ទាមទាររបស់រដ្ឋាភិបាលសៀមនេះ។ នៅថ្ងៃទី២៥កញ្ញាម្តង ថ្ងៃទី៣០កញ្ញាម្តង រដ្ឋាភិបាលសៀម បានធ្វើការទាមទារដដែលៗ។ ប៉ុន្តែនៅថ្ងៃទី១៤តុលា រដ្ឋាភិបាលក្រុងវីស៊ី បានប្រកែកទាត់ចោលជាដាច់អហង្ការនូវការទាមទារមិនសមហេតុសមផលរបស់អ្នកនយោបាយសៀម។ ចាប់ពីខែធ្នូ១៩៤០មកសង្គ្រាមបារាំង-សៀម ចាប់ផ្តើមបើកឆាកប្រយុទ្ធខ្លាំងនៅតាមព្រំប្រទល់។ គ្រាន់តែរយៈពេល៤០នាទី នាវាចំបាំងរបស់សៀមទាំងអស់ត្រូវអន្តរាយ។ នៅចំពោះមុខការខូចខាតយ៉ាងធ្ងន់ធ្ងរបែបនេះ ជប៉ុនមិនអាចឈរអោបដៃមើលសម្ព័ន្ធមិត្តចាញ់ប្រៀបបារាំងឡើយ។ មេដឹកនាំជប៉ុន បានប្រគល់អោយមេដឹកនាំបារាំងនូវឱសានវាទមួយច្បាប់ បង្ខំអោយបារាំងឈប់ច្បាំង ហើយទទួលយកប្រទេសជប៉ុនជាអជ្ញាកណ្តាល។ មេដឹកនាំបារាំងបានយល់ព្រម ហើយកិច្ចចរចារវាងបារាំងនិងសៀម ចាប់ផ្តើមនៅថ្ងៃទី៧កុម្ភៈ

១៩៤១ នៅទីក្រុងតូក្យូ។ ពេលនោះរដ្ឋាភិបាលជប៉ុនបានធ្វើការគាបសង្កត់ទៅលើរដ្ឋាភិបាលបារាំងតាមផ្លូវទូតខ្លាំងឡើងៗ ទើបរដ្ឋាភិបាលបារាំងយល់ព្រមចុះហត្ថលេខានៅថ្ងៃទី១១មីនា១៩៤១ ប្រគល់ទឹកដីដែលរដ្ឋាភិបាលសៀមទាមទារដោយខុសច្បាប់នោះទៅអោយប្រទេសសៀម ដូចជាខេត្តបាត់ដំបង សៀមរាប កំពង់ធំមួយផ្នែក ស្ទឹងត្រែង។ ទន្ទឹមនិងនេះរដ្ឋាភិបាលបារាំង បានទទួលជាថ្នូរនូវទឹកប្រាក់ចំនួន៦លានប្យ៉ាស្ត្រ៍។

ដោយមានភស្តុតាងទាំងប៉ុន្មាននេះ យើងអាចឆ្លើយបានត្រូវៗចំពោះសំនួរខាងលើថា មេដឹកនាំសៀមអង្គុយសំកុក ដេកបើកភ្នែក រង់ចាំមើលតែឱកាសនិងលក្ខខណ្ឌប៉ុណ្ណោះ។ បើលក្ខខណ្ឌល្អមកដល់ហើយសៀមប្រហែលជាមិនទទួលស្គាល់ជីវិតនៃពូជអំបូរខ្មែរទេមើលទៅ។ តែមេដឹកនាំសៀមខុសពីមេដឹកនាំយួនត្រង់ថា មេដឹកនាំសៀមមិនប្រើដៃក្តៅទេប្រើដៃត្រជាក់។ នេះគឺជារូបមន្តមួយដែលអ្នកនយោបាយសៀមបានរកឃើញ។ យើងមើល ប្រជាពលរដ្ឋខ្មែររាប់លាននាក់ដែលរស់នៅលើទឹកដីខ្មែរដែលត្រូវប្រទេសសៀមកាន់កាប់ គឺរស់ដោយស្ងៀមស្ងាត់។ នេះប្រហែលជាគ្មានទទួលការធ្វើបុកទុក្ខម្និញពីរដ្ឋាភិបាលសៀម ដូចប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងទឹកដីខ្មែរ "កម្ពុជាក្រោម" ដែលត្រូវបានមេដឹកនាំយួនកាន់កាប់រហូតដល់សព្វថ្ងៃនេះទេមើលទៅ។ បើយ៉ាងនេះ បានសេចក្តីថាត្រីស្លាប់ក្នុងទឹកត្រជាក់មែន(ទឹកក្តៅត្រីរស់ ទឹកត្រជាក់ត្រីស្លាប់) ហើយរូបមន្តខាងលើនេះត្រូវបានមេដឹកនាំសៀមចាប់ផ្តើមទូលចូល និងអនុវត្តក្នុងកម្ពុជាយើងនាគ្រាបច្ចុប្បន្ននេះ។

ក្នុងឱកាសដែលប្រជាពលរដ្ឋខ្មែរ កំពុងជួបការលំបាកមួយរយជំពូកណាមួយត្រូវអន្តរជាតិបង្ខំអោយលោកធំខ្មែរត្រូវតែទទួលយក នូវដំណោះ



ស្រាយជំលោះនេះតាមផ្លូវនយោបាយ និងឆ្លៀតពេលនោះគេខំប្រឹងប្រយុទ្ធវាយសំរុកដើម្បីទាញយកតំបន់មកដាក់ក្នុងកណ្តាប់ដៃរបស់ខ្លួនដែលលោក ហ៊ុន សែន ហៅថា ជាដំណាក់ការចរចារផង និងបាញ់ប្រយុទ្ធយកស្លាប់រស់ផងនោះ មេដឹកនាំសៀមសំងំប្រមូលកើបយកទ្រព្យសម្បត្តិខ្មែរ និងបង្ហូរសេដ្ឋកិច្ចដែលមិនមែនជាការធម្មតាចូលមកក្នុងប្រទេសខ្មែរ ដែលយើងទាំងអស់គ្នាសប្បាយប្រើសម្ភារ: មកពីប្រទេសសៀមនោះ។

នាថ្ងៃទី២៥មករា១៩៨៩ លោក ហ៊ុន សែន បានធ្វើដំណើរទៅប្រទេសសៀមចំនួន២ថ្ងៃ។ ក្នុងឱកាសនោះ លោកបានពន្យល់ពីជំហររបស់ខ្លួនក្នុងដំណោះស្រាយជំលោះកម្ពុជា និងជាបន្ថែម បានពិភាក្សាពីការចង់ធ្វើទំនាក់ទំនងសេដ្ឋកិច្ចរវាងកម្ពុជា-សៀម។ ក្នុងពេលជាមួយគ្នានោះ មេដឹកនាំសៀមបានបង្ហាញនូវបំណងពិសេសរបស់ខ្លួនពីឈើ ត្បូង ពេជ្រ និងការនេសាទត្រី។ មេដឹកនាំសៀមត្រូវតែបន្ថយការគាំទ្ររបស់ខ្លួទៅលើពួកខ្មែរតស៊ូប្រឆាំង ហើយបើកចំហរចំពោះរបបលោក ហ៊ុន សែន។ ហេតុអ្វីបានមេដឹកនាំក្រុងបាងកក ពេលនេះមានការធូរលុងជាមួយរបបហ៊ុន សែនយ៉ាងនេះ? នេះមកពីមេដឹកនាំសៀមដើរទាន់សភាពការណ៍ពិភពលោកហើយគេចាប់ផ្តើមប្តូរនយោបាយរបស់ប្រទេសសៀម រួចជាស្រេចដែរ។ នាយករដ្ឋមន្ត្រីសៀមលោក CHATIHAI បានប្រកាសថា តំបន់នេះត្រូវតែទំរង់ពីកន្លែងប្រឈមមុខទៅជាទីផ្សារ។ នាខែមករា១៩៨៩ រដ្ឋមន្ត្រីការបរទេសសៀម លោក SHIDDHI SAVETSALA បានធ្វើដំណើរទៅទីក្រុងហាណូយ និងជួបពិភាក្សាជាមួយលោក NGAYEN COTHATH។ ក្នុងឱកាសនោះ លោក SHIDDHI SAVETSALA បានបង្ហាញថា៖ ការដែលយើងបានដាក់កំហុសលើគ្នាទៅវិញទៅមកតាំងពី១០ឆ្នាំមកហើយនោះ ត្រូវបញ្ចប់

និងយើងទាំងពីរខាងនេះមានកាតព្វកិច្ច ដើម្បីធ្វើការងារជាមួយគ្នាក្នុងដំណោះស្រាយជំលោះកម្ពុជា។ ក្រោយមកលោក កាទីហៃ បានអនុវត្តមួយជំហ៊ានទៀត គឺនៅខែកុម្ភៈ១៩៨៩ លោកបានធ្វើការអញ្ជើញលោក ហ៊ុន សែន អោយទៅធ្វើដំណើរទស្សនកិច្ចនៅទីក្រុងបាងកក។ ក្នុងពេលនោះ លោក ហ៊ុន សែន បានអំពាវនាវដល់ក្រុមពាណិជ្ជកម្មសៀម ជាមួយនឹងការដាក់ទុនក្នុងប្រទេសកម្ពុជាកុំអោយយឺតយ៉ាវពេក។ ពីរបីសប្តាហ៍បន្ទាប់ពីធ្វើដំណើរទស្សនកិច្ចនៅប្រទេសយួន លោក SHIDDHI បានធ្វើដំណើរទៅទីក្រុងប៉េកាំង ក្នុងគោលបំណងលប់បំបាត់ក្នុងការធ្វើអោយខឹងដោយសារតែនយោបាយថ្មីរបស់ប្រទេសសៀមនៅតំបន់នេះ។

នៅក្នុងទស្សនាវដ្តីរបស់អាល្លឺម៉ង់ឈ្មោះ Der Spiegel 1991 បានសរសេរថា៖ ក្រុមប៉ុល ពត បានធ្វើការវាយលុកយកបានតំបន់ប៉ៃលិន និងកាន់កាប់តំបន់នេះ ហើយបានបើកអោយពួកជំនួញសៀមចូលមកប្រមូលយកសម្បត្តិធម្មជាតិខ្មែរ ដូចជា ត្បូង តាមចិត្តគ្មានការកំណត់ និងត្រួតពិនិត្យទេ។ ជារៀងរាល់ខែ ពួកសៀមត្រូវប្រគល់ប្រាក់អោយពួកប៉ុល ពត ចំនួន ៥លានដុល្លាអាមេរិក។ មិនតែប៉ុណ្ណោះ ក្រុមប៉ុល ពត បានកសាងផ្លូវថ្នល់ ដើម្បីអោយក្រុមជំនួញសៀមចូលមកដឹកយកឈើពីស្រុកខ្មែរទៀតផង។

បានសេចក្តីថា មេដឹកនាំសៀមពេលនេះ វៃឆ្លាតខាងខូច ចំពោះជីវិតខ្មែរ តែល្អចំពោះជាតិសៀមដែលធ្វើអោយប្រទេសសៀម រីកចំរើនដល់សព្វថ្ងៃ។ មេដឹកនាំសៀមជាអ្នកឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយ។ ខាងរបបលោក ហ៊ុន សែនក៏មេដឹកនាំសៀមមានទំនាក់ទំនងលើផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម ហើយខាងក្រុមលោក ប៉ុល ពត ក៏មេដឹកនាំសៀមមិនផ្តាច់ខ្លួនចេញ។ មេដឹកនាំសៀមបានចំណេញកប់ក្តោងទាំងសងខាង។



# ជំហរជប៉ុនចំពោះខ្មែរ

តើជប៉ុនមានឥទ្ធិពលក្នុងវិបត្តិកម្ពុជារឺទេ?

នៅកំឡុងខែកក្កដា១៩៨៤ រដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន លោក ABE SHINTARO បានលាតត្រដាងនូវសំណូមពរ ដើម្បីដោះស្រាយវិបត្តិកម្ពុជា ដែលមាន៣ចំណុច៖

១- បើសិនជារដ្ឋទាំងអស់ដែលចូលរួមដោះស្រាយ បានសំរេចយល់ព្រមអំពីការដកកងទ័ពយួនចេញពីព្រំប្រទល់ខ្មែរ-សៀម និងបង្កើតបានជាតំបន់សន្តិភាពមួយ ដែលឋិតនៅក្រោមការត្រួតត្រាពិនិត្យរបស់កងទ័ពសន្តិភាព ប្រទេសជប៉ុននឹងទទួលខុសត្រូវខាងថវិកា។

២- បើសិនជាបន្ទាប់ពីការដកកងទ័ពយួនចេញអស់ពីកម្ពុជា ត្រូវមានការបោះឆ្នោតដោយសេរី ដែលឋិតនៅក្រោមការត្រួតពិនិត្យរបស់អន្តរជាតិ ប្រទេសជប៉ុននឹងទទួលជួយនូវអ្វីដែលមិនមែនជាយោធា។

៣- បើសិនជាមានសន្តិភាពពិតប្រាកដនៅប្រទេសកម្ពុជា រដ្ឋាភិបាលជប៉ុនទទួលជួយខាងសេដ្ឋកិច្ច និងបច្ចេកទេស។

នៅក្នុងឱកាសជួបជាមួយរដ្ឋមន្ត្រីការបរទេសអាស៊ានលោក ABE បានចោទថា៖ មេដឹកនាំក្រុងហាណូយមិនយកចិត្តទុកដាក់និងសំណូមពររបស់ជប៉ុន។ ពិសេសទៅទៀត ថែមទាំងធ្វើការវាយប្រហារ កាន់តែខ្លាំង ដែលបណ្តាលអោយប្រជាពលរដ្ឋកម្ពុជារាប់ពាន់នាក់ ត្រូវភៀសខ្លួនរត់ចូលទៅដីសៀម។ លោក ABE បានទិតៀនយ៉ាងខ្លាំងចំពោះឥរិយាបថរបស់មេដឹកនាំក្រុងហាណូយ។ រដ្ឋាភិបាលជប៉ុន បានធ្វើការគាបសង្កត់ទៅក្រុងហាណូយកាន់តែខ្លាំង។ បន្ទាប់ពីការលុកលុយរបស់ក្រុងហាណូយក្នុង

ប្រទេសកម្ពុជា មេដឹកនាំជប៉ុនធ្លាប់តែជួយផ្នែកសេដ្ឋកិច្ចប្រទេសយួនប្រហែល 14 Mrd-Yen(ប្រហែល 57 Mio.US) ក៏ត្រូវផ្អាក់។

ចូលមកដល់ឆ្នាំ១៩៨៧ ដោយសារតែផលប្រយោជន៍ខាងសេដ្ឋកិច្ចធំជាងជីវិតប្រជាពលរដ្ឋខ្មែរ ដែលធ្វើអោយមេដឹកនាំជប៉ុនប្តូរឥរិយាបថ។ ចាប់តាំងពីលោក NGUYEN VAN LINH ចូលមកក្នុងខែធ្នូ១៩៨៦ គឺការខិតខំរបស់ប្រទេសយួនក្នុងការរកថវិកាពីបរទេស ត្រូវបានជំរុញកាន់តែខ្លាំង និងដើម្បីធ្វើសេដ្ឋកិច្ចក្នុងប្រទេសអោយមកជាធម្មតាវិញ។ ការបង្រួបបង្រួមពាណិជ្ជកម្មរវាងប្រទេសជប៉ុន និងយួន ត្រូវបានបើកការពិភាក្សាដើម្បីធ្វើគំរោងដាក់ទន់។ រដ្ឋាភិបាលយួនត្រូវបង្ហាញពីទីកន្លែង និងកម្មករ ចំណែករដ្ឋាភិបាលជប៉ុនចេញថវិកាចំនួន៥០០Mio.Yen។ នៅខែមេសា ប្រទេសយួនបានដឹកនាំប្រេងទៅប្រទេសជប៉ុន និងមានសន្និសញ្ញាផ្សេងៗខាងផ្នែកពាណិជ្ជកម្មជប៉ុន និងយួនដែលបានសរសេរនៅក្នុងទស្សនាវដ្តីអាល្លឺម៉ង់ Suedostasien aktuell ចេញខែឧសភា១៩៨៧នៅលើទំព័រ២៨៣។

ការចាប់ផ្តើមរបស់ប្រទេសជប៉ុនខាងផ្នែកពាណិជ្ជកម្មជាមួយប្រទេសយួន បានធ្វើអោយប្រទេសមួយចំនួនដែលចង់ដោះស្រាយវិបត្តិកម្ពុជាមានការបារម្ភ។ ប្រទេសអាស៊ានបានធ្វើការទិតៀនជាខ្លាំងចំពោះពាណិជ្ជកម្មរបស់ប្រទេសជប៉ុនជាមួយប្រទេសយួន។ ប្រទេសអាស៊ានបារម្ភខ្លាចតែការប្រឹងប្រែងដើម្បីដោះស្រាយវិបត្តិកម្ពុជា ត្រូវវិនាស។ ហេតុនេះ បានជាមានប្រតិកម្មជាច្រើន ដូចជា ក្នុងដំណើរទស្សនកិច្ចមួយក្នុងទីក្រុងតូក្យូនៅចុងខែឧសភា១៩៨៧ លោករដ្ឋមន្ត្រីក្រសួងការបរទេសសឹង្ហបុរី DHANABALAN ប្រកាសអោយដឹងថា៖ រដ្ឋអាស៊ានមិនធ្វើការជំទាស់និងសកម្មភាពរបស់ថៅកែជប៉ុននៅប្រទេសយួន ក្នុងករណីដែលសកម្មភាពនោះប្រព្រឹត្តទៅតែ



ក្នុងវិស័យពាណិជ្ជកម្ម។ លោក DHANABALAN បានសង្កត់ធ្ងន់អំពីជំហរអាស៊ាន។ រដ្ឋនៃសមាជិកអាស៊ានសង្ឃឹមថា ថៅកែជប៉ុននឹងមិនបញ្ចេញឥណទានទៅអោយរដ្ឋាភិបាលយួនឡើយ។ លោកបានប្រកាសទៀតថា៖ នេះគឺជាគោលបំណងរបស់អាស៊ាន ក្នុងការបដិសេធគ្រប់ជំនួយទាំងអស់ចំពោះប្រទេសយួន។ ភាគីប្រទេសជប៉ុនក៏បានធានានៅចំពោះមុខលោក DHANABALAN ថា៖ សកម្មភាពរបស់ថៅកែជប៉ុននៅប្រទេសយួនគឺជាវិស័យពាណិជ្ជកម្មសុទ្ធ។ ការជំនួយអំពីគមនាគមន៍ត្រូវតែបញ្ចប់។ ប្រទេសអាស៊ានបានយល់ព្រមតាមការពន្យល់នេះ។

នេះសរបញ្ជាក់ថា៖ រដ្ឋាភិបាលជប៉ុនវាងវៃ ហក់លោតទៅតាមពេលវេលាដែលអាចធ្វើអោយប្រាក់ហូរចូលតែប៉ុណ្ណោះ។ រដ្ឋាភិបាលជប៉ុន គឺជាអ្នកចូលរួមបន្ថយបញ្ហាជំលោះកម្ពុជា បន្ថយទុក្ខសោកខ្មែរ តាមរយៈទំនាក់ទំនងពាណិជ្ជកម្មរបស់ខ្លួនជាមួយប្រទេសយួន។ ប្រទេសអាស៊ានក្តី សហគមអន្តរជាតិក្តី ខំហ៊ុំព័ទ្ធសេដ្ឋកិច្ចប្រទេសយួនអោយដុនដាប ដើម្បីអោយមេដឹកនាំយួនបង្ខំខ្លួនលះបង់កម្ពុជាជាបន្ទាន់ បែរជាមេដឹកនាំជប៉ុនទៅលួចសហការខាងពាណិជ្ជកម្ម និងទ្រទ្រង់ប្រទេសយួនទៅវិញ។ បើសិនជាពុំមានប្រតិកម្មពីបណ្តាប្រទេសអាស៊ានទេនោះ ប្រហែលជាជប៉ុនមិនរវល់និងជីវិតខ្មែរទេ អោយតែខ្លួនបានចំណេញ។

# ហេតុអ្វីបានគេនាំគ្នាធ្វើបាបខ្មែរ

ប្រទេសដែលតែងតាមព្យាបាទ ឈ្នានីស និងតាមឈ្លានពានប្រទេសខ្មែរ គឺប្រទេសចិន យួន និងសៀម ដូចបានរៀបរាប់ក្នុងទំព័រមុខមកហើយ។ ចំណែក ប្រទេសបារាំង ជប៉ុន សហរដ្ឋអាមេរិក អតីតសហភាពសូវៀត សុទ្ធតែធ្លាប់មកធ្វើចៅហ្វាយនៅតំបន់នេះ ទោះយូរឺឆាប់។ ថា មេដឹកនាំចិន យួន និងសៀមចុះ ព្យាយាមឈ្លានពានប្រទេសខ្មែរ ចុះមូលហេតុអ្វីបានជាជប៉ុន អតីតសហភាពសូវៀត សហរដ្ឋអាមេរិក បារាំងព្រួតគ្នាធ្វើបាបខ្មែរខ្លាំងម្ល៉េះដែរ? ហើយបែរជាអោយផលប្រយោជន៍ទៅប្រទេសយួន និងសៀមទៅវិញ។ ត្រង់វគ្គនេះ សូមលើកជាសង្ខេបមកវិញដូចតទៅ៖

ឆ្នាំ១៩៤១ មេដឹកនាំជប៉ុនបានទាមទារទឹកដី ដែលជារបស់ខ្មែរសុទ្ធសាធទៅអោយប្រទេសសៀម។ ក្នុងអំឡុងពេលដែលសហគមអន្តរជាតិកំពុងស្វែងរកដំណោះស្រាយវិបត្តិកម្ពុជា ហើយសហគមអន្តរជាតិ បានប្រើមធ្យោបាយហ៊ុំព័ទ្ធសេដ្ឋកិច្ចប្រទេសយួនអោយដុនដាប ដើម្បីអោយមេដឹកនាំយួនបង្ខំខ្លួនលះបង់កម្ពុជាជាបន្ទាន់ បែរជាក្រុមមេដឹកនាំជប៉ុនទៅលួចសហការខាងពាណិជ្ជកម្ម និងទ្រទ្រង់ប្រទេសយួនទៅវិញ ដែលធ្វើអោយមេដឹកនាំយួនបានចិត្ត បន្តសង្គ្រាមនៅកម្ពុជា (សូមអានត្រង់ "ជំហរជប៉ុនចំពោះខ្មែរ")។

ចំណែកឯ សហភាពសូវៀតចង់ពង្រឹងឥទ្ធិពលលទ្ធិកុំមុយនិស្តរបស់ខ្លួនដើម្បីត្រួតត្រាតំបន់នេះ ស្រាប់តែទៅជួយមេដឹកនាំយួនអោយឈ្លានពានប្រទេសខ្មែរ និងសំលាប់ខ្មែរ។ ក្នុងសៀវភៅរបស់លោក Peter J. Opitz ទំព័រ១២២បានសរសេរថា៖ បើគ្មានសូវៀតនៅពីក្រោយ និងជួយទាំង



នយោបាយ និងសម្ភារៈ ព្រមទាំងមានសន្ធិសញ្ញារវាងសូវៀត និងប្រទេសយួនអំពីមិត្តភាព និងសហប្រតិបត្តិការរយៈពេលយូរអង្វែងជាមូលដ្ឋានទេ ក្រុមមេដឹកនាំក្រុមហាណូយមិនអាចសំរេចចិត្តចូលលុកលុយ និងកាន់កាប់កម្ពុជាឡើយ។

ឯសហរដ្ឋអាមេរិក ក៏បានធ្វើបាបខ្មែរ ដូចបាននិយាយនៅក្នុងទំព័រមុនរួចហើយ ដូចជា ការទំលាក់គ្រាប់បែកក្នុងប្រទេសខ្មែរដើម្បីកំទេចយួនយៀកកុង តែទំលាក់មិនចំងាប់ពួកយួនយៀកកុង គឺចំស្លាប់តែពលរដ្ឋខ្មែរ និងការយកទាហានយួនខាងត្បូងធីវគី មកអោយជួយច្បាំងរដ្ឋាភិបាលលន់នល់ តែទីបំផុតពួកយួនធីវគីធ្វើបាបខ្មែរ សំលាប់ខ្មែរយ៉ាងព្រៃផ្សៃ។

បើនិយាយពីបារាំងវិញ ស្ទើរយើងមិនអាចជឿបាន មិនគួរណាក្រុមមេដឹកនាំបារាំង ធ្វើបាបខ្មែរដល់ម្លឹងសោះ(សូមអានត្រង់ "ប្រទេសខ្មែរ និងមហិច្ឆតាបារាំង")។ នៅឆ្នាំ១៩៤៩ មេដឹកនាំបារាំងបានកាត់ទឹកដីរបស់ខ្មែរ "កម្ពុជាក្រោម" អោយទៅប្រទេសយួន។ បារាំងដកយកបឹងឡូនេសាទដែលប្រជាពលរដ្ឋខ្មែរធ្លាប់រកត្រីផ្គត់ផ្គង់គ្រួសារ ហើយលក់ទៅអោយដង្ហៅយួនក្នុងសម័យអាណាព្យាបាលបារាំង(ហ៊ិន ស៊ីថាន ទំព័រ២១)។ ទន្ទឹមនិងនេះ បារាំងជាអ្នកចូលរួមបង្កើតអោយមានសង្គ្រាមសំលាប់ខ្មែរ និងបង្កអោយមានភាពវិនាសកម្មហិនហោចនៃប្រទេសខ្មែរ។ នៅពេលដែលប្រទេសបារាំងមកធ្វើចៅហ្វាយខ្មែរ មេដឹកនាំបារាំងបានយកជនជាតិយួនរាប់សែននាក់អោយមកធ្វើការក្នុងស្រុកខ្មែរ ជាកម្មករចំការកៅស៊ូ អ្នកធ្វើការនៅក្នុងរដ្ឋបាល និងអ្នកជំនួយការក្នុងប៊ុយរ៉ូ ដោយយកលេសថា ជនជាតិយួនឧស្សាហ៍ និងធ្វើការល្អ ចំណែកខ្មែរខ្ជិល ធ្វើការមិនកើត និងទន់ជ្រាយក្នុងការងារ។ បើខ្មែរមានភាពដូច បារាំងមូលបង្កាច់មែននោះ គឺខ្មែរមិនអាច

មានភាពជឿនលឿនក្នុងសម័យអង្គរបានទេ។ ការវាយតំលៃរបស់បារាំងបែបនេះគ្រាន់យកធ្វើជាលេសដើម្បីទៅយកជនជាតិយួនអោយមករំលាយជាតិខ្មែរតែប៉ុណ្ណោះ និងទៅជួយផ្តល់លទ្ធភាពដល់មេដឹកនាំយួនអោយពង្រីកទឹកដីថែមទៀតផង។ ពួកយួនដែលបារាំងជញ្ជូនមកទាំងនេះទីបំផុតធ្វើអោយខ្មែររងទុក្ខវេទនា ធ្វើអោយប្រទេសខ្មែរកើតសង្គ្រាមសំលាប់ខ្មែរ ព្រោះពួកយួននេះដែលស្គាល់ដឹងកិច្ចការផ្ទៃក្នុងរបស់ខ្មែរ និងក្លាយជាភ្នាក់ងារពិសេសរបស់រដ្ឋាភិបាលយួន ក្នុងការបង្កធ្វើអោយមានភាពរំជើបរំជួលក្នុងសង្គមខ្មែរ បង្កើតអោយមានអសន្តិសុខ។ ពួកយួនទាំងនេះគឺសុទ្ធតែជាសមាជិករបស់បក្សកុំមុយនីស្តឥណ្ឌូចិន ដែលធ្វើសកម្មភាពពាសពេញប្រទេសខ្មែរ។ សៀវភៅរបស់លោក បិន ខៀនិន "ប្រវត្តិវិទូអូស្រ្តាលី" បានសរសេរនៅលើទំព័រ៣៥"សាខាបក្សកុំមុយនីស្តយួននៅជប់ដែលពេលនោះបានក្លាយជាផ្នែកមួយរបស់បក្សកុំមុយនីស្តឥណ្ឌូចិនទៅហើយ មានតែកម្មករយួន ចំណែកឯកម្មករខ្មែរវិញបានចូលរួមក្នុងផ្នែកខ្លះៗប៉ុណ្ណោះ។ ក្នុងអំឡុងពេលស្ទើរពេញមួយទសវត្សឆ្នាំ១៩៣០ សកម្មភាពបដិវត្តនៅក្នុងប្រទេសកម្ពុជា មានតែជនជាតិយួន(ជនទាំងនោះជា កម្មករចំការកៅស៊ូ មន្ត្រីថ្នាក់តូច កម្មករជំនាញក្នុងទីក្រុង កសិករនៅតាមព្រំដែន)និងសមាជិកនៃសមាគមចិនប៉ុណ្ណោះ"។ ពួកទាំងនេះ តែងដើរបញ្ចុះបញ្ចូលពលរដ្ឋខ្មែរទៅតាមមនោគមន៍របស់ពួកគេ។ នៅលើទំព័រ៤០នៃសៀវភៅដដែលនេះបានសរសេរបន្តថា៖ សកម្មជនយួនបានធ្វើកិច្ចប្រឹងប្រែងជាច្រើនដើម្បីបង្កើតបក្សកុំមុយនីស្តឥណ្ឌូចិននៅជនបទនៃប្រទេសកម្ពុជា។ បក្សកុំមុយនីស្តនៅពេលនោះបានបោះពុម្ពផ្សាយនូវកាសែតតាមផ្លូវច្បាប់ នៅទីក្រុងហាណូយ។ កាសែតនោះឈ្មោះ"ការងារ"។ អ្នកអានជាច្រើននៅទីក្រុង



ភ្នំពេញ។ ប៉ុន្តែមើលទៅទំនងជាអ្នកអានទាំងនោះភាគច្រើនពុំមែនជាខ្មែរ។

ជនរួមជាតិជាទីស្នេហា! តើខ្មែរមានកំហុសអ្វី បានជាគេចោមរោមធ្វើបាបខ្មែរយ៉ាងនេះ? នេះគឺជាសំនួរដែលខ្មែរត្រូវតែប្រឈមមុខរុករកអោយឃើញរឹសគល់ និងមូលហេតុច្បាស់លាស់នាពេលនេះ ដើម្បីចៀសវាងកុំអោយអំពើនេះកើតមានឡើងម្តងហើយម្តងទៀត។

# សង្គ្រាមសំលាប់ខ្មែរត្រូវបានបញ្ចប់ (ឆ្នាំ ១៩៩១)

នៅឆ្នាំ១៩៨៩ ព្រឹត្តិការណ៍ពិភពលោកត្រូវប្រែក្រឡះ។ ក្រុមបណ្តាប្រទេសធ្លាប់ប្រកាន់លទ្ធិសង្គមនិយម ត្រូវបាក់បែក រលំរលាយ ជាពិសេសអតីតសហភាពសូវៀត និងបណ្តាប្រទេសនៅអ៊ឺរ៉ុបខាងកើត។ ការប្រឈមមុខរវាងបក្សសម្ព័ន្ធលោកខាងលិច (បណ្តាប្រទេសប្រកាន់យករបបប្រជាធិបតេយ្យសេរី) និងលោកខាងកើត(បណ្តាប្រទេសប្រកាន់យករបបលទ្ធិសង្គមនិយម) ត្រូវរលាយ(ដែលហៅថា សង្គ្រាមត្រជាក់)។ បណ្តាប្រទេសនៅអឺរ៉ុបខាងកើត ដែលជាប្រទេសធ្លាប់ប្រកាន់យករបបលទ្ធិសង្គមនិយម បានធ្វើដំណើរតំរង់ទៅរកលទ្ធិប្រជាធិបតេយ្យសេរីនិយមវិញ។

ចាប់តាំងពីលោក GORBATSCHOW បានឡើងកាន់អំណាចធ្វើជាមេដឹកនាំ(General-Secretary)របស់សហភាពសូវៀតមក ធ្វើអោយជំលោះកម្ពុជាធូរស្រាល។ នយោបាយរបស់លោក GORBATSCHOW បានរកឃើញនូវផលប្រយោជន៍ និងមិត្តភាពជាមួយប្រទេសចិន។ សហភាពសូវៀតបានអោយតំលៃទៅលើលទ្ធផលនៅ JIM ថា ជាវិជ្ជមាន។ សហភាពសូវៀតត្រៀមខ្លួនជាស្រេច ដើម្បីចូលរួមធ្វើការជាមួយរដ្ឋដែលមានចំណាប់ចំណូលចិត្តក្នុងការចូលរួមដោះស្រាយវិបត្តិកម្ពុជា។ នេះជាការពិតថា មេដឹកនាំទីក្រុងម៉ូស្គូ បានអនុវត្តការគាបសង្កត់មេដឹកនាំក្រុងហាណូយរួចជាស្រេចទៅហើយ។ ចំពោះការពិភាក្សាមួយរវាងមេដឹកនាំសៀម និងសូវៀតកាលពីខែឧសភា១៩៨៨ ជាឧទាហរណ៍ថា រដ្ឋាភិបាលសូវៀតបានធានាចំពោះភាគីសៀមថា យើងបានបង្ខំក្រុមមេដឹកនាំយួន ដើម្បីអោយដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជា។



នៅថ្ងៃទី១៨កក្កដា១៩៩០ រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក JAMER BACKER បានប្រកាសពន្យល់បន្ទាប់ពីការពិភាក្សាជាមួយរដ្ឋមន្ត្រីក្រសួងការបរទេសសូវៀត SCHEARDNADSE ថា៖ សហរដ្ឋអាមេរិកចាប់ពីពេលនេះទៅ ឈប់ទទួលស្គាល់រដ្ឋាភិបាលត្រីភាគី ដែលដឹកនាំដោយលោក នរោត្តម សីហនុ ជាតំណាងរបស់កម្ពុជានៅអង្គការសហប្រជាជាតិ។ ក្នុងពេលជាមួយគ្នានេះដែរ លោក BACKER បង្ហាញពីការត្រៀមខ្លួនជាស្រេចរបស់សហរដ្ឋអាមេរិក ដើម្បីទទួលយកការពិភាក្សាជាមួយរដ្ឋាភិបាលយួនក្នុងការសំរេចនូវវិបត្តិកម្ពុជា។ គំនិតផ្តួចផ្តើមរបស់សហរដ្ឋអាមេរិកនេះ គឺជាចំណុចយ៉ាងសំខាន់បំផុតដែលមេដឹកនាំក្រុងហាណូយរង់ចាំជាយូរមកហើយ។

ម្យ៉ាងទៀតគឺសំណាងយ៉ាងខ្ពស់បំផុតរបស់មេដឹកនាំយួនដើម្បីបង្កើតអោយមានទំនាក់ទំនងជាធម្មតាវិញជាមួយក្រុងវ៉ាស៊ីនតោន។ ប៉ុន្តែផ្ទុយទៅវិញ ការប្តូរនយោបាយដ៏រហ័សរបស់សហរដ្ឋអាមេរិកនេះ មានន័យថា បរាជ័យសំរាប់នយោបាយរបស់អ្នកដឹកនាំក្រុងប៉េកាំង។ ត្រង់ខណៈនេះ មេដឹកនាំក្រុងប៉េកាំងត្រូវពិចារណាថា មតិរបស់អន្តរជាតិដែលបានដាក់ទណ្ឌកម្មទៅលើប្រទេសយួន ទាំងផ្នែកសេដ្ឋកិច្ច និងនយោបាយពីមុន បន្ទាប់ពីមេដឹកនាំក្រុងវ៉ាស៊ីនតោនប្តូរនយោបាយ នឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗនេះ។ ពេលនេះធ្វើអោយមេដឹកនាំក្រុងប៉េកាំង ត្រូវតែតម្រង់ទិសដៅនៃនយោបាយការបរទេសខ្លួនម្តងទៀត ព្រោះមេដឹកនាំក្រុងប៉េកាំងម្នាក់ឯងមិនអាចធ្វើអោយនយោបាយរបស់មេដឹកនាំក្រុងហាណូយ នៅឯកោលើឆាកអន្តរជាតិបានឡើយ។ មេដឹកនាំក្រុងប៉េកាំងមិនអាចទទឹងរឹងរូស និងពង្រឹងនូវគោលនយោបាយរបស់ខ្លួន ចំពោះវិបត្តិកម្ពុជាបានទៀតទេ គឺត្រូវ

បង្ខំខ្លួនលះបង់មហិច្ឆតាក្នុងតំបន់នេះ និងបង្ខំធ្វើយ៉ាងណាដើម្បីរកភាពស្របគ្នាជាមួយក្រុងម៉ូស្គូ និងក្រុងហាណូយអោយទាន់ពេលវេលា។ កត្តាទាំងពីរខាងលើនេះ(១- ក្រុមមេដឹកនាំយួនអស់បង្អែក ២- ក្រុមមេដឹកនាំចិនអស់បរិវារ) ដែលជាពេលមួយដ៏ល្អសំរាប់ការចុះសំរុងគ្នាអំពីវិបត្តិកម្ពុជា។

សហរដ្ឋអាមេរិកដែលពីមុនបានដាក់ទណ្ឌកម្មដល់ប្រទេសយួន ពេលនេះចង់រៀបចំធ្វើទំនាក់ទំនងឡើងវិញ តែដោយភ្ជាប់ទៅនឹងបញ្ហាកម្ពុជា។ កាសែតអាល្លឺម៉ង់ឈ្មោះ កាសែតប្រជាជនប៊ែឡាំង(Berliner Zeitung)ចុះថ្ងៃទី២៧មេសា១៩៩១ បានសរសេរក្រោមចំណងជើង "សហរដ្ឋអាមេរិក-យួន-សហានិមិត្តហេតុចុងបញ្ចប់ត្រូវជំនះ(USA-Vietnam-Symdrom endlich ueberwunden)"។ ដើម្បីធ្វើទំនាក់ទំនងជាធម្មតាវិញ សហរដ្ឋអាមេរិក បានដាក់លក្ខខណ្ឌដល់អ្នកនយោបាយយួនដែលមានចំណុចដូចតទៅ៖

- បើមេដឹកនាំយួនចាប់ផ្ដើមបញ្ចប់នូវសន្ធិសញ្ញាអន្តរជាតិ ជាមួយប្រទេសកម្ពុជា មេដឹកនាំក្រុងវ៉ាស៊ីនតោននឹងអនុញ្ញាតអោយថៅកែអាមេរិកធ្វើដំណើរមកកាន់ប្រទេសយួន។

- បើមេដឹកនាំយួនទទួលស្គាល់ការឈប់បាញ់នៅកម្ពុជា ដែលរៀបចំដោយអង្គការសហប្រជាជាតិ ការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច ប្រឆាំងប្រទេសយួននឹងបន្ថយមួយចំនួន។

- ក្រោយមានវត្តមានរបស់អង្គការសហប្រជាជាតិ ក្នុងប្រទេសកម្ពុជា មេដឹកនាំយួន ត្រូវតែដកអ្នកជំនាញការរបស់ខ្លួនទាំងអស់ចេញពីប្រទេសកម្ពុជា សហរដ្ឋអាមេរិកនឹងលប់បំបាត់ទាំងស្រុងនូវការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច។ ក្រុងហាណូយ និងក្រុងវ៉ាស៊ីនតោនត្រូវបង្កើតអ្នកតំណាងជាផ្លូវការ និងមេដឹកនាំយួន ត្រូវអនុញ្ញាតអោយខ្ចីប្រាក់នៅអន្តរជាតិខ្លះ។



- ប្រទេសកម្ពុជាធ្វើការបោះឆ្នោតដោយសេរី ក្រោមការត្រួតពិនិត្យរបស់អន្តរជាតិ សហរដ្ឋអាមេរិកនឹងធ្វើការទំនាក់ទំនងជាផ្លូវការធម្មតាវិញជាមួយក្រុងហាណូយ និងភ្នំពេញនៅលើគ្រប់វិស័យ និងការខ្ចីប្រាក់ដោយគ្មានកំណត់។

ក្នុងកាសែតនេះបានសរសេរបន្តទៀតថា៖ លក្ខខណ្ឌខាងលើនេះប្រាដកជាពិបាក ជូរចត់ រឹង និងឥតមេត្តាចំពោះប្រទេសយួន។ តែក្នុងពេលជាមួយគ្នានេះ បានធ្វើអោយមេដឹកនាំយួនចាប់ចិត្តចាប់អារម្មណ៍ដែរ។ ប៉ុន្តែចុងបញ្ចប់ វាគ្មានផ្លូវណាដែលអ្នកនយោបាយយួន អាចជ្រើសរើសតទៅទៀតបានដែរ ព្រោះថា ជំនួយដែលចេញពីបណ្ដាប្រទេសសហព័ន្ធសង្គមនិយមសំខាន់ៗ បន្ទាប់ពីការប្រែប្រួលនយោបាយនៅអឺរ៉ុបខាងកើត និងសហភាពសូវៀត មិនមានសង្ឃឹមទៀតឡើយ។

ទន្ទឹមនឹងនោះ សាធារណមតិលើសកលលោកបានខំធ្វើការគាបសង្កត់ជាខ្លាំងទៅលើក្រុមមេដឹកនាំយួនពីមួយថ្ងៃទៅមួយថ្ងៃ ដូចជា បណ្ដាប្រទេសអាស៊ានជាដើម។ ទាំងអស់នេះគឺជាសម្ពាធដែលធ្វើអោយក្រុមមេដឹកនាំយួនត្រូវតែប្ដូរគំនិត និងបង្ខំខ្លួនក្នុងការលះបង់ប្រទេសកម្ពុជាដោយទាំងស្រណោះស្រណោក។ ចាប់ពីឆ្នាំ១៩៩១មក យើងសង្កេតឃើញការរកដំណោះស្រាយ ស្ដីពីវិបត្តិកម្ពុជាកាន់តែមានភាពធូរស្រាលឡើងជាងមុន ហើយក្នុងពេលជាមួយគ្នានោះដែរ ប្រទេសដែលចង់យកដំលោះកម្ពុជាធ្វើជាឈ្នាន់ ដើម្បីឈានទៅដោះស្រាយវិបត្តិទ័លច្រករបស់ពួកគេនោះ ក៏ទទួលបានជោគជ័យជាបណ្ដើរៗដែរ ដូចជា៖

ប្រទេសយួន

- បន្ទាប់ពីការយល់ព្រមដកកងទ័ពរបស់ខ្លួនជាផ្លូវការចេញពីប្រទេស

កម្ពុជា និងទទួលយកដំណោះស្រាយខាងផ្នែកនយោបាយអំពីបញ្ហាកម្ពុជា ប្រទេសជឿនលឿននៅអាស៊ីនិងអឺរ៉ុប បង្កើនការជួយដល់សេដ្ឋកិច្ចប្រទេសយួន និងការវិនិយោគទុន។

- ទំនាក់ទំនងជាមួយក្រុងប៉េកាំងត្រូវបានដោះស្រាយមកធម្មតាវិញ។

- ទំនាក់ទំនងសេដ្ឋកិច្ចប្រទេសយួន ត្រូវបានសំរេចក្នុងការប្តូរទិសដៅចូលមកបណ្តាប្រទេសអាស៊ាន។

- ក្រុងហាណូយ មានទំនាក់ទំនងធម្មតាជាមួយក្រុងវ៉ាស៊ីនតោន។

ប្រទេសចិន

- ទំនាក់ទំនងរបស់ក្រុងប៉េកាំង ជាមួយនិងក្រុងហាណូយ ត្រូវបានសំរួលមកកាន់តែល្អប្រសើរ។

- ប្រទេសចិនទៅរកបណ្តាប្រទេសអាស៊ាន ក៏ធូរស្រាល។

ប្រទេសសូវៀត

- ភាពធូរស្រាលក្នុងទំនាក់ទំនងទៅរកក្រុងប៉េកាំង និងវ៉ាស៊ីនតោន ក៏កាន់តែប្រសើរឡើងជាលំដាប់។

ប្រទេសសូវៀត-ចិន

- សំរាប់ប្រទេសទាំងពីរមានសារសំខាន់ណាស់ គឺការប្រឈមមុខរវាងកងទ័ពនៃមហាអំណាចទាំងពីរនៅតំបន់ខាងជើងនៃប្រទេសចិន ត្រូវបានកាត់បន្ថយ។

សហរដ្ឋអាមេរិក

- ឥទ្ធិពលដែលចេញពីក្រុងម៉ូស្គូនៅក្នុងតំបន់នេះ ត្រូវបានរាំងស្ទះ។

ប្រទេសសៀម

- ទំនាក់ទំនងរបស់ខ្លួនទៅរកប្រទេសយួន និងប្រទេសចិន ត្រូវទទួល



បានជោជ័យ។

ចំណែកអង្គការសហប្រជាជាតិវិញ ខិតខំរិះរកគ្រប់មធ្យោបាយក្នុងការអោយជំបូន្មានផង បញ្ចុះបញ្ចូលផង បង្ខំផងដល់មេដឹកនាំខ្មែរទាំងបួនបក្សដែលត្រូវបរទេសចាប់បំបែក គួរមុខ លាបពណ៌អោយមាននិន្នាការនយោបាយខុសគ្នា ហើយធ្លាប់តែមានការបង្ហូរឈាមគ្នាគ្មានពេលឈប់ និងព្រមទាំងមិនចង់ឈប់នោះ អោយយល់ព្រមចុះសន្ធិសញ្ញាឈប់សំលាប់គ្នាតទៅទៀតនិងទទួលយកគំរោងសន្តិភាពរបស់អង្គការសហប្រជាជាតិដើម្បីកសាងប្រទេសជាតិឡើងវិញ។ ដោយកត្តាខាងលើទាំងប៉ុន្មាននេះ ទើបនៅថ្ងៃទី២៣តុលា១៩៩១ មានបើកសន្និសិទ្ធយល់ព្រមចុះហត្ថលេខាបញ្ចប់សង្គ្រាមសំលាប់ខ្មែររបស់លោកធំខ្មែរ នៅក្នុងទីក្រុងប៉ារីសប្រទេសបារាំងបានសំរេចជោគជ័យជាស្ថាពរ។

បើតាមការសង្កេតទៅសកម្មភាពរបស់លោកធំខ្មែរយើង ក្នុងការដោះស្រាយរកសន្តិភាពតាមផ្លូវនយោបាយសំរាប់ប្រជាពលរដ្ឋខ្មែរ ឃើញថាលោកធំខ្មែរសុទ្ធតែគួរវង្វេងក្នុងនយោបាយខ្មែរ។ ពួកគេគ្មានសារសំខាន់អ្វីសោះ ចំពោះការរកដំណោះស្រាយដើម្បីបញ្ចប់ការកាប់សំលាប់គ្នានេះ ថ្វីត្បិតតែយើងបានឃើញលោកធំយើងខិតខំយ៉ាងសកម្ម និងមមាញឹក ស្ទើររកពេលសំរាកគ្មាន ក៏ពិតមែន។ យើងគិតមើលតាំងពីឆ្នាំ១៩៨៥ រហូតដល់ឆ្នាំ១៩៩០ លឺសូរតែលោកធំជិះយន្តហោះទៅប្រជុំផង មកធ្វើសន្និសិទ្ធអន្តរជាតិផង ដើម្បីរកដំណោះស្រាយបញ្ចប់សង្គ្រាម តែលទ្ធផលនៅបាញ់សំលាប់ខ្មែរដដែល។ ក្នុងកិច្ចប្រជុំម្តងៗ ពិសេសលោក ហ៊ុន សែន មើលទៅហាក់ដូចជាអ្នកឆ្អិននយោបាយខ្លាំងណាស់។ គាត់ខំតវ៉ាមិនចេះចប់ និងជំទាស់មិនឈប់ឈរ ធ្វើហាក់ដូចជាគាត់មានទិសដៅនយោបាយអ្វីមួយ

ដោយខ្លួនឯងមែនទែនពិតប្រាកដ គ្មានអ្នកណាបញ្ជា គ្មានអ្នកណាបង្គាប់។ តែដល់ពេលលទ្ធផលចុងក្រោយ ទើបយើងឃើញថា៖ គាត់(លោក ហ៊ុន សែន) ប្រៀបបានសត្វសារិកាដែលគេបង្គាប់អោយថាយ៉ាងណា គឺចេះថាតែយ៉ាងនោះ។ ក្រោយពេលដែលសង្គ្រាមត្រជាក់រលាយបាត់ទៅ គេសំរុះសំរួល ចែកផលប្រយោជន៍គ្នាត្រូវ តែជាមួយក្រុងប៉េកាំង ក្រុងហាណូយ ក្រុងបាងកក និងបណ្តាលប្រទេសផ្សេងៗទៀត ស្រាប់តែបញ្ហាជំលោះរវាងលោកធំខ្មែរ ត្រូវបានធូរស្រាលទៅដោយឯកឯង និងលោកធំខ្មែរទៅជាមានការយោគយល់គ្នាជាងមុន និងរហូតដល់យល់ព្រមឈប់ខាំគ្នាទៀតផង។ ឯការខំប្រឹងតវ៉ា ខំប្រឹងជំទាស់របស់លោក ហ៊ុន សែន ពីមុនមកនោះគ្មានន័យអ្វីទាំងអស់សំរាប់ពេលនេះ។ ការដែលគេត្រូវរ៉ូវគ្នាបញ្ចប់សង្គ្រាមសំលាប់ខ្មែរក្នុងប្រទេសខ្មែរនេះ គេគ្មានចំបាច់សួរនាំ រឺពិភាក្សាប្តូរយោបល់ជាមួយលោកធំខ្មែរឡើយ។ ឱ ! លោកធំខ្មែរ។



# បញ្ហាបន្សល់ទុក

បងប្អូនរួមជាតិជាទីស្នេហា រហូតដល់ថ្ងៃនេះ លោកធំប៉ុន្មានទសវត្សរ៍ចុងក្រោយ បានបន្សល់ទុកនូវសោកនាដកម្មដ៏សែនរន្ធត់ សំរាប់កូនខ្មែរជំនាន់ក្រោយក៏ដូចសង្គមខ្មែរទាំងមូល ព្រោះតែគេដឹកនាំប្រជាពលរដ្ឋខ្មែរធ្វើសង្គ្រាមសំលាប់គ្នាឯង ដើម្បីអោយតែឈ្នះតាមចិត្តមានៈនៃបុគ្គលភាព។ លោកធំខ្មែរ តែងតែបង្ខំប្រជាពលរដ្ឋខ្មែរអោយធ្វើសង្គ្រាមដើម្បីដណ្តើមអំណាចអោយខ្លួន។ លោកធំខ្មែរមិនញញើតនឹងបំផ្លាញសម្បត្តិវប្បធម៌ជាតិគ្រប់បែបយ៉ាង រួចស្រែកថាជាអ្នកស្នេហាជាតិ។ តើជាទឹកចិត្តជាតិនិយមបំផ្លិចបំផ្លាញ? រឺទឹកចិត្តជាតិនិយមកសាង?។ សរុបកេរ្តិ៍ដំណែលដែលបានបន្សល់ទុកអោយកូនខ្មែរជំនាន់ក្រោយគឺ៖

- ភាពក្រីក្រទុរគតរបស់ប្រជាពលរដ្ឋខ្មែរ ពិសេស ស្ត្រីមេម៉ាយរាប់ពាន់រាប់ម៉ឺននាក់ និងកុមារគ្របដណ្តប់ដោយជំងឺគ្រប់ប្រភេទ។
- ជនពិការរាប់ម៉ឺននាក់ មានទាំងបាក់ដៃ បាក់ជើង របួសសុះខ្លួន។
- ខ្វះអ្នកមានសមត្ថភាពនៅគ្រប់ស្ថាប័ន ព្រោះលោកធំខ្មែរតែងសំលាប់អ្នកចេះចោល។
- រចនាសម្ព័ន្ធសង្គមធ្លាក់ដល់សូន្យ ផ្លូវគមនាគមន៍ ស្ពាន ត្រូវខ្ទេចខ្ទីដោយសារតែមីន និងគ្រាប់គ្រប់ប្រភេទ។
- ដីស្រែចំការមួយចំនួន ត្រូវក្លាយជាចំការមីន ដែលពួកគេបានកប់នៅក្នុងសម័យសង្គ្រាមដណ្តើមអំណាចគ្នា និងកន្លែងខ្លះទៀតក្លាយជាវាលរណ្តៅគ្រាប់។ មីនរាប់លានគ្រាប់ត្រូវបានកប់ក្នុងដីរហូតដល់សព្វថ្ងៃ ដែលជាឧបសគ្គដ៏ធ្ងន់ធ្ងរដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

- សម្បត្តិវប្បធម៌ មានទាំងរូបចំលាក់នៅតាមប្រាសាទនានា ជាពិសេសប្រាសាទនៅខេត្តសៀមរាប ត្រូវបានបាក់បែកដោយសារសង្គ្រាមមួយផ្នែក និងមួយផ្នែកត្រូវបាត់បង់ពីប្រទេសខ្មែរទៅនៅឯបរទេស។

- ខ្មែរបាត់អស់សុជីវធម៌ជាខ្មែរ ដែលធ្លាប់តែមានប្រពៃណីសាមគ្គីគ្នា ស្រលាញ់គ្នា ជួយគ្នា ឧស្សាហ៍ព្យាយាម និងខំកសាងប្រទេសខ្លួន។ ឥឡូវទៅជាឃោរឃៅ សំលាប់គ្នាយ៉ាងសាហាវ។

- ជាពិសេសជំងឺបាក់ស្បាត

របបគ្រប់គ្រងនីមួយៗ អប់រំ បង្ខំអោយកូនខ្មែរទទួលយកគំនិតនៃបុគ្គលមួយក្តាប់តូច ដើម្បីបំរើមហិច្ឆតារបស់ក្រុមខ្លួន។ មិនត្រឹមតែប៉ុណ្ណោះ លោកធំខ្មែរតែងបង្កើតពាក្យចោទប្រកាន់ ដើម្បីបានជាលេសយកប្រជាពលរដ្ឋខ្មែរទៅសំលាប់។ ប្រាកដណាស់មកដល់ថ្ងៃនេះ បានធ្វើអោយស្មារតីខ្មែរស្ថិតក្នុងសភាពភ័យខ្លាច មិនហ៊ានបញ្ចេញមតិ ដែលផុសចេញពីបេះដូងរបស់ខ្លួនទេ។ វាទាល់តែជិតដិតនិងគ្នាណាស់ រាប់អានគ្នាណាស់នោះទើបខ្មែរហ៊ាននិយាយ ហ៊ានបញ្ចេញមតិតាមការពិតដែលខ្លួនបានយល់ឃើញ។ ឯមន្ត្រីរាជការខ្លះ ធ្វើការទាំងបង្ខំបេះដូងរបស់ខ្លួន ព្រោះខ្មែរបាក់ស្បាតនឹងពាក្យចោទថា៖

- ក្បត់និងរាជបល័ង្គ
- មិនស្មោះត្រង់និងអង្គការ
- ជនមុខពីរ
- ជនក្បត់ជាតិ
- ខ្មាំង

ក្នុងរបបលោក សីហនុ បានបំបាក់កូនខ្មែរអោយឱនលំទោន លុត



ក្រាប មិនអនុញ្ញាតអោយកូនខ្មែរនិយាយការពិត និងចេះដឹងជាងឪឡើយ។ អ្នកដែលចេះដឹងជាងឪ រមែងចោទថា ខ្មែរសេរី រឺខ្មែរក្រហម និងទីបញ្ចប់ គឺជនក្បត់ជាតិ។ អ្នកដែលត្រូវចោទប្រកាន់យ៉ាងនេះហើយ យូរឆាប់មិនបាននៅស្រុក និងនៅមានជីវិតឡើយ។

ក្នុងរបបលោក ប៉ុល ពត គេអប់រំកូនខ្មែរអោយចងកំហឹងនឹងខ្មែរអ្នកចេះដឹង បញ្ញវន្ត គ្រូបង្រៀន អ្នកធ្លាប់នៅទីក្រុង និងប្រជាពលរដ្ឋដែលអង្គការមិនទុកចិត្ត ដោយប្រើពាក្យថា ពួកនេះជាអ្នកជិះជាន់ កេងប្រវ័ញ្ច ជាអ្នកមិនស្មោះត្រង់និងអង្គការ។ ដើម្បីជាលេសយកទៅសំលាប់ តែងចោទអ្នកនេះ អ្នកនោះថា "ជនក្បត់ រឺខ្មាំង"។

ក្នុងរបបលោក ហ៊ុន សែន គេអប់រំអោយកូនខ្មែរចងកំហឹងជានិច្ច មិនអាចបំភ្លេចបានចំពោះពួកខ្មែរក្រហម ដោយគេប្រើពាក្យថា ពួកខ្មែរក្រហមជាអ្នកសំលាប់បងប្អូន ឪពុកម្តាយគ្រួសារខ្លួន។ ចំពោះអ្នកមិនព្រមធ្វើតាមការបញ្ជារបស់ក្រុមខ្លួនតែងចោទថា "ជនមុខពី រឺខ្មែរក្រហម"។ ក្រោយពីចោទយ៉ាងនេះ អ្នកនោះត្រូវបាត់ខ្លួន។

គោលគំនិតនៃរបបនីមួយៗ សុទ្ធតែបង្កើតពាក្យចោទប្រកាន់ ដើម្បីបានជាលេសយកទៅសំលាប់ និងដើម្បីបំបាក់ស្មារតីកុំអោយហ៊ានបញ្ចេញមតិតាមការពិតដែលខ្លួនបានយល់ឃើញ ហើយត្រូវតែហៃអើ លុតក្រាបឱនលំទោន។ ការឱនលំទោន ការលុតក្រាប ការអែបអបបានក្លាយជាមេរោគរាតត្បាតពេញសង្គមខ្មែរ។ សង្គមដ៏ចង្រៃនេះនៅជិតដាមស្ទើរពេញខួរក្បាលកូនខ្មែរ។ ប្រជាពលរដ្ឋខ្មែរស្ទើរតែជាប្រជាពលរដ្ឋ លុតក្រាបដើម្បីបានកិច្ចការអ្វីមួយ ដោយគ្មានគិតពីសមត្ថភាពរបស់ខ្លួន។ ប្រទេសខ្មែរធ្លាក់ចុះដុនដាបដល់សព្វថ្ងៃ ព្រោះតែមនុស្សគ្មានសមត្ថភាពនេះ ធ្វើការមិន

ស្គាល់កិច្ចការដែលខ្លួនត្រូវធ្វើ គឺចេះតែឱនលំទោន ផ្គាប់ផ្គន់ បំពេញមុខលោកធំថ្នាក់លើតែប៉ុណ្ណោះ។ គេធ្វើការបំរើលោកធំថ្នាក់លើជាបុគ្គល មិនមែនបំរើប្រជាពលរដ្ឋទេ។

មិនតែប៉ុណ្ណោះរបបនីមួយៗ បំផុសគំនិតអោយតែឈ្លោះគ្នា ទាស់គ្នាគុំនុំគុំគួន សងសឹករវាងមនុស្សដូចគ្នាគ្មានទីបញ្ចប់ ហើយគ្មានគំនិតចង់អោយប្រជាពលរដ្ឋរស់នៅក្នុងសន្តិភាព និងរកភាពរុងរឿងសំរាប់ប្រទេសជាតិអ្វីបន្តិច ដែលមិនសមរម្យជាមេដឹកនាំប្រទេសសោះ។ គេប្រើអំណាចខុសច្បាប់រំលោភមកលើប្រជាពលរដ្ឋដើម្បីបំបាក់ផ្ទត់គំនិត ដែលធ្វើអោយពលរដ្ឋមិនហ៊ានបញ្ចេញមតិជឿនលឿនរបស់ខ្លួន ក្នុងការតវ៉ារកយុត្តិធម៌ជាមួយលោកធំ។ គេធ្វើនេះក្នុងគោលបំណងបង្កើតភាពច្របូកច្របល់ក្នុងស្រទាប់មហាជន ដើម្បីកុំអោយមានពេលនឹងគិតទៅដល់អំពើពុករលួយ បញ្ហាគ្មានសមត្ថភាពដោះស្រាយវិបត្តិសេដ្ឋកិច្ច វិបត្តិសង្គមនៃរដ្ឋាភិបាលរបស់ខ្លួនតែប៉ុណ្ណោះ។ ទាំងនេះគឺសុទ្ធជាល្បិចបំភាន់មតិ បោកប្រាស់របស់លោកធំខ្មែរ ដើម្បីប្រមូល និងរក្សាអំណាច។

នេះ គឺជាលក្ខណៈខុសប្លែកពីមេដឹកនាំនៃបណ្តាប្រទេសជឿនលឿនលើពិភពលោក។ ក្នុងគោលនយោបាយដឹកនាំប្រទេសរបស់គេ មានតែសេដ្ឋកិច្ច បញ្ហាសង្គម ដែលត្រូវដោះស្រាយទៅថ្ងៃមុខ។ តើគេត្រូវអនុវត្តនយោបាយសេដ្ឋកិច្ចរបៀបណា ដើម្បីអោយប្រជាពលរដ្ឋមានការងារធ្វើគ្រប់គ្រាន់ និងមានជីវភាពធូរធារ ហើយនឹងធ្វើអោយប្រទេសឆាប់រុងរឿង និងរៀបចំនយោបាយសង្គមបែបណា ដើម្បីអោយប្រជាពលរដ្ឋទទួលបានភាពយុត្តិធម៌តាមផ្លូវច្បាប់ និងទទួលបានសមធម៌ក្នុងសង្គម។ ទាំងនេះទើបហៅថា គំនិតជាតិនិយមកសាង។



ជំពូក IV

## ដើម្បីអនាគតខ្មែររុងរឿង

នៅថ្ងៃទី២៣តុលា១៩៩១ ភ្លើងសង្គ្រាមដ៏ចង្រៃនេះត្រូវបានរលត់ក្រោមឥទ្ធិពលយ៉ាងស័ក្តិសិទ្ធរបស់អង្គការសហប្រជាជាតិ។ អង្គការសហប្រជាជាតិបានរៀបចំអោយប្រជាពលរដ្ឋខ្មែររស់នៅឡើងវិញ ក្នុងសន្តិភាពតាមបែបប្រជាធិបតេយ្យដែលមានការរៀបចំបោះឆ្នោតដោយសេរី។ នេះគឺជាឱកាសមួយដ៏ល្អ សំរាប់ខ្មែរយើងក្នុងការចាប់ផ្តើមរៀនសូត្រនូវលិទ្ធិប្រជាធិបតេយ្យសេរីនិយមពិតប្រាកដទៀតផង។ ពហុគណបក្សចាប់បដិសន្ធិលើទឹកដីកម្ពុជាគឺជាប្រព័ន្ធមួយប្រសើរបំផុត ក្នុងការកសាងប្រទេសជាតិអោយសម្បូររុងរឿង។ យើងសំឡឹងមើលចុះលើពិភពលោកនេះ មានតែប្រទេសដែលប្រកាន់យករបបពហុគណបក្សពិតប្រាកដទេដែលរុងរឿងជឿនលឿនប្រកបដោយចេរភាព។ ក្នុងប្រទេសរីកចំរើនលើសកលលោក គេបង្កើតគណបក្សមួយ បានសេចក្តីថា មាននយោបាយដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ច បញ្ហាសង្គមមួយ។ កាលណាមានគណបក្សច្រើន គឺមានផ្លូវសំរាប់ដោះស្រាយកាន់តែច្រើនដែរ។ ដោយមានផ្លូវច្រើនយ៉ាងនេះ ទើបគេបើកការពិភាក្សាជាចំហររកផ្លូវណា ដែលអាចធ្វើអោយប្រទេសឆាប់លូតលាស់ រីកចំរើន និងធ្វើអោយចំណេញដល់ជាតិ រួចទុកអោយប្រជាពលរដ្ឋជាអ្នកវិនិច្ឆ័យ សំរេចជ្រើសរើសយកមួយដែលគេយល់ថា ត្រឹមត្រូវជាងក្នុងកាលៈទេសៈមួយ អោយដឹកនាំតាមរយៈការបោះឆ្នោតជាសកល។ គេមិនធ្វើតាមហឹង្សាយ៉ាងណា អោយតែគណបក្សខ្លួនឈ្នះ ទោះជាតិរបស់គេត្រូវលិចលង់នោះទេ។ គេបង្កើតគណបក្សមិនដើម្បីឈ្លោះគ្នា មើលមុខគ្នា

មិនត្រង់ តាមឈ្នានីស ដេរតិះដៀលគ្នា បន្ទុះបង្អាប់គណបក្សផ្សេងទៀត រឺលីកាំបិត ដំបងកាប់ចាក់គ្នា រឺលីកាំភ្លើងបាញ់គ្នា ហើយក៏មិនមែនដើម្បីលួចតាមសំលាប់គណបក្សដទៃទៀតបំផុតពូជដែរ។ សូមអស់លោកដែលតាំងខ្លួនជាសមាជិកនៃគណបក្សនីមួយៗបច្ចុប្បន្ន ត្រូវតែរៀនសូត្រតាម និងមេត្តាលះបង់គំនិតចាស់គំរិលអន់ថយនេះចោលទៅ ព្រោះនេះមិនមែនជាសីលធម៌របស់អ្នកនយោបាយសម័យជឿនលឿនទេ។ បើចង់តាំងខ្លួនជាអ្នកនយោបាយត្រូវមានសីលធម៌ និងសុជីវធម៌ខ្ពស់។ អ្នកនយោបាយត្រូវប្រកាន់ជំហរថ្លៃថ្នូរ មិនត្រូវទទួលយកអំពើអមនុស្សដាក់ខ្លួនឡើយ ដូចជាហឹង្សា ការអោនលំទោនក្រាបលូនដើម្បីបុណ្យសក្តិ ព្រោះអំពើនេះ គឺសំរាប់តែមនុស្សគ្មានសមត្ថភាពប៉ុណ្ណោះ។ បុណ្យសក្តិដែលបានមកដោយសារការប្រើហឹង្សា គឺមិនថ្លៃថ្នូរទេ។

សូមបញ្ជាក់ចំពោះលោកធំខ្មែរមួយចំនួន ដែលកំពុងតែងប់ងល់និងអំណាចបានមកដោយការប្រើហឹង្សា អំណាចបរទេសលើកបន្តុប ហើយគេប្រើអោយអស់លោកបំផ្លាញមនុស្សខ្មែរ តាមសំលាប់មនុស្សខ្មែរដូចគ្នាថា៖ ថ្ងៃនេះអស់លោកសប្បាយនឹងឃើញជនខ្មែរដទៃទៀត រងទុក្ខវេទនាដោយសារអំណាចខ្លួនក៏ពិតមែន តែនៅថ្ងៃស្អែក លោកពិតជានឹងក្លាយជាជនដែលគេបំបិទសិទ្ធសេរីភាព ក្លាយជាជនដែលត្រូវគាបសង្កត់ តាមដាននិងបុណ្យសក្តិទាំងប៉ុន្មាននឹងត្រូវរលាយដោយស្វ័យប្រវត្តិ។ ពិសេស លោកនឹងជូតទឹកភ្នែកនិងក្បាលជង្គង់ពុំខាន ពេលដែលខ្មែរក្លាយជាជនជាតិភាគតិចរបស់គេ រស់នៅលើទឹកដីកំណើតរបស់ខ្លួន។ ខ្មែរមិនទាន់ឈានដល់ដំណាក់ការហួសពេលនៅឡើយទេ បើសិនជាចាប់ពីពេលនេះតទៅ ផ្តើមពិចារណាឡើងវិញក្នុងការទទួលយកផលប្រយោជន៍សង្គមទាំងមូលជាធំ។



គឺយើងពិតជារឹងមាំ យើងពិតជាធ្វើជាម្ចាស់នៃជីវិតរបស់យើង និងគ្មានជនជាតិណាហ៊ានមើលងាយ មើលថោកទៀតឡើយ។ គ្មានអ្វីប្រសើរជាងរស់នៅក្នុងគ្រួសារយើងទេ។

យើងត្រូវតែយករឿងដែលកន្លងផុតទៅ ទុកមួយកន្លែង។ កំហឹង សងសឹករវាងខ្មែរនិងខ្មែរ ទោះថិតនៅជាប់ខ្លួនប្រាណយើងតិច រឺច្រើន រឺមួយនៅជាប់ដោយអចេតនា រឺចេតនាក្តី ត្រូវតែពន្លត់និងត្រូវដោះស្រាយដោយប្រើតាមច្បាប់ប្រកបដោយយុត្តិធម៌។ បើពុំដូចនោះទេ ខ្មែរមិនអាចរស់នៅក្នុងសុខសន្តិភាពបានឡើយ ព្រោះយើងម្នាក់ៗសុទ្ធតែមានវិបត្តិដូចគ្នា រហូតដល់ថ្ងៃនេះ។ ក្នុងរបបមួយទៅរបបមួយ អ្នកខ្លះមានរឿងនេះ អ្នកខ្លះមានបញ្ហានោះ ពិសេសយើងសុទ្ធតែមានបងប្អូន រឺឪពុកម្តាយដែលត្រូវស្លាប់ រឺទទួលរងគ្រោះ។ បើគុំនុំសងសឹកនេះនៅតែក្តៅគគុកដូចភ្លើងនោះ គឺប្រាកដជាសង្គ្រាមសំលាប់ខ្មែរនិងខ្មែរត្រឡប់មកវិញ ហើយខ្មែរអាចនឹងក្លាយជាជនជាតិភាគតិចរបស់គេ រស់លើទឹកដីកំណើតរបស់ខ្លួន នៅថ្ងៃណាមួយមិនខានដោយមិនបានព្រាងទុក ព្រោះកត្តាដែលគុំនុំ សងសឹកតាមសំលាប់គ្នានេះដែលជាហេតុធ្វើអោយបរទេសលូកដៃ ចូលមកទទួលផល។ ការនិយាយនេះ ដោយសារបារម្ភខ្លាច ពួកបរទេសចូលមកពន្យុះយើងថែមដូចពេលកន្លងមក។

ជាពិសេស ចំពោះអ្នកដែលតាំងខ្លួនជាអ្នកនយោបាយ និងមេដឹកនាំគណបក្សទាំងអស់ បើសិនជាលោកស្រលាញ់ជាតិខ្មែរ ចង់រស់ក្នុងមហាគ្រួសារខ្មែរតទៅទៀត និងចង់អោយពលរដ្ឋខ្មែររស់ក្នុងសន្តិភាពមែននោះ គួរណាស់តែលោកចាប់ពីពេលនេះ ឈប់បង្កាត់ភ្លើងសង្គ្រាមឡើងវិញ ដោយឈប់លាបពណ៌អោយខ្មែរគ្នាឯង ឈប់ពន្យុះ ឈប់ដុតបញ្ឆេះនូវ

រាល់គំនុំគុំគួន នូវរាល់ការដែលធ្វើអោយហិនហោចដល់ខ្មែរមកលើពលរដ្ឋខ្មែរទៀត។ មិនត្រឹមតែប៉ុណ្ណោះត្រូវបណ្តុះគំនិតសន្តិភាព កសាងជាតិ និងចេះដោះស្រាយនូវរាល់បញ្ហា តាមការពិភាក្សាបែបប្រជាធិបតេយ្យ តាមច្បាប់ដោយសន្តិវិធី ទើបនាំមកនូវសេចក្តីសុខ។ ត្រូវបើកសិទ្ធសេរីភាពសំរាប់ពលរដ្ឋអោយទូលាយ មិនត្រូវចង្អៀតចង្អល់ឡើយ។ ថាមពលដ៏ស័ក្តិសិទ្ធ និងជាកំលាំងចលករដ៏សំខាន់បំផុត ដើម្បីយិតយោងប្រទេសអោយរួចផុតពីរណ្តៅទុរគតនេះ គឺមានតែការរួមគ្នាជាធ្លុងមួយដោយសុទ្ធចិត្ត ហើយមិនមែនថិតនៅលើការឈ្នានីស និងតាមសំលាប់គ្នាទេ។ ដើម្បីកសាងប្រទេសអោយរីកចំរើន ត្រូវការទាំងកំលាំងកាយ កំលាំងងចិត្ត និងកំលាំងប្រាជ្ញាពីមនុស្សខ្មែរគ្រប់មជ្ឈដ្ឋាន គ្រប់និន្នាការ ព្រោះមានការងារច្រើនណាស់ដែលត្រូវធ្វើ និងទាមទារឯកទេសផ្សេងៗគ្នាទៀតផង។

ការបង្រួបបង្រួមជាតិ គឺការប្រមូលគ្រប់កំលាំងជាតិទាំងអស់ដើម្បីកសាងជាតិតែមួយទិសដៅ។ ការបង្រួបបង្រួមជាតិ មិនមែនមានន័យដូចទង្វើរបស់លោក សីហនុ កាលពីទសវត្សរ៍ឆ្នាំ៦០នោះទេ។ លោក សីហនុ តាមឈ្នានីស តាមសំលាប់អ្នកដែលមិនស្របនិងខ្លួន មិនព្រមធ្វើតាមបញ្ញាបុគ្គលខ្លួន និងគណបក្សប្រឆាំងត្រូវរំលាយចោលតាមកំលាំងអំណាច ទុកតែគណបក្សខ្លួននិងបង្ខំអោយគេគាំទ្រខ្លួន រួចយកលេសថា បង្រួបបង្រួមជាតិ។ ការបង្រួបបង្រួមជាតិរបៀបនេះ គឺការប្រមូលអំណាចផ្តាច់ការ ការប្រមូលបក្សពួកដើម្បីបំផ្លាញជាតិ មិនមែនរួមគ្នាកសាងជាតិទេ។ ការរួបរួមគ្នាកសាងជាតិនោះ គឺត្រូវប្រមូលគ្រប់កំលាំងនិន្នាការនយោបាយទាំងអស់ មិនប្រកាន់បក្សពួក និងត្រូវរក្សាគ្រប់គណបក្សនយោបាយដែលមាន។ ត្រូវទុកអោយគណបក្សនីមួយៗ ធ្វើទៅតាមគោលនយោបាយរបស់គេ មិនត្រូវ



លូកដៃកកូរក្នុងគណបក្សផ្សេង និងត្រូវទុកអោយប្រជាពលរដ្ឋជាអ្នកសំរេចជ្រើសរើសយកនយោបាយរបស់គណបក្សនីមួយៗអោយកាន់អំណាចតាមរយៈការបោះឆ្នោតជាសកលដោយសេរី ក្នុងរយៈពេលមួយកំណត់។ ការបង្រួបបង្រួមជាតិ មិនមែនជាការបង្ខំអោយគេថិតនៅក្រោមចំណុះខ្លួនទេ។ ដូចនេះ ការបង្រួបបង្រួមជាតិដើម្បីកសាងប្រទេស មានន័យថា ការគោរពសិទ្ធិមនុស្ស ធ្វើអោយមានយុត្តិធម៌តាមផ្លូវច្បាប់ ធ្វើអោយមានសមធម៌ក្នុងសង្គម និងការគោរពលទ្ធិប្រជាធិបតេយ្យ។

ទន្ទឹមនិងនេះ សូមកូនខ្មែរ ចូលរួមក្នុងសកម្មភាពសង្គមអោយបានសស្រាក់សស្រាំ ដើម្បីកុំអោយលោកធំយើង ចង់ធ្វើអ្វីស្រេចចិត្តដូចពេលកន្លងមក។ មើលចុះ ប្រទេសដែលជឿនលឿន រីកចំរើនលើសកលលោកនេះ គឺដោយសារពលរដ្ឋនៃប្រទេសនោះ ក្លាហាន សកម្មក្នុងគ្រប់ការងារសង្គម។ កាលណាពលរដ្ឋចូលរួមក្នុងសកម្មភាពសង្គមកាន់ច្រើន នោះពលរដ្ឋភាគច្រើនកាន់តែយល់ដឹងច្បាស់ អំពីនយោបាយរបស់មេដឹកនាំ ហើយគេមិនចេះតែទុកអោយមេដឹកនាំធ្វើអ្វីស្រេចចិត្តទេ។ កត្តានេះធ្វើអោយមេដឹកនាំខ្លាចប្រជាពលរដ្ឋឈប់គាំទ្រ ដូចនេះត្រូវតែខិតខំគិតស្វែងរកផលប្រយោជន៍ជូនប្រជាពលរដ្ឋ ខិតខំបំរើប្រជាពលរដ្ឋ បំរើប្រទេសជាតិ ដែលធ្វើអោយប្រទេសគេមានការរីកចំរើន។ ដោយឡែកប្រទេសខ្មែរ រយៈពេលកន្លងមក ដោយសារយើងមិនសូវចូលរួមក្នុងសកម្មភាពសង្គមអោយបានច្រើន ដែលធ្វើអោយយើងមិនបានដឹង មិនបានយល់ ដូចនេះបានជាលោកធំយើងធ្វើអ្វីស្រេចចិត្ត ដែលបណ្តាលអោយប្រទេសយើងមិនរីកចំរើន និងជីវភាពរបស់យើងកាន់តែក្រីក្រទៅៗ។ បើចង់អោយប្រទេសជាតិយើងមានការរីកចំរើន ចង់បានជីវភាពធូរធារ ដូចក្នុងបណ្តាប្រទេសជឿនលឿនលើ

សកលលោក គឺត្រូវនាំគ្នាចូលរួមក្នុងសកម្មភាពសង្គម។ ម្យ៉ាងទៀតការចូលរួមក្នុងសកម្មភាពសង្គមសស្រាក់សស្រាំ គឺដើម្បីកុំអោយលោកធំយើងបំភ័ន្ត បោកប្រាសយើងបានទៀត ព្រោះធ្វើអោយយើងអាចវាយតំលៃបានច្បាស់អំពីសមត្ថភាពរបស់លោកធំ។ ពេលនោះយើងមិនចេះតែលើកជើងគាត់អោយផុតពីដីឡើយ។ បើគាត់មានសមត្ថភាពចិតនៅកំពស់តែមួយម៉ែត្រ សូមលើកគាត់ត្រឹមមួយម៉ែត្របានហើយ។ បើសិនជាយើងលើកគាត់រហូតដល់កំពស់ពីរម៉ែត្រ ពិតជាគាត់ជោរមិនខាន ហើយគាត់នឹងដឹកនាំប្រទេសទៅតាមការជោរនោះទៀត យើងនឹងរងទុក្ខវេទនាដូចអតីតកាល។ យើងជាខ្មែរអ្នកជា មិនត្រូវចាត់ទុកបុគ្គលណាជាអទិទេពឡើយ និងមិនត្រូវសំលាប់មនុស្សខ្មែរគ្នាឯងតាមការបញ្ជារបស់គេ។ មិនត្រឹមតែប៉ុណ្ណោះដើម្បីអោយប្រទេសយើងមានការអភិវឌ្ឍន៍ត្រឹមត្រូវ និងជីវភាពរបស់យើងសម្បូររុងរឿង ចុំថ្កើងដោយចេរកាល យើងជាខ្មែរត្រូវខិតខំប្រឹងប្រែងខ្លួនឯងផងដែរក្នុងការតាមដានសកម្មភាពមេដឹកនាំ និងហ៊ានវិនិច្ឆ័យជ្រើសរើសយកមេដឹកនាំដែលមានសីលធម៌ សុជីវធម៌ និងសមត្ថភាពអោយដឹកនាំប្រទេសតាមបែបលទ្ធិប្រជាធិបតេយ្យ។

កាតព្វកិច្ចមួយទៀតសំរាប់កូនខ្មែរ គឺត្រូវមានសមត្ថភាពក្នុងការវែកមុខអោយឃើញលោកធំខ្មែរ ដែលបរទេសបន្តុបឡើង ព្រោះដូចយើងឃើញស្រាប់ហើយរហូតដល់ថ្ងៃនេះ។ ភាពហិនហោច ទុរគតនៃប្រទេសខ្មែរ គឺសុទ្ធតែជាស្នាដៃរបស់លោកធំលើកបន្តុបនេះឯង ដែលយើងទាំងអស់គ្នាធ្លាប់គាំទ្រដោយភ្លេចពិចារណា។ កាលបើយើងស្គាល់ហើយ មិនត្រូវទុកអោយជននេះបន្តសកម្មភាពពង្រិចពង្រិលប្រទេសខ្មែរឡើយ។

ចាប់ពីពេលនេះទៅ យើងត្រូវស្រាក់ដៃគ្នា ឈរលើទស្សនៈសន្តិភាព



រកភាពរីកចំរើនដែលជាផលប្រយោជន៍ជាតិ។ យើងជាកូនខ្មែរត្រូវក្លាហានក្នុងការបញ្ចេញមតិ ការពិភាក្សារកភាពត្រឹមត្រូវនិយមបរិសុទ្ធ មិនត្រូវមានគំនិតអញត្រូវនិយមសោះឡើយ និងមិនត្រូវទុកខ្លួនធ្វើជាអាយ៉ងរបស់បុគ្គល ត្រូវធ្វើយ៉ាងណាអោយក្លាយជាអាយ៉ងរបស់ជាតិខ្មែរ។ មានបញ្ហាអ្វីកើតឡើង ត្រូវចេះប្តូរយោបល់គ្នារកខុសត្រូវតាមបែបប្រជាធិបតេយ្យ កុំចាំតែចាប់កំហុសគ្នាទៅវិញទៅមក វាមិនចំរើនដល់ជាតិទេ និងមិនត្រូវធ្វើសកម្មភាពណាដែលបណ្តាលអោយជនជាតិដទៃ អាចឆ្លៀតឱកាសជ្រៀតជ្រែកចូលក្នុងរឿងនោះឡើយ។ មុននឹងធ្វើអ្វី ត្រូវពិចារណាអោយបានច្បាស់ មិនត្រូវបំផ្លាញជាតិឯង កុំមានៈអោយខាងតែឈ្នះ ទោះជាផលប្រយោជន៍ជាតិត្រូវបាត់បង់នោះ។

ចំណុចសំខាន់បំផុត ត្រូវចៀសវាងនូវការប្រេះឆាបាក់បែកគ្នាជាថ្មី និងត្រូវប្រុងប្រយ័ត្នជានិច្ចនូវរាល់ការញុះញង់អោយយើងបែកបាក់គ្នា ពីបណ្តាប្រទេសខាងក្រៅ ពិសេសប្រទេសជិតខាងយើងនេះឯង ព្រោះគេមានកលល្បិចច្រើនណាស់ ដូចបានរៀបរាប់មកហើយក្នុងអតីតកាល។

បងប្អូនរួមជាតិជាទីស្នេហា យើងបានយល់ជ្រាបពីមូលហេតុនៃសង្គ្រាមកាប់សំលាប់ខ្មែរគ្នាឯង។ ពេលនេះ លោកធំយើងបានយល់ព្រមចុះសន្ធិសញ្ញា នៅលើក្រដាស់យល់ព្រមឈប់បាញ់សំលាប់គ្នាក៏ពិតមែន។ តែយើងសួរថា តើវាអាចក្លាយទៅជាការអនុវត្តន៍ជាអមតៈបានទេ?។ នេះបើខ្មែរយើងមិនភ្ញាក់រលឹក និងខ្វះការពិចារណាដោយយកប្រវត្តិសាស្ត្រមកធ្វើជាកញ្ចក់ឆ្លុះបញ្ចាំង នោះពិតជាសំនួរនេះអាស្រ័យលើមេដឹកនាំយួន សៀម និងមេដឹកនាំចិន។ យើងសួរទៀតថា តើមេដឹកនាំយួន សៀម និងមេដឹកនាំចិនសុខចិត្តយល់ព្រមអោយខ្មែររស់ក្នុងសុខសន្តិភាព ឯករាជ្យ និង

ភាពរុងរឿងស្រស់បំព្រងក្បែរគេរឺទេ? បើគេមិនទោមនស្សទេនោះ យើងមានសេចក្តីសោមនស្សណាស់ចំពោះទឹកចិត្តដ៏សប្បុរសធម៌។ តែការមួយទៀតដែលយើងមិនត្រូវដេកភ្លេចខ្លួន គឺបុគ្គលណាក៏ចង់អោយខ្លួន និងគ្រួសាររបស់គេមានបាន រុងរឿង និងមានជីវភាពធូរធារ។ ឯជនជាតិនៃប្រទេសនីមួយៗក៏យ៉ាងដូចនេះ។ គេតែងរិះរកគ្រប់មធ្យោបាយដើម្បីធ្វើអោយជាតិរបស់គេ សំបូររុងរឿង ដោយមិនគិតពីការហិនហោចនៃប្រទេសដ៏ទៃឡើយ ព្រោះនេះជាច្បាប់ធម្មជាតិ។ មិនថាឡើយតែប្រទេសកម្ពុជាទេ ដែលរងគ្រោះដោយសារតែមហិច្ឆតារបស់បរទេស។ នៅលើលោកយើងនេះមានប្រទេសជាច្រើនដែលរងគ្រោះ និងទទួលផលវិបាក ដូចកម្ពុជាយើងដែរ។ តែគេអាចថែរក្សាវង្សត្រកូល និងដែនដីរបស់គេបាន មិនតែប៉ុណ្ណោះប្រទេសជាតិគេមានសន្តិភាព ឯករាជ្យ ជឿនលឿន និងរុងរឿងទៀតផង។ ដូចនេះប្រទេសកម្ពុជាយើង អាចនៅគង់វង្ស និងរុងរឿនបាន រឺខ្មែរក្លាយជាជនជាតិភាគតិចរបស់គេ គឺថិតនៅលើឧត្តមគតិជាតិ មនសិការ និងសតិសម្បជញ្ញៈយើងជាខ្មែរម្នាក់ៗផ្ទាល់តែម្តង។

ចុងបញ្ចប់ សូមអោយសៀវភៅនេះ ជួយរួមចំណែកក្នុងការផ្តល់ជាយោបល់ដល់កូនខ្មែរសំរាប់ធ្វើការពិចារណា ដើម្បីចៀសវាងអោយផុតនូវទំនាស់គ្រប់បែបយ៉ាង ដែលបណ្តាលអោយកើតជាសង្គ្រាមសំលាប់ខ្មែរគ្នាឯង និងសង្គ្រាមពង្រិចពង្រិលជាតិខ្មែរសារឡើងវិញ។ គ្រប់បញ្ហាទាំងអស់ទាំងក្នុង និងក្រៅប្រទេស ត្រូវដោះស្រាយតាមការចរចារ តាមច្បាប់ដោយសន្តិវិធី ហើយមិនត្រូវទុកអោយបរទេសមានឥទ្ធិពលមកលើឡើយ។

សូមខ្មែរភ្ញាក់ឡើង ដឹងខ្លួនឡើង រួមគ្នាស្វែងរកប្រយោជន៍ជាតិជាធំ

**ហេង ហុង**



# លោកធំ

១- លោកធំ!

អំណាចមិនមែនជាឧបករណ៍សំរាប់ប្រើដើម្បីគាបសង្កត់ប្រជាពលរដ្ឋ ដើម្បីយកទៅបិទបាំង រឺគំរាមកំហែង មិនអោយនិយាយអំពីអំពើពុករលួយរបស់លោក និងអំណាចក៏មិនមែនជាមធ្យោបាយសំរាប់រកលុយរឺជាដើមទុនសំរាប់ធ្វើជំនួញបំរើគ្រួសារខ្លួនដែរ។ សូមយកអំណាចទៅបំរើប្រទេសជាតិ ដូចជា ការពារបូរណភាពទឹកដី ដោះស្រាយបញ្ហាសេដ្ឋកិច្ច បញ្ហាសង្គម កុំអោយមានភាពអនាធិបតេយ្យ អសន្តិសុខ។ គេប្រើអំណាចចំពោះបុគ្គលដែលប្រព្រឹត្តខុសនិងច្បាប់សង្គម។

២- លោកធំ!

អំណាចមិនមែនជាកេរ្តិ៍មរតកទេ។ លោកធំខ្មែរក្រាញ់ននាលទាំងងឹតងងល់និងអំណាចណាស់ និងចង់អោបអំណាចទុកដូចជារបស់កេរ្តិ៍តាំងពីឪពុក ម្តាយ ជីដូនជីតាខ្លួន។ មិនតែប៉ុណ្ណោះ គេតែងប្រើគ្រប់កលល្បិចដើម្បីរក្សាអំណាចនោះ ទោះជាផលប្រយោជន៍ជាតិត្រូវបាត់បង់ក៏ដោយ ហើយលោកធំរបៀបនេះតែងបែងចែកអំណាចទៅអោយវង្សគ្រួសារខ្លួនដូចសម្បត្តិរបស់ខ្លួនទៀត។ សូមលោកធំពិចារណាប្រកបដោយវិចារណញ្ញាណមើលទៅចុះ តើមានន័យអ្វីចំពោះអំណាចដែលបានមកដោយគ្មានការគាំទ្រពីប្រជាពលរដ្ឋរបៀបនេះ។ អំណាចដែលប្រកបដោយកិត្តិយសនោះ គឺអំណាចដែលប្រជាពលរដ្ឋភាគច្រើនប្រគល់អោយ។ តែបើពលរដ្ឋភាគច្រើនដកសេចក្តីទុកចិត្តហើយ សូមប្រគល់អំណាចនោះ អោយគេទៅ វាមិនខុសច្បាប់សង្គមអីទេ និងថ្លៃថ្នូរទៀតផងជាតិជាមនុស្ស។

៣- លោកធំ!

លោកធំត្រូវប្រកាន់ខ្លួនជាមនុស្សធម្មតា ទើបប្រទេសជាតិរីកចំរើន។ លោកធំខ្មែរតែងលើកខ្លួនឯងអោយលើសពីមនុស្សតាមច្បាប់ធម្មជាតិ និងតែងចង់អោយគំនិត និងយោបល់ខ្លួនក្លាយជាវត្ថុទិព្វ មិនចេះខុសគ្រប់កាលៈទេសៈ។ បើនរណាជំទាស់ មិនព្រមធ្វើតាមខ្លួន រមែងមិនសប្បាយចិត្ត ហើយតែងរកគ្រប់វិធីដើម្បីតាមព្យាបាទ។ លោកធំប្រភេទនេះដែលធ្វើប្រទេសជាតិយើង មិនអោយមានការរីកចំរើន។

៤- លោកធំ!

ការចែកអំណោយគឺបំផ្លាញជាតិ។ អ្នកនយោបាយដែលស្វែងរកការគាំទ្រ រឺប្រជាប្រិយភាពតាមវិធីចែកអំណោយ គឺជាអ្នកនយោបាយប្រជាភិថុត ព្រោះលោកពិតជាមិនមែនអទិទេពឯណា ដែលអាចចេះជប់យកលុយរឺរបស់របរទាំងនេះដើម្បីដើរចែកគ្រប់ពេលវេលា។ ដូចនេះ ប្រជាពលរដ្ឋក្រនៅតែក្រដដែល ល្ងង់នៅតែល្ងង់ ហើយអនាគតប្រទេសជាតិនឹងគ្មានការរីកចំរើន។

ការស្វែងរកប្រជាប្រិយភាព រឺការគាំទ្រយូរអង្វែង មិនមែនថិតនៅលើការលួចកិបកេងយកលុយរដ្ឋ ទិញសម្ភារៈធ្វើជាអំណោយដើរចែកនោះទេ។ ប្រជាប្រិយភាព រឺការគាំទ្របែបនេះនឹងរលាយសាបសូន្យ នៅពេលដែលប្រជាពលរដ្ឋយល់ និងចោទសួរថា៖ តើលោកបានលុយនិងសំភារៈនោះមកពីណាសំរាប់ដើរចែក?។ ម្យ៉ាងទៀត ការទទួលបានប្រជាប្រិយភាព រឺការគាំទ្រតាមវិធីដើរចែកអំណោយ ក៏មិនសរបញ្ជាក់ពីសមត្ថភាពរបស់លោកក្នុងការដឹកនាំប្រទេសដែរ។



៥- លោកធំ!

ត្រូវគិតថ្ងៃស្អែកផង។ លោកធំយើង ពុំមានការទទួលខុសត្រូវចំពោះជោគវាសនាជាតិឡើយ គឺធ្វើអ្វីសំរាប់តែមួយថ្ងៃប៉ុណ្ណោះ មិនគិតដល់ស្អែកទេ។ មុននឹងសំរេចធ្វើអ្វីមួយនៅថ្ងៃនេះត្រូវគិតថា តើវានឹងហុចលទ្ធផលអ្វីខ្លះ សំរាប់ប្រទេសជាតិទៅអនាគត។ បើប្រទេសជាតិនៅថ្ងៃអនាគតកើតភាពរីករវ អសន្តិសុខ រឺនឹងរលាយបាត់ទៅដោយសារតែអំពើប្រព្រឹត្តនោះ តើរូបលោកផ្ទាល់នឹងក្លាយជាស្អី?។ សូមលោកធំឈប់បណ្តោយអោយកាមតណ្ហា តណ្ហាអំណាច និងសម្ភារៈ អូសទាញទៀត។

៦- លោកធំ!

ត្រូវរៀនទទួលពាក្យរិះគន់។ លោកធំយើងមិនចូលចិត្តពាក្យរិះគន់ទេ។ គាត់ប្រកាន់យកគំនិតថា អ្នករិះគន់ខ្លួន គឺសុទ្ធតែជាអ្នកប្រឆាំងខ្លួន និងចាត់ទុកអ្នករិះគន់ជាសត្រូវស្លាប់រស់របស់ខ្លួនទៀត។ គាត់មិនទទួលស្គាល់ថា អ្នករិះគន់ខ្លួនគឺជាអ្នកកែលំអរខ្លួន និងចង់អោយខ្លួនធ្វើអោយបានល្អប្រសើរថែមទៀតសំរាប់ជាប្រយោជន៍ប្រទេសជាតិទេ។ ក្នុងរបបលោក នរោត្តម សីហនុ អ្នករិះគន់ចោទថា ក្បត់រាជបល្ល័ង្គ រឺក្បត់ជាតិ។ ក្នុងរបបលោក ប៉ុល ពត អ្នករិះគន់ចោទថា ក្បត់អង្គការ រឺខ្មាំង។ ក្នុងរបបលោក ហ៊ុន សែន អ្នករិះគន់ចោទថា ជនមុខពីរ រឺខ្មែរក្រហម រឺខ្មាំង។ អ្នកដែលត្រូវបានចោទយ៉ាងនេះ សុទ្ធតែត្រូវបានតាមប្រមាញ់ និងមិនសូវនៅមានជីវិតឡើយ រឺត្រូវរត់ចោលស្រុក។ ដោយសារលោកធំប្រកាន់យកគំនិតអន់ថយបែបនេះ បានជាដឹកនាំប្រទេសរហូតដល់ប្រទេសមហាក្រ ទុរគតទល់សព្វថ្ងៃនេះ។ សូមលោកធំដេកពិចារណាបន្តិចមើលថា៖ ខ្លួនលោកក៏ជាមនុស្ស

តាមធម្មជាតិដូចគេឯងដែរ លោកមិនមែនជាព្រះអទិទេពមកពីឋានណាទេ។ បើលោកជាមនុស្សដែរនោះ រឿងអីដែលលោកធ្វើអ្វីមិនខុសសោះនោះ។ កុំអញត្រូវនិយមខ្លាំងពេកលោក វាមិនចំរើនដល់ជាតិទេ។

៧- លោកធំ!

សូមលះបង់គំនិតគុំគួនចោលទៅ ព្រោះវាអាចផ្តល់លទ្ធផលគ្រោះថ្នាក់ដល់ប្រទេសជាតិខ្លាំងណាស់។ ដូចយើងឃើញស្រាប់ មូលហេតុនៃសង្គ្រាមសំលាប់ខ្មែរ គឺដោយសារតែគំនិតគុំគួននេះ ដែលក្លាយជាការសងសឹករបស់អ្នកដឹកនាំខ្មែរ។ ដូចជា ដោយសារតែការបាត់អំណាច រឺការបែងចែកអំណាចរវាងលោកធំគ្នាឯង មិនសមស្របតាមការលោភលន់របស់ខ្លួនក៏មានគំនិតគុំគួន សងសឹក រួចបែរជាមកឃោសនាបបួលប្រជាពលរដ្ឋធ្វើសង្គ្រាម ដើម្បីដណ្តើមអំណាចអោយខ្លួន។

៨- លោកធំ!

ត្រូវឈប់បំផ្លាញថវិកាជាតិដើម្បីកិត្តិយសផ្ទាល់ខ្លួន។ លោកធំខ្មែរស្រឡាញ់ណាស់កិត្តិយស។ តាមពិតត្រឹមត្រូវហើយ អ្នកណា រឺជនជាតិណាក៏ដោយ តែគេធ្វើទៅតាមលទ្ធភាពនិងសមត្ថភាពរបស់ប្រទេសជាតិ។ ដោយឡែក លោកធំខ្មែរ មិនគិតដល់បញ្ហានេះទេ។ លោកចេះតែបញ្ចេញ បំប៉ោងសំបកក្រៅ ដើម្បីបង្អួតគេប៉ុណ្ណោះ។ មានឧទាហរណ៍ជាច្រើនតាំងពីលោកធំលើដល់ក្រោមដូចជា៖

កំឡុងឆ្នាំ១៩៦៥ លោកប្រធានាធិបតីរបស់បារាំងឈ្មោះ ឌីគោល (DEGAULLE)បានមកធ្វើដំណើរទស្សនកិច្ចស្រុកខ្មែរ លោក នរោត្តម



សីហនុបានរៀបចំធ្វើបុណ្យយ៉ាងធំ ដែលលើសពីកំរិតជីវភាពរបស់ប្រជាពលរដ្ឋ។ ប្រហែលជាចំណាយប្រាក់រដ្ឋអស់មិនតិចទេ សួរថា ដើម្បីអ្វី?។ ចុះបើយកថវិកានោះ សង់ផ្លូវគមនាគមន៍ មន្ទីរពេទ្យ រឺចំណាយទៅលើក្រសួងអប់រំ វាមិនចំរើនសេដ្ឋកិច្ចជាតិ។

ឥឡូវមើលលោក ហ៊ុន សែន ប្រទេសមិនទាន់ងើបពីរណ្តៅអត់ឃ្លានរួចផង តាមភូមិនៅមានប្រជាពលរដ្ឋស្លាប់និងអត់ឃ្លាននៅឡើយ ស្រាប់តែលោក ហ៊ុន សែន ចំណាយប្រាក់រាប់លាន ក្នុងការធ្វើបុណ្យជ័យជំនះគគ្រឹកគគ្រេង។ ក្រោយមកទៀតពេលដែលប្រទេសខ្មែរក្រោមការប្រឹងប្រែងរបស់អង្គការសហប្រជាជាតិ ត្រូវបានដោះស្រាយបញ្ចប់សង្គ្រាមតាមផ្លូវនយោបាយ ទទួលបានជោគជ័យនៅថ្ងៃទី២៣តុលា១៩៩១ ហើយគ្រប់គណបក្សខ្មែរទាំងអស់ ត្រូវត្រឡប់ចូលស្រុកវិញក្នុងនោះមានទាំងលោក នរោត្តម សីហនុ ជាដើម។ លោក ហ៊ុន សែន បានបំផ្លាញប្រាក់អស់២០០០០ដុល្លាអាមេរិកដើម្បីជួសជុលផ្ទះ(វាំង)ដែលលោក នរោត្តម សីហនុ ត្រូវមកនៅ។ ចំនួនទឹកប្រាក់នេះស្ទើរតែមិនអាចជឿបានចំពោះប្រទេសដែលក្របំផុតក្នុងពិភពលោក ហើយប្រាក់ខែដែលអ្នករដ្ឋការបានទទួលតែ៦ដុល្លាអាមេរិកក្នុងមួយខែ។

៩- លោកធំ!

ត្រូវបោះបង់គំនិតសង្ស័យជ្រុលក្រែងខ្លាចចោលទៅ ហើយត្រូវចេះស្រាវជ្រាវរកហេតុផលអោយបានច្បាស់ និងរៀនទទួលយកយោបល់អ្នកក្រៅមកពិចារណាផង កុំស្តាប់តែអ្នកហៃអើ អ្នកលូនក្រាប ស្លាប់គេស្លាប់ឯង និងធ្វើអោយប្រទេសជាតិហិនហោចទៀតផង។ ដោយសារតែគំនិត

នេះដែលធ្វើអោយប្រទេសសព្វថ្ងៃ គ្មានខ្មែរអ្នកចេះដឹងជ្រៅជ្រះ ដូចប្រទេសគេផ្សេងៗទៀត។

១០- លោកធំ!

ត្រូវមានសមត្ថភាពក្នុងការរែករកជនលុតក្រាប ឱនលំទោនខុសពីច្បាប់ធម្មជាតិ ព្រោះពួកនេះភាគច្រើនគឺជាក្រុមដែលគ្មានចំណេះដឹង ដែលគ្មានសមត្ថភាពបានជាមកធ្វើរបៀបនេះដើម្បីសុំបុណ្យសក្តិ។ ជនប្រភេទនេះដែលគ្រោះថ្នាក់ដល់ប្រទេសជាតិ ដែលជាអ្នកបង្កនូវអំពើពុករលួយបក្សពួកនិយម និងបំផ្លាញជាតិ។

១១- លោកធំ!

ចេញធ្វើពលកម្ម គឺលោកធំបំផ្លាញប្រជាពលរដ្ឋ។ លោកធំចេញធ្វើពលកម្មកាប់ដីបាន១០ចប ស្រាប់តែប្រជាពលរដ្ឋរស់អស់មួយភូមិមួយឃុំក្នុងការរៀបចំទទួល។ រៀបចំតាំងពីសម្លពិសេស ទឹកតែ ទឹកដូង។ តើការកាប់ដីបាន១០ចបនេះ វាស្មើនិងការរស់ប្រជាពលរដ្ឋមួយភូមិ មួយឃុំមួយស្រុកដើម្បីទទួលលោករឺ?។ មិនត្រឹមតែប៉ុណ្ណោះ ចំណាយពេលយ៉ាងតិច៥ថ្ងៃមុន ដើម្បីសំអាតទីកន្លែងដែលលោកចង់ដើរ។ លោកធំធ្វើនេះគឺបង្ខិនបង្ខោចសុទ្ធសាធ មិនមែនទៅជួយទេ។ ការស្វែងរកប្រជាប្រិយភាពដោយប្រើវិធីប្រជាភិថុតនេះ ពិតជាលោកមិនមែនមានឈ្មោះថា ជាអ្នកស្រឡាញ់ជាតិ ជាអ្នកកសាងជាតិទេ។ លោកពិតជាមានឈ្មោះជាអ្នកបំផ្លាញជាតិដែលប្រជាពលរដ្ឋខ្មែរចារទុកក្នុងប្រវត្តិសាស្ត្រ។

បើសិនជាលោកមានពេលទំនេរច្រើន ចូរប្រើពេលវេលានោះ ដើម្បី



គិតរកមធ្យោបាយដោះស្រាយនយោបាយសេដ្ឋកិច្ចអោយបានល្អ អោយឆាប់បានចំរើន និងនយោបាយសង្គមអោយមានយុត្តិធម៌តាមផ្លូវច្បាប់ ធ្វើអោយមានសមធម៌ក្នុងសង្គម ទើបលោកមានឈ្មោះជាអ្នកកសាងជាតិ ជាអ្នកស្រឡាញ់ប្រជាពលរដ្ឋ ហើយនេះគឺជាភារកិច្ចនិងកាតព្វកិច្ចរបស់លោកទៀតផង។

១២- លោកធំ!

ប្រទេសដែលជឿនលឿនក្នុងលោកនេះគឺជាប្រទេសដែលយកច្បាប់ជាធំ ជាអ្នកដឹកនាំ មិនមែនបុគ្គលទេ។ ថ្វីត្បិតមនុស្សជាអ្នកបង្កើតច្បាប់ តែច្បាប់ថិតនៅពីលើបុគ្គលគ្រប់រូប សូម្បីបុគ្គលនោះជាមេដឹកនាំប្រទេសក៏ដោយ។ ចំណែកប្រទេសខ្មែរដែលក្រីក្រដល់ថ្ងៃនេះ ដោយសារតែប្រទេសខ្មែរត្រូវដឹកនាំដោយបុគ្គល និងបុគ្គលនោះធំជាងច្បាប់។

១៣- លោកធំ!

ការមិនគាំទ្រ មិនមែនមានន័យថា ប្រឆាំងនឹងរូបលោកទេ។ លោកធំយើង ទំនងជាគាត់យល់ឃើញថា ប្រទេសខ្មែរទាំងមូលគឺជាកម្មសិទ្ធដាច់មុខរបស់គាត់តែម្នាក់ឯងមើលទៅ បានជាគាត់ចង់ដឹកនាំប្រទេសទៅណាក៏បាន ចង់សំរេចធ្វើអ្វីស្រេចចិត្ត ដោយគ្មានគិត គ្មានក្រែង គ្មានអោរប្រជាពលរដ្ឋបន្តិចសោះ។ មិនត្រឹមតែប៉ុណ្ណោះ អោយតែប្រជាពលរដ្ឋខ្មែរណាមិនគាំទ្រ រមែងមិនសប្បាយចិត្ត និងចោទថាប្រឆាំងខ្លួន រួចតាមយាយី ឈ្នានីសគ្រប់បែបយ៉ាង។

សូមលោកធំគិតបន្តិចមើល នោះនឹងបានយល់ថា ប្រទេសខ្មែរ មិន

មែនជាកម្មសិទ្ធដាច់មុខរបស់លោកតែម្នាក់ឯងទេ។ ផ្ទុយទៅវិញ ប្រទេសខ្មែរជាកម្មសិទ្ធរបស់ខ្មែរគ្រប់រូប។ បើប្រទេសខ្មែរជាកម្មសិទ្ធរបស់ខ្មែរគ្រប់រូប នោះបុគ្គលខ្មែរណាក៏មានសិទ្ធចូលរួមចំណែកក្នុងការការពារ អភិវឌ្ឍន៍ និងពិសេសមានសិទ្ធបារម្ភអំពីជោគវាសនារបស់ប្រទេសខ្មែរដែរ ហើយមិនមែនមានសិទ្ធតែរូបលោកម្នាក់ទេ។ ដូចនេះ កាលបើលោកជាមេដឹកនាំសំរេចធ្វើអ្វីមួយ ប្រជាពលរដ្ឋខ្មែរអាចគាំទ្រ រឺក៏អាចជំទាស់ បើទង្វើនោះវាធ្វើ រឺវានឹងធ្វើអោយខូចផលប្រយោជន៍ជាតិ។ ការមិនគាំទ្រ រឺការជំទាស់បែបនេះ មិនមែនមានន័យថា ប្រជាពលរដ្ឋខ្មែរប្រឆាំងនឹងរូបលោកជាបុគ្គលទេ គឺប្រឆាំងនិងទង្វើ រឺសេចក្តីសំរេចរបស់លោក ព្រោះទង្វើ រឺសេចក្តីសំរេចរបស់លោកធ្វើអោយប្រទេសខ្មែរបាត់បង់ប្រយោជន៍។

១៤- លោកធំ!

បើបានធ្វើធំ សូមធំតែខ្លួនឯងម្នាក់បានហើយ កុំធំទាំងពូជ វាមិនល្អមើលទេ។

២៨ ១០ ១៩៩៤

**ហេង ហុង**



## ឯកសារ

១- ជ័យវរម័នទី៧៖ លោកស៊ិក្សសីដេសចាងហ្វាងសាលាបារាំងនៅចុងបូព៌ា។ លោកជុំ មៅប្រែចេញជាភាសាខ្មែរការផ្សាយរបស់រាជបណ្ណាល័យ

២- ប៉ុណ្ណ ចន្ទម៉ុល៖ ចរិកខ្មែរ

៣- ចេង ហេង៖ សេចក្តីថ្លែងការណ៍របស់លោក ចេង ហេង (១៩៧៣)

៤- ស៊ីសុវត្ថិ សិរិមត:៖ លិខិតចំហររបស់លោក ស៊ីសុវត្ថិ សិរិមត: ចំពោះនរោត្តម សីហនុ(១៩៧៣)

៥- នួន ឃឿន៖ រដ្ឋប្រហារ ១៩៣២ ពីសៀមទៅថៃឡង់

៦- បិន ឃៀនិន៖ តើ ប៉ុល ពត ចូលកាន់អំណាចបែបណា? (១៩៩២)

៧- ហ៊ិន ស៊ីថាន៖ នរណាជាឃាតករ?

៨- William Shawcross៖ Schattenkrieg Kissing, Nixon und Zerstoerung Kambodscha (1979)

៩- Peter j.Opitz៖ Frieden fuer Kambodscha (1991)

១០- Peter Schier៖ Indochina, Der permanente Konfrikt (1987)

១១- Winfried Scharlau៖ Vier Drachen am Mekong (1989)

១២- Michael Sontheimer៖ Kambodscha-Land der sanften Moerd(1990)

១៣- Haupt Kirten៖ Vortrag fuer den Kambodscha-Seminar (29.11.1992) Aufstandsbewegung in Kambodscha in 19.Jahrhundert